**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍវិស័យកសិកម្មខេត្តស្វាយរៀង

កម្មសិក្សា ពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩

ឈ្មោះស្ថាប័ន៖ **មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្តស្វាយរៀង**


តាក់តែងដោយ

និស្សិតឈ្មោះ **កែវ បូណា**

**វ៉ែន វណ្ណា**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឈុន ពហុ**


ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍

ជំនាន់ទី ៣

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេររបាយការណ៍ ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ កែវ បូណា និង វ៉ែន វណ្ណា ជានិស្សិតបរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី៣ ក្រុមE4B1 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ

លោកឪពុក អ្នកម្តាយរបស់យើងខ្ញុំដែលបានផ្តល់កំណើត និងខិតខំប្រឹងប្រែងបីបាច់ថែរក្សាកូនតាំងពីតូចរហូតដល់ធំដឹងក្តីប្រកបដោយព្រហ្មវិហារធម៌ចំពោះកូន។ លោកទាំងទ្វេរជួយផ្គត់ផ្គង់គ្រប់បែបយ៉ាង តាំងពីកម្លាំងកាយកម្លាំងចិត្ត ផ្នែកស្មារតី និងផ្នែកសម្ភារៈ។ លោកជាព្រះព្រហ្មរបស់កូន ជាគ្រូរបស់កូន ជាពេទ្យរបស់កូន ជាអ្នកចាំលើកទឹកចិត្តកូនគ្រប់ពេលវេលា។ ដើម្បីឱ្យកូនបានចេះដឹងបានបញ្ជូនកូនឱ្យទៅរៀននៅសាលាតាំងពីថ្នាក់កុមារដ្ឋាន បន្តរហូតដល់ថ្នាក់ឧត្តមសិក្សា។ គុណនូបការៈដ៏ធំធេងនេះ ពិតជាមិនអាចយកអ្វីមកប្រៀបផ្ទឹមបានឡើយ។

ឯកឧត្តមសាកលវិទ្យាការ សាកលវិទ្យាការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធានការិយាល័យសិក្សា និងបណ្ឌិតសាស្រ្តាចារ្យគ្រប់មុខគ្រប់វិជ្ជាទាំងអស់នៃសាកលវិទ្យាភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយកម្លាំងចិត្តក្នុងការអប់រំបង្ហាត់បង្រៀន និងបានផ្តល់ចំណេះដឹងដល់យើងខ្ញុំ និងនិស្សិតដទៃទៀតតាំងថ្នាក់ឆ្នាំមូលដ្ឋាន រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ។

លោកសាស្រ្តចារ្យបណ្ឌិត ឈុន ពហុ ដែលជាសាស្រ្តាចារ្យបង្ហាត់បង្រៀន និងដឹកនាំយើងខ្ញុំដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំជាមតិយោបយល់ ជួយត្រួតពិនិត្យ កែតម្រូវក្នុងកិច្ចការស្រាវជ្រាវនេះតាំងពីដំណើរការចាប់ផ្តើមរហូតដល់របាយការណ៍មួយនេះចងក្រងចប់ជាស្ថាពរ។

លោក ហែម សារិទ្ធ អភិបាលរងស្រុកស្វាយជ្រំ ដែលលោកបានជួយក្នុងការទំនាក់ទំនងទៅមន្ទីរតាំងពីដំបូង ដើម្បីដឹងពីឯកសារដែលមន្ទីរត្រូវការសម្រាប់ចុះកម្មសិក្សានៅទីនោះ។ ជាងនេះទៅទៀត លោកក៏បានផ្តល់នូវឯកសារមួយចំនួនតាមដែលអាចធ្វើបានដល់យើងខ្ញុំផងដែរ។

លោកប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង និងបុគ្គលិកក្រោមឱវាទជាពិសេសគឺលោកប្រធានការិយាល័យរដ្ឋបាល និងសហការីនៅមន្ទីកសិកម្មខេត្ត ព្រមទាំងនៅមន្ទីរផែនការខេត្តស្វាយរៀងផងដែរ ដែលលោកតែងតែសហការក្នុងការផ្តល់ឯកសារដែលមានតាមតម្រូវការ និងបានចូលរួមផ្តល់ជាមតិយោបល់ពន្យល់កែលំអឱ្យដល់យើងខ្ញុំកាន់តែប្រសើរឡើង។

ជាទីបញ្ចប់យើងខ្ញុំសូមគោរពជូនពរដល់អ្នកមានគុណទាំងពីរ ឯកឧត្តមសាកលវិទ្យាការ

សាកលវិទ្យាការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកសាស្ត្រាចារ្យគ្រប់មុខវិជ្ជាទាំងអស់ ព្រមទាំងមិត្ត និស្សិតគ្រប់រូប សូមឱ្យសមប្រកបនូវសេចក្តីសុខ សុខភាពបរិបូរណ៍ ទទួលជោគជ័យគ្រប់ភារកិច្ច និងជួបប្រទះនូវពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

និស្សិតគ្រប់រូបដែលបានសិក្សាថ្នាក់បរិញ្ញាបត្ររយៈពេល៤ឆ្នាំនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ត្រូវបញ្ចប់ការសិក្សារបស់ខ្លួនតាមរយៈការប្រឡង ឬការសរសេរសារណា ឬអាចបញ្ចប់ដោយជ្រើសរើសយកការសរសេររបាយការណ៍ចុះកម្មសិក្សាទៅតាមជំនាញដែលខ្លួនបានសិក្សាមក។ ចំពោះក្រុមយើងខ្ញុំបានសម្រេចជ្រើសរើសចុះទៅធ្វើកម្មសិក្សានៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀងដែលទាក់ទងនឹងប្រធានបទ **"ការអភិវឌ្ឍវិស័យកសិកម្មខេត្តស្វាយរៀង"** តាមរយៈពេលដែលសាលាបានកំណត់។ ការសម្រេចជ្រើសរើសប្រធានបទ និងទីតាំងកម្មសិក្សានេះ ដោយមើលឃើញថាខេត្តនេះ គ្មានតំបន់ទេសចរណ៍ តំបន់ទឹក ធ្លាក់ ភ្នំ ឬកន្លែងកម្សាន្តសម្បូរបែបដូចខេត្តដទៃនោះទេ។ ប្រជាជនភាគច្រើនមានតែការធ្វើកសិកម្មនេះហើយដែលជាការងារចម្បងសម្រាប់ពួកគាត់។ តែបច្ចុប្បន្នដោយមានការរីកចម្រើនបន្ថែមទៀតលើវិស័យរោងចក្រឧស្សាហកម្ម បានជួយបង្កើតការងារឱ្យប្រជាជនក្នុងខេត្តបានមួយចំនួនធំផងដែរ។ វិស័យកសិកម្មនៅជាវិស័យអាទិភាពមួយក្នុងខេត្ត។ ដោយសារការចង់ដឹងពីការប្រព្រឹត្តទៅរបស់វិស័យកសិកម្មក្នុងខេត្តមួយនេះយ៉ាងដូចម្តេច? ទើបក្រុមយើងខ្ញុំសម្រេចចុះទៅធ្វើកម្មសិក្សានៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតែម្តង។ មួយទៀតសម្រាប់អត្ថប្រយោជន៍ដែលយើងខ្ញុំទទួលបានពីការចុះកម្មសិក្សាឬដំណើរការចងក្រងរបាយការណ៍មួយនេះឡើងមានជាច្រើនដូចជា ចំណេះដឹងពីប្រវត្តិខេត្ត វិស័យអាទិភាពផ្សេងទៀតរបស់ខេត្តក្រៅពីវិស័យកសិម្ម។ ក្រៅពីនេះតាមរយៈការចុះកម្មសិក្សាក៏បានពង្រឹងចំណេះដឹងក្នុងការវិនិច្ឆ័យអំពីការអនុវត្តជាក់ស្តែងដែលមានភាពមិនងាយស្រួលដូចដែលបានរៀននោះទេ។ បន្ថែមពីនេះទៀតបានស្វែងយល់ពីភាពមិនងាយស្រួលក្នុងការស្វែងរកឯកសារព័ត៌មានការទំនាក់ទំនងរបស់មន្ត្រីពាក់ព័ន្ធជាដើម តែក្រុមយើងខ្ញុំនៅតែប្រឹងរកវិធីដោះស្រាយរហូតទទួលបានជោគជ័យក្នុងការតាក់តែងជារបាយការណ៍មួយនេះឡើង។

ទោះបីជារបាយការណ៍មួយនេះបានលេចចេញជារូបរាងហើយក្តី តែក្រុមយើងខ្ញុំជឿជាក់ថានឹងមាននូវចំណុចខ្វះខាត់ខ្លះជាមិនខាន។ តែវាអាចជាឯកសារសិក្សាពិគ្រោះរបស់មិត្តនិស្សិតដែលចង់ស្វែងយល់ពីខេត្តស្វាយរៀង ជាពិសេសនោះគឺវិស័យកសិកម្ម។ វាអាចជាទុនសម្រាប់ពង្រីកចំណេះដឹងរបស់និស្សិតផ្ទាល់ខ្លួន ឬជាឯកសារយោងសម្រាប់អ្នកស្រាវជ្រាវផងដែរ។

ជាមួយគ្នានេះដែរយើងខ្ញុំទាំងពីររូបសូមអភ័យទោសពីសំណាក់ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត និងមិត្តអ្នកអានទាំងអស់នូវរាល់ចំណុចខ្វះខាត់ទាំងខ្លឹមសារ និងអក្ខរាវិរុទ្ធមិនត្រឹមត្រូវដែលមានក្នុងរបាយការណ៍នេះ។

# មាតិកា


បញ្ជីអក្សរកាត់ ........ vi
បញ្ជីតារាង ........ vii
បញ្ជីក្រាហ្វិក ........ viii
បញ្ជីឧបសម្ព័ន្ធ ........ ix


## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
២. ចំណោទបញ្ហា ........ ២
៣. គោលបំណងនៃការស្រាវជ្រាវ ........ ២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ២
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២
ក.ការប្រមូលឯកសារទិន្នន័យ ........ ៣
ខ. ការវិភាគទិន្នន័យ ........ ៣
៦. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤


## ជំពូកទី១
## រំលឹកទ្រឹស្តីកសិកម្ម


១.១ និយមន័យ និងទ្រឹស្តីនៃពាក្យគន្លឹះ ........ ៥
១.១.១ និយមន័យការអភិវឌ្ឍ ........ ៥
១.១.២ ទ្រឹស្តីការអភិវឌ្ឍ ........ ៥
១.១.៣ ទ្រឹស្តីកសិកម្ម ........ ៦
១.២ ប្រវត្តិកសិកម្ម ........ ៦
១.២.១ ដំណាក់កាលមិនទាន់មានកសិកម្ម ........ ៦
១.២.២ ដំណាក់កាលកសិកម្មដោយប្រើកម្លាំងមនុស្ស និងសត្វ ........ ៧
១.២.៣ ដំណាក់កាលទំនើបកម្មកសិកម្ម ........ ៨

១.៣ តួនាទីកសិកម្មក្នុងការអភិវឌ្ឍ ........ ៨

១.៣.១ ការដកហូតកម្លាំងពលកម្ម ........ ៩

១.៣.២ ការបង្កើតទីផ្សាសម្រាប់ផលិតកម្មឧស្សាហាកម្ម ........ ៩

១.៣.៣ បង្កើតការងារតាមរដូវ ........ ១០

១.៣.៤ ការបង្កើតរូបិយវត្ថុអន្តរជាតិ ........ ១០

១.៣.៥ ការធ្វើបដិវត្តន៍បៃតង ........ ១០

១.៣.៦ បច្ចេកវិទ្យាបដិវត្តន៍បៃតង ........ ១១

១.៤ ស្ថានភាពសេដ្ឋកិច្ចកម្ពុជា ........ ១១

១.៤.១ ការវាយតម្លៃកំណើនសេដ្ឋកិច្ចកម្ពុជា ........ ១៣

១.៤.២ ការចូលរួមរបស់វិស័យកសិកម្មក្នុង ផ.ស.ស. ........ ១៥

១.៥ សមាសភាគនៃអនុវិស័យក្នុងវិស័យកសិកម្ម ........ ១៦

១.៦ ស្ថានភាពនៃការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជា២០០៨-២០១៨ ........ ១៧

១.៦.១ ផលិតកម្មដំណាំស្រូវ ........ ១៧

១.៦.២ ការវិវឌ្ឍផលិតកម្មដំណាំរួមផ្សំ និងឧស្សាហាកម្មពីឆ្នាំ ២០០៨ -២០១៨ ........ ២១

១.៦.៣ ការវិវឌ្ឍនៃវិស័យជលផល ........ ២៣

១.៦.៤ ការវិវឌ្ឍវិស័យបសុសត្វឆ្នាំ ២០០៨ - ២០១៨ ........ ២៦

១.៦.៥ ការវិវឌ្ឍនៃផលិតផលកៅស៊ូ ២០០៨-២០១៨ ........ ២៨

១.៦.៦ ការគ្រប់គ្រង់ និងអភិវឌ្ឍព្រៃឈើ ........ ៣១

១.៧ យុទ្ធសាស្រ្តចម្បងៗសម្រាប់តម្រង់ទិសអភិវឌ្ឍន៍កសិកម្ម ........ ៣២

១.៧.១ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣ ........ ៣២

១.៧.២ យុទ្ធសាស្រ្តចម្បងៗសម្រាប់តម្រង់ទិសអភិវឌ្ឍន៍កសិកម្ម ........ ៣៤

## ជំពូកទី២

## វិស័យកសិកម្មខេត្តស្វាយរៀង

២.១ ស្ថានភាពខេត្តស្វាយរៀង ........ ៣៧

២.១.១ ប្រវត្តិការបង្កើតខេត្ត ........................................................ ៣៧

២.១.២ និមិត្តសញ្ញាសម្គាល់ខេត្តស្វាយរៀង ........................................ ៣៨

២.១.៣ ទីតាំងភូមិសាស្រ្ត និងសណ្ឋានដីក្នុងខេត្តស្វាយរៀង ........................ ៣៩

២.១.៤ ស្ថានភាពប្រជាសាស្រ្ត ........................................................ ៤១

២.១.៥ វិស័យដែលមានសក្តានុពលក្នុងខេត្ត ........................................ ៤៣

២.២ រចនាសម្ព័ន្ធគ្រប់គ្រងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង ........ ៤៥

២.២.១ រចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរ ................................................ ៤៥

២.២.២ តួនាទី និងភារកិច្ច ........................................................ ៤៦

២.៣ ស្ថានភាពកសិកម្មក្នុងខេត្តស្វាយរៀង ............................................ ៤៨

២.៣.១ ស្ថានភាពអភិវឌ្ឍនៃដំណាំស្រូវក្នុងខេត្តស្វាយរៀងឆ្នាំ២០០៩-២០១៨ ............ ៤៨

២.៣.២ បសុសត្វនៅក្នុងខេត្ត ........................................................ ៥២

២.៣.៣ ការដាំដុះដំណាំរួមផ្សំ និងដំណាំកសិឧស្សាហកម្ម .............................. ៥៥

២.៣.៤ វិស័យជលផល ........................................................ ៥៨

ក.វារីវប្បកម្ម: ........................................................ ៥៨

ខ.ផលនេសាទ ........................................................ ៥៨

២.៥ បញ្ហាប្រឈម ........................................................ ៥៩

២.៦ ដំណោះស្រាយ ........................................................ ៦០

ក. បញ្ហាប្រព័ន្ធធារាសាស្រ្ត ........................................................ ៦០

ខ.បសុព្យាបាល ........................................................ ៦១

គ. អភិរក្ស និងការពារជលផល ........................................................ ៦១

២.៧ ទិសដៅសម្រាប់អភិវឌ្ឍ ២០១៩ ........................................................ ៦១


**ជំពូកទី៣**

**ការវិភាគលើលទ្ធផលនៃការស្រាវជ្រាវ**


៣.១ ការវិភាគលើទិន្នន័យផលិតកម្មកសិកម្មដល់ឆ្នាំ ២០២៣ ........................................ ៦៣

៣.១.១ ការព្យាករណ៍លើការអនុវត្តផលិតកម្មដំណាំស្រូវ ........ ៦៣
៣.១.២ ការព្យាករណ៍ទិន្នផលសត្វគោ ........ ៦៤
៣.១.៣ ការព្យាករណ៍ទិន្នផលសត្វក្របី ........ ៦៥
៣.១.៤ ការព្យាករណ៍ទិន្នផលសត្វជ្រូក ........ ៦៦
៣.១.៥ ការព្យាករណ៍ទិន្នផលសត្វមាន់ទា ........ ៦៨
៣.១.៦ ការព្យាករណ៍ផ្ទៃដីដាំដុះសរុប និងទិន្នផលដំណាំផ្សេងៗ ........ ៦៩
៣.២ ការសិក្សាលើបញ្ហាប្រឈមរបស់វិស័យកសិកម្មក្នុងខេត្ត ........ ៧០
៣.២.១ គ្រោះទឹកជំនន់ ........ ៧១
៣.២.២ គ្រោះរាំងស្ងួត ........ ៧២
៣.២.៣ បញ្ហាទឹកស្រោចស្រព ........ ៧៣
៣.២.៤ ការប្រើប្រាស់ដី ........ ៧៤
៣.២.៥ ដីខ្វះជីវជាតិ ........ ៧៥
៣.២.៦ បញ្ហាថ្លៃទីផ្សារកសិផល ........ ៧៦
៣.២.៧ បញ្ហាសត្វចង្រៃ ........ ៧៧
៣.៣ ដំណោះស្រាយបញ្ហាវិស័យកសិកម្ម ........ ៧៨
៣.៣.១ ដំណោះស្រាយបញ្ហាគ្រោះទឹកជំនន់ រាំងស្ងួត និងប្រព័ន្ធស្រោចស្រព ........ ៧៨
៣.៣.២ ដំណោះស្រាយបញ្ហាដីខ្វះជីជាតិ ........ ៨០
៣.៣.៣ ដំណោះស្រាយថ្លៃទីផ្សារកសិផល ........ ៨១
៣.៣.៤ ដំណោះស្រាយបញ្ហាសត្វចង្រៃ និងជម្ងឺសត្វ ........ ៨៤
ក.សត្វទ្រីប ........ ៨៥
ខ.សត្វមមាចត្នោត ........ ៨៦
គ. សត្វដង្កូវម្ទេសស្លឹក ........ ៨៧
ឃ.ជម្ងឺសារទឹក: ........ ៨៨
ង.ជម្ងឺអុតក្តាម: ........ ៨៩

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន ........................................................ ៩០

២. អនុសាសន៍ ........................................................ ៩០

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ផ.ស.ស=GDP | ៖ | ផលិតផលក្នុងស្រុកសរុប |
| ម.ម | ៖ | មីលីម៉ែត្រ |
| ម | ៖ | ម៉ែត្រ |
| ហ.ត | ៖ | ហិចតា |
| គ.ម២ | ៖ | គីឡូម៉ែត្រការេ |
| គ.ម៣ | ៖ | គីឡូម៉ែត្រគូប |
| NGO | ៖ | Non-Government Organization<br>អង្គការមិនមែនរដ្ឋាភិបាល |
| GAP | ៖ | Good Agricutural Pratices<br>ការអនុវត្តល្អក្នុងវិស័យកសិកម្ម |
| GAHP | ៖ | Good Animal Husbandry Pratices<br>អនុវត្តន៍ការចិញ្ចឹមសត្វល្អ |
| SPS | ៖ | Stanitary and Phytosanitary<br>កិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យ |
| MRC | ៖ | Mekong River Commission<br>គណៈកម្មាធិការទន្លេមេគង្គ |
| IPM | ៖ | Irrigated Pest Management<br>ការគ្រប់គ្រងសមាសភាគចង្រៃចម្រុះ |

## បញ្ជីតារាង


តារាង១៖ ផ្ទៃដីដាំដុះផលិតកម្មដំណាំរួមផ្សំ និងឧស្សាហកម្ម២០០៩-២០១៤ ............................ ២១

តារាងទី២៖ បង្ហាញពីលក្ខណៈរួមនៃប្រជាសាស្ត្រឆ្នាំ២០១៤-២០១៨ ........................................ ៤២

តារាងទី៣៖ ការបង្ហាញពីចំនួនរោងចក្រ សហគ្រាស និងអ្នកបម្រើការ........................................៤៤

តារាងទី៤៖ បង្ហាញពីការដាំដុះដំណាំរួមផ្សំនិងកសិ-ឧស្សាហកម្ម ..............................................៥៦

តារាងទី៥៖ បង្ហាញពីចំនួនគ្រឿងយន្តកសិកម្មក្នុងខេត្តឆ្នាំ២០១៥-២០១៨..................................៥៩

តារាងទី៦ ៖ ការព្យាករណ៍ពីផ្ទៃដីដាំដុះ និងបរិមាណផលស្រូវរយៈពេល៥ឆ្នាំ .............................៦៤

តារាងទី៧៖ ការព្យាករណ៍ពីទិន្នផលសត្វគោ(គិតជាក្បាល)រយៈពេល៥ឆ្នាំខាងមុខ .....................៦៥

តារាង៨៖ ការព្យាករណ៍ពីទិន្នផលសត្វក្របី(គិតជាក្បាល)រយៈពេល៥ឆ្នាំខាងមុខ .......................៦៦

តារាងទី៩៖ ការព្យាករណ៍ពីទិន្នផលសត្វជ្រូក(គិតជាក្បាល)រយៈពេល៥ឆ្នាំខាងមុខ .................. ៦៧

តារាងទី១០៖ ការព្យាករណ៍ពីទិន្នផលសត្វមាន់ទា(គិតជាក្បាល)រយៈពេល៥ឆ្នាំខាងមុខ.............៦៩

តារាងទី១១៖ ការព្យាករណ៍ពីផ្ទៃដីសរុប និងទិន្នផលដំណាំផ្សេងៗរយៈពេល៥ឆ្នាំខាងមុខ.......... ៧០

តារាងទី១២៖ បង្ហាញពីការខូចខាតដោយទឹកជំនន់................................................................ ៧១

តារាងទី១៣៖ ដីស្រែមានប្រឡាយស្រោចស្រព .................................................................... ៧៤

តារាងទី១៤៖ ស្ថានភាពដីស្រែចំការរបស់កសិករ ................................................................. ៧៥

# បញ្ជីក្រាហ្វិក


ក្រាហ្វិកទី១៖ បង្ហាញពីការរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ............................. ១៥
ក្រាហ្វិកទី២៖ បង្ហាញពីការកើនឡើងតម្លៃបន្ថែមសរុបនៃវិស័យកសិកម្មឆ្នាំ២០០៩-២០១៨ ......... ១៦
ក្រាហ្វិកទី៣៖ បង្ហាញពីការចូលរួមនៃអនុវិស័យកសិកម្ម(%)..................................................១៧
ក្រាហ្វិកទី៤៖ ការបង្ហាញពីបរិមាណផលស្រូវឆ្នាំ ២០០៨-២០១៨...............................................២០
ក្រាហ្វិកទី៥៖ ផលិតកម្មសាកវប្បកម្ម និងដំណាំឧស្សាហកម្មឆ្នាំ២០១៤-២០១៨........................ ២៣
ក្រាហ្វិកទី៦៖ ផលនេសាទទឹកសាប ទឹកសមុទ្រ និងវារីវប្បកម្ម...................................................២៥
ក្រាហ្វិកទី៧៖ ផលិតកម្មសត្វឆ្នាំ២០១៤-២០១៨ .................................................................... ២៧
ក្រាហ្វិកទី៨៖ ការបង្ហាញពីការចិញ្ចឹមបក្សីឆ្នាំ២០០៨-២០១៨ ......................................................២៨
ក្រាហ្វិកទី៩៖ បង្ហាញពីផ្ទៃដីនៃការដាំដុះកៅស៊ូឆ្នាំ២០១៣-២០១៨ ............................................. ៣០
ក្រាហ្វិកទី១០៖ បង្ហាញពីការទប់ស្កាត់ និងការបង្ក្រាបបទល្មើសព្រៃឈើឆ្នាំ២០១៤-២០១៨......... ៣២
ក្រាហ្វិកទី១១៖ បង្ហាញពីផ្ទៃដីបង្កបង្កើនផលស្រូវឆ្នាំ២០០៨-២០១៨.......................................... ៥១
ក្រាហ្វិកទី១២៖ បង្ហាញពីផ្ទៃដីបង្កបង្កើនផលស្រូវឆ្នាំ២០០៨-២០១៨ ..........................................៥២
ក្រាហ្វិកទី១៣៖ បង្ហាញពីការចិញ្ចឹមសត្វពីឆ្នាំ២០១៤-២០១៨.....................................................៥៤
ក្រាហ្វិកទី១៤៖ បង្ហាញពីការចិញ្ចឹមសត្វមាន់ទា ឆ្នាំ២០០៩-២០១៨ ...........................................៥៥
ក្រាហ្វិកទី១៥៖ ការបង្ហាញពីបរិមាណផលដំណាំរួមផ្សំ និងកសិឧស្សាហកម្មឆ្នាំ២០១២-២០១៨...៥៧
ក្រាហ្វិកទី១៦៖ បង្ហាញពីទិន្នផលស្រូវ និងផ្ទៃដីដាំដុះ..............................................................៦៣
ក្រាហ្វិកទី១៧៖ បង្ហាញពីទិន្នផលសត្វគោ.............................................................................. ៦៥
ក្រាហ្វិកទី១៨៖ បង្ហាញពីទិន្នផលសត្វក្របី........................................................................... ៦៦
ក្រាហ្វិកទី១៩៖ បង្ហាញពីទិន្នផលការចិញ្ចឹមសត្វជ្រូក ..............................................................៦៧
ក្រាហ្វិកទី២០៖ បង្ហាញពីទិន្នផលសត្វមាន់ទា.........................................................................៦៨
ក្រាហ្វិក២១៖ បង្ហាញពីផ្ទៃដីសរុប និងទិន្នផលសរុបនៃដំណាំផ្សេងៗ..........................................៧០
ក្រាហ្វិកទី២២៖ បង្ហាញពីផ្ទៃដីប៉ះពាល់ដោយគ្រោះរាំងស្ងួត...................................................... ៧៣

# បញ្ជីឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី១ : ផែនទីខេត្តស្វាយរៀង

ឧបសម្ព័ន្ធទី២ : ព្រះរាជក្រឹត្យស្តីពីការបង្កើតខេត្តស្វាយរៀង និងបែងចែកស្រុក ខណ្ឌ ក្នុងខេត្តស្វាយរៀង

ឧបសម្ព័ន្ធទី៣ : ផលិតកម្មដំណាំស្រូវរយៈពេល១០ឆ្នាំ

ឧបសម្ព័ន្ធទី៤ : ស្ថិតិផ្ទៃដីផលិតផល ទិន្នផល និងការនាំចេញកៅស៊ូឆ្នាំ២០០១-២០១៨

ឧបសម្ព័ន្ធទី៥ : ស្ថានភាពប្រជាសាស្ត្រក្នុងខេត្តស្វាយរៀងក្នុងឆ្នាំ២០១៩

ឧបសម្ព័ន្ធទី៦ : រចនាសម្ព័ន្ធដឹកនាំរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង

ឧបសម្ព័ន្ធទី៧ : ស្ថិតិផ្ទៃដីដាំដុះ ទិន្នផល និងអតិរេកស្រូវក្នុងខេត្តស្វាយរៀងឆ្នាំ២០០៨-២០១៨

ឧបសម្ព័ន្ធទី៨ : តារាស្ថិតិការចិញ្ចឹមសត្វក្នុងខេត្តស្វាយរៀងឆ្នាំ២០០៨-២០១៨

ឧបសម្ព័ន្ធទី៩ : តារាង ស្ថិតិការប្រែប្រួលកសិកម្មក្នុងខេត្តស្វាយរៀង

ឧបសម្ព័ន្ធទី១០: តារាស្ថិតិប្រែប្រួលចំនួនគោ ក្របី និងជ្រូកក្នុងខេត្តស្វាយរៀង

ឧបសម្ព័ន្ធទី១១: តារាស្ថិតិចំនួនសត្វមាន់ទាក្នុងខេត្តស្វាយរៀង

ឧបសម្ព័ន្ធទី១២: តារាស្ថិតិផ្ទៃដីដាំ និងទិន្នផលដំណាំផ្សេងៗក្នុងខេត្តស្វាយរៀង

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាជាប្រទេសមួយដែលបាន និងកំពុងមានខឿនសេដ្ឋកិច្ចពឹងផ្អែកលើកសិកម្ម ក្នុងការជួយជំរុញដល់កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ ហើយមានប្រជាជនប្រមាណ ៨៥% រស់នៅតាមតំបន់ជនបទ និងក្នុងនោះក៏មានប្រជាពលរដ្ឋប្រមាណជា៦០%កំពុងប្រកបរបរកសិកម្ម។ ការអភិវឌ្ឍវិស័យកសិកម្ម គឺជាគន្លឹះមួយក្នុងការកាត់បន្ថយនូវភាពក្រីក្រតាមតំបន់ជនបទដើម្បីធានាឱ្យបាននូវសន្តិសុខស្បៀង និងការទ្រទ្រង់បាននូវកំណើនសេដ្ឋកិច្ច។ សម្រាប់ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងផលិតផលសរុបក្នុងស្រុក(GDP)ក្នុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះមានការថយចុះអន់ថយជាបន្តបន្ទាប់ពិតមែន តែមិនមែនមានន័យថាវិស័យនេះចុះអន់ថយនោះទេគឺដោយសារតែកំណើនរបស់វិស័យឧស្សាហកម្ម និងសេវាកម្មមានកំណើនលឿនជាងប៉ុណ្ណោះ ព្រោះថាផលិតភាពរបស់វិស័យកសិកម្មពីមួយឆ្នាំទៅមួយឆ្នាំមានការកើនឡើងជាបន្តបន្ទាប់។ កំណើននៃផលិតភាពកសិកម្មនេះក៏បានពឹងផ្អែកលើអនុវិស័យសំខាន់ៗដូចជា ផ្នែកដំណាំ ជលផល ផលិតកម្មសត្វ និងព្រៃឈើ។

ចំពោះការធ្វើកសិកម្មនៅក្នុងខេត្តស្វាយរៀងវិញ យើងឃើញថា ក៏មិនខុសគ្នាប៉ុន្មានអីពីខេត្តដទៃនៅក្នុងប្រទេសកម្ពុជាដែរ ព្រោះថាប្រជាកសិករខេត្តនេះភាគច្រើនយកការដាំដុះដំណាំស្រូវជាសំខាន់។ ពួកគាត់ច្រើនធ្វើកសិកម្មតែនៅរដូវវស្សា ដោយហេតុថាគ្មានទឹកគ្រប់គ្រាន់នោះទេនៅរដូវប្រាំង។ វិស័យមួយនេះ នៅតែជាវិស័យអាទិភាពនៅក្នុងខេត្តដែលអាចទាក់ទាញកម្លាំងពលកម្មបានដល់ទៅ ៦០.៩%នៃចំនួនអ្នកមានការងារសរុប។ បច្ចុប្បន្ននេះ វិស័យកសិកម្មក្នុងខេត្តនេះមានការីកចម្រើនគួរឱ្យកត់សម្គាល់ ដោយសារមានការផ្លាស់ប្តូរពីកសិកម្មបែបប្រពៃណីដោយប្រើកម្លាំងសត្វងាក់មកការប្រើប្រាស់គ្រឿងយន្តកសិកម្មជំនួសក្តី ក៏វិស័យនេះនៅតែរណបទៅនឹងការប្រែប្រួលរបស់ធម្មជាតិ ហើយនឹងមាននិន្នាការថយចុះនៅពេលដែលមានការប្រែប្រួលធម្មជាតិដូចជាភាពរាំស្ងួត ទឹកជំនាន់ សត្វល្អិតបំផ្លាញដំណាំ និងជម្ងឺសត្វចិញ្ចឹមផ្ទុះឡើងជាដើម។ ទាំងនេះគឺទាមទារឱ្យមានការចូលរួមបន្ថែមទៀត ក្នុងការដោះស្រាយបញ្ហាទាំងនេះដោយការកសាងប្រព័ន្ធស្រោចស្រព ផ្លូវលំ ផ្លូវថ្នល់បន្ថែម និងការចាប់យកនូវបច្ចេកទេសជំនាញថ្មីៗមកអនុវត្តជាពិសេសនេះគឺការសិក្សាស្រាវជ្រាវកសិកម្មទំនើបដែលអាចបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ក្រៅពីនេះ ការគិតគូរពីតម្លៃសម្ភារកសិកម្ម និងទីផ្សារកសិផលក៏សុទ្ធសឹងតែជាបញ្ហាស្នូលក្នុងការជំរុញលើកទឹកចិត្តកសិករឱ្យប្រឹងប្រែងផលិត និងធ្វើឱ្យវិស័យកសិកម្មមានការរីកចម្រើនបន្ថែមទៀត។

ដោយមើលឃើញពី សារប្រយោជន៍ដ៏សំខាន់នៃវិស័យកសិកម្មសម្រាប់ប្រជាជននៅតាមតំបន់ជនបទ ព្រមទាំងសេដ្ឋកិច្ចជាតិទើបជំរុញឱ្យក្រុមយើងខ្ញុំសម្រេចយកប្រធានបទ "**ការអភិវឌ្ឍវិស័យកសិកម្មខេត្តស្វាយរៀង**" មកធ្វើការសិក្សាស្រាវជ្រាវ។

## ២. ចំណោទបញ្ហា

ដោយសារតែការចង់ស្វែងយល់ពីការវិវត្តក្នុងការចូលរួមរបស់វិស័យកសិកម្មក្នុងវិស័យសេដ្ឋកិច្ចខេត្តស្វាយរៀងឱ្យកាន់តែច្បាស់ និងគោលការអនុវត្តជាក់ស្តែងជាមួយនឹងទ្រឹស្តីដែលបានសិក្សានៅសាលា។ បញ្ហាដែលត្រូវសិក្សាក្នុងនេះមានដូចជា៖

- តើស្ថានភាពកសិកម្មក្នុងខេត្តមានលក្ខណៈដូចម្តេច?
- តើបញ្ហាប្រឈមអ្វីខ្លះក្នុងការអភិវឌ្ឍវិស័យនេះ?
- តើគួរដោះស្រាយបញ្ហាទាំងនោះយ៉ាងណាទើបសមស្រប?

## ៣. គោលបំណងនៃការស្រាវជ្រាវ

- ស្វែងយល់ពីវិស័យកសិកម្មខេត្តស្វាយរៀង
- ស្វែងយល់ពីការរីកចម្រើនរបស់វិស័យនេះ
- ចង់ដឹងពីទំនាក់ទំនងរបស់វិស័យនេះជាមួយនឹងជីវភាពប្រជាជនក្នុងខេត្ត
- តើមានបញ្ហាប្រឈមអ្វីខ្លះក្នុងវិស័យនេះ? ហើយដោះស្រាយបញ្ហាទាំងនោះយ៉ាងណា?

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវប្រធានបទ "**ការអភិវឌ្ឍវិស័យកសិកម្មខេត្តស្វាយរៀង**" ក្រុមយើងខ្ញុំនឹងផ្តោតជាសំខាន់លើការសិក្សាពី៖

- ដាំណាំស្រូវ
- ដំណាំរួមផ្សំ
- បសុសត្វ

ដោយធ្វើការសិក្សានៅចន្លោះឆ្នាំ ២០០៨ ដល់ ២០១៨ផ្អែកលើឯកសារដែលមានជាក់ស្តែង ហើយនឹងធ្វើការព្យាករណ៍អនុវិស័យមួយចំនួនពីឆ្នាំ២០១៩ ដល់ ២០២៣។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវទៅលើប្រធានបទ "ការអភិវឌ្ឍវិស័យកសិកម្មខេត្តស្វាយរៀង" នេះក្រុមយើងខ្ញុំប្រើវិធីសាស្ត្រក្នុងការស្រាវជ្រាវជាពីរបែប:

- **ទិន្នន័យចម្បង:** ការសាកសួរ និងការធ្វើសំភាសន៍ដល់ទីកន្លែងគឺនៅមន្ទីរកសិកម្មខេត្ត

- **ទិន្នន័យបន្ទាប់បន្សំ:** ការប្រមូលឯសារតាមមន្ទីរ និងស្ថាប័ននានាដែលពាក់ព័ន្ធ។

**គ.ការប្រមូលឯកសារទិន្នន័យ**

**-ការប្រមូលទិន្នន័យបឋម:** យើងខ្ញុំបានធ្វើការសំភាសន៍ជាមួយនឹងមន្ត្រីដែលបំរើនៅក្នុងមន្ទីរកសិកម្មសាកសួរព័ត៌មានពីចំណុចដែលនៅខ្វះខាតដើម្បីទទួលបានឯកសារ ហើយសួរព័ត៌-មានទាក់ទងនឹងកសិកម្មក្នុងខេត្តនេះ ព្រមទាំងបានទៅមន្ទីរផែនការស្វែរកឯកសារដែលពាក់ព័ន្ធ។

**-ការប្រមូលទិន្នន័យមានស្រាប់**

ការប្រមូលទិន្នន័យមានស្រាប់មានដូចជា:

- ឯកសារសារណា និងរបាយការណ៍បញ្ចប់ការសិក្សានៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិ-សាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- របាយការណ៍បូកសរុបប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្នាំ២០១៤-២០១៨
- របាយការណ៍បូកសរុបប្រចាំឆ្នាំរបស់មន្ទីរកសិកម្មខេត្ត
- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៥របស់រាជរដ្ឋាភិបាល និងឯកសារមួយចំនួនដែលប្រមូលយកមកពីបណ្ណាល័យ ស្ថាប័ននានា និងតាមអ៊ីនធឺណែត។

**ខ. ការវិភាគទិន្នន័យ**

បន្ទាប់ពីប្រមូលបានព័ត៌មាន យើងបានជ្រើសរើសព័ត៌មានដែលល្អៗមកចងក្រង ដើម្បីធ្វើជារបាយការណ៍ ព្រមទាំងបានដកស្រង់ចំណុចដែលសំខាន់ៗមកធ្វើការព្យាករណ៍សម្រាប់ឆ្នាំខាងមុខទៀត ដោយប្រើកម្មវិធី Excel ជាជំនួយក្នុងការវិភាគ ដើម្បីឱ្យមានភាពសុក្រិត និងមានបង្ហាញជាតារាងទិន្នន័យព្យាករណ៍នៅក្នុងឧបសម្ព័ន្ធ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

អត្ថប្រយោជន៍នៃការស្រាវជ្រាវអំពីប្រធានបទ ″**ការអភិវឌ្ឍវិស័យកសិកម្មខេត្តស្វាយរៀង**″ មានដូចខាងក្រោម៖

- ទទួលបាននូវចំណេះដឹងផ្នែកទ្រឹស្តី និងវិភាគទិន្នន័យជាក់ស្តែង
- ទទួលបាននូវចំណេះដឹងថ្មី និងការពិគ្រោះយោបល់ពីសាស្ត្រាចារ្យណែនាំចាប់តាំងពីការប្រមូលទិន្នន័យ ចងក្រង ពិភាក្សា រហូតដល់របាយការណ៍មួយនេះបានលេចចេញជារូបរាង។
- ទទួលបាននូវចំណេះដឹងក្នុងការទំនាក់ទំនងល្អជាមួយសង្គម និងមន្ត្រីរាជរដ្ឋាភិបាល។

– ទទួលបាននូវចំណេះដឹងទាក់ទងនឹងវិស័យកសិកម្មដូចជា ផលិតកម្មដំណាំស្រូវ ដំណាំរួមផ្សំ និងកសិឧស្សាហកម្ម ផលិតកម្មសត្វ ផលិតផលជលផល និងព្រៃឈើផងដែរ។ ម្យ៉ាងទៀតនោះគឺបានដឹងពី ទិន្នន័យពិតប្រាកដរបស់មន្ទីរ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
– ជាពិសេសនោះ គឺអាចបន្សល់ទុករបាយការណ៍សិក្សាមួយនេះសម្រាប់ជាឯកសារកសិកម្មដល់និស្សិតជំនាន់ក្រោយ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងប្រធានបទ "**ការអភិវឌ្ឍវិស័យកសិកម្មខេត្តស្វាយរៀង**" ត្រូវបានបែងចែកជាប្រាំផ្នែកសំខាន់ៗ ដូចខាងក្រោម៖

– **សេចក្តីផ្តើម** គឺជាចំណុចចាប់ផ្តើមនៃប្រធានបទដែលសិក្សាពីខ្លឹមសារសំខាន់ៗមួយចំនួនដូចជាស្ថានភាពទូទៅ មូលហេតុដែលនាំឱ្យមានការស្រាវជ្រាវពីប្រធានបទនេះ ទំហំ និងដែនកំណត់ ចំណោទបញ្ហា ព្រមទាំងមានបង្ហាញពីវិធីសាស្ត្រការស្រាវជ្រាវ។ល។
– **ជំពូកទី១ ផ្នែកទ្រឹស្តី** គឺបង្ហាញពីទ្រឹស្តីទាក់ទងនឹងការអភិវឌ្ឍកសិកម្មដែលជាទ្រឹស្តីរបស់អ្នកប្រាជ្ញមួយចំនួន។ ក្រៅពីនេះក៏មានបង្ហាញពីលក្ខណៈទូទៅនៃស្ថានភាពកសិកម្មរបស់កម្ពុជានាពេលបច្ចុប្បន្ននេះ។
– **ជំពូកទី២ កសិកម្មខេត្តស្វាយរៀង** ក្នុងជំពូកនេះយើងសិក្សាទៅលើស្ថានភាពទូទៅរបស់ខេត្តរាប់បញ្ចូលទាំងប្រវត្តិខេត្ត ទីតាំងភូមិសាស្ត្រ ប្រជាសាស្ត្រ វិស័យអាទិភាពរបស់ខេត្ត។ ជាងនេះទៅទៀត ក៏បានបង្ហាញពីស្ថានភាពរបស់មន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង ស្ថានភាពកសិកម្មខេត្ត ព្រមទាំងមានការសិក្សាពីបញ្ហាប្រឈមក្នុងវិស័យកសិកម្មរបស់ខេត្ត និងដំណោះស្រាយមួយចំនួនរបស់ស្ថាប័នពាក់ព័ន្ធផងដែរ។
– **ជំពូកទី៣** ក្នុងជំពូកនេះ យើងសិក្សាពីការព្យាករណ៍ទៅលើអនុវិស័យមួយចំនួនក្នុងវិស័យកសិកម្មខេត្តដោយប្រើកម្មវិធី Excel ជាជំនួយ។ បន្ថែមពីនេះទៀត ក៏មានការសិក្សាពីបញ្ហាប្រឈមដែលកើតមានក្នុងការអភិវឌ្ឍវិស័យមួយនេះ ព្រមទាំងមានដំណោះស្រាយមួយចំនួនផងដែរ។

- **សន្និដ្ឋាន និងអនុសាសន៍** ជាចំណុចចុងក្រោយបង្អស់ដែលធ្វើការសង្ខេបប្រធានបទនេះឡើងវិញ ហើយថែមទាំងមានភ្ជាប់ជាមួយនូវមតិយោបល់មួយចំនួនជុំវិញប្រធានបទនេះទៀតផង។

# ជំពូកទី១
# រំលឹកទ្រឹស្តីកសិកម្ម

# ជំពូកទី១
# រំលឹកទ្រឹស្តីកសិកម្ម

## ១.១ និយមន័យ និងទ្រឹស្តីនៃពាក្យគន្លឹះ

### ១.១.១ និយមន័យការអភិវឌ្ឍ

ការអភិវឌ្ឍ គឺជានីតិវិធីនៃការប្រែក្លាយរចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងស្ថាប័ន ដែលបង្កភាពងាយស្រួល ឬមានអំណោយផលដល់ការជំរុញសេដ្ឋកិច្ចឱ្យមានភាពរីកចម្រើន និងមានកំណើនបន្តបានយូរ ឬក៏ការអភិវឌ្ឍ គឺជាការធ្វើឱ្យសេដ្ឋកិច្ចមានកំណើនជាចីរភាព។[1]

អភិវឌ្ឍន៍ គឺជាដំណើរដែលធ្វើឱ្យការរស់នៅរបស់មនុស្សទាំងអស់ប្រកបដោយគុណភាព ហើយការអភិវឌ្ឍនេះ បង្ហាញក្រោមលក្ខខណ្ឌចំនួនបីដូចខាងក្រោម៖

- ការធ្វើឱ្យមានភាពប្រសើរឡើងនូវកម្រិតការរស់នៅរបស់ប្រជាពលរដ្ឋ តាមរយៈកម្រិតប្រាក់ចំណូលខ្ពស់ ការប្រើប្រាស់របស់ពួកគេមានការកើនឡើង សេវាសុខភាពល្អប្រសើរ និងកម្រិតការអប់រំល្អប្រសើរជាងមុន ដោយយោងទៅលើកម្រិតនៃកំណើនសេដ្ឋកិច្ច។
- ការបង្កើតមានលក្ខខណ្ឌដែលនាំឱ្យមានការគោរពឱ្យតម្លៃខ្លួនឯង តាមរយៈការបង្កើនស្ថាប័ននយោបាយ សេដ្ឋកិច្ច និងសង្គម។
- ការលើកកម្ពស់សេរីភាពរបស់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់សិទ្ធិ ដើម្បីធ្វើការសម្រេចចិត្ត ការជ្រើសរើស ការប្រើប្រាស់នូវទំនិញ និងសេវាកម្មឱ្យកាន់តែមានភាពទូលំទូលាយ។

### ១.១.២ ទ្រឹស្តីការអភិវឌ្ឍ

អភិវឌ្ឍន៍ គឺជាពាក្យដែលមានអត្ថន័យទូលំទូលាយ មានការប្រែប្រួលពីមួយសម័យទៅមួយសម័យ និងមានអត្ថន័យខុសគ្នាៗទៅតាមទស្សនៈយល់ឃើញរបស់អ្នកប្រាជ្ញនីមួយៗ។ ដើម្បីឱ្យកាន់តែមានភាពច្បាស់លាស់ពីពាក្យ "អភិវឌ្ឍន៍" យើងសូមលើកយកការបកស្រាយ និងការឱ្យនិយមន័យទៅតាមអ្នកប្រាជ្ញមួយចំនួន ដូចខាងក្រោម៖

**ទ្រឹស្តីរបស់លោក Michel P. Todaro**

ការអភិវឌ្ឍអាចកើតមាន និងប្រកបដោយនិរន្តរភាពគឺចាំបាច់ត្រូវផ្តើមចេញពីតំបន់ជនបទជាពិសេសការផ្តោតលើវិស័យកសិកម្ម។ គាត់បានលើកឡើងបន្តទៀតថា ប្រជាជាតិមួយអាចឈានដល់ការអភិឌ្ឍ យ៉ាងហោចណាស់ត្រូវមានកត្តាដូចជា៖ ការពន្លឿន output តាមរយៈការធ្វើ

[1] ឡៃ បូរ៉ាពីន, *ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា* (២០១៧), ទំព័រ ៦។

កំណែទម្រង់ផ្នែកស្ថាប័ន និងបច្ចេកវិទ្យាដែលត្រូវរៀបចំឡើងដើម្បីបង្កើនផលិតភាពសម្រាប់កសិករតូចតាចបង្កើនតម្រូវការក្នុងស្រុកសម្រាប់ផលិតភាពកសិកម្មដែលមានប្រភពពីយុទ្ធសាស្ត្រអភិវឌ្ឍន៍ការងារជាយក្រុង សកម្មភាពអភិវឌ្ឍន៍ជនបទដើម្បីពង្រឹងកម្លាំងពលកម្មមិនមែនកសិកម្ម និងវិស័យដទៃទៀតដែលគាំទ្រដោយផ្ទាល់ ឬដោយប្រយោលពីសមាគមន៍កសិកម្ម។

**ទ្រឹស្តីរបស់លោក W. Arthur Lewis**

លោក Lewis គាត់បានឱ្យនិយមន័យ ការអភិឌ្ឍ ថាជាការផ្លាស់ប្តូរនូវអ្វីដែលជាចំបាច់ដំបូងសម្រាប់ជាតម្រូវការមូលដ្ឋានរបស់ប្រជាជន។ តួយ៉ាងការអភិវឌ្ឍប្រទេសមួយជាដំបូងត្រូវពឹងផ្អែកជាសំខាន់លើការងារកសិកម្ម ហើយទើបគេផ្លាស់ប្តូរទៅរកវិស័យផ្សេងៗទៀតដែលទាក់ទងគ្នា។[2]

### ១.១.៣ ទ្រឹស្តីកសិកម្ម

កសិកម្ម ត្រូវបានអ្នកប្រាជ្ញនីមួយៗ ឱ្យនិយមន័យទៅតាមទស្សនៈយល់ឃើញផ្សេងៗពីគ្នា តែអត្ថន័យរបស់វាក៏មិនខុសពីគ្នាប៉ុន្មានដែរ។ និយមន័យទាំងនោះរួមមានៈ

កសិកម្ម សំដៅដល់ការធ្វើផលិតកម្មរបស់មនុស្សជំនាន់ដើមដែលមានការចូលរួមពីកត្តាផលិតកម្មផ្សេងៗដូចជា កម្លាំងពលកម្មរបស់មនុស្ស ដើម្បីធ្វើការកែប្រែដីកសិកម្ម និងការចិញ្ចឹមសត្វ។

កសិកម្ម គឺជាវិទ្យាសាស្ត្រ ឬសិល្បៈនៃការកែច្នៃដី ការធ្វើគ្រាប់ពូជ ការផលិត ការបង្កាត់ពូជ និងស្បៀងអាហារគ្រប់ប្រភេទសម្រាប់ការផ្គត់ផ្គង់ទីផ្សារ។

កសិកម្ម :ការភ្ជួររាស់ ឬការងារដែលគេប្រកបក្នុងការភ្ជួររាស់ គឺការធ្វើស្រែចំការ។[3]

## ១.២ ប្រវត្តិកសិកម្ម

### ១.២.១ ដំណាក់កាលមិនទាន់មានកសិកម្ម

ចាប់តាំងពីដើមកំណើតដំបូងរបស់មនុស្ស ពួកគេគឺមិនទាន់ចេះធ្វើកសិកម្មនៅឡើយនោះទេ ហើយបានរស់នៅរាយប៉ាយពីគ្នាដោយប្រកបរបរការបរបាញ់សត្វ និងការប្រមូលអនុផលព្រៃឈើដើម្បីចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ពួកគេ។ ដោយសារកំណើនមនុស្សចេះតែមានការកើនឡើងបានធ្វើឱ្យអនុផលព្រៃឈើ និងសត្វព្រៃនៅទីតាំងគេរកក្នុងព្រៃមានការថយចុះ ដូច្នេះហើយពួកគេបានចល័តពីកន្លែងមួយទៅមួយកន្លែងក្នុងគោលបំណងរកទីកន្លែងដែលសម្បូរចំណីអាហារ។ ក្នុងការផ្លាស់ប្តូរទីកន្លែងនេះពួកគេបានជួបប្រទះនូវមនុស្សផ្សេងៗជាច្រើនដែលនាំឱ្យពួកគេមាន

[2] ឡៃ បូរ៉ាពីន, *ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា (២០១៧),* ទំព័រ ៦-៨។

[3] ឡៃ បូរ៉ាពីន, *ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា (២០១៧),* ទំព័រ១២ ។

ជម្លោះជាមួយគ្នា និងវាយប្រហារគ្នាទៅវិញទៅមកក្នុងការដណ្តើមទីកន្លែងដែលសម្បូរអនុផលព្រៃឈើយករៀងៗខ្លួន។ យូរៗទៅមនុស្សបានរស់នៅប្រមូលផ្តុំគ្នាព្រមទាំងបានបង្កើតជាគ្រួសារ ហើយនៅពេលចំនួនគ្រួសារមានការកើនឡើង ពួកគេបានបង្កើតទៅជាកុលសម្ព័ន្ធតូចៗដែលរស់នៅប្រមូលផ្តុំគ្នា។ ចាប់តាំងពីការបង្កើតជាកុលសម្ព័ន្ធពួកគេបានបែងចែកឋានៈ និងតួនាទីបានច្បាស់លាស់ក្នុងការគ្រប់គ្រងមានដូចជា មេកន្ទ្រាញជាអ្នកដឹកនាំ ហើយបុរសជាអ្នកបរបាញ់សត្វ ចំណែកឯស្ត្រី និងកុមារជាអ្នកប្រមូលនូវអនុផលព្រៃឈើ។ ទោះបីជាមានការបង្កើតជាកុលសម្ព័ន្ធក៏ដោយ ពួកគេទាំងអស់នោះនៅតែបន្តរស់ដោយចល័តពីកន្លែងមួយទៅកន្លែងមួយទៀត ដោយសារតែសត្វព្រៃ និងអនុផលព្រៃឈើមិនអាចធ្វើការផ្គត់ផ្គង់ដល់ក្រុមកុលសម្ព័ន្ធរបស់ពួកគេបាន ហើយសង្គ្រាមរវាងកុលសម្ព័ន្ធ និងកុលសម្ព័ន្ធបានកើតឡើងជារឿយៗដែលបានបណ្តាលឱ្យមនុស្សជាច្រើននាក់បានស្លាប់។ ពេលមួយ ពួកគេបានឃើញគ្រាប់រុក្ខជាតិដែលពួកគេបានបោះចោលនៅក្បែរទីតាំងពួកគេរស់នៅបានដុះលូតលាស់ល្អ និងផ្តល់ផលមកវិញ។ ម្យ៉ាងវិញទៀត សត្វព្រៃដែលពួកគេបរបាញ់បានអាចរក្សាទុកបានយូរថ្ងៃផងដែរ។ ចាប់តាំងពីពេលនោះមកពួកគេបានរក្សាទុកនូវគ្រាប់រុក្ខជាតិសម្រាប់ធ្វើការដាំដុះ និងសត្វព្រៃយកមករក្សាទុកផងដែរ។ ពេលនោះហើយដែលសញ្ញាណនៃការធ្វើកសិកម្មបានលេចរូបរាងឡើង។[4]

### ១.២.២ ដំណាក់កាលកសិកម្មដោយប្រើកម្លាំងមនុស្ស និងសត្វ

ឯកសារខ្លះបានលើកឡើងថា មនុស្សបានចេះធ្វើកសិកម្ម និងចិញ្ចឹមសត្វតាំងពីក្នុងកំឡុងពេល១៤,០០០-១៥,០០០ឆ្នាំមុនគ.ស.មកម្លេះ។ ឯកសារខ្លះទៀត វាបានបង្ហាញថា ប្រហែលជា ១០,០០០-១២,០០០ឆ្នាំមុន ក្រុមមនុស្សខ្លះចេះដាំដំណាំមួយចំនួន និងក្រុមមួយចំនួនទៀតអាចបង្កាត់សត្វព្រៃដែលពួកគេបរបាញ់បានយកមកចិញ្ចឹមផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ វាមិនមានការបកស្រាយឱ្យបានច្បាស់លាស់នោះទេ ថាការធ្វើកសិកម្មបានកើតឡើងមុនគេនៅទីណា។

តំបន់មួយចំនួនដូចជា តំបន់អេស៊ីប អ៊ីរ៉ាក់ អ៊ីរ៉ង់ បាលេស្ទីន និងអាស៊ីខាងត្បូងគេធ្លាប់ជឿថា ជាតំបន់ដែលមានកសិកម្មមុនគេ។ ប្រហែលសតវត្សរ៍ទី៥០មុនគ.ស. ប្រទេសចិន និងប្រទេសឥណ្ឌា ទើបតែមានការធ្វើកសិកម្មប៉ុណ្ណោះ។ ប្រហែល៦,០០០ឆ្នាំមុនគ.ស. តំបន់អាស៊ីខាងលិចបានដាំពោត សាលី ស្រូវសាលី និងចិញ្ចឹមចៀម ពពែមុនគេ ចំណែកឯតំបន់អាស៊ីអាគ្នេយ៍បានដាំស្រូវ ចិញ្ចឹមជ្រូក និងមាន់មុនគេក្នុងកំឡុង៣,០០០ឆ្នាំមុនគ.ស. ហើយតំបន់ដែលបានដាំពោតមុន

[4] ខូយ រ៉ាដា, *មូលដ្ឋានគ្រឹះនៃវិស្វកម្មកសិកម្ម (វិច្ឆិកា២០១១)*, ទំព័រ១-២។

គេប្រហែល៦,០០០ឆ្នាំមុនគ.ស. គឺតំបន់អាមេរិចខាងជើង និងអាមេរិចកណ្តាល។ គួរកត់សម្គាល់ផងដែរ នៅពេលដែលកសិកម្មមានការកើនឡើង មនុស្សបានចាប់ផ្តើមមានទីលំនៅអចិន្ត្រៃយ៍ ហើយការធ្វើកសិកម្មនេះបានជួយផ្គត់ផ្គង់តម្រូវការរបស់មនុស្សបានគ្រប់គ្រាន់ផងដែរ។

### ១.២.៣ ដំណាក់កាលទំនើបកម្មកសិកម្ម

នៅក្នុងឆ្នាំ១៧៦៥ ប្រទេសអង់គ្លេសបានរកឃើញម៉ាស៊ីនដើរដោយចំហាយទឹក ដូច្នេះហើយដំណាក់កាលកសិកម្មដោយប្រើកម្លាំង មនុស្ស សត្វ ត្រូវបានបញ្ចប់នៅស.វ.ទី១៨។ វិស័យកសិកម្មមានការប្រែប្រួលជាខ្លាំងគឺ ដោយសាររបកគំហើញនេះបានធ្វើឱ្យការងារក្នុងកសិដ្ឋានជាច្រើនត្រូវបានគេជំនួសដោយកម្លាំងម៉ាស៊ីនដែលដើរដោយចំហាយទឹក។ ដោយសារតែប្រជាជនមានកំណើនយ៉ាងខ្លាំង បើទោះបីជាមានការរីកចម្រើនខាងវិស័យកសិកម្មខ្លាំងយ៉ាងណាក៏ដោយក៏ពិភពលោកយើងនេះនៅតែជួបប្រទះបញ្ហាកង្វះស្បៀងអាហារ។ ហេតុនេះហើយ អ្នកវិទ្យាសាស្ត្របានខិតខំស្រាវជ្រាវរកមធ្យោបាយ និងបច្ចេកវិទ្យាថ្មីៗជាច្រើនដើម្បីធ្វើឱ្យវិស័យកសិកម្មកាន់តែមានភាពជឿនលឿន និងការអភិវឌ្ឍក្នុងគោលបំណងផ្គត់ផ្គង់នូវតម្រូវការស្បៀងអាហារដ៏ច្រើនលើសលប់របស់មនុស្ស។ ការប្រែប្រួលនេះបានឈានដល់បដិវត្តន៍បៃតងដែលជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រក្នុងការអភិវឌ្ឍន៍វិស័យកសិកម្ម។ ពេលនោះយើងឃើញថា ទិន្នផលដំណាំស្រូវបានកើនឡើងចំនួនពីរដង រីឯដំណាំស្រូវសាលីនៅក្នុងប្រទេសអភិវឌ្ឍន៍បានកើនឡើងដល់ទៅបីដងហើយ ការកើនឡើងនេះដោយសារតែមានពូជទំនើបៗជាច្រើនត្រូវបានគេបង្កើតឡើងដើម្បីបង្កើនទិន្នផលដំណាំឱ្យទទួលបានជាអតិបរមា។ ការផ្ទុះឡើងនៃបដិវត្តន៍បៃតងត្រូវបានគេកត់សម្គាល់ឃើញថា គឺបានបែងចែកជាពីរដំណាក់កាលគឺ ក្នុងប្រទេសអភិវឌ្ឍដូចជា ប្រទេសកាណាដា អាមេរិច អ៊ឺរ៉ុប និងញ៉ូវសេឡែន បដិវត្តន៍បៃតងនេះបានកើតឡើងនៅកំឡុងឆ្នាំ១៩៥០-១៩៧០ ចំណែកឯបដិវត្តន៍បៃតងដែលបានកើតឡើងនៅអំឡុងទសវត្សរ៍ទី៦០ នៅក្នុងប្រទេសកំពុងអភិវឌ្ឍដូចជាប្រទេសចិន ឥណ្ឌា និងហ្វីលីពីនជាដើម។

## ១.៣ តួនាទីកសិកម្មក្នុងការអភិវឌ្ឍ

បច្ចុប្បន្ននេះ ប្រទេសកាន់តែមានការអភិវឌ្ឍជឿនលឿន យើងឃើញថាវិស័យកសិកម្មបានចូលរួមតិចតួចណាស់ នៅក្នុងផលិតផលក្នុងស្រុកសរុបដោយខុសពីវិស័យឧស្សាហកម្មបានចូលរួមក្នុងកម្រិតខ្ពស់ជាង។ ចំពោះប្រទេសកំពុងអភិវឌ្ឍ ឬប្រទេសក្រីក្រ វិស័យកសិកម្មមានតួនាទីយ៉ាងសំខាន់ណាស់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យមានភាពរីកចម្រើន ដោយសារតែវិស័យកសិ-កម្មបានចូលរួមក្នុងផលិតផលសរុបក្នុងស្រុកមានកម្រិត និងបានចូលរួមដោយកម្លាំងពលកម្ម

ច្រើនជាង៧០%។ ដូច្នេះហើយ ប្រទេសកំពុងអភិវឌ្ឍ ឬប្រទេសក្រីក្រគួរតែសិក្សា និងពិចារណាឱ្យបានច្បាស់លាស់ ព្រមទាំងស៊ីជម្រៅទៅលើទំនាក់ទំនង និងកត្តាដែលវិស័យកសិកម្មនេះនាំឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ច។[5]

### ១.៣.១ ការដកហូតកម្លាំងពលកម្ម

ប្រទេសកំពុងអភិវឌ្ឍ ឬប្រទេសក្រីក្រការប្រើប្រាស់ឧបករណ៍តាមបែបបុរាណមានតួនាទីសំខាន់ខ្លាំងណាស់នៅក្នុងការផលិត ដោយសារតែប្រទេសទាំងនេះពុំទាន់មានការរីកចម្រើនខ្លាំងនៅក្នុងវិស័យកសិកម្ម។ ពួកគេនឹងអាចដកហូតកម្លាំងយកទៅប្រើប្រាស់នៅក្នុងវិស័យផ្សេងទៀតបាន ប្រសិនបើពួកគេធ្វើការផ្លាស់ប្តូរកសិកម្មបែបបុរាណឱ្យក្លាយទៅជាវិស័យកសិកម្ម បែបប្រពលវប្បកម្មដោយប្រើប្រាស់កម្លាំងម៉ាស៊ីនជំនួសកម្លាំងគោក្របី និងមនុស្ស។

### ១.៣.២ ការបង្កើតទីផ្សារសម្រាប់ផលិតកម្មឧស្សាហកម្ម

នៅពេលវិស័យកសិកម្មមានការអភិវឌ្ឍ ឬប្រជាពលរដ្ឋបានធ្វើកសិកម្មបែបប្រពលវប្បកម្ម ដូច្នេះហើយពួកគេតែងតែមានតម្រូវការនូវផលិតផលឧស្សាហកម្ម។ ជាក់ស្តែងឧបករណ៍ដូចជា ផ្លែចប នង្គ័ល កណ្តៀវត្រូវបានគេជំនួសដោយប្រើប្រាស់ម៉ាស៊ីនច្រូតកាត់ ម៉ាស៊ីនបោកស្រូវ ត្រាក់ទ័រ គោយន្ត ជាពិសេសពួកគេប្រើប្រាស់នូវជីគីមីបន្ថែមលើលាមកសត្វ ឬជីកំប៉ុស្ត។

ការអភិវឌ្ឍវិស័យកសិកម្មកាន់តែមានភាពជឿនលឿនខ្លាំង វានឹងបង្កើននូវទិន្នផលកសិកម្មដែលអាចជួយឱ្យប្រជាពលរដ្ឋកាន់តែមានចំណូលច្រើនឡើងបន្ថែមទៀត។ ដូច្នេះហើយទើបកសិករមានតម្រូវការកាន់តែច្រើនបន្ថែមទៀតទៅលើផលិតផលឧស្សាហកម្មសម្រាប់សម្រួលដល់ការរស់នៅរបស់ពួកគេ ហើយផលិតផលឧស្សាហកម្មទាំងអស់នោះមានដូចជាសម្លៀកបំពាក់ ឆ្នាំង ចាន និងសម្ភារសម្រាប់សាងសង់ផ្ទះជាដើម។ ដើម្បីធ្វើឱ្យវិស័យឧស្សាហកម្ម ឬសិប្បកម្មរបស់ប្រទេសខ្លួនមានការរីកចម្រើនក្នុងដំណាក់កាលដំបូងប្រទេសកំពុងអភិវឌ្ឍ ឬប្រទេសក្រីក្រគួរតែកាត់បន្ថយការនាំចូលនូវផលិតផលឧស្សាហកម្មណា ដែលប្រទេសខ្លួនអាចមានលទ្ធភាពផលិតបានដូចជាចាន ឆ្នាំង គ្រឿងឧបភោគបរិភោគ ឬផលិតផលងាយៗផ្សេងទៀត។ កាលបើពុំមានការរីកចម្រើនខាងផ្នែកសិប្បកម្មទេ ប្រទេសនឹងមានការនាំចូលកាន់តែច្រើន ហើយវានឹងនាំឱ្យពលករក្នុងស្រុកគ្មានការងារធ្វើ។ ម្យ៉ាងវិញទៀត ប្រជាពលរដ្ឋក្នុងប្រទេសនោះនឹងមិនមានគំនិតចង់អភិវឌ្ឍវិស័យឧស្សាហកម្មឡើយ។

[5] ឡៃ បូរ៉ាពីន, *ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា (២០១៧)*, ទំព័រ១២-១៥។

### ១.៣.៣ បង្កើតការងារតាមរដូវ

ទៅតាមពេលវេលាខុសគ្នា ការប្រើប្រាស់កម្លាំងពលកម្មក្នុងកសិកម្មប្រពៃណី គឺមានការប្រែប្រួលខ្លាំង។ មូលហេតុនៃភាពខុសគ្នាគឺមកពីធម្មជាតិនៃផលិតកម្មកសិកម្មមានការប្រែប្រួលទៅតាមរដូវកាលនៃការប្រើប្រាស់ និងស្ថានភាពនៃការផ្គត់ផ្គង់ចំណីអាហារ។ យើងធ្វើការពិចារណាដល់គ្រួសារកសិករដែលបានដាំស្រូវធ្ងន់។ យើងឃើញថា ចាប់ពីខែមករា ដល់ខែឧសភា កសិករមិនសូវមានការធ្វើទេដោយពួកគេពឹងផ្អែកលើស្រូវក្នុងជង្រុកផ្ទុយទៅវិញ ខែកក្កដា ដល់ខែតុលា កសិករមានភាពមមាញឹកច្រើនក្នុងការធ្វើកសិកម្មដោយសារតែស្បៀងខ្សត់ខ្សោយ ឬរដូវកាលនៃការធ្វើស្រែ។ នៅរដូវវស្សា ពេលខ្វះខាតស្បៀងកសិករតែងតែខ្ចីបុលពីអ្នកដែលមានស្បៀង ហើយកសិករនឹងធ្វើការសងស្បៀងទៅគេវិញ បន្ទាប់ពីការច្រូតកាត់រួចហើយបញ្ហានេះអាចមកពីកសិករមិនមានកន្លែងទុកដាក់ ឬក៏ខ្វះខាតយន្តការសម្រាប់សន្សំស្បៀង។ ដូច្នេះហើយផលដែលទទួលបានពីការច្រូតកាត់មិនសូវនៅច្រើនទេដើម្បីទុកដាក់ក្នុងជង្រុក។

ទោះបីជាកសិករមិនមានការងារធ្វើគ្រប់រដូវកាលក៏ដោយយើងឃើញថាកសិករទាំងនោះមួយចំនួនធំមិនមានលទ្ធភាពប្រកបមុខរបរផ្សេងទៀតទេ ក្រៅពីឡើងត្នោត និងរកអុសទុកដុត។ កសិករនៅក្នុងប្រទេសកម្ពុជាពួកគេមិនសូវមានចំណេះដឹងអ្វីផ្សេងទេ ក្រៅពីធ្វើស្រែចម្ការ កង្វះខាតដើមទុន និងពុំមានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់សម្រាប់ធ្វើស្រែចម្ការនៅក្នុងរដូវប្រាំង។

### ១.៣.៤ ការបង្កើតរូបិយវត្ថុអន្តរជាតិ

វិស័យកសិកម្មមានលទ្ធភាពក្នុងការបង្កើតរូបិយវត្ថុអន្តរជាតិអាចធ្វើឡើងតាមរយៈ៖

- ផលិតផលកសិកម្មត្រូវបានគេនាំយកទៅលក់នៅបរទេស
- ផលិតផលក្នុងស្រុកត្រូវបានគេរៀបចំលក់ឱ្យបានច្រើន ហើយកាត់បន្ថយការនាំចូលផលិតផលមកពីបរទេស ហើយប្រាក់ចំណូលទាំងនោះគេត្រូវយកទៅប្តូរជារូបិយវត្ថុអន្តរជាតិ
- វិស័យកសិកម្មទាមទារឱ្យផលិតលើសពីសេចក្តីត្រូវការរបស់ផលិតករ
- គ្រប់កសិផលដែលត្រូវបានគេផលិតលើសពីសេចក្តីត្រូវការក្នុងស្រុកត្រូវមានការនាំចេញទៅក្រៅប្រទេស ឬជំនួសផលិតផលអ្វីដែលបាននាំចូល
- ក្នុងវិស័យឧស្សាហកម្ម ឬវិស័យផ្សេងៗទៀត រូបិយវត្ថុអន្តរជាតិគួរត្រូវបានគេយកទៅប្រើប្រាស់ក្នុងការអភិវឌ្ឍប្រទេសពេលដែលចាំបាច់បំផុត។

### ១.៣.៥ ការធ្វើបដិវត្តន៍បៃតង

ការចាប់ផ្តើមរបស់បដិវត្តន៍បៃតង គឺជាការផ្លាស់ប្តូរបច្ចេកទេសដែលមានលក្ខណៈច្បាស់

លាស់ជាក់ស្តែងនឹងសមស្របទៅតាមសណ្ឋានដី អាកាសធាតុ សង្គមសេដ្ឋកិច្ច ប្រពៃណីរបស់ប្រទេសតតីយលោក។ ការចម្លងបច្ចេកទេសពីប្រទេសអភិវឌ្ឍន៍នេះត្រូវបានបង្ហាញដោយលោក Schutz ហើយគាត់បានធ្វើការស្នើសុំប្រទេសអភិវឌ្ឍន៍ដើម្បីធ្វើការផ្ទេរបច្ចេកទេសទាំងនេះទៅកាន់ប្រទេសក្រីក្រដែលគ្មានបច្ចេកទេសទាំងនេះ។ ប៉ុន្តែបច្ចេកទេសទាំងអស់នេះ គឺមិនមែនប្រទេសជឿនលឿនលែងប្រើ ឬហួសសម័យកាលនោះទេ។ ការប្រើប្រាស់នូវបណ្តុំនៃចំណេះដឹងនេះបានធ្វើឱ្យប្រទេសជឿនលឿនធ្វើការផលិត និងប្រើប្រាស់នូវបច្ចេកវិទ្យាថ្មីៗ និងទំនើបជាងប្រទេសផ្សេងៗទៀត។ ការប្រើប្រាស់នូវបច្ចេកវិទ្យានេះ គឺត្រូវសមស្របទៅនឹងសណ្ឋានដីជីវសាស្ត្រ និងទីកន្លែង។

### ១.៣.៦ បច្ចេកវិទ្យាបដិវត្តន៍បៃតង

វិធីសាស្ត្រថ្មី៤យ៉ាង ត្រូវបានគេបង្កើតឡើងក្នុងការធ្វើបដិវត្តន៍បៃតង៖

- សម្ភារៈជីវសាស្ត្រ ដែលទទួលបានលទ្ធផលល្អបំផុតត្រូវបានគេផ្សព្វផ្សាយមានដូចជាគ្រាប់ពូជដែលមានទិន្នផលខ្ពស់
- ការផ្សព្វផ្សាយពីការប្រើប្រាស់ជី(គីមីកំប៉ុស) ពូជដែលលក្ខណៈល្អប្រសើរក្នុងការបង្កើនទិន្នផល
- ប្រព័ន្ធធារាសាស្ត្រគួរតែរៀបចំកសាងឱ្យបានល្អប្រសើរ
- ការបង្កើនល្បឿននៃវដ្តរុក្ខជាតិតាមរយៈការធ្វើប្រពលវប្បកម្មក្នុងការប្រើប្រាស់ដីដែលត្រូវបានគេអនុវត្តដូចជា បច្ចេកទេសនៃការដាំដុះ និងការប្រមូលផល។[6]

## ១.៤ ស្ថានភាពសេដ្ឋកិច្ចកម្ពុជា

ក្រោយពីសង្គ្រាមស៊ីវិល ដែលបានអូសបន្លាយអស់រយៈពេលជាងបីទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាបានទទួលនូវសន្តិភាពពេញលេញចាប់ពីឆ្នាំ១៩៩៨ បានកំពុងស្តាបនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច រចនាសម្ព័ន្ធមូលដ្ឋានរបស់សង្គម។ ប្រទេសអាចប្រើប្រាស់ធនធាន និងកម្លាំងរបស់ខ្លួនទៅរកទិសដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព និងស្មើរភាព។ ប្រទេសកម្ពុជាមានអត្រាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំកើនឡើងមិនលើស៣៥% (ក្នុងឆ្នាំ១៩៨៨-១៩៩១) ទោះបីជាវាមានកំណើនមធ្យមប្រចាំឆ្នាំក្នុងវិស័យរោងចក្រកើនឡើងដល់៦.៣% យ៉ាងណាក៏ដោយ។[7] ក្រោយពីមានសន្និសិទ្ធអន្តរជាតិនៅទីក្រុងប៉ារីសនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ដែលបានចុះហត្ថលេខា

[6] ឡៃ បូរ៉ាពីន, *ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា (២០១៧)*, ទំព័រ១៥-១៨។
[7] បណ្ឌិត ហង់ ជួន ណារ៉ុន, សេដ្ឋកិច្ចកម្ពុជា (២០១៥),ទំព័រទី ១០។

លើកិច្ចព្រមព្រៀងស្តីអំពី ដំណោះស្រាយនយោបាយគ្រប់ជ្រុងជ្រោយនៃវិបត្តិកម្ពុជាតាមរយៈការបោះឆ្នោតជាសកលដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ១៩៩៣។ នៅក្នុងអំឡុងទសវត្សរ៍ទី៩០កម្ពុជាគឺ ជាប្រទេសដែលមានកម្រិតនៃការអភិវឌ្ឍនៅមានកម្រិតទាបដោយសារប្រទេសនេះបានទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរដោយសារភ្លើងសង្គ្រាម និងភាពឯកាពីសហគមន៍អន្តរជាតិ។ ប្រជាជនម្នាក់ៗមានប្រាក់ចំណូលប្រចាំឆ្នាំមិនដល់ ២០០ដុល្លារផង។ ម្យ៉ាងទៀតគឺបានជួបប្រទះនូវគ្រោះហន្តរាយសង្គមយ៉ាងធំធេងនៅដើមទសវត្សរ៍៩០នោះ។ កម្ពុជាមានអាត្រាមរណៈទារកកម្រិតខ្ពស់ជាងគេលើពិភពលោក។ ក្រៅពីនេះអត្រាជនពិការ និងករណីជម្ងឺរបេងក៏ច្រើនជាងគេលើពិភពលោកផងដែរ និងមានប្រជាជនតែ ១២%ប៉ុណ្ណោះដែលមានទឹកស្អាតប្រើប្រាស់។ ចំណែកឯកុមារនៅជនបទខ្លះបានទៅចុះឈ្មោះចូលរៀនមានមិនដល់៣០%ផង។ ដើម្បីលើកកម្ពស់ចីរភាពសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់រហ័សរាជរដ្ឋាភិបាលបានផ្តល់អាទិ-ភាពទៅលើការវិនិយោគក្នុងវិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គឺលើផ្លូវដឹកជញ្ជូន ទូរគមនា-គមន៍ ថាមពលអគ្គិសនី ការអភិវឌ្ឍធនធានមនុស្ស ឧស្សាហកម្មអតិពលកម្ម ព្រមទាំងផលិតផលកម្មន្តសាលសម្រាប់នាំចេញ និងទេសចរណ៍ដែលគោលនយោបាយទាំងនេះមានគោលដៅបង្កើតនូវមូលដ្ឋានគ្រឹះដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព។ ក្នុងរយៈពេល១៥តែប៉ុណ្ណោះ ក្រោយពីបានសន្តិភាពពេញលេញក្នុងឆ្នាំ១៩៩៩មក កម្ពុជាបានផ្លាស់ប្តូរយ៉ាងឆាប់រហ័សពីប្រទេសដែលគ្មានស្ថិរភាព សង្គ្រាមរ៉ាំរ៉ៃ ឧក្រិដ្ឋកម្ម និងការបែកបាក់សាមគ្គីទៅជាប្រទេសដែលមានសុខសន្តិភាពស្ថិរភាព ការបង្រួមជាតិ ប្រជាធិបតេយ្យ និងនីតិរដ្ឋ។ ចំពោះវិស័យសេដ្ឋកិច្ចកម្ពុជាសម្រេចបាននូវភាពជោគជ័យដ៏ធំធេងដែលប្រែក្លាយពីប្រទេសមានសេដ្ឋកិច្ចបែបប្រពៃណីដោយពឹងផ្អែកលើវិស័-យកសិកម្មជាចម្បង ទៅជាប្រទេសដែលមានសេដ្ឋកិច្ចទំនើបដោយអាស្រ័យលើវិស័យឧស្សាហ-កម្ម និងសេវាកម្មដើរតួនាទីឈានមុខ។ នាពេលបច្ចុប្បន្នសម្រាប់វិស័យកសិកម្មមានការប្រើប្រាស់គ្រឿងយន្តកសិកម្មដែលតម្រូវឱ្យកសិករ ត្រូវពង្រឹងសមត្ថភាពបន្ថែមទៀតដើម្បីក្លាយជាកសិករសម័យទំនើប។ រាជរដ្ឋាភិបាល បានផ្តល់អាទិភាពលើការវិនិយោគសាធារណៈក្នុងការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ និងការវិនិយោគឯកជនដែលក្លាយជាមូលដ្ឋានគ្រឹះសម្រាប់កំណើនសេដ្ឋកិច្ច។ យុទ្ធសាស្ត្រសេដ្ឋកិច្ចកម្ពុជាគឺប្រែក្លាយការវិនិយោគទាំងក្នុង និងក្រៅប្រទេសឱ្យទៅជាការនាំចេញទំនិញ និងសេវាកម្មដែលកម្ពុជាមានឧត្តមភាពប្រៀបធៀប។ លើសមរភូមិសេដ្ឋកិច្ចឆ្នាំ ១៩៩៩ ដល់ឆ្នាំ២០១៤កម្ពុជាមានកំណើនសេដ្ឋកិច្ចជាមធ្យម ៧% ក្នុងមួយឆ្នាំដែលជាកំណើនខ្ពស់ក្នុងតំបន់។ នៅឆ្នាំ២០១៤ កំណើនសេដ្ឋកិច្ចកម្ពុជាសម្រេចបានប្រមាណ៧% ក្នុងនោះមានវិស័យ

អាទិភាពសំខាន់ៗដូចជា៖

ទី១ គឺឧស្សាហកម្មដែលមានកំណើនប្រមាណ៩៦%ដោយសារតែមានការនាំចេញផលិតផលវាយនភ័ណ្ឌរក្សាបាននូវកំណើនខ្ពស់ ហើយផ្នែកសំណង់ក៏បានកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ។

ទី២ គឺវិស័យសេវាកម្មមានកំណើន៧.៥% ដោយមានការរួមចំណែកពីផ្នែកពាណិជ្ជកម្ម សណ្ឋាគារ ភោជនីយដ្ឋាន អចលនទ្រព្យ ធនាគារ និងភាពប្រសើរឡើងនៃប្រព័ន្ធឡូជីស្ទិក។

ទី៣ វិស័យកសិកម្មសម្រេចបានកំណើន ២.៦%ដោយសារពិពិធកម្មនៃការដាំដុះ និងការកើនឡើងនៃផលិតភាព។[8]

សម្រាប់រយៈពេល៥ចុងក្រោយនេះ រាជរដ្ឋាភិបាលសម្រេចបានតាមការគ្រោងទុកនូវកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំក្នុងរង្វង់៧% ប្រកបដោយបរិយាប័ន្ន និងសមធម៌។ កម្ពុជាថែមទាំងសម្រេចបាននូវបង្គោលចរជាប្រវត្តិសាស្ត្រ គឺការឆ្លងកាត់ពីឋានៈប្រទេសដែលមានចំណូលទាបទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបជាផ្លូវការក្នុងឆ្នាំ២០១៥ ព្រមទាំងត្រូវបានគេចាត់ទុកថាជា "ខ្លាសេដ្ឋកិច្ចនៅអាស៊ី" ក្នុងឆ្នាំ២០១៦។ កំណើនដ៏គួរឱ្យស្ញប់ស្ញែងនេះបានបង្កើតការងារជាច្រើនដល់ពលរដ្ឋទូទាំងប្រទេស ដែលវាឆ្លុះបញ្ចាំងតាមរយៈតួលេខរបស់ធនាគារពិភពលោកបានបង្ហាញថា ភាពគ្មានការងារធ្វើនៅកម្ពុជាស្ថិតក្នុងអត្រា០.៣% និងភាពក្រីក្រតោកយ៉ាកត្រូវបានលុបបំបាត់ទាំងស្រុងក្នុងឆ្នាំ២០១៧។ ចំពោះប្រាក់ចំណូលរបស់ប្រជាជនក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ដោយសារ ផ.ស.ស.ក្នុងមនុស្សម្នាក់កើនដល់ពី ១,០៤២ដុល្លារអាមេរិកក្នុងឆ្នាំ២០១៣ ដល់១,៤២៧ដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ និង១,៥៦៣ដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៨។[9]

### ១.៤.១ ការវាយតម្លៃកំណើនសេដ្ឋកិច្ចកម្ពុជា

ចំពោះការវាយតម្លៃកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០១៨ បើទោះបីជាស្ថានភាពពិភពលោកកំពុងជួបប្រទះនូវបញ្ហាប្រឈម និងភាពមិនប្រាកដប្រជាជាច្រើន ជាពិសេសភាពតានតឹងនៃសង្គ្រាមពាណិជ្ជកម្មរវាងប្រទេសចិន និងសហរដ្ឋអាមេរិក។ វាបានធ្វើឱ្យសេដ្ឋកិច្ចទាំងពីនេះ និងប្រទេសដទៃទៀតមានកំណើនថមថយក្តី ប៉ុន្តែសេដ្ឋកិច្ចកម្ពុជានៅតែអាចបន្តរក្សាបានកំណើន

[8] បណ្ឌិត ហង់ ជួន ណារ៉ុន, *សេដ្ឋកិច្ចកម្ពុជា(២០១៥)* ,ទំព័រទី៤

[9] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ,*ក្របខ័ណ្ឌនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៩*,ទំព័រទី១,២

ខ្ពស់ និងរឹងមាំក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ។ ក្នុងឆ្នាំ២០១៧កន្លងទៅ កម្ពុជារក្សាបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រា៧.០% ដែលគាំទ្រដោយកំណើនរឹងមាំនៃអនុវិស័យសំណង់ និងការបន្តកំណើននៃអនុវិស័យកាត់ដេរ ព្រមទាំងវិស័យកសិកម្ម។ ការងើបឡើងខ្លាំងនៃអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន និងអនុវិស័យលក់ដុំរាយ។ ទោះជាយ៉ាងនេះក្តី អនុវិស័យកម្មន្តសាលនៅកម្ពុជាដែលផ្តោតលើផលិតកម្មតម្លៃបន្ថែមទាបនិងកំណើនយឺតនៃអនុវិស័យកាត់ដេរក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ វាបង្ហាញពីភាពចាំបាច់ និងបន្ទាន់ក្នុងការកែទម្រង់រចនាសម្ព័ន្ធ និងពិពិធកម្មសេដ្ឋកិច្ចទៅរកវិស័យកាត់ដេរដែលមានតម្លៃបន្ថែមខ្ពស់ ព្រមទាំងវិស័យដែលមានសក្តានុពលផ្សេងទៀតដើម្បីបន្តចីរភាពកំណើនក្នុងរយៈពេលមធ្យម និងវែង។

សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០១៨ ត្រូវបានប៉ាន់ស្មានថានឹងមានកំណើនក្នុងរង្វង់ ៧.៥%ដែលជាកំណើនមួយខ្ពស់បំផុតក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ។ ក្នុងនោះវិស័យឧស្សាហកម្មបានដើរតួរយ៉ាងសំខាន់ព្រោះវិស័យជំរុញឱ្យមានកំណើន និងមានការកើនឡើងក្នុងអត្រាប្រមាណ ១២.៣% ដោយសារកំណើនលើសពីការរំពឹងទុកនៃអនុវិស័យកាត់ដេរ កំណើនរឹងមាំនៃអនុវិស័-យសំណង់ និងអនុវិស័យឧស្សាហកម្មមិនមែនកាត់ដេរ។ ដោយឡែកវិស័យសេវាកម្មនៅតែបន្តកំណើនរឹងមាំក្នុងអត្រាប្រមាណ៦.៥% ដែលគាំទ្រដោយកំណើនល្អប្រសើរនៃអនុវិស័យមួយចំនួនដូចជា សណ្ឋាគារ ភោជនីយដ្ឋាន ការលក់ដុំរាយ ការដឹកជញ្ជូន គមនាគមន៍ និងអចលនទ្រព្យ។ វិស័យកសិកម្មនៅតែបន្តកំណើនទាបពោលគឺក្នុងអត្រា១.៧% ដោយសារការថមថយកំណើននៃការដាំដុះដំណាំ និងការចិញ្ចឹមសត្វ បើទោះបីជាការនេសាទអាចរក្សាបានកំណើនខ្ពស់ជាងឆ្នាំ ២០១៧បន្តិចបន្តួចក្តី។ ជាមួយនឹងកំណើនរឹងមាំក្នុងឆ្នាំ២០១៨នេះ ផ.ស.ស. ថ្លៃបច្ចុប្បន្នត្រូវបានប៉ាន់ស្មានថានឹងកើនឡើងដល់ ២៤.៤ប៊ីលានដុល្លាអាមេរិកដែលធ្វើឱ្យ ផ.ស.សសម្រាប់មនុស្សម្នាក់អាចនឹងកើនឡើងដល់ ១,៥៤៨ដុល្លាអាមេរិក។ លើសពីនេះ កម្ពុជាអាចរក្សាបាននូវអតិផរ-ណាដែលស្ថិតក្នុងកម្រិតទាប និងអាចគ្រប់គ្រងបានក្នុងអត្រាមធ្យមប្រចាំឆ្នាំប្រមាណជា ២.៥% ក្នុងឆ្នាំ២០១៨ ដោយថយពី ២.៩%ក្នុងឆ្នាំ២០១៧ ដោយសារកំណើនទាបនៃថ្លៃម្ហូបអាហារក្នុងស្រុក។ ជាមួយគ្នានេះដែរ អត្រាប្តូរប្រាក់នៅបន្តមានស្ថិរភាពជាមួយនឹងការរំពឹងទុកថា ប្រាក់រៀលនឹងនៅបន្តរក្សាបាននូវតម្លៃប្រមាណជា ៤,០៥៣រៀល ក្នុង ១ដុល្លារអាមេរិក នៅក្នុងឆ្នាំ ២០១៨ នេះ។[10]

[10] https://www.mef.gov.kh

### ១.៤.២ ការចូលរួមរបស់វិស័យកសិកម្មក្នុង ផ.ស.ស.

វិស័យកសិកម្មបានរួមចំណែកក្នុង ផ.ស.ស. ក្នុងឆ្នាំ២០១៤ បានប្រមាណ ៣០.៧% (គិតថ្លៃបច្ចុប្បន្ន) ខណៈដែលវិស័យឧស្សាហកម្មបានរួមចំណែកចំនួន ២៧.២% និងវិស័យសេវាកម្មចំនួន៤២.២%។

ក្នុងរយៈពេលប្រមាណ៥ឆ្នាំចុងក្រោយនេះ ការរួមចំណែកវិស័យកសិកម្មក្នុងផ.ស.ស.មានការថយចុះជាបន្តបន្ទាប់។ តែនេះមិនមែនមានន័យថា វិស័យកសិកម្មមានការអន់ថយនោះទេគឺដោយសារតែវិស័យឧស្សាហកម្ម និងសេវាកម្មមានសន្ទុះខ្លាំងជាងតែប៉ុណ្ណោះ។

ក្រាហ្វិកទី១៖ បង្ហាញពីការរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ




*ប្រភព៖ របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៨-២០១៩, ទំព័រទី ១១*

នៅក្នុងឆ្នាំ ២០១៨ វិស័យកសិកម្មបានរួមចំណែកក្នុង ផ.ស.ស.ធ្លាក់មកត្រឹមតែ ២៣.៥% គឺថយចុះអស់ប្រមាណ ៧.២% (បើធៀបនឹងឆ្នាំ២០១៤) នៅពេលដែលវិស័យឧស្សាហកម្មមានសន្ទុះកើនដល់ ៣៤.៤% និងវិស័យសេវាកម្មថយបន្តិចគឺត្រឹម ៤២.១%។ បើយើងពិនិត្យឱ្យបានច្បាស់ជាងនេះទៀត គេឃើញថា តម្លៃបន្ថែមសរុបនៃផលិតផលកសិកម្មមានការកើនឡើងជារៀងរាល់ឆ្នាំ។ នៅឆ្នាំ២០០៩ តម្លៃបន្ថែមសរុបនៃវិស័យកសិកម្មមានចំនួន ១៤,៤២០ពាន់លានរៀលបានកើនដល់ ១៩,៤៧០ពាន់លានរៀលនៅឆ្នាំ២០១៤ ហើយបន្តកើនដល់ ២១,៩១៣ពាន់លានរៀលនៅឆ្នាំ២០១៨។ បើធៀបនឹងឆ្នាំ២០០៩មកឆ្នាំ២០១៨ គឺកើនបានទឹកប្រាក់ ៧,៤៩៣ពាន់លាន

រៀល ស្មើនឹង៥១.៩៦% ដែលនេះបានបង្ហាញពីកំណើនផលិតភាពក្នុងវិស័យកសិកម្មមានការកើនឡើងគួរ ជាទីមោទនៈ។[11]

ក្រាហ្វិកទី២៖ បង្ហាញពីការកើនឡើងតម្លៃបន្ថែមសរុបនៃវិស័យកសិកម្មឆ្នាំ២០០៩-២០១៨




ប្រភព៖របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៨-២០១៩, ទំព័រទី ១១

## ១.៥ សមាសភាគនៃអនុវិស័យក្នុងវិស័យកសិកម្ម

នៅឆ្នាំ២០១៩ ដំណាំគ្រប់ប្រភេទបានចូលរួមជាងពាក់កណ្តាលគឺចំនួន៥៩.៥%នៃផ.ស.ស របស់វិស័យកសិកម្ម ផ្នែកជលផលមានចំណែក ២២.២% ផ្នែកផលិតកម្មសត្វ ១១.៣% និងព្រៃឈើ បាន ៧.០% តែប៉ុណ្ណោះ។ ក្នុងឆ្នាំ២០១៨ ផលិតកម្មផ្នែកដំណាំនៅតែរក្សាទីតាំងលំដាប់លេខ ១ ដដែលក្នុងការចូលរួមក្នុងផ.ស.ស. នៃវិស័យកសិកម្មដែលបានចំនួន៥៨.១% និងផ្នែកជលផល បាន២៤.១% ឈរនៅលំដាប់លេខពីរ។ ចំណែកផ្នែកផលិតកម្មសត្វគឺមានប្រមាណ១១.១% និងផ្នែកព្រៃឈើប្រមាណ៦.៧%ផងដែរ។ ជាការកត់សម្គាល់ផលិតកម្មដំណាំ និងផ្នែកជលផលគឺជាកម្លាំងចលករនាំមុខនៅក្នុងផលិតកម្មកសិកម្ម ចំណែកឯផលិតកម្មសត្វគឺ ជាមុខព្រួញដ៏សំខាន់

[11] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ,*របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០១៨-២០១៩,* ទំព័រទី១១

មួយទៀតក្នុងការផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងការនាំចេញដែលទាំងផ្នែកនេះត្រូវមានការយកចិត្តទុកដាក់ និងជំរុញបន្ថែមទៀត។[12]

ក្រាហ្វិកទី៣៖ បង្ហាញពីការចូលរួមនៃអនុវិស័យកសិកម្ម(%)




| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| ដំណាំ | ៥៩.៤% | ៥៩.៥% | ៥៩.០% | ៥៨.៥% | ៥៨.១% |
| សត្វ | ១១.៣% | ១១.៣% | ១១.៣% | ១១.២% | ១១.១% |
| ជលផល | ២២.២% | ២២.៣% | ២២.៩% | ២៣.៥% | ២៤.០% |
| ព្រៃឈើ | ៧.០% | ៦.៩% | ៦.៨% | ៦.៨% | ៦.៧% |

ប្រភព៖ របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៨-២០១៩, ទំព័រទី ១២

## ១.៦ ស្ថានភាពនៃការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជា២០០៨-២០១៨

វិស័យកសិកម្មមានសារសំខាន់ណាស់ក្នុងការជំរុញឱ្យមានកំណើនសេដ្ឋកិច្ច និងរក្សាបានសន្តិសុខស្បៀង ដោយហេតុថាវាជាប្រភពអាហាររបស់ប្រជាជនកម្ពុជាប្រចាំថ្ងៃ ហើយក៏ជាវិស័យមួយដែលផលិតនូវវត្ថុធាតុដើមមួយចំនួនសម្រាប់ការអភិវឌ្ឍដល់កសិឧស្សាហកម្មផងដែរ។ ក្រៅពីនេះទៅទៀត វាជាវិស័យដែលអាចផ្តល់ចំណូលដល់ជាតិដ៏សំខាន់មួយដែរ តាមរយៈការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិ ។

### ១.៦.១ ផលិតកម្មដំណាំស្រូវ

ផលិតកម្មស្រូវ នៅតែជាផលិតកម្មដ៏ចម្បងមួយសម្រាប់ទ្រទ្រង់ជីវភាពប្រជាជនក្រីក្រនៅតាមតំបន់ជនបទ។ ស្រូវជាផលិតផលសំខាន់បំផុតសម្រាប់កម្ពុជាដែលស្មើនឹង៨៤% នៃផលិតកម្មស្បៀងអាហារប្រចាំឆ្នាំ និងផ្គត់ផ្គង់បាន៦៨%នៃតម្រូវការអាហារថាមពលសរុប។ ដំណាំនេះត្រូវ

[12] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ,*របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០១៨-២០១៩*, ទំព័រទី១២

បានកសិករភាគច្រើនដាំដុះនៅក្នុងតំបន់អាងកណ្តាលនៃដីសណ្តរទន្លេមេគង្គ និងវាលទំនាបនៃទន្លេសាប។[13]

នៅឆ្នាំ២០០៨ ផ្ទៃដីទូទាំងប្រទេសមានចំនួនប្រមាណ ២,៦១៥,៧៤១ហិចតា ដែលលើសពីឆ្នាំមុនចំនួន ២៩,៨៣៦ហិចតា ក្នុងនោះមានការអនុវត្តនៅរដូវវស្សាបានចំនួន ២,២៥៥,១០៤ ហិចតា ដែលខ្ពស់ជាងឆ្នាំមុនចំនួន ៧៩,១២៤ហិចតា និងនៅរដូវប្រាំងអនុវត្តបានតែ ៣៦០,៦៣៧ ហិចតា។ ចំណែកផ្ទៃដីដែលរងការខូចខាតមានចំនួន ៣,១៦៣ហិចតា ក្នុងនោះមានស្រូវវស្សាចំនួន ៣,១៥៦ហិចតា ប៉ុន្តែគេស្តារឡើងវិញបានចំនួន ៧៨៥ហិចតា។ ចំពោះផ្ទៃដីប្រមូលផលមានចំនួន២,៦១៣,៣៦៣ហិចតា លើសឆ្នាំមុនចំនួន ៤៦,៤១១ហិចតា ស្មើនឹង ១.៨%។ សម្រាប់ទំហំផ្ទៃដីនេះមានផ្ទៃដីរដូវវស្សាដែលអាចប្រមូលផលបាន ២,២៥២,៧៣៣ហិចតា និងនៅរដូវប្រាំងមានចំនួន ៣៦០,៦៣០ហិចតា។ ទិន្នផលស្រូវបានទទួលនៅឆ្នាំ២០០៨ សរុបមានចំនួន ៧,១៧៥,៤៧៣តោន លើសឆ្នាំមុនចំនួន ៩៤៨,៣៤៦តោន ក្នុងនោះស្រូវវស្សាទទួលបានចំនួន ៥,៧២២,១៤២តោន (ច្រើនជាងស្រូវរដូវវស្សាឆ្នាំមុន ៨៩,៨៩៤តោន) និងរដូវប្រាំងទទួលបានផលចំនួន ១,៤៥៣,៣៣១តោន។ បើយើងគិតពីទិន្នផលប្រចាំឆ្នាំមានចំនួន ២.៧៤៦តោន/ហិចតាដែលមានការកើនឡើងប្រមាណ ០.១២៥តោន/ហិចតា បើធៀបនឹងឆ្នាំមុនក្នុងនោះទិន្នផលជាមធ្យមនៅរដូវវស្សាមានចំនួន ២.៥៤០តោន/ហិចតា ខណៈដែលនៅរដូវប្រាំងអាចទទួលផលអាចដល់ទៅ ៤.០៣០តោន/ហិចតា។ មួយវិញទៀត តុល្យភាពស្បៀងនៅឆ្នាំ២០០៨ ប្រទេសកម្ពុជាមានតម្រូវការស្បៀង ១,៩៧០,២៧០តោន ហើយមានអតិរេកស្រូវ ៣,១៦៤,១១៤តោន បើគិតជាអង្ករស្មើនឹង ២,០២៥,០៣៣តោន។[14]

នៅរយៈពេល៥ឆ្នាំក្រោយនេះគឺឆ្នាំ២០១៤ យើងឃើញថា ផលិតផលស្រូវមានការរីកចម្រើនគួរឱ្យកត់សម្គាល់ព្រោះថាទំហំផ្ទៃដីនៃការដាំដុះមានការកើនឡើងពី ២,៦១៥,៧៤១ហិចតា (២០០៨) ដល់ ៣,០៥៥,៥០៧ហិចតា(២០១៤) គឺកើនឡើងប្រមាណជា ៤៣៩,៧៦៦ហិចតា ស្មើនឹង ១៦.៨១%។ ចំពោះផ្ទៃដីនេះមានការដាំដុះនៅរដូវវស្សាចំនួន ២,៥៦៤,៥៧២ហិចតា។ ទំហំនៃផ្ទៃដីដាំដុះទាំងអស់នេះមិនអាចធ្វើការប្រមូលផលបានទាំងអស់នោះទេដោយហេតុថាមានការខូចខាតដោយសារគ្រោះធម្មជាតិ(រាំងស្ងួត) សត្វល្អិតបំផ្លាញជាដើម។ ជាក់ស្តែងផ្ទៃដីឆ្នាំ២០១៤នេះ

[13] បណ្ឌិត ហាង់ ជួន ណារ៉ុន, *សេដ្ឋកិច្ចកម្ពុជា(២០១៥)* ,ទំព័រទី១៨០។

[14] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ,*របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០១៥-២០១៦,* ឧបសម្ព័ន្ធទី១៥។

ផ្ទៃដីដែលអាចប្រមូលផលប្រចាំឆ្នាំបានមានតែ ៣,០២៨,៨៣៦ហិចតាប៉ុណ្ណោះ ដោយរងការខូចខាតទាំងស្រុងចំនួន ២៦,៦៧១ហិចតា ស្មើនឹង ០.០៨៧%នៃផ្ទៃដីដាំដុះស្រូវសរុប។ ផ្ទៃដីដែលអាចប្រមូលផលបាននេះគឺនៅរដូវវស្សាមានចំនួន ២,៥៣៧,៩៧៦ហិចតា និងសម្រាប់នៅរដូវប្រាំងអាចប្រមូលផលបានលើផ្ទៃដីបានចំនួន ៤៩០,៨៦០ហិចតា។ ចំពោះទិន្នផលជាមធ្យមប្រចាំឆ្នាំ ២០១៤ បានកើនដល់៣.០៧៩តោន/ហិចតាដែលទំហំនេះខុសគ្នាជាងមួយដងកន្លះបើធៀបនឹងឆ្នាំ ២០០៨។ ជារួមនៅក្នុងឆ្នាំ២០១៤នេះ ប្រទេសកម្ពុជាទទួលបានបរិមាណផលស្រូវសរុប ៩,៣២៤,៤១៦តោន ដែលមានការកើនឡើងចំនួន ២,១៩៨,៩៤៣តោន ដែលស្មើនឹងជិតប្រមាណ ៣០%(ធៀបឆ្នាំ២០០៨)។ ទិន្នផលនេះត្រូវប្រមូលបានពីស្រូវនៅរដូវវស្សាចំនួន ៧,១៤៣,៥២១តោន និងនៅរដូវប្រាំងមានចំនួន ២,១៨០,៨៩៦តោន។ ផលស្រូវប្រមាណជាង៩លានតោននេះក្នុងឆ្នាំ២០១៤ ប្រទេសកម្ពុជាត្រូវការស្បៀងប្រមាណតែ ២,១៧៨,០៥០តោន ហើយមានអតិរេកអង្ករចំនួនប្រមាណជា ៣,០១៣,៧៨៣តោន បើគិតជាស្រូវមានចំនួន ៤,៧០៩,០៣៦តោន។[15]

ដោយមានការយកចិត្តទុកដាក់របស់ក្រសួង មន្ទីរ និងសហាគមន៍ពាក់ព័ន្ធបានធ្វើឱ្យទំហំនៃផ្ទៃដីដាំដុះស្រូវ និងទិន្នផលស្រូវនៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ ជាក់ស្ដែងនៅឆ្នាំ ២០១៨នេះ ផ្ទៃដីដែលបានធ្វើការភ្ជួររាស់ដាំដុះស្រូវទូទាំងប្រទេសមានចំនួន ៣,៣៣៥,៩២៩ហិចតា ដែលទំហំនេះបើធៀបនឹងឆ្នាំ២០០៨ មានការកើនឡើងជាង ២៧% និងបើធៀបនឹងឆ្នាំ ២០១៤ មានការកើនឡើងប្រមាណ ៩.១%តែប៉ុណ្ណោះ។ ផ្ទៃដីដែលដាំដុះទាំងនេះភាគច្រើនត្រូវបានភ្ជួររាស់ដោយគ្រឿងយន្តជាង ៩៦%ស្មើនឹងផ្ទៃដីប្រមាណ ៣.៥២លានហិចតា។ ផ្ទៃដីភ្ជួររាស់នៅទូទាំងប្រទេសនេះ បើធៀបនឹងឆ្នាំ២០០៨ កើន ៤៨៤,៣៨២ហិចតា និងកើនបាន ១៧៤,៨៧៤ហិចតា បើធៀបនឹងផ្ទៃដីស្រូវវស្សាឆ្នាំ២០១៤។

ដោយឡែកសម្រាប់ផ្ទៃដីដែលអាចប្រមូលផលប្រចាំឆ្នាំ២០១៨ មានចំនួន ៣,២៨៨,០៦១ហិចតាដោយផ្ដល់ផលបានជាមធ្យមប្រចាំឆ្នាំចំនួន ៣.៣៥៣តោន/ហិចតា និងទទួលបានផលស្រូវសរុបទូទាំងប្រទេសមានចំនួនប្រមាណជា ១០,៨៩១,៧៣៥តោន។ អតិរេកស្បៀងគិតជាអង្ករមានចំនួន៣,៧៣៥,១៥៣តោន ស្មើនឹង ៥,៨៣៦,១៧៧តោន បើគិតជាស្រូវ។ ការប្រមូលផលនៅរដូវវស្សាឆ្នាំ២០១៨ សម្រេចបានលើផ្ទៃដីសរុបចំនួន ២,៦៥៤,៣១៤ហិចតា (ច្រើនជាងឆ្នាំមុនចំនួន ១២,៦៧៧ហិចតា) ព្រោះវាបានរងផលប៉ះពាលដោយភាពរាំងស្ងួត សត្វល្អិត និងទឹកជំនន់ចំនួន

[15] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០១៥-២០១៦,* ឧបសម្ព័ន្ធទី១៤

៣៣៣,០២៦ហិចតា ហើយខូចខាតចំនួន ១២៤,៩៥០ហិចតា តែត្រូវស្តារឡើងវិញបានចំនួន ៣៩,៣១៨ហិចតា និងទំហំដែលត្រូវខូចខាតទាំងស្រុងមានចំនួន ៨៥,១៣២ហិចតា។[16]សម្រាប់ទិន្នផលស្រូវវស្សានៅឆ្នាំ២០១៨ ទទួលបានផលប្រមាណ ៨,២១២,៨៩៣តោន លើសឆ្នាំមុនចំនួន ១៦៤,០៩៦តោន និងលើសឆ្នាំ២០១៤ប្រមាណជាង ១លានតោន ហើយបើធៀបនឹងស្រូវរដូវវស្សាក្នុងរយៈពេលដូចគ្នា ឆ្នាំ២០០៨ នោះច្រើនជាងដល់ទៅជាង ២លានតោន។ ទិន្នផលស្រូវរដូវវស្សាជាមធ្យមចំនួន ៣.០៩៤តោន/ហិចតា បើធៀបនឹងទិន្នផលឆ្នាំមុនកើនបាន ០.០៤៧តោន/ហិចតា (ទិន្នផលជាមធ្យមស្រូវវស្សា)។ ចំណែកឯការបង្កបង្កើនផលស្រូវនៅរដូវប្រាំងឆ្នាំ២០១៨នេះអនុវត្តបានផ្ទៃដីចំនួន ៥៩៦,៨៨៣ហិចតា ច្រើនជាងឆ្នាំមុន ៤៧,៧២៨ហិចតា។ ផ្ទៃដីដែលអាចប្រមូលផលស្រូវនេះមានចំនួន ៥៩៣,៧៤៧ហិចតា ហើយទទួលបានផលស្រូវសរុបចំនួន ២,៦៧៨,៨៤២ តោន ច្រើនជាងឆ្នាំមុន ២០៩,៣០០តោន។ ទិន្នផលជាមធ្យមនៅរដូវប្រាំងនេះមានចំនួន ៤.៥១២ តោន/ហិចតា ដែលកាលពីឆ្នាំមុនបាន ៤.៥០៨តោន/ហិចតា។

ក្រាហ្វិក៤៖ ការបង្ហាញពីបរិមាណផលស្រូវឆ្នាំ ២០០៨-២០១៨




ប្រភព៖របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៨-២០១៩,ឧបសម្ព័ន្ធទី១៣

ក្នុងរយៈពេល៥ឆ្នាំនេះ២០១៤-២០១៨ ការបង្កបង្កើនផលស្រូវនៅកម្ពុជាមានការកើនឡើងជាបន្តបន្ទាប់ទាំងផ្ទៃដីដាំដុះនិងបរិមាណផលស្រូវ។ ទាំងនេះដោយមានការយកចិត្តទុកដាក់ពី

[16] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ,*របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០១៨-២០១៩,* ទំព័រ១៣-១៤,ឧបសម្ព័ន្ធទី៧,១៣។

សំណាក់ថ្នាក់ដឹកនាំមានក្រសួងជាអាទ៍ ដែលទទួលបានការចង្អុលបង្ហាញពីរាជរដ្ឋាភិបាលតាមរយៈគោលនយោបាយលើកកម្ពស់វិស័យកសិកម្មនេះបានធ្វើឱ្យផលិតភាពនៃវិស័យនេះមានការកំណើន។ ជាក់ស្តែងបរិមាណផលស្រូវដែលមានអតិរេកបានកើនពី ៣,១៦៤,១១៤តោន នៅឆ្នាំ២០០៨ដល់ ៤,៧០៩,០៣៦តោន នៅឆ្នាំ២០១៤ និងបន្តកើនដល់ ៥,៨៣៦,១៧៧តោន នៅឆ្នាំ២០១៨ ដែលអាចឱ្យកម្ពុជាមានលទ្ធភាពអាចនាំទៅផ្គត់ផ្គង់ក្រៅប្រទេសបានរាប់លានតោនក្នុងមួយឆ្នាំ។(សូមមើលឧបសម្ព័ន្ធទី៣)

### ១.៦.២ ការវិវឌ្ឍផលិតកម្មដំណាំរួមផ្សំ និងឧស្សាហកម្មពីឆ្នាំ ២០០៨ -២០១៨

ក្នុងចំណោមដំណាំ ពោត ដំឡូងមី សណ្តែកបាយ និងសណ្តែកសៀងគេឃើញថាចាប់ពីឆ្នាំ១៩៩៩មក ដំណាំពោត និងដំឡូងមីជាដំណាំឈានមុខគេក្នុងការដាំដុះ ចំណែកឯសណ្តែកបាយ និងសណ្តែកសៀងវិញមានការប្រែប្រួលទៅតាមអាកាសធាតុ។ នៅឆ្នាំ២០០៨ ពោតត្រូវបានគេដាំដុះលើផ្ទៃដីចំនួន ១៦៣,១០៦ហិចតា ដំឡូងមីមានចំនួន ១៧៩,៩៤៥ហិចតា សណ្តែកបាយ ៩៥,៦០៥ហិចតា និងសណ្តែកសៀងត្រូវបានគេដាំដុះប្រមាណតែ ៩៥,៦០៥ហិចតា។[17] ផលិតកម្មដំណាំរួមផ្សំ និងឧស្សាហកម្មដូចជា ពោត ដំឡូងមី សណ្តែកបាយ និងសណ្តែកសៀងជាដើមមានការប្រែប្រួលចុះឡើង ទៅតាមបម្រែបម្រួលអាកាសធាតុ ឥទ្ធិពលថ្លៃ និងទីផ្សារដែលតម្រូវការ។

តារាង១៖ ផ្ទៃដីដាំដុះផលិតកម្មដំណាំរួមផ្សំ និងឧស្សាហកម្ម២០០៩-២០១៤

| ប្រភេទដំណាំ/ឆ្នាំ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|
| ពោត | ២២១,២៨៧ | ២១៣,៦២២ | ១៧៤,២៥៧ | ២១៦,៣៣០ | ២៣៩,៧៤៨ | ១៤៣,៥១៧ |
| ដំឡូងឈើ | ១៦០,៣២៦ | ២០៦,២២៦ | ៣៩១,៨៥៤ | ៣១៦,៨៥៤ | ៤២១,៣៧៥ | ៥២១,៤៥៩ |
| ដំឡូងជ្វា | ៩,២៨៣ | ១១,៤៥២ | ៨,២០៤ | ១០,៤២៨ | ៧,៤៣២ | ៥,៩១៥ |
| បន្លែ | ៥០,២៧៨ | ៥២,៧៣២ | ៥២,៨៣០ | ៧៦,៤៩៥ | ៥២,៤៤៩ | ៥១,៦៣៧ |
| សណ្តែកបាយ | ៤៩,៥៩៩ | ៦៩,២០៦ | ៦៨,១១១ | ៦៦,៨៥០ | ៥៤,៣១២ | ៥៣,២៩៤ |
| សណ្តែកដី | ១៦,៤៧៤ | ២០,០៤១ | ១៦,២៨៧ | ១៨,០៤៨ | ១៩,៩៥៤ | ១៧,៨១៨ |
| សណ្តែកសៀង | ៩៦,៣៨៨ | ១០៣,១៩៨ | ៧០,៥៨៤ | ៧១,៣៣៧ | ៨០,៦៨៨ | ៧២,៥១១ |
| ល្ង | ៤២,២០៦ | ៤៨,២៩៩ | ៤២,៥៩៩ | ៣៦,៧២២ | ៣៤,១៣៦ | ២៨,១៧០ |

[17] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ,*របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០១២-២០១៣*,ទំព័រទី១៨។

| | | | | | | |
|---|---|---|---|---|---|---|
| អំពៅ | ១៣,៥៣៣ | ១៧,២០៧ | ២២,៦១៤ | ៤៨,៥៨៦ | ២៣,៨១០ | ៤៨,៣៥៧ |
| ក្រចៅ | ៣៤៧ | ៥៩៤ | ៣៤២ | ២៨៦ | ២៤៣ | ១៩២ |
| ថ្នាំជក់ | ៩,២៦៩ | ១០,០៦២ | ៨,៣១៨ | ៥,៩៤៧ | ៦,៨៨១ | ១០,៧២៧ |
| សរុប (ហ.ត) | **៦៦៩,៩៩០** | **៧៥២,៦៣៩** | **៨៥៥,៨៦០** | **៩១២,៨៨៣** | **៩៤១,០២៨** | **៩៥៣,៥៩៧** |
| សរុបបរិមាណផល (តោន) | **៥,៤២៥,៣១០** | **៥,៧២៨,១៧៥** | **៦,១៣៨,៥៣២** | **១០,៨៥៩,៨០៦** | **១០,៥៣៦,៧៤២** | **១៤,៧២៧,២៦២** |

ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨,ទំព័រទី១៦

ក្នុងរយៈពេល៥ឆ្នាំនេះ(២០១៤-២០១៨) ផលិតកម្មដំណាំរួមផ្សំ និងឧស្សាហកម្មត្រូវបានគេបង្កបង្កើនផលលើផ្ទៃដី ៩៥៣,៥៩៧ហិចតា នៅឆ្នាំ២០១៤ ហើយកើនដល់ ១,០៩១,៨៨៧ហិចតា នៅឆ្នាំ២០១៨ ទំហំដីផ្ទៃដាំដុះកើនបាន ១៤.៥០% គឺស្មើទំហំផ្ទៃដីចំនួន ១៣៨,២៩០ហិចតា និងកើន ៣.៤២% បើគិតជាផ្ទៃដីស្មើ ៣៦,១៩៥ហិចតា បើធៀបនឹងឆ្នាំ២០១៧។ ចំពោះបរិមាណផលផលិតកម្មវិញដំណាំរួមផ្សំ និងឧស្សហកម្មរយៈពេលខ្លីកើនពី ១៤,៧២៧,២៦២តោន (ឆ្នាំ២០១៤) កើនដល់ ១៦,៦៤៥,៣៦០តោននៅឆ្នាំ២០១៨។ គួរបញ្ជាក់ផងដែរថាដំណាំដំឡូងឈើឈរលំដាប់លេខមួយកាលពីឆ្នាំ២០១៤ដែលត្រូវបានគេដាំដុះលើផ្ទៃដីប្រមាណជាង ៥៤.៦៨% នៃផ្ទៃដីដាំដំណាំរួមផ្សំ និងឧស្សាហកម្មសរុប។ តែនៅឆ្នាំ២០១៨នេះវិញ កសិករបានពេញនិយមដាំដំឡូងមីទៅវិញ ហើយត្រូវបានដាំដុះលើផ្ទៃដីទំហំប្រមាណ ៥៩.៧៣%នៃផ្ទៃដីដាំដំណាំរួមផ្សំ និងឧស្សាហកម្មសរុប។

សូមរំលឹកផងដែរថា ផលិតកម្មដំណាំរួមផ្សំ (ពោត ដំឡូងមី បន្លែគ្រប់ប្រភេទ ម្ទេស ឪឡឹក) បានដាំដុះលើផ្ទៃដីសម្រេចបានចំនួន ៨៥,៣៤៥ហិចតា កើនលើសឆ្នាំមុន ២,៣៤៣ហិចតា ស្មើនឹង ២.៨២%។ ទំហំនៃផ្ទៃដីនេះបានធ្វើការប្រមូលផលបានតែ ៨៤,៣៧៦តោន ដែលនៅរដូវវស្សាមានចំនួន ៤៩,៤៦៥តោន/ហិចតា ហើយទទួលបានបរិមាណផលចំនួន ៤៣៧,៧៧២តោន និងនៅរដូវប្រាំងបានធ្វើការប្រមូលផលលើផ្ទៃដី ៣៤,៩១១ហិចតា/តោន ដោយទទួលបានផលចំនួន ៣៥៩,៧៨៧តោន។ ជារួមនៅឆ្នាំ២០១៨ បរិមាណផលដំណាំរួមផ្សំទទួលបានចំនួន ៧៩៧,៥៥៩ តោន។ មួយវិញទៀត ដំណាំឧស្សាហកម្មក្នុងរយៈពេលខ្លី (ពោតក្រហម ដំឡូងមី សណ្តែកបាយ សណ្តែកសៀង ល្ង អំពៅ ក្រចៅ ថ្នាំជក់ ឈូក) ត្រូវបានគេដាំដុះលើផ្ទៃដីចំនួន ១,០០៦,៥៤២ ហិចតា ក្នុងនោះនៅរដូវវស្សាបានចំនួន៩១៧,៧០៣ហិចតា និងរដូវប្រាំងចំនួន៨៨,៨៣៩ហិចតា។ តែសម្រាប់ការងារប្រមូលផលនៅរដូវវស្សាបានអនុវត្តន៍លើផ្ទៃដីចំនួន ៩០៨,១២៧ហិចតា ហើយ

ទទួលបានបរិមាណផលចំនួន ១៤,៨៧២,៣០៩តោន។ ចំណែកឯរដូវប្រាំងវិញទទួលបានចំនួន ៩៧៥,៩៩២តោន។ ដូចនេះនៅឆ្នាំ២០១៨នេះ ដំណាំឧស្សាហកម្មរយៈពេលខ្លីបានអនុវត្តការប្រមូលផលលើផ្ទៃដីចំនួន ៩៩៦,៩៦៦ហិចតា និងបានបរិមាណផលចំនួន ១៥,៨៤៧,៨០១តោន។[18]

ក្រាហ្វិកទី៥៖ ផលិតកម្មសាកវប្បកម្ម និងដំណាំឧស្សាហកម្មឆ្នាំ២០១៤-២០១៨




ប្រភព៖របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៨-២០១៩, ទំព័រទី ១៥

### ១.៦.៣ ការវិវឌ្ឍនៃវិស័យជលផល

វិស័យជលផលជាអនុវិស័យដ៏សំខាន់មួយក្នុងវិស័យកសិកម្ម វាបានចូលរួមក្នុងផ.ស.ស. នៃវិស័យនេះនៅឆ្នាំ២០១៨ បានចំនួន២៤.១%។ ដោយសារលក្ខណៈភូមិសាស្ត្រនៃប្រទេសកម្ពុជាសម្បូរដោយប្រព័ន្ធផ្លូវទឹកខ្វាត់ខ្វែង ហើយបានធ្វើឱ្យវិស័យកម្មមួយនេះទទួលបានចំណូលយ៉ាងច្រើនសម្រាប់ទ្រទ្រង់ជីវភាពប្រជាជន និងជាប្រភពម្ហូបអាហាររបស់ប្រជាជនភាគច្រើននៅកម្ពុជាផងដែរ។ នៅរដូវវស្សា ទឹកនៅទន្លេមេគង្គបានបង្កើតជាតំបន់ទឹកលិចជាច្រើន ជាពិសេសនៅជុំវិញបឹងទន្លេសាបដែលមានតំបន់ព្រៃលិចទឹកមួយចំនួនក្លាយជាជម្រកត្រី វាបានបង្កលក្ខណៈងាយស្រួលសម្រាប់ត្រីពងកូន និងក្លាយជាប្រភពចំណីសម្រាប់ត្រីលូតលាស់។ នៅរដូវវស្សាផ្ទៃទឹកនៃបឹងទន្លេសាបកើនឡើងប្រហែល៤-៥ដងគឺកើនពី២,០០០គ.ម$^{៣}$-៣,០០០គ.ម$^{៣}$ទៅ១០,០០០គ.ម$^{៣}$-១៥,០០០គ.ម$^{៣}$ ជាមួយនឹងជម្រៅទឹកពី១-២ម៉ែត្រ នៅរដូវប្រាំង និង៨-១០ម៉ែត្រនៅរដូវវស្សា ។

[18] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ,*របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០១៨-២០១៩,* ទំព័រទី១៤,ឧបសម្ព័ន្ធទី១៨។

នៅឆ្នាំ២០០៨ ការនេសាទត្រីទឹកសាបមានការថយចុះពី ៣៩៥,០០០តោន នៅឆ្នាំ២០០៧ មកត្រឹមតែ៣៦៥,០០០តោន នៅឆ្នាំ២០០៨ ដោយសារកត្តានៃទឹកទន្លេសាបមានទាបជាងឆ្នាំមុន។ ចំណែកការនេសាទនៅតាមតំបន់សមុទ្រមានការកើនឡើងប្រមាណជិត៥% គឺកើនពី ៦៣,៥០០ តោននៅឆ្នាំ២០០៧ និងកើនដល់ ៦៦,០០០តោន នៅឆ្នាំ២០០៨។ មួយទៀតសម្រាប់វារីវប្បកម្មការចិញ្ចឹមត្រី បង្គា ការញាស់កូនត្រីពូជ និងក្រពើបានកើនឡើងបាន ៤,០០០តោន ច្រើនជាងឆ្នាំមុនពីឆ្នាំ២០០៧ ប្រមាណចំនួន ៤,៧៥០តោន។ ការរីកចម្រើននេះ ដោយសារតែមានការបង្កើតស្ថានីយ៍ផលិតកូនត្រីពូជរបស់រដ្ឋ ១៣កន្លែង របស់កសិករ ១៥២កន្លែង ស្រះចំនួន ៤៩,៤៦៣ស្រះ បែរចំនួន៣,៨០២បែរ និងស៊ង៥ដង។ ការនេសាទគ្រប់ប្រភេទប្រមូលផលបាន ៤៧១,០០០តោន លើសឆ្នាំមុន ១៧៤,៧៦០តោន។[19]

មួយវិញទៀតសម្រាប់ឆ្នាំ២០១៥ ផលនេសាទទឹកសាបបានថយចុះពី ៥០៥,០០៥តោននៅឆ្នាំ២០១៤ មកត្រឹម៤៨៧,៩០៥តោននៅឆ្នាំ២០១៥នេះដោយសារបញ្ហានៃទឹកទន្លេមានកម្រិតទាបជាងឆ្នាំមុន។ ចំពោះការនេសាទត្រីទឹកសាបនេះនៅរដូវនេសាទអនុវត្តបាន ១៣,៤២៦តោន ដែលមានការនេសាទជាលក្ខណៈគ្រួសារក្នុងដែននេសាទបាន ៣៣៦,២៦៩តោន និងក្នុងវាលស្រែបាន ១៣៥,២១០តោន។ ចំពោះការនេសាទនៅសមុទ្រវិញ វាទទួលបានផលកើនឡើងគឺកើនពី ១២០,២៥០តោន នាឆ្នាំ២០១៤ដល់ ១២០,៥០០តោននាឆ្នាំ២០១៥ ពោលគឺកើនបានតែ ២៥០ តោនប៉ុណ្ណោះ។[20]នៅឆ្នាំ២០១៥នេះ ផលនេសាទដែលបានមកពីការធ្វើវារីវប្បកម្មវិញ មានការកើនឡើប្រមាណចំនួន ២៣,០៨៦តោន បើធៀបនឹងឆ្នាំមុនគឺ១២០,០៥៥តោន(២០១៤) ដល់ទៅ ១៤៣,១៤១តោន(២០១៥)។ ជាលទ្ធផលនៅឆ្នាំ២០១៥នេះ ទិន្នផលវិស័យជលផលជារួមទទួលបាន ៧៥១,៥៤៦តោន ដែលមានការកើនឡើងចំនួន ២៨០,៥៤៦តោន ស្មើនឹង ៥៩,៥៦% បើធៀបនឹងឆ្នាំ២០០៨។ ដោយសារមានការរីកចម្រើនខ្លាំងខាងនេសាទគ្រប់ប្រភេទ ជាពិសេសគឺកំណើនការធ្វើវារីវប្បកម្ម ។

បើយើងពិនិត្យនៅឆ្នាំ២០១៨នេះវិញ យើងឃើញថាផលនេសាទត្រីទឹកសាបមានចំនួនដល់ទៅ ៥៣៥,០០៥តោន គឺកើនឡើងប្រមាណជា ១.៣៦% បើធៀបនឹងឆ្នាំ២០១៧ និង៩.៦៥% បើធៀបនឹងឆ្នាំ២០១៥។ ចំពោះផលនេសាទសមុទ្រវិញមានចំនួន ១២១,១០០តោន ដែលមានការ

[19] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ,*របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០០៨-២០០៩,ទំព័រទី ១៩,២០,៤៣*

[20] ទៀ្យ បូរ៉ាពីន, ការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជា(២០១៧), ទំព័រទី៣៥,៣៦

កើនឡើងច្រើនជាងឆ្នាំមុនចំនួន ៧៥តោន។ មួយវិញទៀត សម្រាប់ផលវារីវប្បកម្មមានចំនួន ២៥៤,០៤៨តោន បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុនកើនដល់ទៅ ២២,៤៧% និង ៧៧,៤៨% បើធៀបនឹងឆ្នាំ២០១៥ ហើយកើនបានដល់ទៅជាង៦ដង បើធៀបនឹងវារីវប្បកម្មកាលឆ្នាំ២០០៨។

ក្រាហ្វិកទី៦៖ ផលនេសាទទឹកសាប ទឹកសមុទ្រ និងវារីវប្បកម្ម




ប្រភព៖របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៨-២០១៩,ទំព័រទី៤៨

ជារួមនៅក្នុងឆ្នាំ២០១៨នេះ បរិមាណផលនៃវិស័យនេះដែលសរុបមានចំនួន ៩១០,១៥៣តោន កើនលើសនៅឆ្នាំមុនដល់ទៅ ៥៣,៨៩០តោន ឬកំណើន ៦.២៩% នេះដោយសាតែមានការយកចិត្តទុកដាក់ពីក្រសួងផ្ទាល់ និងរដ្ឋបាលជលផលបានព្យាយាមបង្កើតសហគមន៍នេសាទនៅទូទាំងប្រទេសបាន ៥១៦សហគមន៍ បង្កើតស្រះជម្រកត្រីនៅតាមខេត្តបានចំនួន ៨៨៩កន្លែង ព្រមទាំងមានការខិតខំការពារតំបន់អភិរក្ស និងបង្ក្រាបនូវរាល់បទល្មើសនេសាទគ្រប់ប្រភេទ។[21] សូមបញ្ជាក់ដែរថា បច្ចុប្បន្ននេះអាកាសធាតុមានការប្រែប្រួល និងការប្រើប្រាស់ថ្នាំកសិកម្មរបស់ប្រជាកសិករក៏មានកម្រិតខ្ពស់ណាស់ដែរ ហើយវាធ្វើឱ្យមានផលប៉ះពាល់ដល់វារីវប្បកម្មដែលមាននៅក្នុងស្រែ ស្រះ ឬបឹង។ ដូចនេះ ការធ្វើវារីវប្បកម្មដែលជាការចិញ្ចឹមសត្វនៅក្នុងស្រះ និងបឹងពិតជាមានសារៈសំខាន់ណាស់ដើម្បីសន្តិសុខស្បៀង និងជីវភាពរបស់ប្រជាជន។

[21] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ,*របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០១៥-២០១៦,* ទំព័រទី៤៧,៤៨

### ១.៦.៤ ការវិវឌ្ឍវិស័យបសុសត្វឆ្នាំ ២០០៨ - ២០១៨

បសុសត្វនៅឆ្នាំ២០០៨ គេឃើញថាចំនួនគោមានការកើនឡើងពី ៣,៣៦៨,៨៤៩ក្បាល នាឆ្នាំ២០០៧ និង៣,៤៥៧,៧៨៧ក្បាលឆ្នាំ២០០៨ ខណៈដែលចំនួនក្របីត្រូវថយចុះពី៧៧២,៧៨០ក្បាលមកត្រឹមតែ ៧៤៦,២០៧ក្បាល(២០០៧)នេះ ដោយសារតែការប្រើប្រាស់ជាកម្លាំងអូសទាញត្រូវបានកាត់បន្ថយ ហើយជំនួសគ្រឿងយន្ត។ ឯសម្រាប់សត្វជ្រូកវិញនៅឆ្នាំ២០០៨នេះ ក៏មានការធ្លាក់ចុះប្រមាណ៨%ដែរគឺ ២,៣៨៩,៣៨៩ក្បាល(២០០៧) មកត្រឹម ២,២១៥,៦៤១ក្បាល(២០០៨) នេះ មកពីមានការនាំជ្រូកចូលពីខាងក្រៅធ្វើឱ្យផលិតផលក្នុងស្រុកមានការថយចុះ ។[22]

ផលិតកម្មសត្វក្របីក្នុងរយៈពេល៥ឆ្នាំក្រោយគឺ ២០០៩-២០១៣ មានការថយចុះប្រមាណជាង១៦.២៩%គឺថយពី ៧៣៩,៦៤៦ក្បាល(២០០៩) មកត្រឹម ៦១៩,១១៤ក្បាល(២០១៣)។ ចំពោះការចិញ្ចឹមគោក៏មានការថយចុះចំនួន ១៤៨,៩៨៧ក្បាល ឬ៤.១៦% គឺនៅឆ្នាំ២០០៩ មានដល់ទៅ ៣,៥៧៩,៨៨២ក្បាល តែនៅឆ្នាំ២០១៣មានតែ ៣,៤៣០,៨៩៥ក្បាលប៉ុណ្ណោះ។ ការថយចុះចំពោះការចិញ្ចឹមសត្វគោនេះ បណ្តាលមកពីការប្រើប្រាស់កម្លាំងសត្វដើម្បីភ្ជួររាស់មានការធ្លាក់ចុះ ការខ្វះខាតកម្លាំងដើម្បីថែរទាំព្រោះអ្នកដែលពេញកម្លាំងបានធ្វើចំណាកស្រុក និងដោយមានការប្រើប្រាស់គ្រឿងយន្តកសិកម្មជំនួសវិញ។ មួយវិញទៀត ការចំពោះការចិញ្ចឹមសត្វនេះ វាមានការលំបាកជាងមុន ដោយសារតែបញ្ហាទឹក ស្មៅ ការប្រែប្រួលអាកាសធាតុ និងជម្ងឺសត្វ។ តែផ្ទុយទៅវិញការចិញ្ចឹមជ្រូកមានការកើនឡើង គឺកើនពី ២,១២៦,៣០៤ក្បាល នៅឆ្នាំ២០០៩ ដល់ទៅ ២,៤៣៦,៦៩៩ក្បាលនៅឆ្នាំ២០១៣ គឺកើនចំនួន ៣១០,៣៩៥ក្បាល ស្មើនឹង ១៤.៥៩%។ នេះដោយសារ មានការវិនិយោគបង្កើតកសិដ្ឋានចិញ្ចឹមសត្វជ្រូក ខ្នាតមធ្យម និងខ្នាតធំបន្ថែម។ ចំណែក ការផលិតចំណីសត្វមានការវិនិយោគបង្កើតរោងចក្រចំណីសត្វសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក ហើយប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការផលិតដំណាំចំណីសត្វ យល់ដឹងពីការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចយ៉ាងផុសផុល តែទោះយ៉ាងនេះក្តី ចំណីសត្វ និងថ្នាំសត្វនៅមានតម្លៃខ្ពស់នៅឡើយ។[23]

[22] ឈឹម ច័ន្ទបុត្រ និង ចូ ឌីន, *ការអភិវឌ្ឍវិស័យកសិកម្មខេត្តព្រៃវែង(២០១២)*,ទំព័រ៣១។

[23] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្ម២០១៤-២០១៨(២០១៥)*, ទំព័រទី ១៩។

ក្រាហ្វិកទី៧៖ ផលិតកម្មសត្វឆ្នាំ២០១៤-២០១៨




*ប្រភព៖របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៨-២០១៩, ទំព័រទី ៣៦*

សម្រាប់ឆ្នាំ២០១៦ ការចិញ្ចឹមសត្វគោមាននៅកម្ពុជាមានចំនួន ២,៩២០,៣១៤ក្បាល ក្របីមានចំនួន ៥២៣,១៥៤ក្បាល ជ្រូកមានចំនួន២,៩៧០,៦២៤ក្បាល។ ជារួមផលិតកម្មសត្វគ្រប់ប្រភេទរយៈពេល៥ឆ្នាំចុងក្រោយ គឺមានការកើនឡើងគួឱ្យកត់សម្គាល់គឺចាប់ពី ៣៧,៩៤៨,៨៧៨ ក្បាល នៅឆ្នាំ២០១៤ កើនដល់ ៤៤,៣៧៥,៣៩៥ក្បាល នាឆ្នាំ២០១៨ គឺកើនចំនួន ៦,៤២៥,៦១៧ ក្បាល(បញ្ចូលទាំងបក្សី)ស្មើនឹង១៦.៩៣%។ ក្នុងឆ្នាំ២០១៨នេះ ផលិតកម្មសត្វសរុបនៅកម្ពុជាមានចំនួន ៤៤,៣៧៥,៣៩៥ក្បាល ក្នុងនោះគោមានចំនួន២,៩២៨,៥៣៤ក្បាល ក្របី៥០០,៩៩៥ក្បាល ជ្រូក២៧៤៧,៨៥៥ក្បាល បក្សី ៣៨,១៦៦,៧៥ក្បាល សេះចំនួន ៤,២៩៦ក្បាល ចៀម ៤៥៩ក្បាល ពពែ ២៦,៤៤៧ក្បាល និងដំរីចំនួន ៨៨ក្បាល។ ចំនួននេះបើធៀបនឹងឆ្នាំ២០១៧ មានការកើនឡើងមាន ៣.៦%ក្នុងនោះបក្សី៥.៣% ដោយឡែកគោក្របីថយចុះ ១.៥% និងការថយចុះចំនួនជ្រូកដោយសារតែការចិញ្ចឹមជាលក្ខណៈគ្រួសារមានថយចុះចំនួនប្រមាណដល់ទៅ ១៧% បើធៀបនឹងឆ្នាំ២០១៧ ។[24]

[24] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ,*របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០១៨-២០១៩*, ទំព័រទី៣៤-៣៦។

ក្រាហ្វិកទី៨៖ ការបង្ហាញពីការចិញ្ចឹមបក្សីឆ្នាំ២០០៨-២០១៨




*ប្រភព៖របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១២-២០១៣,ទំព័រទី១៩ ២០១៨-២០១៩, ទំព័រទី៣៦*

ចំពោះការចិញ្ចឹមសត្វស្លាបវិញគឺមានការរីកចម្រើនគួរឱ្យកត់សម្គាល់តាំងពីឆ្នាំ២០០៨ដែលមានចំនួនតែ ១៦.៩លានក្បាល កើនដល់២៧.៣លានក្បាល នៅឆ្នាំ២០១៣ ហើយនៅឆ្នាំ២០១៨នេះបន្តកើនដល់ជាង៣៨លានក្បាលនេះ ដោយសារប្រទេសយើងមិនមានការផ្ទុះឡើងនៃជម្ងឺបក្សីគួរឱ្យកត់សម្គាល់នោះទេ ហើយមានវិធានការល្អប្រសើរសម្រាប់ទប់ស្កាត់ មួយទៀតដោយសារមានការចិញ្ចឹមជាលក្ខណៈគ្រួសារ និងពាណិជ្ជកម្មមានការកើនឡើងជាបន្តបន្ទាប់ ។

### ១.៦.៥ ការវិវឌ្ឍនៃផលិតផលកៅស៊ូ ២០០៨-២០១៨

ដំណាំកៅស៊ូគេឃើញមានវត្តដាំដុះនៅប្រទេសកម្ពុជាពីឆ្នាំ១៩១០(សម័យបារាំង) នៅស្រុកព្រៃនប់ លុះដល់ឆ្នាំ១៩២១ ទើបគេឃើញមានការដាំដុះជាលក្ខណៈឧស្សាហកម្មជាទ្រង់ទ្រាយធំដោយក្រុមហ៊ុនវិនិយោគបារាំងក្នុងទឹកដីខេត្តក្រចេះ និងកំពង់ចាម។ មកដល់ឆ្នាំ១៩៦៩ ដំណាំនេះត្រូវបានពង្រីកផ្ទៃដីដាំដុះបានជាង ៦៤ពាន់ហិចតាដែលផ្ទៃដីចៀរជ័រមានជាង ៣៩ពាន់ហិចតា ហើយទទួលបានទិន្នផលបានជាង ៥០,០០០តោនសម្រាប់ការប្រើប្រាស់ក្នុងស្រុក និងនាំចេញទៅបរទេស។ ចំពោះអត្ថប្រយោជន៍កៅស៊ូបានផ្តល់ផលជាច្រើនដល់អ្នកដាំ និងសេដ្ឋកិច្ចសង្គមទាំងមូល ព្រមទាំងបរិស្ថានផងដែរ។ តួយ៉ាងដូចជាចូលរួមក្នុងការលើកម្ពស់សេដ្ឋកិច្ចគ្រួសារកសិករ កាត់បន្ថយការចំណាកស្រុក ផ្តល់ឈើសម្រាប់ប្រើប្រាស់ ផលិតជាគ្រឿងសង្ហារឹម ជាឈើឥន្ធនៈ

កាត់បន្ថយការហូរច្រោះដី ជាគម្របបៃតងដែលចូលរួមក្នុងការថែរក្សាលំនឹងបរិស្ថាន ដោយកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ពិសេសនោះគឺរួមចំណែកក្នុងការទប់ស្កាត់បម្រែបម្រួលអាកាសធាតុដែលជាបញ្ហាចម្បងមួយរបស់ពិភពលោក។[25]

ឆ្នាំ២០០៨ ផ្ទៃដីដាំដុះកៅស៊ូទូទាំងប្រទេសសរុបមានចំនួន ១០៧,៩០០ហិចតា គឺកើនបាន ៣១%បើធៀបនឹងឆ្នាំ២០០៧។ ការកើនឡើងនេះគឺបណ្តាលមកពីកាកើនឡើងនៃក្រុមហ៊ុនវិនិយោគលើដីសម្បទានសេដ្ឋកិច្ច និងការដាំដុះកៅស៊ូជាលក្ខណៈគ្រួសារមានការកើនឡើងដែរគឺប្រមាណជា ១៦,០០០ហិចតា និង៦,៩៧០ហិចតា រៀងគ្នាក្នុងឆ្នាំ២០០៧-២០០៨។ ចំណែកផ្ទៃដីចៀរជ័រវិញមានចំនួន ៣៣,៦៧០ហិចតា ក្នុងនោះមានផ្ទៃដីចៀរជ័រគ្រួសារមានចំនួន ១៣,០៣៧ ហិចតាដែលអាចផលិតបានជាកៅស៊ូស្ងួតចំនួន ៣១,៦៧៦តោន និងធ្វើការនាំចេញបាន ៣០ពាន់តោន។ ចំពោះតម្លៃកៅស៊ូមានការធ្លាក់ចុះចំនួន៦០% នៅលើទីផ្សារអន្តរជាតិចាប់ពីឆមាសទី២នាឆ្នាំ២០០៨នេះ បើធៀបនឹងតម្លៃកៅស៊ូនៅឆមាសទី១នៅឆ្នាំដដែល(ពីតម្លៃ ៣,៥០០ដុល្លា មកនៅប្រមាណតែ ១,៥០០ដុល្លាក្នុងមួយតោន)។ ការធ្លាក់ចុះនេះបណ្តាលមកពីកត្តា៤យ៉ាងគឺៈ ការផ្គត់ផ្គង់តម្រូវការកៅស៊ូ តម្លៃប្រេង និងវិបត្តសេដ្ឋកិច្ចពិភពលោក។[26] នៅឆ្នាំ២០១២ ផ្ទៃដីដាំកៅស៊ូមានការកើនឡើងដល់ ២៨០,៣៥៥ហិចតា គឺកើនឡើងបាន៣១.៥៥% បើធៀបនឹងឆ្នាំ២០១១ ហើយកើនបានជាង២.៦ដង នៃផ្ទៃដាំដុះកៅស៊ូឆ្នាំ២០០៨។ ផ្ទៃដីកៅស៊ូត្រូវបានគេបែងចែកជាពីរគឺ ៖ ផ្ទៃដីកៅស៊ូក្រុមហ៊ុនកសិឧស្សាហកម្ម (ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច អតីតចម្ការកៅស៊ូរដ្ឋ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូនៅកម្ពុជា) និងកៅស៊ូគ្រួសារ។ សម្រាប់ផ្ទៃដីជិត ៣សែនហិចតានេះមានផ្ទៃដីកៅស៊ូរបស់ក្រុមហ៊ុកសិឧស្សាហកម្មចំនួន ១៧២,៦៥៨ហិចតា និងកៅស៊ូគ្រួសារចំនួន ១០៧,៦៩៦ហិចតា។ សន្ទុះនៃការដាំដុះកៅស៊ូនៅកម្ពុជាមានការកើនឡើងជាលំដាប់ បើគិតពីឆ្នាំ ២០០៨មកនេះ អាស្រ័យដោយតម្លៃរបស់កៅស៊ូបានឡើងខ្ពស់រួមផ្សំនឹងភាពអំណោយផលនៃនយោបាយ និងបញ្ហាសក្តានុពលដីដ៏សមប្រកប ជាពិសេសនោះគឺនយោបាយសេរីភាវូបនីយកម្មរបស់រាជរដ្ឋាភិបាលក្នុងការលក់ដូរផលិត ផលកៅស៊ូគ្រួសារក្នុងស្រុក។ ក្រៅពីនេះក៏មានការចូលរួមពីផ្នែកឯកជនដែលបានធ្វើការវិនិយោគលើដីសម្បទានសេដ្ឋកិច្ច និងកៅស៊ូគ្រួសារមានការដាំដុះបន្ថែមទៀត។ ជារួមនៅឆ្នាំ២០១២ ទំហំផ្ទៃដីអាចចៀរជ័របានសរុបចំនួន ៥៥,៣៦១ហិចតា បើ

[25] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០១៨-២០១៩,* ទំព័រ ទី២៧។

[26] ឡៃ បូរ៉ាពីន, *ការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជា(២០១៧),* ទំព័រទី៣៩-៤០។

ធៀបទៅឆ្នាំ២០០៨ ធំជាងចំនួន ២១,០៤៨ហិចតា។ ចំពោះផ្ទៃដីចៀរជ័រនេះខាងក្រុមហ៊ុនកសិឧស្សាហកម្មមានចំនួន ២៨,០៦២ហិចតា និងខាងកៅស៊ូគ្រួសារមានចំនួន ៣១,២៩៨ហិចតា ដោយទទួលបានផលរៀងគ្នាចំនួន ២៨,៥៣១តោន និង៣៥,៩៩៣តោន។ ក្នុងនោះបានធ្វើការនាំចេញបានចំនួន ៥៩,៩១៧តោនដែលគិតជាទំហំទឹកប្រាក់ស្មើប្រមាណជាង ១៧៤លានដុល្លា ដោយក្នុងមួយតោនជាមធ្យម ទទួលបានតម្លៃ ២,៩១៧ ដុល្លាអាមេរិច។[27]

ក្រាហ្វិកទី៩៖ បង្ហាញពីផ្ទៃដីនៃការដាំដុះកៅស៊ូឆ្នាំ២០១៣-២០១៨




| | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ចម្ការកៅស៊ូកសិឧស្សាហកម្ម | ១៩១,៣៥៤ | ២១៧,៤៦៣ | ២៣៩,១០២ | ២៧៨,២៨១ | ២៨០,២២៨ | ២៧៥,៥៧៩ |
| ចម្ការកៅស៊ូគ្រួសារ | ១៣៧,៤១៧ | ១៤០,៣៤៦ | ១៤៩,៨៥៣ | ១៥៤,២៥៤ | ១៥៦,១១២ | ១៦១,១០៣ |
| សរុប( ហ.ត) | ៣២៨,៧៧១ | ៣៥៧,៨០៩ | ៣៨៨,៩៥៥ | ៤៣២,៧៣៥ | ៤៣៦,៣៤០ | ៤៣៦,៦៨២ |

ប្រភព៖របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៨-២០១៩, ទំព័រទី ២៨

នៅឆ្នាំ២០១៨ ផ្ទៃដីដាំកៅស៊ូមានចំនួនសរុប ៤៣៦,៦៨២ហិចតា បើធៀបនឹងឆ្នាំ២០១៧ ដែលមានចំនួន ៤៣៦,៣៤០ហិចតាគឺ កើនឡើងបានចំនួន ៣៤២ហិចតា ស្មើនឹង0.0៨% ហើយបើធៀបនឹងឆ្នាំ២០១២គឺកើនបាន ១៥៦,៣២៧ហិចតាត្រូវជា ៥៥.៧៦%។ ក្នុងនោះផ្ទៃដីកៅស៊ូ ២០១៨មានផ្ទៃដីកៅស៊ូក្រុមហ៊ុនកសិឧស្សាហកម្មចំនួន ២៧៥,៥៧៩ហិចតា ស្មើនឹង ៦៣.១០% និងកៅស៊ូគ្រួសារមានចំនួន ១៦១,១០៣ហិចតា ត្រូវជា ៣៦.៩០%នៃផ្ទៃដីកៅស៊ូសរុប។ ចំពោះផ្ទៃ

[27] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ,*របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០១២-២០១៣,* ទំព័រទី២០,២១ និងឧបសម្ព័នទី១៣

ដីចៀរដំរិញអនុវត្តបាន ២០១,៩៥០ហិចតា ធៀបនឹងផ្ទៃដីចៀរដំរកៅស៊ូឆ្នាំ២០១៧ មានចំនួន ១៧០,២៣៣ហិចតាគឺកើនបាន ៣១,៧១៧ហិចតា ស្មើនឹង ១៨.៦៣% ដោយទទួលទិន្នផលកៅស៊ូបានចំនួន ២២០,១០១តោនដែលលើសឆ្នាំ២០១៧ ចំនួន ២៦,៨១៦តោនប្រមាណជា ១៣.៨៧%។ ទិន្នផលជាមធ្យមប្រចាំឆ្នាំ ២០១៨គឺ១,០៩០គ.ក្រ/ហ.ត បើធៀបនឹងឆ្នាំ២០១៧មានចំនួន ១,១៣៥ គ.ក្រ/ហ.ត គឺមានការថយចុះប្រមាណ ៣.៩%នេះ ដោយសារតែមានផ្ទៃដីកៅស៊ូថ្មីច្រើនដែលទើបប្រមូលផលចៀរដំរដំបូងជាទូទៅវាតែងទទួលបានផលទាប។

នៅក្នុងឆ្នាំ២០១៨ នេះផលិតកៅស៊ូកម្ពុជាត្រូវបាននាំចេញចំនួន ២១៧,៥០០តោន គិតជាទឹកប្រាក់ស្មើ ២៨៦,៩៤៤,៥២៩ដុល្លា នេះបើធៀបនឹងឆ្នាំ២០១៧ ដែលការនាំចេញបានច្រើនជាងចំនួន២៨,៩៦៨តោនតែទំហំទឹកប្រាក់បែជាមានការធ្លាក់ចុះប្រមាណ៤.១៦% មូលហេតុគឺបណ្តាលមកពីឆ្នាំ២០១៨នេះ តម្លៃរបស់កៅស៊ូនាំចេញបានតែ ១,៣១៩ដុល្លា/តោនដែលនេះមានការធ្លាក់ថ្លៃប្រមាណ ២៦៧ដុល្លា/តោន ស្មើនឹង១៦.៨៣% បើធៀបនឹងឆ្នាំ ២០១៧ដែលអាចទទួលតម្លៃបានដល់ទៅ ១,៥៨៦ដុល្លា/តោន។[28] (សូមមើលឧបសម្ព័ន្ធទី៤)

### ១.៦.៦ ការគ្រប់គ្រង និងអភិវឌ្ឍព្រៃឈើ

បើគិតចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៨ដីព្រៃដែលត្រូវបានទន្ទ្រានដោយខុសច្បាប់នោះមានចំនួន៤៦៤,៨៦១ហិចតា និងដកហូតដីព្រៃយកមកវិញបានចំនួន ៩១,០៩៩ហិចតា បង្គោលចំនួន ៣,៩៧៣បង្គោល ស្មើនឹង ៧៣៣គ.ម ក្នុងខេត្តចំនួន១៣ ដើម្បីការពារ និងកំណត់ជារបស់រដ្ឋព្រមទាំងបានបង្កើតនូវរុក្ខទិវា និងការដាំឈើជាចម្ការទៀតផង។[29]

ចំពោះការវាយតម្លៃព្រៃឈើវិញគឺនៅឆ្នាំ២០១០-២០១៤ បើតាមទិន្នន័យគម្របព្រៃនៅឆ្នាំ ២០១០ មានផ្ទៃដីសរុបចំនួន ១០,៣៦៣,៧៨៩ហិចតា ស្មើនឹង៥៧.០៧% និងផ្ទៃដីដែលពុំមានគម្របព្រៃឈើមានទំហំចំនួន ៧,៧៩៦,៨៨៥ហិចតាត្រូវជា ៤២.៩៣%នៃផ្ទៃដីសរុប។ នៅឆ្នាំ ២០១៤ គេឃើញថា ផ្ទៃដីគ្របដណ្តប់ដោយគម្របព្រៃឈើមានទំហំ ៨,៩៨៥,១៦៣ហិចតា ដែលស្មើនឹង ៤៩.៤៨%នៃផ្ទៃដីសរុប។ បើប្រៀបធៀបនឹងឆ្នាំ២០១០ មានការថយចុះចំនួន ១,៣៧៨,៦២៦ហិចតា ស្មើនឹង ១៣.៣០%។ ចំណែកផ្ទៃដីដែលគ្មានគម្របព្រៃឈើនៅឆ្នាំ២០១៤ មានចំនួន ៩,១៧៥,៥១០ ហិចតា ស្មើប្រមាណជា ៥០.៥២%នៃផ្ទៃដីសរុប នេះគឺធំជាងកាលពីឆ្នាំ

[28]ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ,*របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០១៨-២០១៩*, ទំព័រទី ២៨,២៩។

[29] ឡៃ បូរ៉ាពីន, *ការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជា(២០១៧)*, ទំព័រទី៤២

២០១០ចំនួនប្រមាណជា ១៧.៦៨%នៃផ្ទៃដីគ្មានគម្របព្រៃឈើឆ្នាំនោះ។ ដោយឡែកបច្ចុប្បន្ននេះបាននឹងកំពុងធ្វើការបកស្រាយពីគម្របព្រៃឈើឆ្នាំ២០១៨ ក្នុងនោះបានបញ្ចប់ការទាញយករូបភាពតាមរយៈផ្កាយរណប (Landsat8) និងបញ្ចប់ការបកស្រាយចំណាត់ថ្នាក់ប្រភេទព្រៃឈើនីមួយៗ។ សម្រាប់ព្រៃសហគមន៍គិតត្រឹមឆ្នាំ២០១៨ មានចំនួនសរុប ៦១៤សហគមន៍ដែលកើនលើសឆ្នាំ២០១៤ចំនួន ១២៩សហគមន៍ (ឆ្នាំ២០១៤ ព្រៃសហគមន៍មានចំនួន ៤៨៥សហគមន៍) ហើយសហគមន៍ទាំងនេះបានគ្របដណ្ដប់លើផ្ទៃដីចំនួន ៥០៨,២០៧ហិចតា។ ចំពោះការទប់ស្កាត់ និងការបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងការកាប់រានព្រៃខុសច្បាប់សរុបមានចំនួន ១,០៩៣ករណីដែលថយចុះចំនួន ៣៣៥ករណី ឬស្មើ២៣% បើធៀបនឹងឆ្នាំ២០១៧ ហើយថយចុះដល់ទៅ ១,៣០៧ករណី បើធៀបជាមួយឆ្នាំ២០១៤។

ក្រាហ្វិកទី១០៖បង្ហាញពីការទប់ស្កាត់ និងការបង្ក្រាបបទល្មើសព្រៃឈើឆ្នាំ២០១៤-២០១៨




*ប្រភព៖របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៨-២០១៩, ទំព័រទី ៥២*

ក្នុងចំណោមបទល្មើសទាំងនោះមាន ៥១១ករណីត្រូវបានបញ្ជូនទៅតុលាការដែលចំនួននេះ បើធៀបទៅនឹងសំណុំរឿង ដែលត្រូវបញ្ជូនទៅតុលាការក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំ២០១៤ គឺថយចុះប្រមាណជា ២៨.៨៥%។[30]

## ១.៧ យុទ្ធសាស្ត្រចម្បងៗសម្រាប់គម្រង់ទិសអភិវឌ្ឍន៍កសិកម្ម[31]

### ១.៧.១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម២០១៩-២០២៣នេះ គឺជាគោលនយោបាយ និងជា

[30] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ,*របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០១៨-២០១៩*, ទំព័រទី៤៩-៥២។

[31] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០១៨-២០១៩*, ទំព័រ៣-៨។

យុទ្ធសាស្ត្រដ៏សំខាន់មួយសម្រាប់រយៈពេលមធ្យម ដែលមានគោលដៅច្បាស់លាស់សម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់អនុវត្តក្នុងរយៈពេល៥ឆ្នាំ ហើយផែនការយុទ្ធសាស្ត្រនេះបានឆ្លុះបញ្ចាំងពីគោលនយោបាយរបស់រាជរដ្ឋាភិបាលជាពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដើម្បីចូលរួមចំណែកដល់ការរីកចម្រើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ផែនការយុទ្ធសាស្ត្រនេះត្រូវបានគេអនុវត្តដើម្បីធ្វើឱ្យសេដ្ឋកិច្ចមានការរីកចម្រើនតាមរយៈចក្ខុវិស័យសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មគឺ "កសិកម្មកម្ពុជាជាកសិកម្មទំនើបមានលក្ខណៈប្រកួតប្រជែងបរិយាប័ន្នធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាពដែលនាំដល់ការកើនឡើងប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា"។ ដើម្បីរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យនេះ គោលនយោបាយរួមមួយនឹងត្រូវបានគេដាក់ចេញដើម្បីអនុវត្តគឺ៖ **ជំរុញកំណើនវិស័យកសិកម្មប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព។**

វិស័យកសិកម្មនេះបានចូលរួមចំណែកតម្លៃបន្ថែមសរុបរបស់វិស័យកសិកម្មសម្រេចបានរង្វង់ ៣ ទៅ៥% ក្នុងមួយឆ្នាំ អស់រយៈពេល៥ឆ្នាំកន្លងមកហើយ ហើយក្នុងរយៈពេល៥ឆ្នាំខាងមុខវិស័យកសិកម្មត្រូវបានគេព្យាករណ៍ថានឹងសម្រេចបាននូវកំណើន ៤%ក្នុងមួយឆ្នាំៗពោលគឺកើនពី ២១,៩១៣ប៊ីលានរៀលនាឆ្នាំ២០១៨ ដល់ ២៥,៧០០ប៊ីលានរៀលនៅឆ្នាំ២០២៣។ ដើម្បីសម្រេចបាននូវកំណើននេះ គេបានកំណត់យកនូវគោលដៅគោលនយោបាយអាទិភាពចំនួន០២ គឺ៖

- ❖ ការបង្កើនការប្រកួតប្រជែង ផលិតភាព ពិពិធកម្មកសិកម្ម និងពាណិជ្ជូបនីយកម្ម
- ❖ ការបង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍ និងគ្រប់គ្រងព្រៃឈើ ធនធានដី និងជលផលប្រកបដោយនិរន្តរភាព។ដើម្បីសម្រេចបាននូវគោលនយោបាយអាទិភាព២ខាងលើ យុទ្ធសាស្ត្រចំនួន៥ នឹងត្រូវបានដាក់ចេញឱ្យអនុវត្តក្នុងរយៈពេល ៥ឆ្នាំខាងមុខនេះគឺ៖

១. បង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងពង្រីកកសិ-ធុរកិច្ច

២. លើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វជាលក្ខណៈពាណិជ្ជកម្ម

៣. ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍នូវធនធានជលផលប្រកបដោយនិរន្តរភាព

៤. ពង្រឹងការគ្រប់គ្រប់ និងអភិឌ្ឍធនធានព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព

៥. បង្កើននូវប្រសិទ្ធភាពនៃការពង្រឹងការគ្រប់គ្រងស្ថាប័ន សេវាគាំទ្រនិងការអភិវឌ្ឍធន

ធានមនុស្ស។

យុទ្ធសាស្ត្រទាំង៥ខាងលើនេះ អាចនឹងសម្រេចបានប្រកបដោយប្រសិទ្ធភាពដោយអនុវត្តតាមកម្មវិធីទាំង៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរួមមាន៖

កម្មវិធីទី១៖ ការបង្កើនផលិតភាព និងពិពិធកម្មដំណាំកសិកម្ម

កម្មវិធីទី២៖ ជំរុញផលិតកម្មសត្វ និងសុខភាពសត្វ

កម្មវិធីទី៣៖ ការអភិវឌ្ឍវារីវប្បកម្ម និងគ្រប់គ្រងធនធានជលផល

កម្មវិធីទី៤៖ ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ

កម្មវិធីទី៥៖ ការអភិវឌ្ឍធនធានមនុស្ស និងបង្កើនប្រសិទ្ធភាពនូវសេវាគាំទ្រ។

**១.៧.២ យុទ្ធសាស្ត្រចម្បងៗសម្រាប់តម្រង់ទិសអភិវឌ្ឍន៍កសិកម្ម**

ទី១៖ ការលើកស្ទួយដល់ការស្រាវជ្រាវសម្រាប់អភិវឌ្ឍន៍បច្ចេកទេស និងបច្ចេកវិទ្យាកសិកម្មទំនើបដើម្បីកំណើនបរិមាណគុណភាព អាហារូបត្ថម្ភ ពិពិធកម្មផលិតកម្ម ក្នុងបរិបទការប្រែប្រួលអាកាសធាតុ និងតម្រូវទីផ្សារកសិកម្មក្នុងស្រុក និងក្រៅស្រុក។ ការលើកកម្ពស់ដល់ការអភិវឌ្ឍធនធានមនុស្ស និងបង្កើននូវចំនួនអ្នកស្រាវជ្រាវខាងផ្នែកវិស័យកសិកម្មឱ្យបានច្រើន ព្រមទាំងជំរុញប្រជាកសិករឱ្យចូលរួមប្រើប្រាស់បច្ចេកវិទ្យាកសិកម្មថ្មីៗ ពិសេសការអនុវត្តកសិកម្ម ការរៀបចំដីដាំដុះ ការជ្រើសរើសពូជ ការកែលម្អប្រព័ន្ធស្រោចស្រព ការបង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុ ជាពិសេស គឺការផ្សព្វផ្សាយពីតម្រូវការទីផ្សារដល់ប្រជាកសិករ។

ទី២៖ ការលើកកម្ពស់សមត្ថភាពសហគមន៍កសិកម្មដែលបានចុះបញ្ជីរួចហើយ ឱ្យមានលក្ខណ:ស្តង់ដាជាពាណិជ្ជកម្ម ដោយជំរុញឱ្យអនុវត្តនូវបច្ចេកទេសសន្សំសំចៃទឹកនៅតាមតំបន់សហគមន៍កសិកម្ម និងលើកកម្ពស់ការចូលរួមវិនិយោគក្នុងវិស័យកសិកម្មក្នុងអភិក្រមភាពជាដៃគូអភិវឌ្ឍរវាងរដ្ឋ ឯកជន និងសហគមន៍កសិកម្ម។ ជាពិសេសទៅទៀត ការធ្វើយ៉ាងណាឱ្យប្រជាសហគមន៍ទទួលបានផលប្រយោជន៍ច្រើន និងទទួលបានភាពជាម្ចាស់ចំការ ព្រមទាំងស្វែងរកដៃគូថ្មីសម្រាប់វិនិយោគថ្មីបន្ថែមទៀតក្នុងវិស័យកសិកម្ម។ លើសពីនេះទៀត គឺការផ្សព្វផ្សាយបណ្តុះបណ្តាលការអប់រំពីផលប៉ះពាល់ដល់ប្រជាសហគមន៍អំពីការអភិវឌ្ឍវិស័យកសិកម្ម។

ទី៣៖ ជំរុញការពង្រីក និងពង្រឹងចំនួនសហគមន៍គ្រួសារកៅស៊ូ ដើម្បីបង្កើនការការពារផលប្រយោជន៍របស់ប្រជាសហគមន៍ទាំងការដាំដុះ ការប្រមូលផល ការកែច្នៃ និងការចរចាថ្លៃនៃការលក់ផលិតផលកៅស៊ូ។ ជាពិសេស ជំរុញការវិនិយោគលើការកែច្នៃកៅស៊ូ ក្នុងគោលបំណងបង្កើនការងារ ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាកសិករ។ ម្យ៉ាងវិញទៀត គឺការរៀបចំ និងត្រួត

ពិនិត្យនូវលិខិតបទដ្ឋានគតិយុត្តសម្រាប់អភិវឌ្ឍន៍ដំណាំកៅស៊ូបែបឧស្សាហកម្មជានិរន្តរភាព។

ទី៤៖ ការលើកកម្ពស់ការធ្វើពិពិធកម្មកសិកម្ម ដើម្បីសម្រេចបាននូវផលិតផលដែលមានតម្លៃខ្ពស់ និងមានសក្តានុពលលើវារីវប្បកម្ម ដំណាំបសុសត្វ ផលិតផលឈើ និងផលិតផលកែច្នៃ។ ទន្ទឹមនឹងនោះត្រូវជំរុញការធ្វើឱ្យប្រសើរឡើងនូវគុណភាព សុវត្ថិភាព ការវេចខ្ចប់ និងបង្កើនសមត្ថភាព ពិសោធន៍ផលិតផលដែលមានស្តង់ដាគុណភាពដូចជា GAP, GAHP, GAQP ព្រមទាំងពង្រឹង គុណភាពនៃដំណាំអនាម័យ(SPS) តាមរយៈការចរចាជាមួយដៃគូបរទេសដែលទិញទំនិញពីកម្ពុជា នាំទៅកាន់ទីផ្សារអន្តរជាតិ។

ទី៥៖ការជំរុញការចិញ្ចឹមសត្វរបស់ប្រជាកសិករឱ្យក្លាយទៅជាបែបពាណិជ្ជកម្មដើម្បីបង្កើនប្រាក់ចំណូលដល់កសិករ ពិសេសការលើកទឹកចិត្តកសិករឱ្យមានការចិញ្ចឹមសត្វខ្នាតតូច មធ្យម និងធំដែលប្រកបដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់សម្រាប់ការផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងក្រៅស្រុក ពិសេសគឺការគ្រប់គ្រងលើទីផ្សារកសិកម្មដូចជា ចំណីសត្វ ផលិតផលសត្វ បសុសត្វ និងគ្រប់គ្រងមិនឱ្យមានការធ្វើអាជីវកម្មផ្តាច់មុខដែលនាំឱ្យប៉ះពាល់ដល់តម្លៃ និងបញ្ហាទីផ្សារ។ លើសពីនេះទៀត គឺការគ្រប់គ្រងលើកន្លែងសត្តឃាត កន្លែងកែច្នៃដែលស្របតាមបទដ្ឋានបច្ចេកទេសស្តង់ដាល្អ ដោយសត្វគ្មានជម្ងឺប៉ះពាល់ ឬឆ្លង និងរាគត្បាតផ្សេងៗ បន្ថែមពីនេះ គឺការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព។

ទី៦៖ ការបង្កើតស្ថានីយ៍ចត្តាឡីស័កសម្រាប់ការចិញ្ចឹមសត្វ ការដាំដំណាំ និងជលផលដើម្បីទប់ស្កាត់ជម្ងឺឆ្លងផ្សេងៗដូចជាជម្ងឺសត្វ ជម្ងឺត្រី និងជម្ងឺស្វិតស្វាល។ ការទប់ស្កាត់ការនាំចេញនូវផលិតផលខូចគុណភាពដែលនាំឱ្យប៉ះពាល់ដល់សុខភាពសាធារណៈជន ទីផ្សារក្នុងស្រុកនិងក្រៅស្រុក។ ម្យ៉ាងវិញទៀត ត្រូវបន្ថែមនូវការជំរុញលើកស្ទួយនូវស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព និងការគ្រប់គ្រងនូវព័ត៌មាននៃការនាំចេញនាំចូលជាមួយបណ្តាប្រទេសជិតខាង ព្រមទាំងធានានូវការគ្រប់គ្រងផលស្តុកក្នុងស្រុក និងផលប៉ះពាលដល់ទីផ្សារក្នុងស្រុក និងអន្តរជាតិប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ទី៧៖ ការជំរុញសហគមន៍នេសាទឱ្យមានសមត្ថភាពដោយគ្មានបទល្មើសជលផលទាំងទឹក ប្រៃ និងទឹកសាប។ ជាមួយបញ្ហានេះ ត្រូវជំរុញលើកស្ទួយការអភិវឌ្ឍវារីវប្បកម្មគ្រប់ប្រភេទ ព្រមទាំងគ្រប់គ្រងការពារ និងអភិរក្សនូវព្រៃលិចទឹក និងព្រៃកោងកាងឱ្យមានប្រសិទ្ធភាពសម្រាប់មច្ឆជាតិ។ លើសពីនេះ គឺការធ្វើវិសោធនកម្មច្បាប់ស្តីពីជលផលដើម្បីប្រយុទ្ធប្រឆាំងនឹងបទល្មើសនេសាទ។

ទី៨៖ ការរៀបចំ និងការអនុវត្តនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ព្រៃផ្តល់ផលដើម្បីឆ្លើយតបនឹងការគ្រប់គ្រងព្រៃឈើឱ្យមានភាពយូរអង្វែងស្របតាមបរិបទកំណែទម្រង់ពេលបច្ចុប្បន្ន។ បន្ថែមពីនេះពង្រឹង និងពង្រីកសហគមន៍ព្រៃឈើដើម្បីបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋតាមរយៈប្រព័ន្ធកសិរុក្ខកម្ម។

ទី៩៖ បន្តការរុករកស្រាវជ្រាវ និងបង្ក្រាបបទល្មើសព្រៃឈើ ជលផល និងការកាប់ព្រៃឈើ និងព្រៃលិចទឹកតាមរូបភាពផ្សេងៗដើម្បីយកដីធ្វើកម្មសិទ្ធផ្ទាល់ខ្លួន ដោយប្រើប្រាស់កម្លាំងប្រដាប់អាវុធ និងស្ថាប័នពាក់ព័ន្ធសម្រាប់បោះបង្គោលព្រំព្រៃឈើ និងព្រៃលិចទឹកឱ្យបានឆាប់រហ័សក្នុងគោលបំណងទប់ស្កាត់ការរំលោភបំពានព្រៃឈើ និងព្រៃលិចទឹកជាដើម។

ទី១០៖ ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយមួយប្រទេសជិតខាង និងដៃគូប្រទេអភិវឌ្ឍនានាដើម្បីស្វែងរកជំនួយ និងបច្ចេកទេសថ្មីៗ សម្រាប់ការធ្វើទំនើបភាវូបនីយកម្មកសិកម្ម និងការចរចារកទីផ្សារកសិកម្មសម្រាប់ប្រជាកសិករក្នុងបរិបទសកលភាវូបនីយកម្ម។ ជាពិសេសនោះ គឺការលើកទឹកចិត្តដល់អ្នកវិនិយោគទុនបរទេសក្នុងការវិនិយោគលើវិស័យកសិកម្ម និងជំរុញឱ្យស្ថាប័នជាតិ និងអន្តរជាតិអភិវឌ្ឍន៍វិស័យកសិកម្មគ្រប់រូបភាពដើម្បីធានានូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ជាមួយគ្នានេះគឺការជំរុញការអនុវត្តនូវគោលនយោបាយ និងយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពសម្រាប់វិស័យកសិកម្ម និងអនុវិស័យកសិកម្ម។

# ជំពូកទី២

# វិស័យកសិកម្មខេត្ត

# ស្វាយរៀង

# ជំពូកទី២
# វិស័យកសិកម្មខេត្តស្វាយរៀង

## ២.១ ស្ថានភាពខេត្តស្វាយរៀង

### ២.១.១ ប្រវត្តិការបង្កើតខេត្ត

យោងតាមឯកសារប្រវត្តិសាស្រ្តមួយចំនួនដូចជា Histore Du Cambodge ដែលស្រាវជ្រាវដោយលោក Adhémard Leclér ឯកសារមហាបុរសខ្មែរ បានបញ្ជាក់ថា សម័យព្រះបាទជ័យវរ្ម័នទី៧ ព្រះអង្គបានរៀបចំ ភូមិ ស្រុកមួយចំនួនដើម្បីគ្រប់គ្រងដឹកនាំលើវិស័យរដ្ឋបាល។ ទីតាំងខេត្តស្វាយរៀងនេះគឺជាផ្នែកមួយនៃខេត្តបាភ្នំ រោងដំរី និងខេត្តព្រៃនគរ(មុនមានឈ្មោះថាព្រៃគរប៉ុន្តែក្នុងសតវត្សរ៍ទី១៥-១៦ក្លាយជា**ព្រៃនគរ**)។ បើតាមការសន្និដ្ឋានរបស់អ្នកប្រវត្តិសាស្រ្តបានសន្និដ្ឋានថាខេត្តនេះស្ថិតនៅចន្លោះខេត្តបាភ្នំ និងខេត្តរោងដំរី ហើយមានភ្នំមួយឈ្មោះថា**ភ្នំជើងមីដែង**។ នៅក្នុងរាជព្រះបាទពញាយ៉ាតខេត្តមួយចំនួនត្រូវបានរៀបចំជាថ្មី និងនៅក្នុងសតវត្សរ៍ទី១៤ ក៏ឃើញមានការរៀបចំបង្កើតខេត្តថ្មីមួយចំនួនឡើងដូចជា**ខេត្តរំដួល ខេត្តស្វាយទាប ខេត្តរមាសហែក** ដែលកាត់ចេញពីទឹកដីខេត្តរោងដំរីខេត្តបាភ្នំ និងខេត្តត្បូងឃ្មុំ។ ព្រំប្រទល់ខេត្តស្វាយទាប និងខេត្តរំដួលភាគខាងត្បូងជាប់នឹងខេត្តទូលតាមោក គោលសណ្តែក ដែលសព្វថ្ងៃនេះស្ថិតក្នុងទឹកដីនៃខេត្តឡុងអាន ប្រទេសវៀតណាម។ ចំពោះខេត្តទើបបង្កើតថ្មីទាំងបីនេះត្រូវប្រមូលពន្ធដាក់ក្នុងឃ្លាំងព្រះរាជទ្រព្យនៅខេត្តបាភ្នំ។

នៅឆ្នាំ១៨៦៣បារាំងបានធ្វើអាណានិគមន៍មកលើរាជការខ្មែរ ហើយបានបង្កើតប៉ុស្តិ៍រដ្ឋបាលដើម្បីជួយសម្រួលដល់ការប្រមូលពន្ធជូនរាជការបារាង-ខ្មែរ(ក្នុងឆ្នាំ១៨៨៩)។ ចំពោះខេត្តដែលធ្លាប់បង់ពន្ធទៅព្រះរាជឃ្លាំងនៅបាភ្នំត្រូវប្តូរទៅបង់ពន្ធនៅប៉ុស្តិ៍រដ្ឋបាលស្វាយរៀងដែលទើបបង្កើតថ្មីវិញ។ នៅក្នុងឆ្នាំ១៨៩៧ ដោយមានជំនួយពីអាណាព្យាបាលបារាំង ព្រះមហាក្សត្រខ្មែរក៏បានរៀបចំប្រកាសដើម្បីធ្វើការរៀបចំរាជការខ្មែរ និងបែងចែករដ្ឋបាលដែនដីតាមបែបផែនរបស់បារាំងដោយចែកជាភូមិឃុំចំណុះឱ្យរាជការខណ្ឌ ស្រុក ខេត្ត។ អគ្គទេសាភិបាលបារាំងប្រចាំឥណ្ឌូចិនបានធ្វើការរៀបចំខេត្តឡើងវិញនៅចន្លោះឆ្នាំ១៩២០-១៩២១ ដោយខេត្តមួយចំនួនត្រូវបានលុបចេញ និងប្តូរឈ្មោះដោយឈរលើស្ថានភាពប្រជាសាស្រ្ត ហើយបានរៀបចំប៉ុស្តិ៍រដ្ឋបាលមួយចំនួនទៅជាខេត្ត និងយកខេត្តចាស់ប្តូរជាខណ្ឌ ឬស្រុកវិញ។ ដោយសារកំណើន និងចំនួនប្រជាជនដ៏តិចតួចរបស់ខេត្តបី គឺខេត្តរំដួល ខេត្តស្វាយទាប និងខេត្តរមាសហែកនៅសម័យនោះដែលមានតែ៥០០គ្រួសារ និងមាន មនុស្សប្រមាណ៥០ពាន់នាក់ប៉ុណ្ណោះ។ ដូច្នេះទើបធ្វើឱ្យរាជការបារាំង-ខ្មែរ

សម្រេចបញ្ចូលខេត្តទាំង បីនេះជាខេត្តតែមួយវិញ។

ក្រោយពីបានធ្វើការសិក្សាពីស្ថានភាពជាក់ស្តែងលើតំបន់ទាំងនេះ មកក្រុមលេខាឋានគណនៃអគ្គទេសាភិបាលបារាំងប្រចាំនៅភ្នំពេញ អមដោយសេនាបតីរាជការខ្មែរជាន់ខ្ពស់ដែលមានដូចជា ក្រសួងមហាផ្ទៃ ក្រសួងពន្ធដារ និងឧកញ៉ាសេនាបតីតំណាងឱ្យព្រះមហាក្សត្រខ្មែរ ព្រះបាទ ស៊ីសុវត្ថិ ក៏បានបើកកិច្ចប្រជុំមួយដែលពិភាក្សាពីការបង្កើខេត្តថ្មីនេះនៅ ថ្ងៃទី២ ខែ មេសា ឆ្នាំ១៩២២។ អង្គប្រជុំក៏បានឯកភាពគ្នាលើការបង្កើតខេត្តថ្មីនេះឡើង ស្របតាមសភាពការណ៍ដែលបារាំងចង់បានដើម្បីអភិវឌ្ឍខេត្តនានាឱ្យដូចនៅបារាំង។ ចំណែកឯព្រះមហាក្សត្រខ្មែរទ្រង់ក៏ឯកភាពលើការសំណូមពរនេះ។ លុះថ្ងៃទី ០៩ ខែមេសា ឆ្នាំ ១៩២២ ព្រះអង្គបានចេញព្រះរាជបញ្ញត្តិមួយលេខ៤៩ ដែលត្រាស់បង្គាប់ឱ្យបង្កើតខេត្ត**ស្វាយរៀង**នេះឡើង ដោយការធ្វើសមាហរ-ណកម្មរវាងខេត្តបីនាសម័យនោះគឺ ខេត្តរំដួល ខេត្តស្វាយទាប និងខេត្តរមាសហែក។[32] (សូមមើលឧបសម្ព័ន្ធទី១)

ខេត្តស្វាយរៀងតាំងពីបង្កើតនៅឆ្នាំ ១៩២២មកដល់បច្ចុប្បន្ននេះ ចៅហ្វាយខេត្ត ឬអភិបាលខេត្តមានចំនួន ៣៣ រូបដែលសព្វថ្ងៃនេះដឹកនាំដោយ **ឯកឧត្តម ម៉ែន វិបុល** ។[33]

### ២.១.២ និមិត្តសញ្ញាសម្គាល់ខេត្តស្វាយរៀង

ក្រោយពីការបង្កើតខេត្តរួចគឺ ពុំមានឯកសារណាមួយដែលបានបញ្ជាក់ពីនិមិត្តសញ្ញាខេត្តនេះឡើយ។ តែនៅអំឡុងឆ្នាំ១៩៤៧ ទើបថ្នាក់ដឹកនាំខេត្តបានរៀបចំរូបព្រះគោនន្ទីដែលត្រូវបានដាក់តាំងនៅតាមបណ្តោយផ្លូវជាតិលេខ១ ត្រង់រង្វង់មូលរូបគោបច្ចុប្បន្ន។ ការយករូបព្រះគោនន្ទីនេះមកគឺដើម្បីបង្ហាញពីគុណសម្បត្តិរបស់សត្វគោ បានចូលរួមជួយបម្រើឱ្យវិស័កសិកម្មក្នុងការភ្ជួររាស់ដែលជាកម្លាំងស្នូលក្នុងការអូសទាញពេលនោះ។ លុះឆ្នាំ១៩៥៧ រូបគោនេះត្រូវបានរចនាបន្ថែម។

**អំពីរូបព្រះគោនន្ទី៖** រូបព្រះគោនន្ទីនេះគ្មានជាប់ ទាក់ទងជាមួយទេវកថា រឿងព្រះគោព្រះកែវនេះទេ តែវាមានប្រវត្តិនៅក្នុងគម្ពីរព្រាហ្មណសាសនាដែលថា វាជាជំនិះរបស់ព្រះឥសូរឬជាសេនារបស់ព្រះឥសូរដែលនៅប្រាសាទព្រាហ្មណ សាសនា បើមានរូបព្រះឥសូរនៅខាងក្នុងនោះនៅច្រកចូលនៃគុហារ ប្រាសាទ គេតែងឃើញរូបគោនន្ទីនេះ។ រូបនេះត្រូវបានគេកសាងឡើងនៅសតវត្សរ៍ទី៧ដែលធ្វើអំពីថ្មភក់ មានកម្ពស់០.៣៣ម៉ែត្រ និងតួខ្លួនមានប្រវែងខ្លួន ០.៥៥ម៉ែត្រ។

[32] ឯកឧត្តម ម៉ែន វិបុល, *ប្រវត្តិខេត្តស្វាយរៀង(២០១៩)*, ទំព័រទី២៣-៣១

[33] ដ.ឯ.ដ ទំព័រទី៣៤



វាត្រូវបានគេឃើញនៅចន្លោះឆ្នាំ១៩៣០-១៩៣៦ ក្នុងប្រាសាទព្រៃបាសាក់ស្ថិតនៅ ឃុំបាសាក់ ស្រុករំដួល(បច្ចុប្បន្នស្រុកស្វាយជ្រំ) ខេត្តស្វាយរៀងដែលត្រូវបានចាត់ទុកថា ជាសម្បត្តិបេតិកភ័ណ្ឌវប្បធម៌ជាតិ ព្រមទាំងត្រូវបានក្រសួងវប្បធម៌ និងវិចិត្រសិល្បៈយកទៅតម្កល់តាំងទុកនៅសារមន្ទីរជាតិ។ ថ្នាក់ដឹកនាំខេត្តមានជំនឿរូបព្រះគោនន្ទីនេះតំណាងឱ្យភាពសម្បូរសប្បាយ សេចក្តីសុខចម្រើននៃប្រជាពលរដ្ឋក្នុងតំបន់វាលរាបរបស់ខេត្តស្វាយរៀងដែលប្រកបរបរកសិកម្ម និងដោយបុណ្យបារមីនៃព្រះគោនេះហើយ ទើបធ្វើឱ្យខេត្តស្វាយរៀងជៀសផុតពីគ្រោះថ្នាក់មហន្តរាយធំៗនានា។ បញ្ជាក់ផងដែរថា រូបព្រះគោនន្ទីរនេះជាវត្ថុបុរាណដែលមានអាយុកាលចាស់ជាងគេក្នុងចំណោមរូបបដិមានានានៅក្នុងខេត្ត ទើបធ្វើឱ្យថ្នាក់ដឹកនាំខេត្តក្នុងបានឯកភាពគ្នាក្នុងទសវត្សរ៍ទី៩០-៥០ បានកំណត់ឱ្យយករូបព្រះគោនន្ទីធ្វើជានិមត្តិរូប ឬនិមត្តសញ្ញារបស់ខេត្តស្វាយរៀងរហូតដល់សព្វថ្ងៃ។[34]

### ២.១.៣ ទីតាំងភូមិសាស្ត្រ និងសណ្ឋានដីក្នុងខេត្តស្វាយរៀង

ខេត្តស្វាយរៀងជាខេត្តមួយដែលស្ថិតនៅភាគអាគ្នេយ៍នៃរាជធានីភ្នំពេញ។ ខេត្តនេះស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខមួយ ហើយមានចម្ងាយប្រមាណ១២៥គ.មប៉ុណ្ណោះ ពីរាជធានីភ្នំពេញ។ ខេត្តស្វាយរៀងមានព្រំប្រទល់ខាងលិច និងខាងជើងទល់នឹង ខេត្តព្រៃវែង ចំណែកឯខាងកើត និងខាងត្បូងជាប់នឹងខេត្តតៃនីញ និងឡុងអាននៃប្រទេសវៀតណាម។ បច្ចុប្បន្ន ខេត្តស្វាយរៀងមានក្រុងចំនួន២ និងស្រុកចំនួន៦ សង្កាត់១២ ឃុំ៨០ និងភូមិចំនួន ៦៩០ ដែលលាតសន្ធឹងលើផ្ទៃដីសរុបចំនួន ២៩៦៦.៩០ គ.ម$^២$ ។ (សូមមើលឧបសម្ព័ន្ធទី២)

ក្រុង និងស្រុកទាំងនោះមានខាងក្រោមៈ

- ក្រុងស្វាយរៀង មាន សង្កាត់ចំនួន ១២ ផ្ទៃដី ១០៣.៧៦ គ.ម$^២$ ។
- ក្រុង បាវិត មាន សង្កាត់ចំនួន ៥ ផ្ទៃដី ២១៨.៣៦ គ.ម$^២$ ។
- ស្រុក ស្វាយទាប មាន ឃុំ ចំនួន ៩ ផ្ទៃដី ៣៤៩.៣៧ គ.ម$^២$ ។

[34] ឯកឧត្តម ម៉ែន វិបុល, *ប្រវត្តិខេត្តស្វាយរៀង(២០១៩)*, ទំព័រទី១៨-២១

- ស្រុក រមាសហែក មាន ឃុំ ចំនួន ១៦ ផ្ទៃដី ៧៨០.៧៧ គ.ម² ។
- ស្រុក រំដួល មាន ឃុំ ចំនួន ១០ ផ្ទៃដី ២៨៧.០៨ គ.ម² ។
- ស្រុក កំពង់រោទិ៍ មាន ឃុំ ចំនួន ១១ ផ្ទៃដី ៤០៣.៤៨ គ.ម² ។
- ស្រុក ចន្ទ្រា មាន ឃុំ ចំនួន ៦ ផ្ទៃដី ៣០១.២៣ គ.ម² ។
- ស្រុក ស្វាយជ្រំ មាន ឃុំ ចំនួន ១៦ ផ្ទៃដី ៥២២.៣៥ គ.ម² ។

នៅទីរួមខេត្តស្វាយរៀងនេះ មានទន្លេមួយព័ទ្ធពីភាគខាងកើត និងខាងត្បូងដែលអ្នកស្រុកហៅថា **ទន្លេវៃគោ**តាំងពីស.វទី១២-១៣មកម្លេះ។ កាលពីដើមពុំមានផ្លូវថ្នល់ដូចបច្ចុប្បន្ននេះទេ កាលនោះប្រជាជននៅតាមដងទន្លេធ្វើជំនួញជាមួយជនជាតិចិន អណ្ណាម ដោយផ្អែកលើផ្លូវទឹក ពីព្រោះទន្លេវៃគោនេះអាចបង្កលក្ខណៈឱ្យសំពៅ ឬទូកតូចធំចេញ-ចូលបានដើម្បីដោះដូរទំនិញផ្សេងៗ។ នៅត្រើយទន្លេនេះហើយ ដែលអ្នកស្រុកតែង **វៃគោ** (ពាក្យ **វៃ** ដូចគ្នាពាក្យ **វាយ** )ឡើងទូក ឬសំពៅ សម្រាប់ឆ្លងទៅត្រើយម្ខាង។ ដូចនេះហើយទើបគេហៅ **ទន្លេវៃគោ** តៗគ្នារហូតដល់សព្វថ្ងៃ។ អំឡុងឆ្នាំ១៨៧០ លោក Bertaur ប្រធានឋានលេខាគណិតសុរិយោដី និងភូមិសាស្ត្រប្រចាំតណ្ឌចិន និងលោក Du Cos ដែលជាអ្នកគូសផែនទីតណ្ឌចិនបានគូសផែនទីចែកទន្លេនេះជាពីរផ្នែកគឺ **ទន្លេវៃគោខាងកើត**(ទន្លេវៃគោធំ)ដែលស្ថិតនៅដែនដីកម្ពុជាក្រោម និង**ទន្លេវៃគោខាងលិច** (ទន្លេវៃគោតូច)ដែលស្ថិតក្នុងទឹកដីកម្ពុជា។ ចំពោះទន្លេវៃគោខាងលិច ឬទន្លេវៃគោតូចនេះមានប្រភពនៅបាភ្នំដែលហូរទៅដីទំនាប់តំបន់ក្រាំងស្លាភាគព្យសានបាភ្នំ តម្រង់ចូលបឹងមេសាង រួចហូរកាត់បឹងជីផុចទើបហូរមកស្វាយរៀងចាប់ពីកំពង់របោះព្រីងទៅដល់ឃុំបាយ៉ាបឆ្លងទៅវៀតណាម។ ចំណែកទន្លេវៃគោខាងកើតគឺមានប្រភពពីទន្លេតូចខេត្តកំពង់ចាម។ ពេលទឹកឡើងបានហូរចេញជាពីរផ្នែក គឺមួយផ្នែកហូរទៅតំបន់ទំនាប់កំចាយមារ និងមួយផ្នែកទៀតបានហូរកាត់ស្រុកកញ្ជៀជ (ខេត្តព្រៃវែង) ហើយប្រសព្វគ្នានៅអណ្តូងត្របែក ទើបមករួមគ្នានៅឃុំក្រសាំង រួចហូរមកកំពង់ត្រាច ត្រស់ ពាមមេត្រី បាត់ត្រាស់ ហើយហូរទៅក្រាច់យ៉ូវ(ទន្លេធំ)នៅប្រទេសវៀតណាម។ ទន្លេវៃគោនៅក្នុងខេត្តស្វាយរៀងនេះ មានជម្រៅជ្រៅដែលអាចផ្ទុកទឹកបានជាច្រើនលានម៉ែត្រគូបដែលអាចស្រោចស្រពលើផ្ទៃដីប្រមាណ៥,៣០០ហិចតា និងផ្តល់ជាជម្រកដល់ពូជត្រីជាច្រើនប្រភេទ។

ផ្ទៃដី និងសណ្ឋានដីនៃខេត្តនេះជាតំបន់វាលរាបហើយមានបឹងបួរ ដោយកន្លែងដីពុំសូវមានជីវជាតិនោះទេ។ នៅតាមបណ្តាស្រុក និងស្រុកមួយចំនួនប្រជាជនខ្វះខាតទឹកប្រើប្រាស់ ដូចជា ឃុំទួលស្ដី និងឃុំចន្ទ្រា ទឹកមានរស់ជាតិជូរ និងប្រៃ ហើយកន្លែងខ្លះខ្វះប្រភពទឹកដែលជាហេតុធ្វើឱ្យការរស់នៅតំបន់នោះជួបប្រទះការលំបាក។ តែដោយមានការយកចិត្តទុកដាក់របស់អាជ្ញាធរ

តាំងពីថ្នាក់លើរហូតដល់មន្ត្រីមូលដ្ឋាន និងសហការជាមួយនឹងអង្គការដៃគូអភិវឌ្ឍផ្សេងៗ(NGO) បានចុះពន្យល់ ណែនាំពលរដ្ឋអំពីការធ្វើកសិកម្មតាមបែបទំនើប និងបច្ចេកទេសនៃការថែទាំដំណាំដែលធ្វើឱ្យប្រជាកសិករទទួលបាននូវកសិផលមានភាពល្អប្រសើជាងមុន។ បច្ចុប្បន្ននេះមានក្រុមហ៊ុនខ្លះបានដាំដំណាំកសិឧស្សាហាកម្មដូចជា កៅស៊ូ អំពៅ និងដំឡូងមីនៅស្រុករមាសហែក រំដួល និងស្រុកស្វាយទាប ហើយក៏មានការវិនិយោគិនទាំងក្នុង និងក្រៅប្រទេស។ ជាពិសេសក្នុងវិស័យវាយនភណ្ឌតាមរយៈការបង្កើតរោងចក្រ សហគ្រាសដែលបានបង្កើតការងារជូនប្រជាពលរដ្ឋ ហើយបានចូលរួមចំណែកយ៉ាងធំធេងក្នុងការលើកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនក្នុងខេត្តឱ្យមានភាពល្អប្រសើរឡើង។[35]

### ២.១.៤ ស្ថានភាពប្រជាសាស្ត្រ

ប្រជាជនភាគច្រើននៃខេត្តនេះមានសម្បុរសណ្តែកបាយប្រើប្រាស់ភាសាខ្មែរ និងអ្នកនៅតាមតំបន់ព្រំដែនក៏ប្រើប្រាស់ភាសាកម្ពីខ្លះដូចជា ឆ្នាំងចារ មើមតយ បាញ់ឆែវ បាញ់ឌុក បាញ់ស៊ុងជាដើម។ បើយើងសង្កេតពីការបរិភោគប្រចាំថ្ងៃវិញ អ្នកស្វាយរៀងនិយមសម្លរដែលប្រើប្រាស់បន្លែដូចជា សម្លរម្ជូរ ប្រហើរត្រឡាច ឃ្លោក និងសម្លរកកូរ។ ក្រៅពីនេះ គេឃើញមានការពេញនិយមណាស់ដែរគឺ ជ្រក់សណ្តែកដែលអ្នកស្រុកក្រៅខ្លះហៅអ្នកស្វាយរៀងថា ជាម្ចាស់នៃជ្រក់សណ្តែក និងសម្លរកកូរកណ្តៀងទៀតផង។ ចំណែកខាងប្រពៃណីសាសនាវិញ អ្នកតំបន់នេះភាគច្រើនគោរពតាមព្រះពុទ្ធសាសនាមិនខុសពីប្រជាជនទូទៅរបស់កម្ពុជាទេ។ នៅតាមឃុំនីមួយៗគេឃើញមាន២ ឬ៣វត្ត ប៉ុន្តែវត្តខ្លះមានព្រះសង្ឃតែ៣ ឬ៤អង្គប៉ុណ្ណោះ។ ប្រជាជនខេត្តស្វាយរៀងក៏តែងប្រារព្ធពិធីបុណ្យតាមប្រពៃណីជាតិ និងបុណ្យផ្សេងៗដូចជា បុណ្យបច្ច័យបួន បុណ្យចម្រើនព្រះជន្ម បុណ្យឡើងអ្នកតា និងបុណ្យកំសាន្តភូមិជាដើម។[36] នៅឆ្នាំ២០១៨នេះ ខេត្តស្វាយរៀងមានប្រជាជនសរុបចំនួន ៦៣៤,៦៣៦នាក់ ក្នុងនោះស្ត្រីមានចំនួន ៣២៦,៣២៩នាក់ស្មើនឹង ៥៤.៨១% នៃប្រជាជនសរុប។ ដង់ស៊ីតេប្រជាជនក្នុងឆ្នាំ ២០១៨មានចំនួន ២១០នាក់/គ.ម$^{2}$ បើធៀបនឹងឆ្នាំ ២០១៤ គឺកើនបាន៤នាក់ដែលកាលពីឆ្នាំ២០១៤ គឺមានតែ ២០៦ក្នុងមួយគីឡូម៉ែត្រក្រឡា។ (សូមមើលឧបសម្ព័ន្ធទី៥)

[35] ឯកឧត្តម ម៉ែន វិបុល, *ប្រវត្តិខេត្តស្វាយរៀង(២០១៩)*, ទំព័រទី៤-៩

[36] ឯកឧត្តម ម៉ែន វិបុល, *ប្រវត្តិខេត្តស្វាយរៀង(២០១៩)*, ទំព័រទី៤-៥

តារាងទី២៖បង្ហាញពីលក្ខណៈរួមនៃប្រជាសាស្ត្រឆ្នាំ២០១៤-២០១៨

| **បរិយាយ** | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| ចំនួនប្រជាជនសរុប(នាក់) | ៦១១,៥១១ | ៦១២,៨៧៨ | ៦១៧,៤៥៨ | ៦២៣,៨៣៤ | ៦៣៤,៦៣៦ |
| អត្រាកំណើនប្រចាំឆ្នាំ (%) | ១.៧៣ | ០.២២ | ០.៧៥ | ១.០៣ | ១.៧៣ |
| សរុបប្រុស | ២៩៦,៥០២ | ២៩៦,៤៧៨ | ២៩៨,៩៤០ | ៣០២,០៧២ | ៣០៨,៣០៧ |
| សរុបស្រី | ៣១៥,០០៩ | ៣១៦,៤០០ | ៣១៨,៥១៨ | ៣២១,៧៦២ | ៣២៦,៣២៩ |
| ចំនួនគ្រួសារ | ១៣៨,៤១១ | ១៤៣,២៧៩ | ១៤៤,៨១៥ | ១៤៧,១០៧ | ១៤៩,៨៩១ |
| គ្រួសារជាមធ្យម(នាក់/គ្រួសារ) | ៤.៤២ | ៤.២៨ | ៤.២៦ | ៤.២៤ | ៤.២៣ |
| ចំនួនមនុស្សអាយុ ០-១៧ឆ្នាំ | ២១៥,៤១០ | ២១១,៣៤១ | ២១៣,២២០ | ២១៥,៣៥៣ | ២១៩,០០៩ |
| %មនុស្សអាយុ ០-១៧ឆ្នាំ | ៣៥ | ៣៤.៤៨ | ៣៤.៥៣ | ៣៤.៥២ | ៣៤.៥១ |
| ចំនួនមនុស្សអាយុ១៨-៦០ឆ្នាំ | ៣៤២,០៩៤ | ៣៤៧,២៣៣ | ៣៤៨,៩៨៤ | ៣៥១,៤២១ | ៣៥៣,០៦០ |
| %មនុស្សអាយុ ១៨-៦០ឆ្នាំ | ៥៥.៩៤ | ៥៦.៦៦ | ៥៦.៥២ | ៥៦.៣៣ | ៥៥.៦៣ |
| ចំនួនមនុស្សអាយុ ៦១ឆ្នាំឡើង | ៥៤,០០៧ | ៥៤,៣០៤ | ៥៥,២៥៤ | ៥៧,០៦០ | ៦២,៥៦៧ |
| %មនុស្សអាយុ ៦១ឆ្នាំឡើង | ៨.៨៣ | ៨.៨៦ | ៨.៩៥ | ៩.១៥ | ៩.៨៦ |

ប្រភព៖ ដកស្រង់ចេញពីឯកសារពត៌មានស្ដីពី ស្ថិតិប្រជាជនពីឆ្នាំ១៩៧៩ដល់២០១៧,ស្ថានភាពសេដ្ឋកិច្ចនិងសង្គមកិច្ចខេត្ត២០១៨(របស់មន្ទីរផែនការខេត្តស្វាយរៀង)

អាត្រាកំណើនប្រចាំឆ្នាំ២០១៨មាន១.៧៣% ហើយប្រជាជនកើនឡើងចំនួន ២៣,១២៥ នាក់ ស្មើនឹង៣.៧៨% បើធៀបនឹងឆ្នាំ២០១៤។ ការបែងចែកតាមក្រុមអាយុបង្ហាញថា ក្រុមអាយុ ០-១៧ឆ្នាំមានចំនួន ៣៤.៥១% កើនបាន១.៦៧% ក្រុមអាយុ១៨-៦០មានចំនួន ៥៥.៦៣% គឺកើនបាន ៣.២០% និងក្រុមអាយុ៦១ឆ្នាំឡើងមានចំនួន ៩.៨៦% ពោលគឺកើនឡើងបាន ១៥.៨៤% បើធៀបនឹងឆ្នាំ ២០១៤ដូចគ្នា។

ប្រជាជនដែលស្ថិតក្នុងក្រុមអាយុ១៨-៦០ឆ្នាំមានចំនួនន ៣៥៣,០៦០នាក់ ស្មើនឹង ៥៥.៦៣%នៃប្រជាជនសរុបក្នុងនោះអ្នកមានមុខរបរជាចម្បងសរុបបចំនួន ៣៣៣,១៦២នាក់ ឬប្រមាណ ៩៤.៣៦%នៃប្រជាជនក្រុមអាយុនេះមានន័យថាប្រជាជនប្រមាណតែ ៥.៦៤%ប៉ុណ្ណោះដែលគ្មានមុខរបរចម្បង។ អ្នកដែលមានមុខរបរចម្បងទាំងនោះកំពុងបម្រើការងារនៅក្នុងផ្នែកសំខាន់ៗបីគឺ ផ្នែកកសិកម្មមានចំនួន ២០៣,០៣៨នាក់ ស្មើនឹង៦០.៩៤% ផ្នែកសិប្បកម្មចំនួន២,៧២៩ នាក់ ស្មើនឹង០.៨២% និងផ្នែកសេវាកម្មមានចំនួន ១២៧,៣៩៥នាក់ ស្មើនឹង ៣៨.២៤% បើធៀប

នឹងចំនួននៃអ្នកមានមុខរបរជាចម្បងសរុប(២០១៨)។[37]

### ២.១.៥ វិស័យដែលមានសក្តានុពលក្នុងខេត្ត

សក្តានុពលរបស់ខេត្តនេះ គឺសម្បត្តិធនធានធម្មជាតិ និងធនធានកែច្នៃស្ថាបនានៅក្នុងផ្នែកកសិកម្មដែលជាមូលដ្ឋានសិប្បកម្មរោងចក្រ និងគ្រឹះស្ថាននានានៅក្នុងផ្នែកសិប្បកម្ម និងសេវាកម្ម។ ផ្នែកកសិកម្មមានផ្ទៃដីសម្រាប់ធ្វើកសិកម្មដាំដុះ និងធនធានទឹកសម្បូរបែប ផ្នែកសិប្បកម្ម និងផ្នែកសេវាកម្មមានតំបន់សេដ្ឋកិច្ចពិសេសសមានរោងចក្រជាច្រើនទាំងខាងក្នុង និងក្រៅតំបន់សេដ្ឋកិច្ច កាស៊ីណូ សណ្ឋាគារ ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រតិបត្តិករឥណទានជនបទ និងអង្គការសមាគមន៍ផ្តល់ឥណទាន និងក្រុមហ៊ុនផ្សេងៗ។ ព្រមទាំងមានច្រកទ្វារជាច្រើនសម្រាប់ជួយសម្រួលការផ្លាស់ប្តូរទំនិញ ទេសចរណ៍ និងសេវាកម្មនានារវាងប្រទេសកម្ពុជា-វៀតណាម។ ខេត្តនេះមានច្រកទ្វារសំខាន់ៗចំនួន ៨កន្លែង គឺច្រកទ្វារអន្តរជាតិ ៣កន្លែង ច្រកទ្វារទ្វេភាគី១កន្លែង និងច្រកទ្វារតំបន់ព្រំដែន ៤កន្លែង តាមបណ្តោយខ្សែបន្ទាត់ព្រំដែនដែនកម្ពុជា-វៀតណាម ប្រវែង ២៥៨ គ.ម។

ច្រកទ្វារអន្តរជាតិ ៣កន្លែងនោះរួមមាន៖

- ច្រកទ្វារអន្តរជាតិ **បាវិត-ម៉ុកបាយ:** ស្ថិតនៅក្នុងភូមិកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កម្ពុជា ទល់នឹងភូមិឡឹយធឹង ឃុំថិនតី ស្រុកបេនកូវ ខេតតៃនិញ ក្នុងវៀតណាម។
- ច្រកទ្វារអន្តរជាតិ **ព្រៃវល្លិ៍-ប៊ិនហៀប:** ស្ថិតនៅភូមិអូរ ឃុំថ្មី ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង កម្ពុជា ទល់នឹងភូមិប៊ិនហៀប ឃុំប៊ិនហៀប ទីរួមខេត្តកៀនទឿង ខេត្តឡុងអាន វៀតណាម។
- ច្រកទ្វារអន្តរជាតិ **សំរោង-មីគ្វីតី:** ស្ថិតនៅភូមិចេក ឃុំសំរោង ស្រុកចន្ទ្រា ខេត្តស្វាយរៀង កម្ពុជាទល់នឹងឃុំមីគ្វីតី ស្រុកឌឹករ៉េ ខេត្តឡុងអាន វៀតណាម ប៉ុន្តែច្រកទ្វារនេះនៅដំណើរការជាច្រកទ្វារទ្វេភាគីនៅឡើយ។

ច្រកទ្វារទ្វេភាគី១កន្លែងគឺ: ច្រកទ្វារ **បុសមន-ភៀកតឹង** (ច្រកតំបន់) នៅក្នុងភូមិបុសមន ឃុំបុសមន ស្រុករំដួល ខេត្តស្វាយរៀង កម្ពុជា ប្រឈមនឹង ឃុំថាញ់ឡុង ស្រុកចូវថាញ់ ខេត្តតៃនិញ ប្រទេស វៀតណាម។

[37] មន្ទីផែនការខេត្តស្វាយរៀង,*ឯកសារព័ត៌មានស្តីពី ស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ចឆ្នាំ២០១៩ខេត្តស្វាយរៀង*, ទំព័រទី ៩,១៨

ច្រកទ្វារតំបន់ព្រំដែន ៤កន្លែង

- ច្រកទ្វារតំបន់ព្រំដែន **ស្រែបារាំង-យ៉ាំងដូង:** ស្ថិតនៅភូមិតាស្អាង ឃុំកំពង់ចំឡង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង កម្ពុជា ប្រឈមនឹង ឃុំវិញទិញអ៊ែរ ស្រុកវិញហ៊ឹង ខេត្តឡុងអាន វៀតណាម ជាច្រកទ្វារតាមផ្លូវទឹក។
- ច្រកទ្វារតំបន់ព្រំដែន **ដូង-វ៉ាមចាងចូវ:** ស្ថិតនៅភូមិដូង ឃុំដូង ស្រុករមាសហែក ខេត្តស្វាយរៀង កម្ពុជា ប្រឈមនឹង ឃុំបៀនយើង ស្រុកចូវថាញ់ ខេត្តតៃនិញ វៀតណាម។
- ច្រកទ្វារតំបន់ព្រំដែន **ព្រៃតាអី-ឡុងភឿក:** ស្ថិតនៅភូមិត្រពាំងតាអី ឃុំព្រៃតាអី ស្រុកស្វាយទាប ខេត្តស្វាយរៀង កម្ពុជា ប្រឈមនឹង ឃុំឡុងភឿក ស្រុកបេនគូរ ខេត្តតៃនិញ វៀតណាម។
- ច្រកទ្វារតំបន់ព្រំដែន **ខ្សែដែក-ហ្វាហៀប:** *(ច្រករបៀង)*ស្ថិតនៅភូមិតាសួស ឃុំត្រស់ ស្រុករមាសហែក ខេត្តស្វាយរៀង កម្ពុជា ប្រឈមនឹង ឃុំហ្វាហៀប ស្រុកតិនបៀន ខេត្តតៃនិញ ប្រទេស វៀតណាម។

**ផ្នែកកសិកម្ម:** មានមនុស្សធ្វើប្រមាណ ៦១.៤% នៃអ្នកដែលមានមុខរបរចម្បងទូទាំងខេត្ត ឬ៥៤.៨៩%ធៀបនឹងសកម្មជនសេដ្ឋកិច្ចសរុបក្នុងខេត្ត(ក្រុមអាយុ១៨-៦០)។ ផ្នែកនេះរួមមានការដាំដុះ និងការចិញ្ចឹមសត្វ ប៉ុន្តែការចិញ្ចឹមមិនសូវមានសកម្មភាពច្រើនទេ។

**ផ្នែកសិប្បកម្ម និងសេវាកម្ម:** ផ្នែកសិប្បកម្មបានផ្តល់ការងារជូនប្រជាជនបានតែ ០.៨% ខណៈដែលផ្នែកសេវាកម្មអាចមានមនុសធ្វើការប្រមាណ ៣៧.៨% នៃអ្នកមានមុខរបរចម្បងនៅក្នុងទូទាំងខេត្តពោលគឺមានកម្មករ និយោជិកបាន និងកំពុងធ្វើការក្នុងផ្នែកទាំងពីរនេះមានចំនួន ៦១,៥៥៧នាក់ ស្ត្រីចំនួន ៤០,២១៣នាក់ ក្នុងនោះមានជនបរទេស ២,៥៣២នាក់ ដែលបម្រើការនៅតាមរោងចក្រ គ្រឹះស្ថាន និងក្រុមហ៊ុននានាចំនួន ១៧៦មូលដ្ឋាន។

តារាងទី៣៖ ការបង្ហាញពីចំនួនរោងចក្រ សហគ្រាស និងអ្នកបម្រើការ

| ប្រភេទរោងចក្រ /សហគ្រាស | ចំនួនរោងចក្រ / សហគ្រាស | ចំនួនអ្នកបម្រើការងារ(នាក់) | | | |
|---|---|---|---|---|---|
| | | ចំនួនសរុប | ជាស្ត្រីសរុប | ជាស្ត្រីបរទេស | ជនបរទេសសរុប |
| រោងចក្រក្នុងតំបន់សេដ្ឋកិច្ចពិសេស | ៦៤ | ៤៧,១៨៨ | ៣៣,៨៦៦ | ៣៤២ | ១,៤០៧ |
| រោងចក្រក្រៅតំបន់សេដ្ឋកិច្ចពិសេស | ១៦ | ២,១៦៣ | ១,៥៩៨ | ១៣ | ៧៨ |
| កាស៊ីណូ-សណ្ឋាគារ | ២១ | ៩,៤៣៥ | ៤,០៦៩ | ៣១៣ | ១,២៤៣ |

| | | | | | |
|---|---|---|---|---|---|
| ធនាគារ | ២១ | ៦៩៩ | ២៣០ | ០ | ១ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | ៣៥ | ៧៩៦ | ២០៣ | ០ | ០ |
| ក្រុមហ៊ុនផ្សេងៗ | ១៩ | ១,១៦១ | ២១៩ | ១៤ | ៩២ |

ប្រភពៈតួលេខដកស្រង់ចេញពីសៀវភៅ,*កម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៩-២០២១*,ទំព័រទី១២

នៅខេត្តស្វាយរៀង មានតំបន់សេដ្ឋកិច្ចពិសេសចំនួន ៨កន្លែង គឺតំបន់សេដ្ឋកិច្ចពិសេស មេនហាតធេន តាយសេង នាគរាជ សាន់ដុងសាន់សៃល ហាយផាក ឈីលូ ស្វាយរៀងហ្គីហ្គា និង តំបន់សេដ្ឋកិច្ចពិសេសអ៊ីនធើរៀអូតូម៉ូលបាលអ៊ីនដាសស្ទ្រីលខមផ្លេកស៍។[38]

## ២.២ រចនាសម្ព័ន្ធគ្រប់គ្រងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង

### ២.២.១ រចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរ

នៅក្នុងឆ្នាំ២០១៩ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង មានអង្គភាព ចំណុះចែកចេញជា១០ការិយាល័យ និងខណ្ឌចំនួន២ នៅថ្នាក់ខេត្ត និង៨ការិយាល័យកសិកម្ម ក្រុង ស្រុក មានរចនាសម្ព័ន្ធ ក្បាលម៉ាស៊ីនដឹកនាំថ្នាក់ និងស្រុកក្រុង មានមន្ត្រីក្របខណ្ឌចំនួន ១២២នាក់ ក្នុងនោះស្រី២១នាក់ និងមន្ត្រីជាប់កិច្ចសន្យាចំនួន១១នាក់ ស្រី១នាក់។

**រចនាសម្ព័ន្ធគ្រប់គ្រងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត** (សូមមើលឧបសម្ព័ន្ធទី៦)




[38] ក្រុមប្រឹក្សាខេត្តស្វាយរៀង,*កម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៩-២០២១*,ទំព័រទី១១-១៣

### ២.២.២ តួនាទី និងភារកិច្ច

**-ការិយាល័យរដ្ឋបាល និងបុគ្គលិក:** មានភារកិច្ចក្នុងការសម្រួលការងារចរាចរឯកសាររដ្ឋបាល ធ្វើលិខិតអញ្ជើញផ្សេងៗ គ្រប់គ្រងទុកដាក់ថែរក្សាឯកសាររបស់មន្ទីរ។ មួយទៀតគឺ រៀបចំការងារបៀវត្សរ៍ដំឡើងកាំបៀវត្សរ៍ចូលនិវត្តន៍ និងរបបធានារ៉ាប់រងសង្គមដល់បុគ្គលិក លើកសំណើររៀបចំកែសម្រួល ឬរំសាយរចនាសម្ព័ន្ធតាមស្ថានភាពជាក់ស្តែង។ ក្រៅពីនេះការិល័យ នេះក៏ជាអ្នករៀបចំគម្រោងតម្រូវការបណ្តុះបណ្តាលបុគ្គលិក និងបញ្ជូនមន្ត្រីឱ្យទៅសិក្សានៅក្នុង និងក្រៅប្រទេស ។

**-ការិយាល័យផែនការ និងគណនេយ្យ:** មានភារកិច្ចវិភាគនិងកសាងផែនការអភិវឌ្ឍវិស័យកសិកម្មរយៈពេលខ្លីមធ្យម និងវែង និងតាមដានការអនុវត្ត ដឹកនាំការអង្កេតទូទៅ ការអង្កេតតាមផ្នែកពាក់ពន្ធ័ការងារកសិកម្ម។ ការិយាល័យនេះជាអ្នកប្រមូលព័ត៌មានស្ថិតិកសិកម្មចងក្រង និងបោះពុម្ពផ្សព្វផ្សាយ ហើយធ្វើគម្រោងថវិកាប្រចាំឆ្នាំ និងតាមដានការអនុវត្ត រួចរៀបចំសំណុំឯកសារ ទូទាត់ជម្រះបញ្ជីចំណូលចំណាយថិវិកា និងធ្វើរបាយការណ៍ហិរញ្ញវត្ថុឱ្យបានសមស្របតាមច្បាប់ ហិរញ្ញវត្ថុ និងតាមដានការអនុវត្ត ព្រមទាំងរាយការណ៍អំពីចំណូលចំណាយប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំឱ្យបានទៀងទាត់ពេលវេលាប្រមូលប្រភពចំណូល និងបង់ចូលថវិការដ្ឋ តាមគោលការណ៍ច្បាប់ហិរញ្ញវត្ថុ។

**-ការិយាល័យផលិតកម្ម និងបសុព្យាបាល:** មានភារកិច្ចតាមដានសកម្មភាពផលិតកម្ម និងបសុព្យាបាល វិភាគពីកត្តាបច្ចេកទេសដែលពាក់ព័ន្ធទៅលើការផ្គត់ផ្គង់សម្ភារៈប្រើប្រាស់ក្នុងផលិតកម្ម និងបសុព្យាបាល ពិនិត្យតាមដានសុខភាពសត្វ ស្ថិតិសត្វ និងធ្វើភិនសត្វ ដើម្បីកំណត់វិធានការគ្រប់គ្រង ការពារ និងចាត់ចែងសកម្មភាពប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងរាលត្បាតទាំងឡាយ។ មួយវិញទៀត ក៏មានភារៈក្នុងការត្រួតពិនិត្យតាមដានការធ្វើអាជីវកម្មសត្វ ផលិតផលមានដើមកំណើតពីសត្វ តាមទីសត្តឃាត និងតាមទីកន្លែងកែច្នៃផលិតផលមានដើមកំណើតពីសត្វ។ ការិយាល័យនេះជាអ្នក តាមដានត្រួតពិនិត្យ និងមានវិធានការបង្ក្រាបបទល្មើសក្នុងការនាំចេញនាំចូលឆ្លងកាត់សត្វដើម្បីទប់ស្កាត់ការរីករាលដាលនៃជម្ងឺឆ្លងដោយសហការជាមួយនឹងអាជ្ញាធរមូលដ្ឋាន។

**-ការិយាល័យផ្សព្វផ្សាយកសិកម្ម:** ជាអ្នកប្រមូលចំណេះដឹង បទពិសោធន៍ចំណេះដឹងរបស់កសិករឆ្នើម និងលទ្ធផលស្រាវជ្រាវរកឃើញថ្មីនៅក្នុងតំបន់ដើម្បីធ្វើការផ្សព្វផ្សាយ និងបំពាក់បំប៉នដល់ប្រជាកសិករ ផ្សព្វផ្សាយព័ត៌មានបច្ចេកវិទ្យាសេដ្ឋកិច្ចកសិកម្មដល់កសិករ និងដៃគូឧស្សាហ

កម្ម ពាណិជ្ជកម្មផ្សព្វផ្សាយ និងផ្តល់សេវាកម្មប្រឹក្សាយោបល់បច្ចេកទេសចំពោះកសិករដែលមានការចាប់អារម្មណ៍ដើម្បីអភិវឌ្ឍបច្ចេកទេសថ្មីៗរបស់កសិកម្ម។

**-ការិយាល័យកសិ-ឧស្សាហកម្ម:** មានភារកិច្ចក្នុងការប្រមូលទិន្នន័យអំពីសក្តានុពលនៃផលិតកម្មកសិកម្ម កំណត់ភូមិសាស្ត្រសម្រាប់អភិវឌ្ឍន៍កសិឧស្សាហកម្ម។ ការិយាល័យនេះគ្រប់-គ្រងការវិនិយោគកសិឧស្សាហកម្ម ហើយលើកកម្ពស់សហគ្រាសកសិឧស្សាហកម្ម និងកសិម្ហូបអាហារដើម្បីតម្រង់ទិសផ្នែកផលិតកម្មផ្នែកកែច្នៃ និងកសិពាណិជ្ជកម្មដល់អង្គការកសិករ និងដៃគូខាងឧស្សាហកម្មដើម្បីបង្កើនតម្លៃបន្ថែមលើផលិតផលកសិកម្ម។ ក្រៅពីនេះ ក៏ជាអ្នកតភ្ជាប់ទំនាក់ទំនងសម្របសម្រួលរវាងភាគីអ្នកផលិត និងភាគីអ្នកទិញ ព្រមទាំងតាមដានការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា។

**-ការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម:** ស្រាវជ្រាវតាមដានផលិតកម្មដំណាំផ្សេងៗ វិភាគពីកត្តាបច្ចេកទេស ដែលពាក់ព័ន្ធទៅលើការផ្គត់ផ្គង់ធាតុចូលកសិកម្មប្រើប្រាស់ក្នុង ផលិតកម្ម ឬក្នុងពាណិជ្ជកម្ម ដែលជះឥទ្ធិពលទៅលើការវិវឌ្ឍផលិតកម្មកសិកម្ម។ មួយទៀតក៏ចូលរួមចាត់ចែងជំរុញដោះស្រាយកម្មវិធីសង្គ្រោះដំណាំនៅពេលខ្វះទឹក ធ្វើកិច្ចសហប្រតិបត្តិការជាមួយនាយកដ្ឋានជំនាញដើម្បីអភិវឌ្ឍសម្ភារៈបំប៉ន កែលម្អការងារស្រាវជ្រាវលើគំរូដាំដុះ និងប្រសិទ្ធភាពនៃប្រព័ន្ធកសិកម្ម។

**-ការិយាល័យកៅស៊ូ:** មាននាទីជម្រុញ និងលើកទឹកចិត្តដល់កសិករក្នុងការដាំដំណាំកៅស៊ូដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធ ណែនាំ និងផ្សព្វផ្សាយបច្ចេកទេស ព្រមទាំងព័ត៌មានថ្មីៗពាក់ព័ន្ធនឹងវិស័យកៅស៊ូដល់អ្នកដាំកៅស៊ូ។

**-ការិយាល័យគ្រឿងយន្តកសិកម្ម:** មានភារកិច្ចប្រមូលទិន្នន័យស្ថិតិគ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្ម ហើយសិក្សាស្រាវជ្រាវពីសក្តានុពល និងប្រសិទ្ធភាពគ្រឿងយន្តកសិកម្ម ឧបករណ៍កសិកម្មមុន និងក្រោយប្រមូលផល និងកំណត់តំបន់ប្រើប្រាស់ឱ្យបានសមស្របទៅតាមប្រភេទដី និងមុខដំណាំ។ ការិយាល័យនេះ ចូលរួមអន្តរាគមន៍លើការងារភ្ជួររាស់ ស្រោចស្រពដឹកជញ្ជូន និងប្រមូលផល បណ្តុះបណ្តាល ផ្ទេរ និងផ្សព្វផ្សាយបច្ចេកទេសតាមបណ្តាព័ត៌មាន ឯកសារ និងណែនាំអនុវត្តបង្ហាញផ្ទាល់ដល់កសិករ សិប្បករអំពីការប្រើប្រាស់ ថែទាំ ជួសជុល ផលិត កែច្នៃ គ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្មផ្សេងៗ។

**-ការិយាល័យអភិវឌ្ឍសហគមន៍កសិកម្ម:** មានភារៈកិច្ចក្នុងការសម្របសម្រួល និងគាំទ្រដល់កសិករក្នុងការបង្កើត និងចុះបញ្ជីសហគមន៍កសិកម្ម ហើយជាអ្នកបើកវគ្គបណ្តុះបណ្តាល និង

ពង្រឹងសមត្ថភាពដល់សហគមន៍កសិកម្ម។ ក្រៅពីនេះ ផ្នែកនេះក៏មាននាទីក្នុងការសម្របសម្រួល រវាងសហគមន៍កសិកម្ម និងសហគមន៍កសិកម្មជាមួយអង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន និង ផ្នែកពាក់ព័ន្ធ ព្រមទាំងធ្វើបច្ចុប្បន្នភាពទិន្នន័យសហគមន៍កសិកម្មប្រចាំឆ្នាំ។

**-ការិយាល័យនីតិកម្មកសិកម្ម:** មានភារៈកិច្ចអនុវត្តត្រួតពិនិត្យលិខិតបទដ្ឋាននានាដែល ពាក់ព័ន្ធនឹងច្បាប់ក្នុង និងក្រៅវិស័យកសិកម្ម ពិនិត្យពិចារណា និងមានមតិលើនីតិវិធីដោះស្រាយ វិវាទនានាពាក់ព័ន្ធនឹងវិស័យកសិកម្ម។ មួយវិញទៀត គឺគ្រប់គ្រងត្រួតពិនិត្យ និងពង្រឹងវិធានការ គ្រប់គ្រងការងារអាជីវកម្មសម្ភារៈកសិកម្មក្នុងខេត្ត ហើយផ្សព្វផ្សាយ និងអប់រំណែនាំពីគោល ការណ៍ក្នុងការធ្វើអាជីវកម្មសម្ភារកសិកម្ម។[39]

-ខណ្ឌរដ្ឋបាលជលផល: មានភារកិច្ចក្នុងការរៀបចំផែនការយុទ្ធសាស្ត្រគ្រប់គ្រង និង ការពារធនធានជលផលសម្រាប់អនុវត្ត ហើយក៏ជាអ្នកត្រួតពិនិត្យ អង្កេតតាមល្បាតលើការធ្វើ អាជីវកម្មជលផល ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល។ ការិយាល័យនេះ ក៏មានតួនាទីក្នុង ការត្រួតពិនិត្យ អង្កេតស្តង់ដា កន្លែងកែច្នៃទីតាំងលក់ និងអនាម័យផលិតផលជលផល។

-ខណ្ឌរដ្ឋបាលព្រៃឈើ: មានភារកិច្ចសម្របសម្រួលបច្ចេកទេសដល់សហគមន៍ព្រៃឈើ ត្រួតពិនិត្យការប្រមូលផល និងអនុផលព្រៃឈើ។ មួយទៀតជាអ្នកផ្សព្វផ្សាយសារប្រយោជន៍ព្រៃ ឈើដល់ពលរដ្ឋឱ្យការពារ និងដាំដើមឈើបន្ថែម ហើយក៏ជាអ្នកស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាប បទល្មើសព្រៃឈើ ព្រមទាំងរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ។[40]

## ២.៣ ស្ថានភាពកសិកម្មក្នុងខេត្តស្វាយរៀង

### ២.៣.១ ស្ថានភាពអភិវឌ្ឍនៃដំណាំស្រូវក្នុងខេត្តស្វាយរៀងឆ្នាំ២០០៩-២០១៨

នៅប្រទេសកម្ពុជាដំណាំស្រូវជាដំណាំអាទិភាពចម្បងក្នុងការដាំដុះ ជាពិសេសគឺប្រជាជន នៅតាមតំបន់ដីសណ្តរទន្លេមេគង្គ និងជុំវិញបឹងទន្លេសាប។ ចំពោះប្រជាកសិករនៅខេត្តស្វាយ រៀងក៏បានធ្វើការដាំដុះស្រូវជាដំណាំនេះចម្បងមិនខុសពីខេត្តដទៃទៀតនោះទេ ហើយពីមួយឆ្នាំ ទៅមួយឆ្នាំបរិមាណផលស្រូវក្នុងខេត្តនោះបានកើនឡើងជាបន្តបន្ទាប់។

ក្នុងឆ្នាំ២០០៩កសិករទូទាំងខេត្តបានធ្វើការស្ទូងដកលើផ្ទៃដីសរុបចំនួន១៨០,៥៣២ហិចតា

---

[39] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *ប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរកសិកម្មរាជធានី ខេត្ត (២០១៤)*, ទំព័រទី៣-៨។

[40] មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង, *សេចក្តីសម្រេចស្តីពីការបៀបរបបការងារ និងការបែងចែកភារកិច្ចជូនប្រធាន-អនុប្រធានការិយាល័យជំនាញថ្នាក់ខេត្ត និងប្រធាន-អនុប្រធានការិយាល័យកសិកម្មស្រុក ក្រុង*,ទំព័រ៣-៦។

បើធៀបនឹងផ្ទៃដីដាំដុះឆ្នាំមុនមានការកើនឡើងចំនួន ៥,២៩១ហិចតាដែល ស្មើនឹង៣%។ ក្នុងនោះ ស្រូវនៅរដូវវស្សាត្រូវបានអនុវត្តលើផ្ទៃដី ១៦៥,០១៥ហិចតា បើធៀបនឹងឆ្នាំមុនកើនបាន ៤,៦០២ ហិចតា។ តែនៅរដូវវស្សាផ្ទៃដីដែលរងប៉ះពាល់ដោយកង្វះទឹក និងសត្វល្អិតសរុប ៥,២៤២ហិចតា ដោយមានការអន្តរាគមន៍សង្គ្រោះពីអាជ្ញាធរពាក់ព័ន្ធជួយសង្គ្រោះបាន ៤,៧២៤ហិចតាមកវិញ ដែលត្រូវខូចខាតទាំងស្រុងតែ ៥១៨ហិចតា។ ចំណែកផ្ទៃដីដាំដុះនៅរដូវប្រាំងវិញមានចំនួន ១៥,៥១៧ហិចតា ដែលកើនឡើងប្រមាណជា ៤.៦៤%បើធៀបនឹងឆ្នាំមុន។ ចំពោះបញ្ហាប្រឈម នៅរដូវប្រាំងគឺបញ្ហាកង្វះទឹកដែលធ្វើឱ្យប៉ះពាល់លើផ្ទៃដីចំនួន ៥៤៦ហិចតា និងការយាយីបំផ្លាញ ពីសត្វល្អិត(មមាចត្នោត)លើផ្ទៃដី ៨២៩ហិចតា តែត្រូវរងការខូចខាតចំនួន ៨៨ហិចតា ព្រោះដោយ មានការបុកអណ្តូងស្រោចស្រព និងការបាញ់ថ្នាំកំចាត់សត្វល្អិត។ ដោយឡែកសម្រាប់ទិន្នផល ស្រូវដែលខេត្តនេះ ទទួលបាននៅក្នុងឆ្នាំ២០០៩នេះ មានសរុបចំនួន ៥៤៣,៦៧៩តោន ដែលកើន ឡើងចំនួន ២៥,៥៣៨តោន ស្មើនឹង៦.១០% បើធៀបនឹងឆ្នាំមុន ហើយកើនបាន ៦៧.៨៦%បើ ធៀបនឹងនឹងរយៈពេល៥ឆ្នាំមុន(២០០៥)។ បរិមាណផលស្រូវនេះត្រូវបានអនុវត្តការប្រមូលផល លើផ្ទៃដីសរុបចំនួន ១៧៩,៩៦៦ហិចតា ហើយទិន្នផលជាមធ្យមប្រចាំឆ្នាំ២០០៩ ទទួលបាន ២.៤៦៥តោន/ហិចតា បើធៀបនឹងឆ្នាំមុនកើនបាន ០.០៧៧តោន/ហិចតា។ ផ្ទៃដីប្រមូលផលស្រូវ ទាំងត្រូវបែងចែកជាពីរគឺរដូវ វស្សាទូទាំងខេត្តអាចប្រមូលផលបាន ១៦៤,៩៩៧ហិចតា ដោយ ទទួលបានទិន្នផលជាមធ្យម ២.៣២តោន/ហិចតា និងនៅរដូវប្រាំងបាន ១៥,៤៦៩ហិចតា ដោយ ទទួលបានទិន្នផល ៤.០១១តោន/ហិចតា។ សម្រាប់តុល្យភាពស្បៀងក្នុងខេត្តប្រជាជនត្រូវការ ចំនួន ៦៩,១៦៣តោន ទុកសម្រាប់បរិភោគព្រោះតាមរបាយការណ៍របស់មន្ទីរក្នុងប្រជាពលរដ្ឋម្នាក់ ត្រូវការអង្ករចំនួន ១៤៣គ.ក្រ/ឆ្នាំ។ ជារួមនៅក្នុងឆ្នាំ២០០៩ ខេត្តស្វាយរៀងមានអតិរេកអង្ករចំនួន ១៧៧,៨៧៧តោន សម្រាប់នាំចេញ។[41]

នៅរយៈពេល៥ឆ្នាំក្រោយគឺនៅឆ្នាំ២០០៩-២០១៣ បរិមាណផលស្រូវមានកើនឡើងជាលំ-ដាប់។ ជាក់ស្តែងនៅក្នុងឆ្នាំ២០១៣ ការបង្កបង្កើនផលស្រូវនៅទូទាំងខេត្តអនុវត្តបាន ១៨៦,៩៧១ ហិចតា បើធៀបនឹងឆ្នាំមុនមានការថយចុះចំនួន ៥៧៨ ឬស្មើនឹង ០.៣%ដោយសារតែនៅក្នុងឆ្នាំ ២០១៣។ ក្នុងខេត្តស្វាយរៀងបានជួបប្រទះនូវភាពរាំងស្ងួតយ៉ាងខ្លាំងដែលកម្ពស់ទឹកភ្លៀងមាន ការថយចុះចំនួន ១៥០.៨ម.ម បើធ្វើការប្រៀបធៀបនឹងឆ្នាំមុន។ ការបង្កបង្កើនផលស្រូវនៅរដូវ

[41] មន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង,*របាយការណ៍បូកសរុបការងារកសិកម្មប្រចាំឆ្នាំ២០០៩*

វស្សាឆ្នាំ ២០១៣មានចំនួន ១៦៦,៥៩៩ហិចតា បើធៀបនឹងឆ្នាំមុនមានការថយចុះចំនួន ១៧១ហិចតា។ តែបើធៀបទៅនឹងឆ្នាំ២០០៩ គឺមានការកើនឡើងបាន ១,៥៣៩ហិចតា ស្មើនឹង0.៩២%។ ដោយសារអាកាសធាតុមិនអនុគ្រោះ(ភាពរាំងស្ងួត)បានធ្វើប៉ះពាល់ដល់ដំណាំស្រូវ ចំនួន ៣,០៨៥ ហិចតា ផ្ទៃដីដែលខូចខាតសរុប ៦៧៥ហិចតា តែស្តារឡើងវិញបាន ៤៣៩ហិចតា (ខូចខាតទាំងស្រុង ២៣៦ ហិចតា)។ ផ្ទៃដីដែលអាចធ្វើការប្រមូលផលបាននៅរដូវវស្សាក្នុងឆ្នាំ២០១៣ មានចំនួន ១៦៦,៣១៣ ហិចតា ដែលមានការថយចុះចំនួន ២៣៨ហិចតា បើធៀបនឹងផ្ទៃដីស្រូវវស្សាឆ្នាំមុន។ ចំពោះទិន្នផលដែលទទួលបានទូទាំងខេត្តនៅរដូវវស្សាវិញគឺមានការកើនឡើងពី ៤៤១,៣៦០តោន នាឆ្នាំ២០១២ ដល់ ៤៥៣,៣៣៨តោន នាឆ្នាំ២០១៣ ពោលគឺកើនបាន ១១,៩៧៨តោន ឬស្មើនឹង ២.៧១% នេះគឺមកពីទិន្នផលជាមធ្យមក្នុងរដូវវស្សាមានការកើនឡើងចំនួន ០.១តោន/ហិចតា(ទិន្នផលទទួលបាន២.៥៥០-២.៦៥០តោន/ហិចតា) និងនៅរដូវប្រាំងបានអនុវត្តលើផ្ទៃដីចំនួន ២០,៤២២ហិចតា តែត្រូវរងការខូចខាតទាំងស្រុងចំនួន ២២ហិចតា។ ផ្ទៃដីដែលមាននៅសល់អាចប្រមូលផលបានចំនួន២០,៤០០ហិចតាដែលអាចផ្តល់ផលបាន ៨៥,៨៦៤ តោន ពោលគឺថយចុះជាងឆ្នាំមុនចំនួន ១,៦៩១តោន ស្មើនឹង១.៩៣%។ វាបណ្តាលមកផ្ទៃដីនៃការដាំដុះនៅរដូវប្រាំងឆ្នាំ២០១៣ មានការថយចុះដល់ទៅ ៥០៧ហិចតា។ នៅក្នុងឆ្នាំ២០១៣នេះ ស្រូវទាំងពីររដូវនេះប្រមូលបានបរិមាណផលសរុបចំនួន ៥៣៩,២០២តោន ដោយក្នុងមួយហិចតាទទួលបានទិន្នផលជាមធ្យមប្រចាំឆ្នាំ(២០១៣) បាន២.៨៨តោន។ ក្នុងឆ្នាំ២០១៣នេះ ខេត្តស្វាយរៀងក៏មានអង្ករដែលលើសតម្រូវការចំនួន ២១៩,៥៣៤តោន គិតជាស្រូវចំនួន ៣៣៥,២០៩តោន។ បរិមាណផលនេះបើធៀបនឹងឆ្នាំ២០១២ មានការកើនឡើងចំនួន១០,២៨៧តោន ស្មើនឹង១.៩% និងកើនបាន ៩៥,៥២៣តោន ឬស្មើនឹង ២១.៥២% បើធៀបនឹងឆ្នាំ២០០៩។[42]

[42] មន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង,*របាយការណ៍បូកសរុបការងារកសិកម្មប្រចាំឆ្នាំ២០១៣*

ក្រាហ្វិកទី១១៖ បង្ហាញពីផ្ទៃដីបង្កបង្កើនផលស្រូវឆ្នាំ២០០៨-២០១៨




ប្រភព៖ ដកស្រង់ពីរបាយការណ៍បូកសរុបការងារកសិកម្មរបស់មន្ទីរកសិកម្មខេត្តស្វាយរៀងប្រចាំឆ្នាំនីមួយៗពីឆ្នាំ ២០០៨-២០១៨

នៅក្នុងឆ្នាំ២០១៨ នេះផលិតកម្មដំណាំស្រូវអនុវត្តបានលើផ្ទៃដីចំនួន ១៨៩,៩២៧ហិចតា បើធៀបនឹងឆ្នាំ២០០៩ មានការកើនឡើងចំនួន ៩,៣៩៥ហិចតា ស្មើនឹង៥.២០% ហើយបើធៀបនឹង ឆ្នាំ២០១៣វិញ គឺកើនបាន ២,៩៥៦ហិចតា ស្មើនឹង១៥.៨១%។ បើនិយាយពីបរិមាណផលស្រូវវិញ នៅឆ្នាំ២០១៨ គេប្រមូលផលបាន ៥៤៧,៩៨៩តោន ដោយទទួលបានទិន្នផលជាមធ្យមប្រមាណ២.៩តោន/ហិចតា។ បរិមាណផលស្រូវនេះ មានស្រូវរដូវវស្សាមានចំនួន ៤៥៨,៩៩៤ តោន និងស្រូវប្រាំងចំនួន ៨៨,៩៩៥តោន។ សម្រាប់បរិមាណផលស្រូវទូទាំងនេះ បើធៀបនឹងឆ្នាំមុនថយចុះអស់ ១៤,១៥៥តោន គឺថយ ចុះអស់ចំនួន២.៥១%ដោយសារការបង្កបង្កើនផលស្រូវបង្កើនរដូវត្រូវបានកាត់បន្ថយតែ។ បើធៀបនឹង២០០៩កើនបាន ១០៤,៣១០តោន ត្រូវនឹង ២៣.៥១% ហើយកើនបាន ៨,៧៨៧តោន គឺស្មើនឹង ប្រមាណជា ១.៦២%បើធៀបឆ្នាំ២០១៣។[43] (សូមមើលឧបសម្ព័ន្ធទី៧)

[43] មន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង,*របាយការណ៍បូកសរុបការងារកសិកម្មប្រចាំឆ្នាំ២០១៨ ។*

ក្រាហ្វិកទី១២៖ បង្ហាញពីផ្ទៃដីបង្កបង្កើនផលស្រូវឆ្នាំ២០០៨-២០១៨




ប្រភព៖ដកស្រង់ពីរបាយការណ៍បូកសរុបការងារកសិកម្មរបស់មន្ទីរកសិកម្មខេត្តស្វាយរៀងប្រចាំឆ្នាំនីមួយៗពីឆ្នាំ២០០៨-២០១៨

បរិមាណស្រូវឆ្នាំ២០១៨នេះបានប្រមូលផលលើផ្ទៃដី ១៨៨,៣២៣ហិចតាដែលមានការកើនចំនួន ៥៧៩ហិចតា បើធៀបផ្ទៃដីប្រមូលផលឆ្នាំមុន។ តែទោះបីទំហំដីដែលប្រមូលផលធំជាងឆ្នាំមុនពិតមែន ប៉ុន្តែផលស្រូវនៅរដូវវស្សាមានការថយចុះប្រមាណ ១៦,០១៦តោន ស្មើនឹង ៣.៣៧%ដែលបណ្តាលមកពីភាពរាំងស្ងួត។ ចំណែកផ្ទៃដីប្រមូលផលនៅរដូវប្រាំង ២០,៩៥០ហិចតាគឺច្រើនជាងឆ្នាំមុន ៣០១ហិចតាដែលត្រូវនឹង ១.៤៥%នៃផ្ទៃដីប្រមូលផលរដូវប្រាំងឆ្នាំមុន។ ចំពោះតម្រូវការ ស្បៀងអាហារសម្រាប់បរិភោគនៅទូទាំងខេត្តមានចំនួន ៤៧៦,៧៥០តោនអង្ករ ឬស្មើនឹងបរិមាណ ៧៤៤.៩២២តោនបើគិតជាស្រូវ ហើយអង្ករដែលលើសតម្រូវការមានចំនួន ២០៥,៤៣៨តោន។[44]

## ២.៣.២ បសុសត្វនៅក្នុងខេត្ត

នៅឆ្នាំ២០០៩ ការចិញ្ចឹមគោក្របីមានចំនួន ២៨២,០៦៣ក្បាល បើធៀបនឹងឆ្នាំមុនកើនបាន ៨,០៣៥ក្បាល ក្នុងនោះមានគោចំនួន ១៥៨,១៦៨ក្បាល និងក្របីចំនួន ១២៣,៨៩៥ក្បាល។ ចំណែកគោក្របីដែលអាចជាកម្លាំងអូសទាញបានមានចំនួន ១៥០,២៨២ក្បាល ស្មើនឹង ៥.៤១%

[44] មន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង,*របាយការណ៍បូកសរុបការងារកសិកម្មប្រចាំឆ្នាំ២០១៨ ។*

នៃចំនួនគោក្របីសរុប។ ចំពោះការចិញ្ចឹមជ្រូកវិញបានចំនួន ៣២៦,៥៥៦ក្បាល និងសត្វស្លាប (មាន់ទា)មានចំនួនសរុប ១,៤១៥,៧៥៥ក្បាល ក្នុងនោះមាន់មានចំនួន ១,២០៥,៧៥២ក្បាល និង ទាចំនួន ២១០,០០៣ក្បាល។[45] នៅឆ្នាំ២០១៣វិញ ចំនួនគោក្របីសរុប ២៨៤,៩៨៥ក្បាល បើធៀប នឹងឆ្នាំមុនមានការកើនឡើងចំនួន៤,៦៤០ក្បាល ត្រូវជា១.៦៥% បើគិតពីឆ្នាំ២០០៩គឺកើនបាន ២,៩២២ក្បាលប៉ុណ្ណោះ។ ក្នុងនោះចំនួនគោមានការកើនឡើងពី ១៥៨,១៦៨ក្បាល(២០០៩) ដល់ ១៦៤,៧៧៥ក្បាល(២០១៣)គឺកើនបានគោ ៦,៦០៧ក្បាល ដែលស្មើនឹង៤.១៧%។ មួយទៀត សម្រាប់ការចិញ្ចឹមជ្រូកមានការថយចុះពី ៣២៦,៥៥៦ក្បាល(២០០៩) មកដល់ ១៥៦,៩៥៩ក្បាល (២០១៣) គឺថយចុះប្រមាណជា ១៦៩,៥៩៧ក្បាល គិតជាភាគរយគឺថយចុះអស់ ៥១.៩២%បើ ធៀប២០០៩។ ការថយចុះនេះ ដោយសារការនាំចូលសត្វជ្រូកមានជម្ងឺ សេវាថែទាំមិនទាន់អនុវត្ត តាមបច្ចេកទេស ចំណីសត្វឡើងថ្លៃ និងតម្លៃលក់ចេញបានថ្លៃទាប។ ខុសពីចំនួនជ្រូកវិញចំនួននៃ ការចិញ្ចឹមសត្វស្លាបនៅឆ្នាំ២០១៣ មានការកើនឡើងគឺមានចំនួន ១,៥០២,០០៣ក្បាល កើនឡើង បាន ៨៦,២៤៨ក្បាល ស្មើនឹង ៦%បើធៀបនឹងឆ្នាំ២០០៩។[46]

សម្រាប់ឆ្នាំ២០១៨នេះ ផលិតកម្មសត្វសរុបមានចំនួន ២,៧៤៣,៩២២ក្បាលដែលក្នុងនោះ មានគោចំនួន ១៣៧,៨៦៣ក្បាលមានការកើនឡើងចំនួន ១៣,៦៤៧ក្បាលស្មើនឹង ១០.៩៨%ក្របី មានចំនួន ៩៦,២៧៥ក្បាលគឺមានការថយចុះប្រមាណ ១០.៣៩%បើធៀបនឹងឆ្នាំមុន។ ចំនួនគោ នេះបើយើងធ្វើការប្រៀបធៀបទៅឆ្នាំ២០១៣ គឺមានការថយចុះចំនួន ១៦.៣៣% បើគិតចំនួនគោ វិញគឺស្មើ ២៦,៩១២ក្បាល ហើយបើធៀបនឹង១០ឆ្នាំមុនវិញគឺឆ្នាំ២០០៩ បែជាមានការកើនឡើង ដល់ទៅ១៤.០២%។ ចំពោះក្របីវិញ បើយើងធៀបត្រឹមរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះគឺមាន ការថយចុះពី ១២០,២១០ក្បាល(២០១៣) មកត្រឹម ៩៦,២៧៥ក្បាលឆ្នាំ២០១៨នេះ គឺថយចុះ ២៣,៩៣៥ក្បាល ឬ១៩.៩១% ហើយបើពិនិត្យទៅកាល១០ឆ្នាំមុន(ឆ្នាំ២០០៩)គឺថយចុះដល់ទៅ ២៩,៣៧៥ក្បាលគឺស្មើប្រមាណជា ២៣.៣៧%។ ការថយចុះចំនួនសត្វគោក្របីនេះបណ្តាលមកពី ការប្រើប្រាស់ជាកម្លាំងអូសទាញត្រូវបានកាត់បន្ថយ ដោយសារកសិករបានងាកមកប្រើប្រាស់ គ្រឿងយន្តជំនួសវិញ។(សូមមើលឧបសម្ព័ន្ធទី៨)

[45] មន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង,*របាយការណ៍បូកសរុបការងារកសិកម្មប្រចាំឆ្នាំ២០០៩*

[46] មន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង,*របាយការណ៍បូកសរុបការងារកសិកម្មប្រចាំឆ្នាំ២០១៣*

ក្រាហ្វិកទី១៣៖ បង្ហាញពីការចិញ្ចឹមសត្វពីឆ្នាំ២០១៤-២០១៨




| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| គោ | ១៦៦,៤២៨ | ១២៤,៩២២ | ១២២,២៥១ | ១២៤,២១៦ | ១៣៧,៨៦៣ |
| ក្របី | ១២២,៥៥៤ | ១០៩,២៨២ | ១០៥,៨៩២ | ១០៧,៤៤៩ | ៩៦,២៧៥ |
| ជ្រូក | ១៨៦,៦៥៧ | ១៣១,២១៦ | ១៤០,៣៤១ | ១៤៧,៤៧២ | ១៥៣,៥៥៣ |
| មាន់ទា | ១,៥៨៤,៥០២ | ១,៥៧៦,៧០២ | ១,១២៣,០៦២ | ២,៩០១,៣៣៥ | ២,៣៥៦,២៣១ |

ប្រភព៖ដកស្រង់ពីរបាយការណ៍បូកសរុបការងារកសិកម្មរបស់មន្ទីរកសិកម្មខេត្តស្វាយរៀងប្រចាំឆ្នាំនីមួយៗពីឆ្នាំ២០០៨-២០១៨

តែនៅក្នុងឆ្នាំ២០១៨ ចំនួនគោមានការកើនឡើង ដោយហេតុថាកសិករបានប្តូរពីការចិញ្ចឹមប្រើកម្លាំងទៅជាការចិញ្ចឹមដើម្បីពាណិជ្ជកម្មទៅវិញ។ ក្រៅពីការចិញ្ចឹមគោក្របីនៅឆ្នាំ២០១៨ ការចិញ្ចឹមសត្វជ្រូកមានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ។ នៅឆ្នាំ២០១៨ នេះជ្រូកមានចំនួនដល់ទៅ ១៥៣,៥៥៣ក្បាល ដែលមានការកើនចំនួន ៦,០៨១ក្បាល បើធៀបឆ្នាំមុនដែលស្មើនឹងកំណើន៤.១២% ហើយកើនឡើងដល់ទៅចំនួន៥៦.៣៦%បើធៀបជាមួយនឹង១០ឆ្នាំមុន(២០០៩)។ ចំពោះការចិញ្ចឹមបក្សី(មាន់ទា)វិញ គឺមានការកើនឡ្ញងជាបន្តបន្ទាប់នៅឆ្នាំ២០០៩ មានចំនួន ១,៩១៥,៧៥៥ក្បាល ដែលមានការថយចុះជាងឆ្នាំមុនចំនួន ៨៦,២២០ក្បាល ដោយសារតែការចិញ្ចឹមសត្វមាន់បានថយចុះអស់ ៣.១៦%។ ក្នុងឆ្នាំ២០១៨វិញ ការចិញ្ចឹមមាន់ទាមានចំនួន ១៥៨៤,៥០២ក្បាល ដែលនេះកើនឡើងបន្តិចប៉ុណ្ណោះ បើធៀបនឹងឆ្នាំ២០០៩ គឺកើនបាន ១៦៨,៧៤៧ក្បាលស្មើនឹង១១.៩១%។

ក្រាហ្វិកទី១៨ ៖ បង្ហាញពីការចិញ្ចឹមសត្វមាន់ទា ឆ្នាំ២០០៩-២០១៨



ប្រភព៖ទិន្នន័យដកស្រង់ពីរបាយការណ៍បូកសរុបការងារកសិកម្មរបស់មន្ទីរកសិកម្មខេត្តស្វាយរៀងឆ្នាំ ២០០៨-២០១៨

ការចិញ្ចឹមសត្វបក្សីក្នុងឆ្នាំ២០១៨មានចំនួន ២,៣៥៦,២៣១ក្បាល បើធៀបនឹងឆ្នាំមុនគឺមានការថយចុះប្រមាណជា ១៨.៧៨% នេះវាបណ្តាលមកពីជម្ងឺបក្សី។ មួយទៀតបើយើងធៀបនឹងឆ្នាំ ២០១៤ វិញគឺកើនបាន ៧៧១,៧២៩ក្បាលត្រូវជាប្រមាណ ៤៨.៧០% និងកើនបានជាង៦៦% នេះបើធៀបនឹងឆ្នាំ២០០៩។[47]

## ២.៣.៣ ការដាំដុះដំណាំរួមផ្សំ និងដំណាំកសិឧស្សាហកម្ម

ក្រៅពីការធ្វើស្រែចំការកសិករខ្លះក៏បានជ្រើសយកដំណាំរួមផ្សំបន្ថែមទៀតដើម្បីបង្កើននូវជី-វភាពរស់នៅរបស់ខ្លួនឱ្យប្រសើរគឺសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ សហគមន៍ និងផ្គត់ផ្គង់តម្រូវការទីផ្សារក្នុង និងក្រៅខេត្តទៀតផង។ នៅក្នុងចំណុចនេះ យើងសុំលើកយកតែដំណាំរួមផ្សំមួយចំនួនមកបង្ហាញក្នុងនោះមានដូចជាដំណាំដំឡូងជ្វាដំឡូងឈើ ដំឡូងមី ពោត និងអំពៅ អំពីការវិវត្តិរបស់ដំណាំទាំងនេះចន្លោះឆ្នាំ២០១២-២០១៨។ ជាលទ្ធផលនៅឆ្នាំ២០១២ ផ្ទៃដីដាំដុះដំណាំទាំង៥មុខនេះសរុបមានចំនួន ២១,៥៤៥ហិចតាដែលក្នុងនោះមានផ្ទៃដីដាំដុះអំពៅមានចំនួន ៤,៧៧៨ហិចតា ដំឡូងឈើ ១,៥២៩ហិចតា ដំឡូងជ្វា ៥៦២ហិចតា បន្លែចំនួន ២,៤៩៨ហិចតា និងដំឡូងមី

[47] មន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង,*របាយការណ៍បូកសរុបការងារកសិកម្មប្រចាំឆ្នាំ២០១៨*

មានចំនួន ១២,១៦៥ហិចតា និងអំពៅចំនួន ១៣ហិចតា។[48]ការដាំដុះដំណាំរួមផ្សំ និងកសិឧស្សាហកម្មទាំងនេះវាមានការប្រែប្រួលទៅស្ថានភាពថ្លៃទីផ្សារ និងការប្រែប្រួលនៃអាកាសធាតុជាដើម។ ផ្ទៃដីដាំដុះដណាំរួមផ្សំ និងកសិឧស្សាហកម្មសម្រាប់សម្រាប់ឆ្នាំ២០១៦ មានចំនួន ២១,២០៥ហិចតា ថយចុះអស់ចំនួន ៣៥០ហិចតាស្មើនឹង ១.៥%បើធៀបនឹងឆ្នាំ២០១២នេះ ដោយសារការថយចុះនូវទំហំផ្ទៃដីដែលដាំដុះ ដំឡូងឈើ និងដំឡូងមី ប្រមាណជាង ៤,១៦១ហិចតា តែផ្ទៃដីនៃការដាំដុះពោត បន្លែជាដើមមានការកើនឡើង។ តែបើធៀបនឹងឆ្នាំមុនគឺមានការកើនចំនួន ១,៦៣៦ហិចតា ដែលស្មើនឹង ៨.៣៦%។ កំណើននេះដោយសារតែទំហំផ្ទៃដីនៃការដាំដុះដំឡូងឈើ ដំឡូងមីបានកើនឡើងដល់ទៅ ១២.១៩%បើធៀបទៅទំហំផ្ទៃដីដាំដុះឆ្នាំមុន។ បើយើងពិនិត្យមើលពីបរិមាណទិន្នផលវិញនៅឆ្នាំ២០១៦នេះ គឺទទួលបានទិន្នផលសរុបចំនួន ៥៧១,២១៣តោន បើធៀបនឹងឆ្នាំមុនមានការថយចុះអស់ចំនួន ៩,២១២តោន ដោយសារទិន្នផលដែលទទួលបានពីការដាំដុះដំឡូងឈើ ដំឡូងមី និងអំពៅមានការធ្លាក់ចុះ។ តែបើផ្ទឹមជាមួយនឹងឆ្នាំ២០១២ គឺទិន្នផលសរុបកើនឡើង បានប្រមាណជាង២៥ពាន់តោន។ នេះដោយសារទិន្នផលអំពៅបានកើនឡើងដល់ទៅ ៣១.១% ច្រើនជាងទិន្នផលអំពៅឆ្នាំ២០១២។[49]

តារាងទី៤៖ បង្ហាញពីការដាំដុះដំណាំរួមផ្សំនិងកសិ-ឧស្សាហកម្ម

| ប្រភេទដំណាំ/ឆ្នាំ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ដំឡូងឈើ+មី | ១៣,៦៩៤ | ១៧,៥៩៧ | ៧,៩៦៥ | ៨,៤៩៧ | ៩,៥៣៣ | ៦,៧២៤ | ៦,០៨៨ |
| ដំឡូងជ្វា | ៥៦២ | ៥៤៣ | ៤៨០ | ១៥៨ | ១១៣ | ១៣៣ | ១៨៩ |
| បន្លែ | ២,៤៨៩ | ២,៩២៩ | ២,៩៦៩ | ២,៨៤០ | ៣,៣៦៧ | ៣,៥២៩ | ៣,៨៣៧ |
| អំពៅ | ៤,៧៧៨ | ៧,៥៣៥ | ៨,០២១ | ៨,០៧១ | ៨,១៦៦ | ៦,០៩៣ | ៦,៦៧១ |
| ពោត | ១៣ | ១៣ | ១៨ | ៣ | ២៦ | ៤១ | ២១៧ |
| **ផ្ទៃដីសរុប(ហ.ត)** | ២១,៥៤៥ | ២៨,៦១៧ | ១៩,៤៥៣ | ១៩,៥៦៩ | ២១,២០៥ | ១៦,៥២០ | ១៧,០០២ |

ប្រភព៖ ដកស្រង់ពីរបាយការណ៍បូកសរុបការងារកសិកម្មរបស់មន្ទីរកសិកម្មខេត្តស្វាយរៀងប្រចាំឆ្នាំនីមួយៗពីឆ្នាំ ២០១២-២០១៨

ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះឆ្នាំ(២០១៤-២០១៨)ដំណាំរួមផ្សំ និងកសិឧស្សាហកម្មទាំងនេះមានការប្រែប្រួលដោយឥតឈប់ឈរ។ នៅក្នុងឆ្នាំ២០១៤ ទិន្នផលដំណាំមុខនេះថយចុះពី៧៩១,៥៧៣តោន(២០១៣) មកត្រឹមតែ ៥៧១,២៦៦តោន(២០១៤) គឺថយចុះអស់ប្រមាណជាង

[48] មន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង,*របាយការណ៍បូកសរុបការងារកសិកម្មប្រចាំឆ្នាំ២០០៩*

[49] មន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង,*របាយការណ៍បូកសរុបការងារកសិកម្មប្រចាំឆ្នាំ២០១៦*

២២០ពាន់តោនដែលក្នុងនោះគឺអំពៅបានថយចុះដល់ទៅជាង២៨ពាន់តោន ទោះបីជាផ្ទៃដីដាំអំពៅ មានទំហំធំជាង២០១៣ប្រមាណជា៦.៩៥%ក្តី តែភាពរាំងស្ងួតបានធ្វើឱ្យទិន្នផលអំពៅថយចុះប្រមាណជាង១៤.៦៩តោន/ហិចតា បើធៀបនឹងឆ្នាំ២០១៣។[50] តែសម្រាប់ឆ្នាំ២០១៥វិញ មានការកើនឡើងលើសឆ្នាំ២០១៤ដល់ទៅ ៩.១៥៩តោនគិតជាភាគរយ១.៦%។ នៅឆ្នាំ២០១៦វិញ មានការប្រែ ប្រួលថយចុះប្រមាណ៨.៦៩% បើធៀបនឹងឆ្នាំមុន។ ចំណែកឆ្នាំ២០១៨នេះ ផ្ទៃដីនៃការដាំដំណាំរួមផ្សំ និងកសិឧស្សាហកម្មសម្រេចបានលើផ្ទៃដីចំនួន ១៧,០០២ហិចតាដែលកើនលើសឆ្នាំមុនចំនួន ៤៨២ហិចតា ស្មើនឹង២.៩% ហើយថយចុះអស់ជាង ២ពាន់ហិចតាបើធៀបនឹងឆ្នាំ២០១៤។ នេះដោយសារតែទំហំនៃការបង្កបង្កើនផលអំពៅបានធ្លាក់ចុះអស់ ១,៣៥០ហិចតា ដំឡូងឈើថយអស់ ១,៨៧៧ហិចតា និងដំឡូងជ្វាក៏ថយអស់ ២៩១ហិចតាដែរ។ ចំណែកផ្ទៃដីដាំអំពៅ និងពោតបានកើនឡើងចំនួន ១,០៦៧ហិចតា។ ដោយឡែកសម្រាប់បរិមាណទិន្នផលសរុបបានដំណាំទាំងនេះ នៅឆ្នាំ ២០១៨ មានកំណើនជាង៩% ដែលស្មើ ៣៨,៥៣៥តោន បើធៀបនឹងឆ្នាំមុនតែមានការថយចុះចំនួន ប្រមាណជាង ១១០ពាន់តោន ស្មើនឹង ១៩.៣៨% បើធៀបជាមួយនឹងឆ្នាំ២០១៤។ ការធ្លាក់ចុះយ៉ាង ទំហំច្រើននេះដោយសារតែធ្លាក់ចុះថ្លៃដំឡូងមី អំពៅ និងការប្រែប្រួលនៃអាកាសធាតុមានភាពរាំងស្ងួតដែលធ្វើឱ្យខ្វះខាតទឹកសម្រាប់ផ្គត់ផ្គង់ដល់ដំណាំទាំងនេះ។

ក្រាហ្វិកទី១៥៖ ការបង្ហាញពីបរិមាណផលដំណាំរួមផ្សំ និងកសិឧស្សាហកម្មឆ្នាំ២០១២-២០១៨



ប្រភព៖ ទិន្នន័យដកស្រង់ពីរបាយការណ៍បូកសរុបការងារកសិកម្មរបស់មន្ទីរកសិកម្មខេត្តស្វាយរៀងឆ្នាំ ២០១២-២០១៨

[50] មន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង,*របាយការណ៍បូកសរុបការងារកសិកម្មប្រចាំឆ្នាំ២០១៤*

ក្រៅពីនេះក៏នៅមានការបង្កបង្កើនផលដំណាំអចិន្ត្រៃយ៍មួយចំនួនដូចជា ដូង ស្វាយ ស្វាយចន្ទី ខ្នុរហូបផ្លែ ចេក ល្ហុង ឪឡឹក ម្ទេស និងត្នោតមេជាដើមផងដែរ ដើម្បីផ្គត់ផ្គង់គ្រួសារ និងទីផ្សារបន្ថែម។ តួយ៉ាងដូចជាក្នុងឆ្នាំ២០១៨នេះ បានដាំឪឡឹកលើផ្ទៃដី៥០ហិចតាដែលបានផលចំនួន ១,៥០០តោន។[51]

**២.៣.៤ វិស័យជលផល**

**ក.វារីវប្បកម្ម:** វារីវប្បកម្មបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកកាត់បន្ថយការចំណាយគ្រួសារបាន និងចូលរួមលើកកំពស់ជីវភាពប្រជាជន។ ទោះបីជាការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារខ្លះវាតូចតាចតែវាក៏ដើម្បីប្រើប្រាស់ជាម្ហូបអាហារក្នុងគ្រួសារបាន។ មួយវិញទៀតគឺនៅមានការចិញ្ចឹមជាលក្ខណៈសហគមន៍ ដែលមានចំនួនដល់ទៅ ៩៥០ស្រះ បានលែងកូនត្រីចំនួន ១៨០,០០០ក្បាល។ ចំពោះកសិដ្ឋានភ្ញាស់កូនត្រីមានចំនួន ៥កន្លែងសម្រាប់ផលិតពូជត្រី និងបំប៉នពូជត្រីក្នុងនោះមានដូចជា ត្រីឆ្ពិន ត្រីឡាព្យា ត្រីកាបសាមញ្ញ ត្រីប្រា និងត្រីអណ្ដែង។ ការរីកចម្រើននូវវារីវប្បកម្មនៅក្នុងខេត្តពិតជាមានសារសំខាន់ណាស់ ព្រោះថាវាជួយជាម្ហូបអាហារផងអាចជាទំនិញដែលកំពុងមានតម្រូវការលើទីផ្សារទៀតផង។

**ខ.ផលនេសាទ** ការនេសាទ គឺជារបរបន្ទាប់បន្សំរបស់ប្រជាជននៅក្នុងខេត្តបន្ទាប់ពីការធ្វើកសិកម្ម ពិសេសនោះ គឺប្រជាជនដែលរស់នៅតាមតំបន់មាត់ទន្លេ ស្ទឹង បឹងបួរ និងព្រែកជាដើម។ ការនេសាទត្រីក្នុងខេត្តស្វាយរៀង ក្នុងឆ្នាំ២០១៨នេះ ទទួលបានផលនេសាទសរុបចំនួន ១៣៤ តោន ។

**២.៣.៥ ការប្រើប្រាស់គ្រឿងយន្តកសិកម្ម**

គ្រឿងយន្តកសិកម្មជាច្រើនត្រូវបានបង្កើនឡើងដើម្បីជួយសម្រួលដល់ការងារក្នុងផលិកម្ម-សិកម្មរហូតដល់ការកែច្នៃ និងស្តុកទុកផលិតផល។ ជាពិសេសគឺត្រាក់ទ័រកសិកម្មដែលអាចជួយសម្រួលការងារផលិតកម្មបានយ៉ាងឆាប់រហ័ស ចាប់តាំងពីការរៀបចំដីរហូតដល់ការប្រមូលផល។ ក្រៅពីត្រាកទ័រគឺមានម៉ាស៊ីន និងឧបករណ៍កសិកម្មជាច្រើនទៀតដែលបានបង្កើតឡើងដើម្បីជួយសម្រួលដល់ការងារក្នុងកសិដ្ឋានដូចជា ម៉ាស៊ីនបូមទឹក ម៉ាស៊ីនភ្លើង សម្ភារៈរៀបចំដី ធ្វើស្មៅ និងប្រមូលផលជាដើម។ ដោយសារតែវត្តមានរបស់ម៉ាស៊ីនទាំងនេះ ហើយទើបធ្វើឱ្យវិស័យកសិកម្ម

[51] មន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង,*របាយការណ៍បូកសរុបការងារកសិកម្មប្រចាំឆ្នាំ២០១៨*

កាត់បន្ថយការពឹងផ្អែកលើកម្លាំងរបស់មនុស្ស និងសត្វដើម្បីអូសទាញ។[52]

តារាងទី៥៖ បង្ហាញពីចំនួនគ្រឿងយន្តកសិកម្មក្នុងខេត្តឆ្នាំ២០១៥-២០១៨

| ល.រ | ប្រភេទម៉ាស៊ីន/ឆ្នាំ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| ១ | ត្រាក់ទ័រសម្រាប់ភ្ជួរដី | ២,២៩៨ | ២,៧៨១ | ២,៩៩៥ | ៣,៣៩៩ |
| ២ | គោយន្តសម្រាប់ភ្ជួរដី | ១៣,៩៥៩ | ១៤,០៦៩ | ១៤,៨៤៧ | ១៤,៨៤០ |
| ៣ | ម៉ាស៊ីនច្រូតស្រូវ | ២៨៨ | ២៦៩ | ៣២៥ | ២៦៧ |
| ៤ | ម៉ាស៊ីនបោកស្រូវ | ១,៣០៣ | ១,១៥៤ | ៩៦៣ | ៧៦៤ |
| ៥ | ម៉ាស៊ីនច្រូត និងបោកស្រូវ | ៣០៥ | ៣២៥ | ៣៧៧ | ៣៧០ |
| ៦ | ម៉ាស៊ីនកិនស្រូវចល័ត | ៨៣៥ | ៧២៨ | ៦៦២ | ៦២៨ |

ប្រភព៖ដកស្រង់ចេញពីកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៩-២០២១,ទំព័រទី១៦ ,ឯកសារពត៌មានស្ដីពីស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ចឆ្នាំ២០១៩,ទំព័រទី១៣

នៅខេត្តស្វាយរៀងនេះ ចំនួនគ្រឿងយន្តកសិកម្មមាននិន្នាការកកើនឡើងស្ទើតែគ្រប់មុខលើកលែង តែម៉ាស៊ីនកិនស្រូវចល័តបានថយចុះ ដោយសារតែមានវត្តមាននៃម៉ាស៊ីនច្រូត និងបោកស្រូវ(ម៉ាស៊ីនស្វ័យប្រវត្តិ)មកជំនួស និងប្រជាកសិករមួយចំនួនបានលក់ស្រូវក្រោយពេលដែលបានប្រមូលផលភ្លាមៗ។ ក្នុងស្រុកទូទាំងខេត្ត គឺស្រុកកំពង់រោទិ៍ មានចំនួននៃការប្រើប្រាស់ត្រាក់ទ័រភ្ជួរច្រើនជាងគេបើធៀប និងស្រុកផ្សេងទៀតគឺក្នុង ១០០គ្រួសារមានរហូតដល់ទៅ ៨២.៣ គ្រឿង និងស្រុកដែលមានការប្រើប្រាស់តិចជាងគេ គឺក្រុងស្វាយរៀងដែលក្នុង ១០០គ្រួសារមានប្រមាណ៤.៣ គ្រឿងប៉ុណ្ណោះ។[53]

## ២.៥ បញ្ហាប្រឈម

នៅក្នុងរយៈកន្លង៥ឆ្នាំនេះ បញ្ហាប្រឈមនៃការធ្វើផលិតកម្មកសិកម្មនៅក្នុងខេត្តគឺការរងគ្រោះនៃផ្ទៃដីដាំដំណាំ ដោយសារតែការប្រែប្រួលអាកាសធាតុ ដែលបណ្ដាលឱ្យមានភាពរាំងស្ងួត (កង្វះទឹក) និងកង្វះប្រព័ន្ធស្រោចស្រពបញ្ចេញ និងបញ្ចូលទឹកទៅក្នុងស្រែ។ ចំពោះបសុសត្វវិញបញ្ហាជួបប្រទះនោះ គឺការផ្ទុះឡើងនៃជម្ងឺឆ្លងសត្វបានក្លាយជាកង្វល់ដល់កសិករ និងមន្ត្រីជំនាញក្នុងការរកវិធានការដោះស្រាយឱ្យទាន់ពេលវេលា។ លើសពីនេះទៀត បច្ចេកទេសរបស់កសិករក្នុងការដាំដុះនៅមានកម្រិត។ លើសពីនេះទៀតគឺបញ្ហាទុនផលិតកម្មរបស់កសិករក៏នៅមានការ

---

[52] ខូយ ដាវ៉ា,*មូលដ្ឋានគ្រឹះនៃវិស្វកម្មកសិកម្ម* (ស.គ.ស ២០១១),ទំព័រទី៣

[53] មន្ទីរផែនការខេត្តស្វាយរៀង,*ឯកសារពត៌មានស្ដីពីស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ចឆ្នាំ២០១៩*,ទំព័រទី១៤

ខ្វះខាត ចំពោះការប្រើប្រាស់ក្នុងដំណើរការផលិតកម្មកសិផលរបស់ពួកគាត់។ បញ្ហាមួយវិញទៀត ទោះបីជា ចំនួនប្រជាជននៅក្នុងខេត្តមានការកើនឡើងជារៀងរាល់ឆ្នាំក៏ពិតមែនតែពលកម្មបម្រើក្នុងវិស័យកសិកម្មនៅមានការខ្វះខាតនៅឡើយ។ បញ្ហាប្រឈមដែលត្រូវមានការយកចិត្តទុកខានមិនបាន មួយទៀតនោះគឺបញ្ហាទីផ្សារ និងតម្លៃរបស់កសិផល។

## ២.៦ ដំណោះស្រាយ

### ក. បញ្ហាប្រព័ន្ធធារាសាស្ត្រ

ដើម្បីដោះស្រាយបញ្ហាកង្វះខាតទឹក ស្ថាប័នរបស់រដ្ឋ សហការជាមួយនឹងអង្គការអន្តរជាតិបានយកចិត្តទុកដាក់ក្នុងការស្តារឡើងវិញ និងជីកនូវប្រព័ន្ធធារាសាស្ត្រមួយចំនួនក្នុងខេត្តស្វាយរៀងមានដូចជា:

❖ **ប្រព័ន្ធធារាសាស្ត្រជូនទយ** វាមានទីតាំងស្ថិតនៅក្នុងឃុំច្រេស ស្រុកចន្ទ្រា ខេត្តស្វាយរៀង ហើយប្រព័ន្ធធារាសាស្ត្រនេះបានរងការខូចខាត ដោយសារគ្រោះទឹកជំនន់នាពេលកន្លងមក។ ប្រព័ន្ធធារាសាស្ត្រមួយនេះត្រូវបានជួសជុល និងស្តារឡើងវិញកាលពី ថ្ងៃទី២៤ ខែមករា ឆ្នាំ ២០១៧ ដោយមន្ទីរធនធានទឹក និងឧតុនិយមខេត្តស្វាយរៀង។ ការជួសជុលនេះត្រូវបានគេអនុវត្តលើទំនប់មេប្រវែង ១,៣៥០ម៉ែត្រ និងទំនប់សណ្តរប្រវែង ៥,០០០ម៉ែត្រ។ ប្រជាជនប្រមាណជា ២,៥៤៨គ្រួសារ នៅក្នុងឃុំសំឡី ឃុំស្វាយតាយាន ស្រុកកំពង់រោទិ៍ និងឃុំច្រេស ស្រុកចន្ទ្រា ព្រមទាំងសង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង នឹងទទួលបានផលពីប្រព័ន្ធនេះ។ ប្រព័ន្ធនេះមានលទ្ធភាពក្នុងការស្រោចស្រពលើផ្ទៃដីស្រូវប្រាំងប្រមាណជា ១,១៩០ហិចតា និងស្រូវវស្សាប្រមាណជា ២,៤១០ហិចតា។

❖ **ប្រព័ន្ធធារាសាស្ត្រកីចក** មានតួនាទីសំខាន់ខ្លាំងណាស់ក្នុងការប្រមូលទឹកពីទន្លេតូច ស្ទឹងកំពង់ត្រាច និងទឹកភ្លៀងពីតំបន់ខ្ពង់រាបខេត្តកំពង់ចាម ព្រៃវែង និងស្វាយរៀង។ ប្រព័ន្ធមួយនេះនឹងប្រែក្លាយតំបន់រាំងស្ងួតហួតហែងឱ្យប្រែក្លាយទៅជាតំបន់បៃតង ដោយសារតែវាមានសក្តានុពលក្នុងការផ្តល់ទឹកសម្រាប់ការស្រោចស្រពលើផ្ទៃដីប្រមាណជា ៥០,០០០ហិចតា នៅក្នុងក្រុងស្វាយរៀង ស្រុករំដួល ស្វាយជ្រំ ស្វាយទាប កំពង់រោទិ៍ និងស្រុករមាសហែក។ ប្រព័ន្ធធារាសាស្ត្រមួយនេះត្រូវបានផ្តើមបើកការដ្ឋានសាងសង់កាល ដោយក្រសួងធនធានទឹក និងឧតុនិយម កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១១ ហើយនឹងបញ្ចប់នៅចុងឆ្នាំ២០១៧ ដែលមានទីតាំងស្ថិតនៅក្នុងស្រុករមាសហែក ស្រុករំដួល ស្រុកស្វាយជ្រំ ស្រុកស្វាយទាប ស្រុកកំពង់រោទិ៍ និងក្រុងស្វាយរៀងក្នុងខេត្តស្វាយរៀង។

❖ **ការស្តារប្រឡាយមេស្វាយជ្រំ** ដែលមានប្រវែងប្រមាណ ៣,១០០ម៉ែត្រដែលស្ថិតនៅក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ ប្រឡាយមេនេះ មានតួនាទីសំខាន់ខ្លាំងណាស់ក្នុងការនាំទឹកពីអាងជូនសតាមរយៈប្រឡាយមេ ៧មករាដើម្បីបែងចែកទៅប្រឡាយរងនានាក្នុងស្រោចស្រពលើផ្ទៃដីកសិកម្មប្រមាណជា ១,០០០ហិចតាដែលស្ថិតនៅក្នុង ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។

**ខ.បសុព្យាបាល**

បញ្ហាសុខភាពសត្វ គឺជារឿងដែលសំខាន់ដែលម្ចាស់របស់សត្វផ្ទាល់ក៏ដូចជាអាជ្ញាធរពាក់ព័ន្ធបានយកចិត្តទុកដាក់យ៉ាងខ្លាំងតាមរយៈការចុះចាក់វ៉ាក់សាំងបង្ការជម្ងឺទុកជាមុន។ បើមិនដូច្នេះទេ នៅពេលដែលជម្ងឺមួយចំនួនដូចជា សារទឹក អ៊ុតក្តាម ប៉េស្ត ញូវកាស អាសន្នរោគជាដើមបានកើតឡើងលើសត្វហើយនោះវានឹងបណ្តាលឱ្យខាត់បង់ពេលវេលា និងថវិកាក្នុងការព្យាបាលសត្វដែលឈឺ។ មិនតែប៉ុណ្ណោះទេវាអាចឆ្លងដល់មនុស្ស និងបណ្តាលឱ្យមានគ្រោះថ្នាក់រហូតដល់បាត់បង់អាយុជីវិតទៀតក៏មាន។ ជាការឆ្លើយតបនឹងបញ្ហានេះមន្ត្រីថ្នាក់មូលដ្ឋាន ក្រោមការចង្អុលបង្ហាញពីមន្ទីរបានចុះចាក់វ៉ាក់សាំង គោក្របី ជ្រូក និងសត្វស្លាប់ផងដែរ។

**គ. អភិរក្ស និងការពារជលផល**

ខេត្តស្វាយរៀងមានតំបន់អភិរក្សចំនួន ៩កន្លែងដែលមានទីតាំងស្ថិតនៅក្នុងទន្លេ **វ៉ៃគោ**។ ចំពោះអភិរក្សកូនត្រី មន្ទីរបានប្រារព្វពិធីមច្ឆទិវាចំនួន ២លើកដោយបានប្រលែងកូនត្រីចំនួន ១១០,០០០ក្បាល ហើយបានផ្សព្វផ្សាយពង្រឹងការគ្រប់គ្រងតំបន់ជម្រកត្រី និងអភិរក្សពូជត្រីបាន ២៩កន្លែង។ ការពារវិស័យជលផលវិញមន្ត្រីរដ្ឋបាលជលផលបានសហការជាមួយនឹងអាជ្ញាធរមូលដ្ឋានមានសមត្ថកិច្ចបានចុះបង្ក្រាប មងរាយនៅក្នុងតំបន់អភិរក្សទន្លេវ៉ៃគោចំនួន ២២លើក និងដកហូតបានមងរាយចំនួន ១,៤១៧ម៉ែត្រ ហើយត្រូវបានបំផ្លាញចោលនៅនឹងកន្លែង។ ក្រៅពីនេះបានចុះបង្ក្រាបបទល្មើសនេសាទផ្សេងទៀតបាន ១០៥ករណី រឹបអូសបានសម្ភារៈមួយចំនួនដូចជា លូស្បៃមុង ២៤៥មាត់ របាំងស្បៃមុង ២,៨៨៥ម៉ែត្រ បង្គោលឬស្សី ១,៩៥៣ដើម ដកហូតអាគុយឆក់ ៧គ្រឿង អំភ្លីឆក់ត្រី និងដៃឆក់ ១៦គូ។

## ២.៧ ទិសដៅសម្រាប់អាណត្តិ ២០១៩

១. ជម្រុញផលិតកម្មដំណាំស្រូវប្រចាំឆ្នាំ២០១៩-២០២០លើផែនការ ១៩៩,០០០ហ.ត(ស្រូវវស្សា ១៦៧,៥០០ហ.ត)។

២. ជម្រុញការអនុវត្តដាំដំណាំរួមផ្សំ កសិ-ឧស្សាហកម្មរដូវវស្សា២០១៩ ឱ្យបានគ្រប់ផែន

ការ ២០,៦០០ហ.ត។

៣. ជម្រុញការថែទាំដំណាំស្រូវដូចជា ជម្រះស្មៅ ថែទាំទឹក ដាក់ជីគីមី និងជីធម្មជាតិ ហើយជម្រុញការប្រមូលផលស្រូវស្រាល ស្រូវកណ្តាល និងអង្កេតទិន្នផលឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

៤. ជម្រុញការអនុវត្តការបង្កបង្កើនផលស្រូវប្រដេញទឹក និងប្រាំងឆ្នាំ២០១៩-២០២០លើផែនការ ២០,៥០០ហ.ត.

៥. ជម្រុញការអនុវត្តដាំដំណាំរួមផ្សំ កសិឧស្សាហកម្មរដូវប្រាំង២០១៩-២០២០ឱ្យគ្រប់តាមផែនការ។

៦. ជម្រុញការចិញ្ចឹមសត្វ និងធ្វើវ៉ាក់សត្វឱ្យបានផុសផុលគ្រប់គ្រួសារ។

៧. ពង្រឹងយន្តការតាមដានគ្រប់គ្រងចរាចរសម្ភារកសិកម្ម និងចលនាសត្វទប់ស្កាត់ការធ្វើចរាចរខុសច្បាប់។

៨. ជម្រុញគ្រួសារ និងសហគមន៍កសិករក្នុងការបណ្តុះកូនឈើ ព្រមទាំងដាំដើមឈើក្នុងសហគមន៍ឱ្យបានទូលំទូលាយ។

៩. ពង្រឹងសមត្ថភាពសហគមន៍ស្រះជម្រកត្រីទាំង ២៨សហគមន៍ និងពង្រឹងការងារអភិរក្សពូជត្រីធម្មជាតិទាំង ៩កន្លែង ហើយនឹងចលនាការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារឱ្យបានច្រើនបន្ថែម។

១០. បន្តកិច្ចសហការជាមួយអាជ្ញាធរដែនដី សមត្ថកិច្ចពាក់ព័ន្ធដើម្បីចុះផ្សព្វផ្សាយច្បាប់ព្រៃឈើ ជលផល និងបន្តកិច្ចខិតខំក្នុងការបង្ក្រាបបទល្មើសធនធានធម្មជាតិឱ្យមានប្រសិទ្ធភាព។

១១. ត្រៀមលក្ខណៈធ្វើអន្តរាគមន៍ទាន់ពេលវេលាក្នុងករណីចាំបាច់។

១២. តាមដាន និងសម្របសម្រួលទីផ្សារកសិផល។

១៣. ពង្រីក និងពង្រឹងការកិច្ចសហប្រតិបត្តការជាមួយអង្គការដៃគូអភិវឌ្ឍ និងផ្នែកឯកជន។

១៤. គ្រប់គ្រង និងប្រើប្រាស់មន្ត្រីរាជការឱ្យបំពេញការងារបានល្អ និងប្រកបដោយប្រសិទ្ធ-ភាពខ្ពស់។

# ជំពូកទី៣

# ការវិភាគលើលទ្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៣
# ការវិភាគលើលទ្ធផលនៃការស្រាវជ្រាវ

នៅក្នុងជំពូកនេះ គឺជាការបកស្រាយលទ្ធផល ហើយក៏ជាស្នូលនៃការស្រាវជ្រាវផងដែរ យើងខ្ញុំ នឹងធ្វើការវិភាគពីចំណុចសំខាន់ៗនៃការអភិវឌ្ឍវិស័យកសិកម្មក្នុងខេត្តស្វាយរៀងដែលកំពុងកើតមាននាពេលបច្ចុប្បន្ននេះ និងស្វែងរកដំណោះស្រាយសមស្របមួយសម្រាប់បញ្ហាទាំងអស់នោះសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ម្យ៉ាងវិញទៀត យើងខ្ញុំនឹងធ្វើការព្យាករណ៍លើអនុវិស័យនៃវិស័យកសិកម្មសំខាន់ៗមួយចំនួន ដែលមានសក្តានុពលក្នុងខេត្ត។

## ៣.១ ការវិភាគលើទិន្នន័យផលិតកម្មកសិកម្មដល់ឆ្នាំ ២០២៣

### ៣.១.១ ការព្យាករណ៍លើការអនុវត្តផលិតកម្មដំណាំស្រូវ

នៅក្នុងខេត្តស្វាយរៀងដំណាំស្រូវជាដំណាំមួយប្រភេទ ដែលប្រជាកសិករនៅក្នុងខេត្តមួយនេះបានធ្វើជាសំខាន់ ហើយវិស័យនេះបានកែប្រែកម្រិតជីវភាពរស់នៅរបស់ប្រជាកសិករឱ្យកាន់តែប្រសើរឡើងផងដែរ។ ដោយសារតែវិស័យនេះបានចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋបានច្រើន និងការយកចិត្តទុកដាក់របស់មន្ទីរកសិកម្មបាននាំឱ្យផ្ទៃដីនៃការដាំដំណាំស្រូវក្នុងឆ្នាំ២០០៨មានប្រមាណតែ ១៧៥,២៤១ ហិកតា និងបានកើនឡើងច្រើននៅក្នុងឆ្នាំ ២០១៨ រហូតដល់ ១៨៩,៩២៧ហិចតា។ ចំពោះទិន្នផល ស្រូវវិញក៏មានការកើនឡើងដែរគឺពី ៤១៨,១៤១តោន នៅក្នុងឆ្នាំ២០០៨ មានការកើនឡើងច្រើន រហូតដល់ ៥៤៧,៩៨៩ តោននៅក្នុងឆ្នាំ២០១៨។

ក្រាហ្វិកទី១៦៖ បង្ហាញពីទិន្នផលស្រូវ និងផ្ទៃដីដាំដុះ



តាមរយៈក្រាហ្វិក នាំឱ្យយើងអាចព្យាករណ៍ពីទំហំផ្ទៃដីដាំដុះ និងទិន្នផលស្រូវតាមរយៈ Time Series (សូមមើលឧបសម្ព័ន្ធទី៩)

តារាងទី៦ ៖ ការព្យាករណ៍ពីផ្ទៃដីដាំដុះ និងបរិមាណផលស្រូវរយៈពេល៥ឆ្នាំដូចខាងក្រោម

| ឆ្នាំ | ២០១៨ | ២០១៩ (ប៉ាន់ស្មាន) | ២០២០ (ប៉ាន់ស្មាន) | ២០២១ (ប៉ាន់ស្មាន) | ២០២២ (ប៉ាន់ស្មាន) | ២០២៣ (ប៉ាន់ស្មាន) |
|---|---|---|---|---|---|---|
| ផ្ទៃដីដាំដុះ (ហ.ត) | ១៨៩,៩២៧ | ១៩២,១៨៧.៥៣ | ១៩៣,២៤៧.៦៩ | ១៩៤,៣០៧.៨៥ | ១៩៥,៣៦៨.០២ | ១៩៦,៤២៨.១៨ |
| បរិមាណ ផលស្រូវ (តោន) | ៥៩៧,៩៨៩ | ៥៩២,៩៤២.៩២ | ៦០៦,២១៣.៨៥ | ៦១៩,៤៨៤.៧៧ | ៦៣២,៧៥៥.៧ | ៦៤៦,០២៦.៦៣ |

យោងតាមរយៈតារាងខាងលើនេះ យើងអាចនិយាយបានថា បរិមាណស្រូវមានការកើនឡើងនៅក្នុងឆ្នាំ២០១៨ ទិន្នផលស្រូវមានត្រឹមតែ ៥៩៧,៩៨៩តោន តាមការប៉ាន់ស្មាន បរិមាណផលស្រូវក្នុងរយៈពេល៥ឆ្នាំខាងមុខនឹងមានការកើនឡើងដល់ទៅ ៦៤៦,០២៦.៦៣តោន ដោយទទួលបានទិន្នផលជាមធ្យមប្រមាណជា ៣.២៨តោន/ហិចតា នៅក្នុងឆ្នាំ២០២៣ខាងមុខនេះ។ ការកើនឡើងនូវបរិមាណផលស្រូវនេះ អាចមកពីកត្តារួមផ្សំជាច្រើនដូចជា ការប្រើប្រាស់ជី ការប្រើប្រាស់ពូជ ការប្រើប្រាស់គ្រឿងយន្ត ហើយពិសេសទៅទៀត គឺតាមរយៈការប៉ាន់ស្មាននៅក្នុងឆ្នាំ ២០២៣ ការប្រើប្រាស់ផ្ទៃដីនឹងមានការកើនឡើងដល់ ១៩៦,៤៨២.១៨ហិចតា។

### ៣.១.២ ការព្យាករណ៍ទិន្នផលសត្វគោ

វិស័យកសិកម្មក្នុងការចិញ្ចឹមសត្វគោនៅក្នុងខេត្តស្វាយរៀង យើងឃើញថា មានការកើនឡើងពី ១២៤,៧៩៣ក្បាល ក្នុងឆ្នាំ២០០៨ រហូតដល់ ១៦៦,៤២៨ក្បាល ក្នុងឆ្នាំ២០១៤ ហើយការកើនឡើងនេះ គឺអាចមកពីកសិករបានប្តូរពីការចិញ្ចឹមគោជាលក្ខណៈគ្រួសារសម្រាប់ប្រើប្រាស់ជាកម្លាំងអូសទាញ មកជាការចិញ្ចឹមបែបពាណិជ្ជកម្មវិញ។ ប៉ុន្តែការចិញ្ចឹមសត្វគោមានការធ្លាក់ចុះវិញមកត្រឹម ១២៤,៩២២ក្បាល ក្នុងឆ្នាំ២០១៥ និង១២២,២៥១ក្បាល ក្នុងឆ្នាំ២០១៦ ការធ្លាក់ចុះនូវចំនួនសត្វគោនេះ គឺអាចមកពីការនាំចូលនូវសត្វគោពីប្រទេសក្រៅ ដែលមានតម្លៃថោកជាងគោនៅក្នុងស្រុក។ យើងឃើញថា ចំនួនសត្វគោមានការកើនឡើងមកវិញប្រមាណជា ១៣៧,៨៦៣ក្បាល នៅក្នុងឆ្នាំ២០១៨។

ក្រាហ្វិកទី១៧៖ បង្ហាញពីទិន្នផលសត្វគោ




តាមរយៈក្រាហ្វិក នាំឱ្យយើងអាចព្យាករណ៍ពីចំនួនសត្វគោតាមរយៈ Time Series។ (សូមមើលឧបសម្ព័ន្ធទី១០)

តារាងទី៧៖ការព្យាករណ៍ពីទិន្នផលសត្វគោ(គិតជាក្បាល)រយៈពេល៥ឆ្នាំខាងមុខដូចខាងក្រោម

| ឆ្នាំ | ២០១៨ | ២០១៩ (ប៉ាន់ស្មាន) | ២០២០ (ប៉ាន់ស្មាន) | ២០២១ (ប៉ាន់ស្មាន) | ២០២២ (ប៉ាន់ស្មាន) | ២០២៣ (ប៉ាន់ស្មាន) |
|---|---|---|---|---|---|---|
| សត្វគោ | ១៣៧,៨៦៣ | ១៣២,៣៣២ | ១៣០,១១៥ | ១២៧,៨៩៧ | ១២៥,៦៧៩ | ១២៣,៤៦២ |

តាមរយៈតារាងខាងលើ បានបង្ហាញថាពីការប៉ាន់ស្មាននូវចំនួនសត្វគោក្នុងរយៈពេល ៥ឆ្នាំខាងមុខនឹងមានការប្រែប្រួលយ៉ាងខ្លាំង គឺសត្វគោមាន ១៣៧,៨៦៣ក្បាល នៅក្នុង២០១៨ ហើយ ៥ ឆ្នាំខាងមុខនឹងមានការថយចុះមកត្រឹមប្រមាណ ១២៣,៤៦២ក្បាលប៉ុណ្ណោះ ក្នុងឆ្នាំ២០២៣។ ការថយចុះនេះអាចមកពីការនាំចូលសត្វគោមានតម្លៃថោកជាង ឬក៏ប្រជាកសិករប្តូរពីការប្រើប្រាស់គោជាកម្លាំងអូសទាញ ដោយជំនួសដោយគ្រឿងយន្ត និងការខ្វះខាតអ្នកវិនិយោគខាងកសិដ្ឋានចិញ្ចឹមគោ។

### ៣.១.៣ ការព្យាករណ៍ទិន្នផលសត្វក្របី

ការចិញ្ចឹមសត្វក្របីនៅក្នុងខេត្តស្វាយរៀង យើងកត់សម្គាល់ឃើញថាក្នុងរយៈពេល១០ឆ្នាំនេះមានការថយចុះជាលំដាប់ ពីចំនួន១៣០,៤៣០ក្បាល នៅក្នុងឆ្នាំ២០០៨ មកនៅត្រឹម៩៦,២៧៥

ក្បាលក្នុងឆ្នាំ២០១៨។ ហើយការធ្លាក់ចុះនេះ អាចបណ្តាលមកពីតម្រូវការសត្វក្របីពុំសូវមានតម្រូវការទាំងជាកម្លាំងអូសទាញ ទាំងសាច់របស់វា និងការចិញ្ចឹមពិបាកក្នុងការរកចំណីឱ្យក្របីស៊ីជាអាហារ។

ក្រាហ្វិកទី១៨៖ បង្ហាញពីទិន្នផលសត្វក្របី




តាមរយៈក្រាហ្វិក នាំឱ្យយើងអាចព្យាករណ៍ពីចំនួនសត្វក្របីតាមរយៈ Time Series។(សូមមើលឧបសម្ព័ន្ធទី១០)

តារាង៨៖ ការព្យាករណ៍ពីទិន្នផលសត្វក្របី(គិតជាក្បាល)រយៈពេល៥ឆ្នាំខាងមុខដូចខាងក្រោម

| ឆ្នាំ | ២០១៨ | ២០១៩ (ប៉ាន់ស្មាន) | ២០២០ (ប៉ាន់ស្មាន) | ២០២១ (ប៉ាន់ | ២០២២ (ប៉ាន់ស្មាន) | ២០២៣ (ប៉ាន់ស្មាន) |
|---|---|---|---|---|---|---|
| សត្វក្របី | ៩៦,២៧៥ | ៩៩,៨០១ | ៩៧,១០៥ | ៩៤,៤០៩ | ៩១,៧១២ | ៨៩,០១៦ |

យោងតាមរយៈតារាងខាងលើនេះ បានបង្ហាញថា ចំនួនសត្វក្របីមានប្រមាណ ៩៦,២៧៥ ក្បាលក្នុងឆ្នាំ២០១៨ ហើយចំនួននេះនឹងមានការកើនឡើងវិញ បើតាមការប៉ាន់ស្មានក្នុងឆ្នាំ២០១៩ ប្រមាណជា ៩៩,៨០១ក្បាល ហើយចំនួនប៉ានស្មាននេះនឹងមានការថយចុះជាលំដាប់ក្នុងរយៈពេល ៥ឆ្នាំខាងមុខនេះ គឺមកនៅត្រឹម ៨៩,០១៦ ក្នុងឆ្នាំ២០២៣។

### ៣.១.៤ ការព្យាករណ៍ទិន្នផលសត្វជ្រូក

ក្នុងរយៈពេល១០ឆ្នាំនេះ យើងសង្កេតឃើញថា ការចិញ្ចឹមសត្វជ្រូកមានការថយចុះយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ គឺក្នុងឆ្នាំ២០០៨ ខេត្តស្វាយរៀងមានជ្រូកប្រមាណជា ៣៥១,៨៥១ក្បាល ហើយចំនួននេះបានថយចុះមកត្រឹម ១៥៣,៥៥៣ក្បាល នៅក្នុងឆ្នាំ២០១៨។ ការចិញ្ចឹមនេះមាន

ការថយចុះគឺអាចមកពីការនាំចូលនូវសត្វជ្រូកពីប្រទេសជិតខាង ដែលមានតម្លៃធូរថ្លៃជាងជ្រូកចិញ្ចឹមក្នុងស្រុក ដោយខ្វះខាតបច្ចេកទេសគ្រប់គ្រាន់ ការប្រើប្រាស់ថ្លៃដើមអស់ច្រើន ពិសេសជាងនេះទៅទៀតគឺពុំមានអ្នកវិនិយោគក្នុងការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មសម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងក្រៅស្រុក។

ក្រាហ្វិកទី១៩ ៖ បង្ហាញពីទិន្នផលការចិញ្ចឹមសត្វជ្រូក




តាមរយៈក្រាហ្វិកនាំឱ្យយើងអាចព្យាករណ៍ពីចំនួនសត្វជ្រូកតាមរយៈTime Series។ (សូមមើលឧបសម្ព័ន្ធទី១០)

តារាងទី៩៖ការព្យាករណ៍ពីទិន្នផលសត្វជ្រូក(គិតជាក្បាល) រយៈពេល៥ឆ្នាំខាងមុខដូចខាងក្រោម

| ឆ្នាំ | ២០១៨ | ២០១៩ (ប៉ាន់ស្មាន) | ២០២០ (ប៉ាន់ស្មាន) | ២០២១ (ប៉ាន់ស្មាន) | ២០២២ (ប៉ាន់ស្មាន) | ២០២៣ (ប៉ាន់ស្មាន) |
|---|---|---|---|---|---|---|
| សត្វជ្រូក | ១៥៣,៥៥៣ | ៩០,៨១៥ | ៧៤,៦៨០ | ៥៨,៥៤៦ | ៤២,៤១១ | ២៦,២៧៧ |

តាមរយៈតារាងខាងលើនេះ បានបង្ហាញពីការព្យាករណ៍នូវចំនួនសត្វជ្រូកក្នុងរយៈពេល៥ឆ្នាំខាងមុខ ដោយសារតែក្នុងឆ្នាំ២០១៨ មានសត្វជ្រូកប្រមាណជា ១៥៣,៥៥៣ក្បាល ប៉ុន្តែតាមរយៈតារាងប៉ាន់ស្មានបានបង្ហាញពីការថយចុះជាលំដាប់មកនៅត្រឹម ២៦,២៧៧ក្បាល

ប៉ុណ្ណោះក្នុង ឆ្នាំ២០២៣ខាងមុខនេះ។ ហើយចំនួននេះនឹងនៅតែបន្តថយចុះទៀត បើមិនមានវិធានការក្នុងការលើកកម្ពស់ដល់ការចិញ្ចឹមសត្វជ្រូកនិងវិធីដោះស្រាយនូវបញ្ហានេះឱ្យបានត្រឹមត្រូវនោះទេ។

### ៣.១.៥ ការព្យាករណ៍ទិន្នផលសត្វមាន់ទា

ការចិញ្ចឹមសត្វមាន់ទាក្នុងខេត្តស្វាយរៀង យើងសង្កេតឃើញថាមានការឡើងចុះទៅតាមឆ្នាំនីមួយៗក្នុងរយៈពេល១០ឆ្នាំនេះគឺនៅក្នុងឆ្នាំ២០០៨ សត្វមាន់ទាមានប្រមាណ១,៥០១,៩៧៥ក្បាល ហើយក្នុងឆ្នាំ២០១៣ចុះមកត្រឹម១,១១៦,៧០២ក្បាល។ ក្នុងឆ្នាំ២០១៧ ចំនួនមាន់ទាមានការកើនឡើងយ៉ាងខ្លាំងគឺមានចំនួនប្រមាណជា ២,៩០១,៣៣៥ក្បាល ហើយចុះមកវិញនៅត្រឹមប្រមាណជា ២,៣៥៦,២៣១ក្បាល។

ក្រាហ្វិកទី២០៖ បង្ហាញពីទិន្នផលសត្វមាន់ទា




តាមរយៈក្រាហ្វិក នាំឱ្យយើងអាចព្យាករណ៍ពីចំនួនសត្វមាន់ទាតាមរយៈ Time Series។ (សូមមើលឧបសម្ព័ន្ធទី១១)

តារាងទី១០៖ ការព្យាករណ៍ពីទិន្នផលសត្វមាន់ទា(គិតជាក្បាល)រយៈពេល៥ឆ្នាំខាងមុខដូចខាងក្រោម

| ឆ្នាំ | ២០១៨ | ២០១៩ (ប៉ាន់ស្មាន) | ២០២០ (ប៉ាន់ស្មាន) | ២០២១ (ប៉ាន់ស្មាន) | ២០២២ (ប៉ាន់ស្មាន) | ២០២៣ (ប៉ាន់ស្មាន) |
|---|---|---|---|---|---|---|
| សត្វមាន់ទា | ២,៣៥៦,២៣១ | ២,១០៦,៣៦៣ | ២,១៩៣,៦៧០ | ២,២៨០,៩៧៨ | ២,៣៦៨,២៨៥ | ២,៤៥៥,៥៩២ |

តាមរយៈតារាងខាងលើនេះ វាបានបង្ហាញពីការព្យាករណ៍នូវចំនួនសត្វមាន់ទាក្នុងរយៈ៥ឆ្នាំ ខាងមុននេះ គឺនៅក្នុងឆ្នាំ២០១៨ ក្នុងខេត្តនេះមានសត្វមាន់ទាប្រមាណជា ២,៣៥៦,២៣១ ក្បាល ហើយចំពោះការប៉ាន់ស្មានសត្វមាន់ទានឹងមានការកើនឡើងវិញរហូតដល់ចំនួន ២,៤៥៥,៥៩២ ក្បាល នៅក្នុងឆ្នាំ២០២៣ខាងមុខនេះ។ ការកើនឡើងនេះ គឺអាចបណ្តាលមកពីប្រជាកសិករមានការយល់ដឹងច្រើនពីរបៀបចិញ្ចឹម និងវិធីទប់ស្កាត់ការផ្ទុះឡើងនៃជម្ងឺសត្វដែលបណ្តាលឱ្យប៉ះពាល់ដល់ការចិញ្ចឹមសត្វរបស់ប្រជាកសិករយើង។

### ៣.១.៦ ការព្យាករណ៍ផ្ទៃដីដាំដុះសរុប និងទិន្នផលដំណាំផ្សេងៗ

ខេត្តស្វាយរៀង គឺមួយដែលមានដំណាំរួមផ្សំមួយចំនួន ក្រៅពីដំណាំស្រូវមានដូចជា ដំឡូងឈើ ដំឡូងមី ដំឡូងជ្វា បន្លែ អំពៅ ពោត ជាដើម។ តាមរយៈក្រាហ្វិកខាងក្រោមបានបង្ហាញឱ្យឃើញថា ផ្ទៃដីដំដុះផ្សេងមានការកើនឡើង និងធ្លាក់ចុះទៅតាមឆ្នាំនីមួយៗ គឺនៅក្នុងឆ្នាំ២០១២ ផ្ទៃដីដាំដុះសរុបមានប្រមាណ ២១,៥៤៥ហិចតា ហើយមានការកើនឡើងក្នុងឆ្នាំ២០១៣ ដល់ប្រមាណជា ២៨,៦១៧ហិចតា ប៉ុន្តែផ្ទៃដីនេះមានការធ្លាក់ចុះវិញនៅឆ្នាំ២០១៨ នៅត្រឹមតែប្រមាណជា ១៧,០០២ ហិចតា។

ក្រាហ្វិកទី២១៖ បង្ហាញពីផ្ទៃដីសរុប និងទិន្នផលសរុបនៃដំណាំផ្សេងៗ




តាមរយៈក្រាហ្វិក នាំឱ្យយើងអាចព្យាករណ៍ពីផ្ទៃដីដាំដុះសរុប និងទិន្នផលដំណាំផ្សេងៗ តាមរយៈ Time Series។ (សូមមើលឧបសម្ព័ន្ធទី១២)

តារាងទី១១ ៖ ការព្យាករណ៍ពីផ្ទៃដីសរុប និងទិន្នផលដំណាំផ្សេងៗរយៈពេល៥ឆ្នាំខាងមុខ ដូចខាងក្រោម

| ឆ្នាំ | ២០១៨ | ២០១៩ (ប៉ាន់ស្មាន) | ២០២០ (ប៉ាន់ស្មាន) | ២០២១ (ប៉ាន់ស្មាន) | ២០២២ (ប៉ាន់ស្មាន) | ២០២៣ (ប៉ាន់ស្មាន) |
|---|---|---|---|---|---|---|
| ផ្ទៃដីសរុប (ហ.ត) | ១៧,០០២ | ១៥,៤០៥.៧១ | ១៤,១១៧.៥០ | ១២,៨២៩.២១ | ១១,៥៤០.៩៦ | ១០,២៥២.៧១ |
| ទិន្នផល (តោន) | ៤៦០,៥២៦ | ៤២១,១១៨.៤ | ៣៨៥,៥៨៥.២ | ៣៥០,០៥២.១ | ៣១៤,៥១៩ | ២៧៨,៩៨៥.៨ |

## ៣.២ ការសិក្សាលើបញ្ហាប្រឈមរបស់វិស័យកសិកម្មក្នុងខេត្ត

នៅក្នុងដំណើរការផលិតកម្មកសិកម្ម តែងតែមានបញ្ហារាំងស្ទះផ្សេងៗដែលមកបង្អាក់ដល់ការរីកចម្រើនវិស័យនេះ។ ការលំបាកទាំងនោះគ្រាន់តែមានទម្រង់ និងរូបភាពផ្សេងៗគ្នាទៅតាមប្រភេទដំណាំសត្វ ឬអនុវិស័យផ្សេងៗគ្នាប៉ុណ្ណោះ។ ការស្វែងយល់ពីបញ្ហាប្រឈម វាជាគន្លឹះដ៏សំខាន់ក្នុងការរៀបចំយុទ្ធសាស្ត្រដើម្បីការពារ ទប់ស្កាត់ និងដោះស្រាយបញ្ហាដែលកើតមាន។ បញ្ហាសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មនៅខេត្តស្វាយរៀងមិនខុសពីខេត្តដទៃប៉ុន្មាននោះទេ ក្នុង

នោះមានដូចជា បញ្ហាកង្វះប្រព័ន្ធធារាសាស្ត្រ ទឹកជំនន់ គ្រោះរាំងស្ងួត គុណភាពដី សត្វចង្រៃ ជម្ងឺរុក្ខជាតិ ជម្ងឺសត្វ និងបញ្ហាពលកម្មជាដើម។

សព្វថ្ងៃនេះ ការធ្វើកសិកម្មនៅក្នុងខេត្តនៅតែពឹងផ្អែកលើធម្មជាតិពោល គឺនៅតែធ្វើស្រែប្រវាស់មេឃដែលការធ្វើស្រែដាំដុះដំណាំភាគច្រើនមានសកម្មភាពនៅតែរដូវវស្សាដែលមានភ្លៀងធ្លាក់។ នៅរដូវវស្សាឆ្នាំខ្លះទឹកនៅតំបន់មួយចំនួនមានច្រើនលើសតម្រូវការរហូតបង្កជាទឹកជំនន់ធ្វើឱ្យជន់លិចទៀតផង។ ខណៈនៅរដូវប្រាំងដីប្រែបែកក្រហែង ដំណាំខ្លះស្រពោនស្វិត ព្រោះមិនមានទឹកគ្រប់គ្រាន់។ បញ្ហាដោយសារតែ គ្មានប្រព័ន្ធធារាសាស្ត្រទឹកគ្រប់គ្រាន់ ការគ្រប់គ្រងទឹកមិនបានល្អ។ កត្តាទាំងនេះបានធ្វើឱ្យប្រជាកសិករភាគច្រើនបានសម្រេចចិត្តផ្អាក់សកម្មភាព កសិកម្មដោយទុកដីឱ្យទំនេពេញមួយរដូវប្រាំងតែម្តង។

### ៣.២.១ គ្រោះទឹកជំនន់

អំឡុងចុងរដូវវស្សាខេត្តនេះទទួលរងនូវការបំផ្លាញដោយទឹកជំនន់ស្ទើជារៀងរាល់ឆ្នាំគ្រាន់តែតិច និងច្រើនតែប៉ុណ្ណោះ។ ទឹកជំនន់នេះបានកើតឡើងដោយសារតែភ្លៀងធ្លាក់ខ្លាំង ហើយគ្មានប្រពន្ធ័ធារាសាស្ត្រដើម្បីរំដោះទឹកឱ្យបានត្រឹមត្រូវ។ ទឹកជំនន់ភ្លាមៗនេះបានបំផ្លាញដល់ដំណាំកសិកម្ម និងសង្គមដូចជា ស្រូវ ពោត ហេដ្ឋារចនាសម្ពន្ធ័ ផ្ទះសំបែង ជាពិសេសនោះគឺសុខភាពប្រជាជន។ ជាក់ស្តែងនៅក្នុងឆ្នាំ ២០១៦ យោងតាមតួរលេខរបស់មន្ទីរផែនការខេត្តស្វាយរៀងបានបង្ហាញថាចំនួនគ្រួសារដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីទឹកជំនន់នេះមានដល់ទៅ ១,៨៥៣គ្រួសារស្មើនឹង១.២៧%នៃចំនួនគ្រួសារសរុប ហើយទំហំនេះបើធៀបនឹងឆ្នាំ២០១៥ គឺឡើងដល់ទៅ៤ដងឯណុះ។ ចំពោះផ្ទៃដីដែលរងការខូចខាតដោយសារទឹកជំនន់មានចំនួន ៣,៥៩៨ហិចតា ហើយឆ្នាំ២០១៦នោះស្រុកដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេគឺ ស្រុកចន្ទ្រា រីឯផ្លូវដែលខូចខាតមានប្រវែង ៨៣,២៥៥ម៉ែត្រ នេះបើធៀបនឹង ឆ្នាំមុនកើនដល់ទៅជាង ២៣ដង។

តារាងទី១២ ៖បង្ហាញពីការខូចខាតដោយទឹកជំនន់

| បរិយាយ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|
| ចំនួនគ្រួសារទទួលការប៉ះពាល់ធ្ងន់ធ្ងរពីទឹកជំនន់(គ្រួសារ) | ១,៨៥៣ | ៦៩៣ | ៩៦ |
| ផ្ទៃដីស្រែដែលខូចខាតដោយសារទឹកជំនន់(ហ.ត) | ៣,៥៩៨ | ១,៣៩៣ | ៦,៩២២ |
| ប្រវែងផ្លូវថ្នល់ដែលខូចខាតដោយសារទឹកជំនន់(ម) | ៨៣,២៥៥ | ៦០,១៩៥ | ១៤,៣២៧ |

ប្រភព៖ មន្ទីរផែនការខេត្តស្វាយរៀង,ឯកសារពត៌មានស្តីពីស្ថានភាព សង្គមកិច្ចឆ្នាំ២០១៩ខេត្តស្វាយរៀង,ទំព័រទី៥១,៥២

នៅក្នុងឆ្នាំ២០១៨ ចំនួនគ្រួសារទទួលរងផលប៉ះពាល់ដោយទឹកជំនន់បានថយចុះមកត្រឹម ៩៨ប៉ុណ្ណោះ បើធៀបនឹងឆ្នាំមុនគឺថយចុះជាង៧ដង ហើយបើធៀបនឹងឆ្នាំ២០១៦វិញ គឺថយចុះអស់ ១៩គ្រួសារ។ ចំពោះផ្ទៃដីស្រែដែលទទួលរងប៉ះពាល់ដោយទឹកជំនន់បានកើនពី ១,៣៩៣ ហិចតា(២០១៧) ដល់៦,៩២២ហិចតា(២០១៨)គឺកើនឡើងបាន ៥,៥២៩ហិចតាដែលស្មើនឹងជិត ៥ ដងនៃផ្ទៃដីរងផលប៉ះពាល់ឆ្នាំមុន។ ផ្ទៃដីដែលរងការខូចខាតច្រើនជាងគេគឺនៅស្រុកស្វាយជ្រំ និងកំពង់រោទិ៍ ចំណែកឯស្រុកស្វាយទាប ស្រុកចន្ទ្រា និងក្រុងបាវិតវិញមិនមានទទួលរងផលប៉ះពាល់ទេ។ ដោយឡែកសម្រាប់ប្រវែងផ្លូវដែលទទួលរងការបំផ្លាញ ដោយគ្រោះធម្មជាតិមួយនេះ មានប្រវែងចំនួន ១៤,៣២៧ម៉ែត្រ គឺថយចុះអស់ប្រមាណជាង៤៥ ពាន់ម៉ែត្រ។

### ៣.២.២ គ្រោះរាំងស្ងួត

សីតុណ្ហភាពនៅកម្ពុជា បានកើនឡើងជាលំដាប់ពីមួយទសវត្សរ៍ទៅមួយទសវត្សរ៍។ យោងតាមគណៈកម្មាការទន្លេមេគង្គ(MRC)បានគណនាថា សីតុណ្ហភាពបានកើនជាមធ្យមនៅកម្ពុជាកើនពី៨ $^0$C ចាប់ពីឆ្នាំ ១៩៦០-២០០៥ ហើយអត្រាកំណើនមួយទស្សវត្សរ៍មានប្រហែល ០.០២-០.២៥ $^0$C នៅរដូវប្រាំង និងកើនពី០.១៣-០.១៦$^0$Cសម្រាប់នៅរដូវប្រាំង។ ដោយផ្អែកលើការវាយតម្លៃទាំងនេះ គេបានប៉ានស្មានថា សីតុណ្ហភាពជាមធ្យមនឹងកើនពី ០.៣-០.៦ $^0$C នៅត្រឹមឆ្នាំ ២០២៥ កើនពី០.៧-២.៧$^0$C នៅត្រឹមឆ្នាំ២០៦០ និងកើនពី១.៤-៤.៣$^0$Cបើគិតត្រឹមឆ្នាំ២០៩០។ ចំពោះកម្ដៅវិញត្រូវបាន គេរំពឹងថានឹងកើនឡើងខ្លាំងចាប់ពីខែធ្នូ ដល់ ខែមិថុនា ដែលអាចបង្កភាពលំបានច្រើនសម្រាប់ ដល់ការបង្កបង្កើនផលកសិកម្ម។ ជាក់ស្ដែងនៅក្នុងខេត្តស្វាយរៀង បញ្ហាភាពរាំងស្ងួតជាជម្ងឺរាំរ៉ៃដែលកើតមានជារៀងរាល់ឆ្នាំដែលភាគច្រើនកើតឡើងនៅពាក់កណ្ដាលខែវស្សា ហើយត្រូវបានគេស្គាល់ថាជាកូនរដូវប្រាំងនោះ។ យ៉ាងណាមិញនៅឆ្នាំ២០១៥ ភាពរាំងស្ងួតបានធ្វើឱ្យខូចខាតលើផ្ទៃដីចំនួន៣,៦១៦ហិចតា។

ក្រាហ្វិកទី២២៖ បង្ហាញពីផ្ទៃដីប៉ះពាល់ដោយគ្រោះរាំងស្ងួត




ប្រភព៖មន្ទីរផែនការខេត្តស្វាយរៀង,ឯកសារពត៌មានស្ដីពីស្ថានភាពសង្គមកិច្ចឆ្នាំ២០១៩ខេត្តស្វាយរៀង,ទំព័រទី៥៣

សម្រាប់ឆ្នាំ ២០១៨ ផ្ទៃដីស្រែទទួលរងផលប៉ះពាល់ដោយគ្រោះធម្មជាតិមួយនេះបានកើនពី ១,២៦៨ហិចតា(២០១៦) ដល់ ១២,៨៥២ហិចតា(២០១៨) គឺកើនបាន១១,៥៨៤ហិចតា ដែលកើនច្រើនជាងដល់ទៅជាង១០ដង។ បញ្ហានេះតម្រូវឱ្យមានការគិតគូរបន្ថែមទៀតពីអាជ្ញាធរដែលពាក់ព័ន្ធដើម្បីចៀសវាងការខូចខាតកាន់ធំឡើងៗពីមួយឆ្នាំទៅមួយឆ្នាំ។

### ៣.២.៣ បញ្ហាទឹកស្រោចស្រព

ទឹកគឺជាធាតុចូលដែលមិនអាចខ្វះបាននៅក្នុងវិស័យកសិកម្ម។ ទោះបីជាទឹកមានគុណភាពល្អ ការប្រើប្រាស់ដី ការគ្រប់គ្រងដីស្រែប្រកបដោយជំនាញរួមផ្សំទាំងការប្រើប្រាស់ឧបករណ៍កសិកម្មទំនើបក្តី ក៏មិនអាចសម្រេចបាននូវទិន្នផលស្រូវខ្ពស់ដែរ ប្រសិនបើការគ្រប់គ្រងទឹកមិនមាន ប្រសិទ្ធិភាព ឬគ្មានប្រព័ន្ធទឹកគ្រប់គ្រាន់។ ទោះបីជាកម្ពុជាមានទឹកច្រើនក៏ដោយ ប៉ុន្តែទឹកទាំងនោះមិនសុទ្ធតែអាចទាញយកមកប្រើប្រាស់បានទាំងអស់នោះទេ។ បរិមាណទឹកមិនទាន់គ្រប់គ្រាន់សម្រាប់ដាំដំណាំនៅរដូវប្រាំងឡើយ លើកលែងតែកន្លែងដែលមានប្រព័ន្ធស្រោចស្រព។

នៅក្នុងខេត្តស្វាយរៀង ទូទាំងខេត្តមានប្រព័ន្ធស្រោចស្រពសរុបចំនួន ៣៩ប្រព័ន្ធ គឺនៅស្រុកចន្ទ្រា មាន៥ប្រពន្ធ័ ស្រុកកំពង់រោទ៍ មាន៧ប្រពន្ធ័ ស្រុករមាសហែក មាន៥ប្រពន្ធ័ ស្រុកស្វាយជ្រំ មាន១៥ប្រពន្ធ័ ក្រុងស្វាយរៀងមាន១ប្រពន្ធ័ និងស្រុកស្វាយទាបក៏មាន១ប្រពន្ធ័ផងដែរ។ ចំពោះប្រពន្ធ័ស្រោចស្រពមានលក្ខណៈជាអាងស្តុកទឹកមាន ១២អាងទឹក ជាប្រឡាយមាន១៦ប្រឡាយ ជាស្ថានីយ៍បូមទឹកមាន ៤ ស្ថានីយ៍ ជាព្រែកមាន៥ប្រពន្ធ័ និងជាទន្លេមាន១ប្រពន្ធ័។[54]

[54] មន្ទីរផែនការខេត្តស្វាយរៀង,*ឯកសារពត៌មានស្ដីពីស្ថានភាពសង្គមកិច្ចឆ្នាំ២០១៩ខេត្តស្វាយរៀង*,ទំព័រទី ១៧។

តារាងទី១៣ ៖ ដីស្រែមានប្រឡាយស្រោចស្រព

| បរិយាយ | | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|
| សរុបដីស្រែទទួលបានប្រព័ន្ធស្រោចស្រព(ហ.ត) | | ១៥,៣២៥ | ១៥,៨៧៩ | ១៦,៤៩៦ |
| ក្នុងនោះ | ដីស្រែវស្សាទទួលបានប្រព័ន្ធស្រោចស្រព | ៨,១៣៣ | ៨,៦៧៤ | ៨,០៧១ |
| | ដីស្រែប្រាំងទទួលបានប្រព័ន្ធស្រោចស្រព | ៧,១៩២ | ៧,២០៥ | ៨,៤២៥ |
| %ដីស្រែទទួលបានប្រព័ន្ធស្រោចស្រព(ហ.ត) | | ៨.៥ | ៩.៦ | ៩.៤ |
| ចំនួនគ្រួសារមានដីស្រែទទួលពីប្រព័ន្ធស្រោចស្រព | | ៧,៤២៧ | ៧,៧៤៤ | ៧,៩១៧ |
| %ចំនួនគ្រួសារមានដីស្រែទទួលពីប្រព័ន្ធស្រោចស្រព | | ៥.១ | ៥.៣ | ៥.៣ |

ប្រភព៖មន្ទីរផែនការខេត្តស្វាយរៀង,*ឯកសារព័ត៌មានស្តីពីស្ថានភាពសង្គមកិច្ចឆ្នាំ២០១៩ខេត្តស្វាយរៀង*,ទំព័រទី១៣

បើយោងតាមឯកសារព័ត៌មានស្តីពីស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ចឆ្នាំ២០១៩របស់ខេត្តស្វាយរៀងរបស់មន្ទីរផែនការខេត្តបានបង្ហាញថា ផ្ទៃដីដែលទទួលបានទឹកស្រោចស្រពមានចំនួនប្រមាណតែ៩.៤%ប៉ុណ្ណោះ បើគិតជាគ្រួសារវិញ គឺគ្រួសារដែលមានដីស្រែអាចទទួលបានទឹកស្រោចស្រពមានប្រមាណ៥.៣%។ ក្នុងចំណោមស្រុកទាំងអស់ក្នុងខេត្ត ហើយស្រុកដែលមានភាគរយនៃផ្ទៃដីធ្វើស្រែមានប្រពន្ធ័ស្រោចស្រពច្រើនជាងគេគឺស្វាយជ្រំ និងក្រុងស្វាយរៀងដែលមានចន្លោះពី ១៧.៩% ទៅ ២០.៨%។

ចំណែកឯ ស្រុកដែលមានផ្ទៃដីធ្វើស្រែអាចទទួលបានប្រព័ន្ធស្រោចស្រពតិចជាងគេគឺស្រុករមាសហែកមានតែ ១.១% ហើយស្រុកស្វាយទាបគឺគ្មានតែម្តង។ ការខ្វះខាត់ប្រពន្ធ័ស្រោចស្រពនេះហើយដែលធ្វើឱ្យផ្ទៃដីកសិកម្មរងការខូចខាតជារៀងរាល់ឆ្នាំមិនដែលខានមួយឆ្នាំណាទេ គ្រាន់តែមានទំហំធំ ឬតូចប៉ុណ្ណោះ។

### ៣.២.៤ ការប្រើប្រាស់ដី

នៅក្នុងខេត្ត ការប្រើប្រាស់ដីនៅតែមានបញ្ហាជាបន្តបន្ទាប់ដោយមានការខ្វះខាតភាពសហការរបស់មន្ទីរជំនាញនានាដូចជា ការកំណត់ដីចំណីបឹង អូរ ព្រែក ប្រឡាយ ក្នុងបញ្ជីដីធ្លីដែលមានលក្ខណៈជាប្រពន្ធ័ ហើយប្រជាជនខ្លះបានស្នើសុំប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលវត្ថុលើដីឯកជនរបស់រដ្ឋ សាធារណៈរបស់រដ្ឋ និងខ្លះទៀតចូលទៅកាន់កាប់រំលោភលើដីរដ្ឋតែម្តង។ ប្រជាជនមួយចំនួនទៀតបានសាងសង់សំណង់លើដីចំណីផ្លូវ ដីសាធារណៈរបស់រដ្ឋ ហើយមួយចំនួនទៀតពុំមានសុំច្បាប់អនុញ្ញាតិមុនពេលសាងសង់នោះទេ។ ចំពោះការដោះស្រាយវិវាទដីធ្លីវិញពុំមានការ

ចូលរួមបានគ្រប់គ្នាឡើយ។ [55] សូមបញ្ជាក់ផងដែរថា នៅឆ្នាំ២០១៨នេះ បញ្ហាទំនាស់ដីធ្លីមាន ៥៣៨ករណី បើធៀបនឹងឆ្នាំមុនមានការកើនឡើងចំនួន ៧៣ករណី ស្មើនឹង ២០% ហើយបើធៀបនឹងឆ្នាំ២០១៥ ក៏កើនបានប្រមាណជា១៨.៩%ផងដែរ។

តារាងទី១៤ ៖ ស្ថានភាពដីស្រែចំការរបស់កសិករ

| បរិយាយ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|
| ចំនួនគ្រួសារដែលគ្មានដីស្រែ | ៨,២៥៥ | ៨,៥៩៨ | ៨,៦៩១ |
| ចំនួនគ្រួសារដែលគ្មានដីដាំដំណាំចំការ | ៦,៤០០ | ៦,៣៨១ | ៧,៩១២ |
| ចំនួនគ្រួសារដែលមានដីស្រែតិចជាង ១ហិចតា | ៥០,២៤១ | ៥១,៦៧៣ | ៥៣,០៤២ |
| ចំនួនគ្រួសារដែលមានដីដាំដំណាំចំការតិចជាង១ហិចតា | ៤,៩៣៣ | ៣,៥៧៨ | ៤,២១៧ |

ប្រភព៖មន្ទីរផែនការខេត្តស្វាយរៀង,ឯកសារពត៌មានស្តីពីស្ថានភាពសង្គមកិច្ចឆ្នាំ២០១៩ខេត្តស្វាយរៀង,ទំព័រទី១៦

ដោយឡែកសម្រាប់ផ្ទៃស្រែចំការរបស់កសិករវិញ បើយោងតាមតួរលេខរបស់មន្ទីរផែនការបានបញ្ជាក់ថានៅឆ្នាំ២០១៨នេះគ្រួសារមានដីស្រែតិចជាង ១ហិចតា មានចំនួន ៣៥,០៤២គ្រួសារ ស្មើនឹង៣៥.៣៨% និងគ្មានដីស្រែមានចំនួន ៨,៦៩១គ្រួសារ ស្មើនឹង៥.៧៦%។ សម្រាប់ គ្រួសារដែលមានដីដាំដំណាំចំការតិចជាង១ហិចតា មានចំនួន៤,២១៧គ្រួសារ ស្មើនឹង ២.៨១% និងគ្រួសារដែលគ្មានដីដាំដំណាំចំការមានចំនួន ៧,៩១២គ្រួសារស្មើនឹង ៥.២៨%នៃ គ្រួសារសរុប។

### ៣.២.៥ ដីខ្វះជីវជាតិ

ការរៀបចំដី ការជ្រើសរើសពូជ ការប្រើប្រាស់ជី ការឆ្លាស់ដំណាំ ប្រពន្ធ័គ្រប់គ្រង់ ថែរក្សា និងយុទ្ធសាស្ត្រការពារសត្វចង្រៃអាចទទូលរងឥទ្ធិពល ដោយសាប្រភេទដីដែលមាននៅតំបន់នោះជាក់ស្តែង។ ដីនៅកម្ពុជាមានលក្ខណៈផ្សេងៗទៅតាមតំបន់ ឬខេត្តនីមួយ។ ជាក់ស្តែងនៅក្នុងខេត្តស្វាយរៀង យោងទៅសម្តីរបស់មន្ត្រីនៅក្នុងមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្តបានបញ្ជាក់ថា៖ នៅក្នុងខេត្តស្វាយរៀងប្រភេទដីកសិកម្មមានដីខ្សាច់២៥% ដីល្បាយខ្សាច់៥៥% និងក្រៅពីនេះជាដីប្រភេទដីខ្មៅអណ្តែត។ គាត់បានបន្តទៀតថាដីទាំងនេះខ្វះនូវសារធាតុអាសូត(N) ផូស្វ័រ(P) និងនៅកន្លែងខ្លះទៀត ក៏ខ្វះនូវសារធាតុប៉ូតាស្យ៉ូម(K)ផងដែរ។

❖ កង្វះសារធាតុអាសូត(N): នឹងបណ្តាលឱ្យមានជាតិពណ៌លឿងខ្ចីមានលក្ខណៈក្រិនស្លឹកចាស់ ឬរុក្ខជាតិទាំងមូលមានពណ៌បៃតងលឿងខ្ចី។ ជាទូទៅការផ្គត់ផ្គង់អាសូតរបស់ដីមិនមានបរិមាណគ្រប់គ្រាន់ ដើម្បីជួយផ្គត់ផ្គង់ទៅដល់ទិន្នផលដែលមានការកើនឡើងខ្ពស់របស់ពូជស្រូវ

[55] មន្ទីរផែនការខេត្តស្វាយរៀង,*ឯកសារពត៌មានស្តីពីស្ថានភាពសង្គមកិច្ចឆ្នាំ២០១៩ខេត្តស្វាយរៀង*,ទំព័រទី៣៣។

ទំនើបបានឡើយ។ ភាពកង្វះអាសូតកើតមានឡើងជាទូទៅនៅក្នុងតំបន់ដាំដុះដំណាំស្រូវសំខាន់ៗទាំងអស់។ ទិន្នផលបានកើនឡើងយ៉ាងខ្ពស់ឆ្លើយតបទៅនឹងការប្រើប្រាស់ជីអាសូតនៅស្ទើរតែគ្រប់ដីស្រែទំនាបទាំងអស់។

➢ ការកើតមានឡើងនៃកង្វះអាសូត

- ដីដែលមានផ្ទុកសារធាតុសរីរាង្គតិចក្នុងដី
- ដីដែលមានការផ្គត់ផ្គង់អាសូតដែលមានស្រាប់របស់ដីក្នុងកម្រិតខ្សោយ( ដីអាស៊ីតស៊ុលហ្វាត ដីប្រៃ ដីកង្វះផូស្វាតដីតំបន់សើមដែលមានការច្រោះទឹក ខ្សោយ)។
- ដីអាល់កាឡាំង និងដីកាល់គែរដែលមានសារធាតុសរីរាង្គតិចនៅក្នុងដី។

❖ កង្វះផូស្វ័រ(P):នឹងធ្វើឱ្យរុក្ខជាតិតឿមានពណ៌បៃតងក្រមៅដោយគែមស្លឹកឈរត្រង់ ហើយកាត់បន្ថយការបែកគុម្ព។ កង្វះផូស្វ័រកើតឡើងដោយការប្រើប្រាស់ជីអាសូត ឬអាសូត+ប៉ូតាស់ ក្នុងបរិមាណច្រើនលើសលុបដោយប្រើប្រាស់ជីផូស្វ័រក្នុងបរិមាណមិនគ្រប់គ្រាន់។

❖ កង្វះប៉ូតាស្យូម(K): ធ្វើឱ្យរុក្ខជាតិមានពណ៌បៃតងក្រមៅដោតគែមស្លឹកមានពណ៌ត្នោតលាយលឿងខ្ចីឬស្នាមអុចៗពណ៌ត្នោតក្រមៅលេចឡើងមុនគេនៅខាងចុងស្លឹកចាស់ៗ។ ការកើតឡើងនូវជំងឺផ្សេងៗច្រើននៅកន្លែងដែលគេប្រើប្រាស់ជីអាសូតច្រើនហួសប្រមាណ និងជីផូស្វ័រក្នុងបរិមាណមិនគ្រប់គ្រាន់។

➢ ការកើតឡើងនៃកង្វះប៉ូតាស្យូម

- ការប្រើប្រាស់ជីអាសូតឬអាសូត+ផូស្វ័រក្នុងបរិមាណច្រើនលើសលុបដោយប្រើប្រាស់ជី ប៉ូតាស្យ៉ូមក្នុងបរិមាណគ្រប់គ្រាន់
- នៅលើស្រូវពង្រោះក្នុងដំណាក់កាលលូតលាស់ដំបូង នៅពេលដែលប្រព័ន្ធឬសរុក្ខជាតិមានចំនួនច្រើន ហើយប្រព័ន្ធ ឬស្ថិតននៅរាក់ៗ។ ការបាត់បង់នូវសារធាតុចិញ្ចឹមទាំងនេះរបស់ដី ដោយសារតែការបាត់បង់នូវគម្រប់ព្រៃឈើដែលជាប្រភពដ៏សំខាន់សម្រាប់ធ្វើឱ្យដីមានជីវជាតិ និងការប្រើប្រាស់នូវសារធាតុគីមី គ្មានបច្ចេក-ទេសត្រឹមត្រូវក៏បានធ្វើឱ្យដីខូចនូវគុណភាពដែរ ដែលវាបណ្តាលឱ្យទិន្នផលដែលទទួលបាននោះក៏មានបរិមាណតិចផងដែរ។

### ៣.២.៦ បញ្ហាថ្លៃទីផ្សារកសិផល

នៅរដូវប្រមូលផលចូលមកដល់ម្តងៗ កសិករមួយចំនួនតែងមានការព្រួយបារម្ភជាមួយនឹងការធ្លាក់ចុះតម្លៃនៃកសិផលរបស់ពួកគាត់។ ការព្រួយបារម្ភនេះកើតចេញពីការដែលគ្មានទីផ្សារលក់ ឬក៏អាចលក់បានដែរ តែត្រូវលក់ទាំងបង្ខំចិត្តក្នុងតម្លៃទាបដែលមិនរួចថ្លៃដើមផង។ កសិផល

ទាំងនោះមានដូចជា ស្រូវ ដំឡូងមី កៅស៊ូ ពោត និងសត្វជ្រូកជាដើម។ បើតាមសម្ដីរបស់មន្ត្រីនៅមន្ទីរកសិកម្មខេត្តបានប្រាប់ថាដំឡូងមីបានធ្លាក់ចុះតម្លៃ ១៨០-២០០រៀល/គ.ក្រ មកត្រឹម ១០០-២០០រៀល/គ.ក្រ(២០១៧-២០១៨)។ រីឯជ្រូកវិញបានធ្លាក់ថ្លៃចុះពី ១៥,០០០រៀល/គ.ក្រ មកត្រឹម ៦,៥០០-៧,០០០រៀល/គ.ក្រ។ ការធ្លាក់ចុះទាបនៃតម្លៃកសិផលនេះហើយ ទើបធ្វើឱ្យកសិករមួយចំនួនមិនសូវសប្បាយចិត្ត និងអស់ទំនុកចិត្តក្នុងការធ្វើកសិកម្ម។ ផ្ទុយពីតម្លៃកសិផល តម្លៃជី ថ្នាំសម្លាប់សត្វល្អិត សម្លាប់ស្មៅ បែជាមានតម្លៃខ្ពស់ទៅវិញ ហើយថែមទាំងមានការនាំចូល ជ្រូកពីបរទេសដោយអនាធិបតេយ្យដែលជាហេតុធ្វើឱ្យសត្វជ្រូកចិញ្ចឹមនៅក្នុងស្រុកធ្លាក់ថ្លៃចុះទាបមិនរួចថ្លៃដើមចិញ្ចឹមនោះទេ។ ក្រៅពីនេះការចិញ្ចឹមសត្វនៅក្នុងខេត្ត ក៏បានប្រឈមយ៉ាងខ្លាំងជាមួយនឹងជម្ងឺសារទឹក និងជម្ងឺអុតក្ដាមដែលបានសម្លាប់សត្វប្រមាណជា២៨០-៣០០ក្បាល។ បញ្ហានេះហើយដែលធ្វើឱ្យកសិករបាក់ទឹកចិត្តអស់ទំនុកចិត្តលើវិស័យមួយនេះហើយ ក៏សម្រេចចិត្តងាកមកបម្រើការឱ្យវិស័យផ្សេង ឬដោយការធ្វើការចំណាក ស្រុកទៅក្រៅខេត្ត ឬក្រៅប្រទេស។

### ៣.២.៧ បញ្ហាសត្វចង្រៃ

ដំណាំកសិកម្ម តែងតែទទួលរងនូវឥទ្ធិពលបំផ្លិចបំផ្លាញពីសត្វល្អិតដែលបញ្ហានេះនឹងធ្វើឱ្យមានការខាតបង់យ៉ាងធ្ងន់ធ្ងរដល់បរិមាណ និងទិន្នផលដំណាំ។ កសិករនៅក្នុងខេត្តក៏បានរអ៊ូរទាំពីសត្វដែលបានបំផ្លាញដំណាំរបស់ពួកគាត់ជារៀងរាល់ឆ្នាំ តែគ្រាន់ទំហំធំ ឬតូចប៉ុណ្ណោះ។

**មមាចត្នោត** : ជាសត្វល្អិតចង្រៃនៃដំណាំស្រូវមានខ្លួនតូចទំហំប៉ុនគ្រាប់អង្ករ និងមានពណ៌ត្នោតនៅពេលពេញវ័យ។ ការបំផ្លាញដំណាំស្រូវរបស់មមាចត្នោតមានពីរបែបគឺ ទីមួយជញ្ជក់យកជ័រពីដើមស្រូវរហូតដល់ដើមស្រូវខ្សោះខ្លោចងាប់ និងទីពីរគឺជាភ្នាក់ងារចម្លងជំងឺវីរុសពីរប្រភេទគឺ ជម្ងឺតឿស្មៅ និងជំងឺតឿរួញស្លឹក ។

**រូបសត្វមមាច**







**ទ្រីប** : ជាពពួកសត្វល្អិតតូចៗដែលពិបាកមើលឃើញដោយភ្នែកទទេដែលកសិករនិយមហៅថា "ក្រានៅលើសំណាប"។ការផ្ទុះឡើងនៃការបំផ្លាញរបស់ទ្រីបជាធម្មតាមានកម្រិតទាប ដោយសារវាបំផ្លាញដំណាំស្រូវតែនៅដំណាក់កាលដំបូង ហើយវានឹងធ្វើឱ្យដំណាំអាចដុះលូតលាស់បំពេញសងនូវការខូចខាតនេះបាន។ ពេលរាំងស្ងួតគឺជាពេលដែលទ្រីបចូលចិត្តបំផ្លាញបំផុត។



**ដង្កូវមូរស្លឹក** : គឺជាសត្វស៊ីស្រូវមួយដែលអាចកើតមាននៅគ្រប់ បរិស្ថានដំណាំស្រូវ។ វាកោសជាលិកាស្លឹកស្រូវផ្នែកខាងលើធ្វើឱ្យមាន ស្នាមសរៗ វែងៗជាច្រើននៅលើស្លឹកស្រូវ។ នៅពេលដែលវាមានការបំផ្លាញខ្លាំងគេឃើញថាមានរមូរស្លឹក និងស្នាមសរៗជាច្រើននៅលើស្លឹកស្រូវ។ ភាគច្រើនវាកើតមាននៅក្នុងស្រែដែលនៅក្រោមម្លប់ឈើ ស្រែដែលមានការប្រើប្រាស់ជីអាសូតច្រើនពេក និងស្រែដែលស្ងួតញឹកពេក។

## ៣.៣ ដំណោះស្រាយបញ្ហាវិស័យកសិកម្ម

### ៣.៣.១ ដំណោះស្រាយបញ្ហាគ្រោះទឹកជំនន់ រាំងស្ងួត និងប្រព័ន្ធស្រោចស្រព

ជារៀងរាល់ឆ្នាំ យើងសង្កេតឃើញថាខេត្តស្វាយរៀង គឺជាខេត្តមួយដែលតែងតែទទួលរងគ្រោះថ្នាក់ ដោយសារតែគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងខ្វះខាតប្រព័ន្ធស្រោចស្រពសម្រាប់ការធ្វើកសិកម្ម។ បញ្ហាខាងលើនេះ បានបំផ្លិចបំផ្លាញនូវផលដំណាំ និងការចិញ្ចឹមសត្វរបស់ប្រជាកសិករក្នុងខេត្តនេះជាច្រើន ដូច្នេះហើយដើម្បីដោះស្រាយនូវបញ្ហាទាំងនេះ ស្ថាប័នពាក់ព័ន្ធគួរតែយកចិត្តទុកដាក់ក្នុងការកសាងនូវប្រព័ន្ធធារាសាស្ត្រ ព្រោះវាមានសារសំខាន់ខ្លាំងណាស់ក្នុងការរំដោះទឹកចេញ ពេលដែលមានគ្រោះទឹកជំនន់ជន់លិចដល់ដំណាំកសិកម្ម និងសត្វចិញ្ចឹមផ្សេងៗ ហើយម្យ៉ាងវិញទៀត ប្រព័ន្ធធារាសាស្ត្រអាចជួយផ្គត់ផ្គង់នូវទឹក នៅពេលដែលមានគ្រោះរាំងស្ងួតផងដែរ។

ដើម្បីដោះស្រាយនូវបញ្ហាទាំងនេះ ប្រជាកសិករ និងអាជ្ញាធរក្នុងខេត្តស្វាយរៀងគួរតែៈ

### ១. លើកទំនប់អាងទឹក និងជីកប្រឡាយស្រោចស្រព

ការងារលើកទំនប់ទឹក និងជីកប្រឡាយទឹក គឺមានសារៈសំខាន់ខ្លាំងណាស់ក្នុងការបង្កើនផ្ទៃដីដាំដុះ និងស្រោចស្រពដំណាំរបស់ប្រជាពលរដ្ឋក្នុងការធ្វើកសិកម្មរបស់ពួកគាត់ ហើយការងារនេះនឹងធានាជូនប្រជាពលរដ្ឋលើការប្រើប្រាស់ទឹកឱ្យបានគ្រប់គ្រាន់ក្នុងវិស័យកសិកម្ម។ ម្យ៉ាងវិញទៀត ទំនប់ទឹក និងប្រឡាយនេះ អាចជួយក្នុងការរំដោះទឹកចេញ នៅពេលដែលមានទឹកជំនន់ជន់លិចដែលនាំឱ្យខូចខាតដល់ដំណាំ និងសត្វធាតុផ្សេងៗ។ ពិសេសទៀត ប្រជាកសិករយើងគួរតែជីកប្រឡាយនៅជាប់វាលស្រែ ឬស្រះតូចៗ ព្រោះវាអាចស្តុកទឹកសម្រាប់ប្រើប្រាស់ ប្រសិនមានកូនរដូវប្រាំងកើតមានក្នុងរដូវវស្សា ហើយយើងអាចបញ្ចូលទឹកទៅក្នុងស្រែនោះបាន នៅពេលទឹកលើសពីតម្រូវការក្នុងការប្រើប្រាស់ក្នុងស្រែ ឬដំណាំផ្សេងៗ គឺយើងអាចបញ្ចេញចូលមកក្នុងប្រឡាយវិញ។




### ២. ជីកអណ្តូងស្រោចស្រព

តំបន់មួយចំនួន គួរតែប្រើប្រាស់អណ្តូងសម្រាប់ជួយ ព្រោះថាអណ្តូង គឺជាប្រភពទឹកក្រោមដីដ៏សំខាន់ណាស់ សម្រាប់ប្រើប្រាស់នៅពេលជួបគ្រោះរាំងស្ងួត គ្រាន់តែការជីកអណ្តូងត្រូវការចំណាយច្រើន និងធ្វើឱ្យដីបាត់បង់គុណភាពនាពេលអនាគត។ បើតាមការពិនិត្យការប្រើប្រាស់អណ្តូងមួយអាចផ្គត់ផ្គង់លើផ្ទៃដីពី ៤ ហ.ត ទៅ ៥ ហ.ត ប៉ុណ្ណោះ។ ទោះបីជាយ៉ាងណា ការប្រើប្រាស់អណ្តូងបានរួមចំណែកយ៉ាងសកម្មនាពេលបច្ចុប្បន្ននេះ ក្នុងការជួយសង្គ្រោះផ្ទៃដីកសិកម្ម (ស្រូវ បន្លែ និងដំណាំផ្សេងៗ) នៅពេលជួបគ្រោះរាំងស្ងួត និងជួយដល់តំបន់មួយចំនួនដែលពុំទាន់មានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់ផងដែរ។

### ៣. ការសាងសង់ស្ថានីយបូមទឹកចល័ត និងអចល័ត

ការសាងសង់ស្ថានីយបូមទឹកទាំងពីរបែបនេះ មានភាពចាំបាច់ខ្លាំងណាស់ ក្នុងការស្រោច

ស្រពនិងជួយសង្គ្រោះដល់ដំណាំរបស់ប្រជាកសិករក្នុងពេលជួបប្រទះបញ្ហាគ្រោះរាំងស្ងួត។ យើងសង្កេតឃើញថា បញ្ហាគ្រោះរាំស្ងួតនេះតែងតែកើតមានឡើង នៅដើមរដូវ និងចុងរដូវបង្កបង្កើនផល។ ការកសាងស្ថានីយនេះគឺអាចប្រើប្រាស់បានទាំងពេលមានគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតសម្រាប់បំពេញសេចក្ដីត្រូវការរបស់ប្រជាកសិករយើង។

**៤. ការស្ដារឡើងវិញនៅប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់**

ខេត្តស្វាយរៀង គឺជាខេត្តមួយដែលមានប្រព័ន្ធធារាសាស្ត្រច្រើនគួរសមដែរ ប៉ុន្តែប្រព័ន្ធធារាសាស្ត្រទាំងនេះត្រូវបានខូចខាត រាក់ ដោយសារការបាក់ដី និងការប្រើប្រាស់ជាយូរមកហើយ។ ហេតុនេះហើយ មន្ទីរពាក់ព័ន្ធគួរតែយកចិត្តទុកដាក់ក្នុងការស្ដារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រទាំងនេះ ដើម្បីបំពេញសេចក្ដីត្រូវការក្នុងវិស័យកសិកម្មនៅក្នុងខេត្តនេះ។

**៣.៣.២ ដំណោះស្រាយបញ្ហាដីខ្វះជីជាតិ**

ដើម្បីកែលម្អរជីជាតិដីឱ្យបានល្អប្រសើរ ប្រជាកសិករត្រូវយកចិត្តទុកដាក់លើការប្រើប្រាស់ជីធម្មជាតិដូចជា៖ លាមកសត្វ ជីកំប៉ុស្តិ៍ ជីស្រស់ ភ្ជួរលុបគល់ជញ្ជ្រាំង ភ្ជួរលុបគល់ដំណាំ ការពន្លិចទឹកស្រែ និងការដាំដំណាំបង្វិលជុំ។ ខាងក្រោមនេះ មានចំណុចមួយចំនួនដែលប្រជាកសិករគួរតែអនុវត្តដើម្បីធ្វើឱ្យដីមានជីជាតិល្អ៖

- ក្រោយពេលច្រូតកាត់ស្រូវរួច ពេលដីកំពុងមានទឹក ឬនៅសើម យើងអាចភ្ជួរលុបជញ្ជ្រាំងនៅក្នុងស្រែ ហើយយើងអាចពោយចំបើង ឬអង្កាមរួចភ្ជួរលុបក៏បាន។
- បន្ទាប់ពីនោះប្រមូលផលដំណាំមួយប្រភេទហើយ យើងអាចដាំដំណាំបង្វិលផ្សេងៗសម្រាប់យកផលដូចជា៖សណ្ដែក ដំឡូង ឪឡឹក ល្ពៅ ត្រសក់ជាដើម។ កាកសំណល់ ដែលសេសសល់ពីរុក្ខជាតិទាំងនេះ គឺជាសារធាតុសំខាន់ក្នុងការលម្អជីជាតិដី។
- យើងអាចដាំរុក្ខជាតិសំបូរជាតិអាសូតដែលមានប្រយោជន៍សម្រាប់ស្រូវដូចជា៖ សង្កែ កន្ទំថេត អំពិលបារាំង អង្គាដី ហើយយកដាក់ក្នុងស្រែរួចភ្ជួរលុប។
- ការប្រើប្រាស់ជីលាមកសត្វ ឬជីកំប៉ុស្ដិ៍មិនត្រូវយកដាក់ហាលថ្ងៃទេ វានាំឱ្យបាត់បង់ជាតិអាសូត។ ដូច្នេះពេលដាក់ជីក្នុងស្រែគប្បីភ្ជួរលុបភ្លាម ពិសេសប្រជាកសិករគប្បីបចំពោងសន្សំជីធម្មជាតិ ដើម្បីរក្សាគុណភាពដី។
- ប្រជាកសិករមិនត្រូវដាំដំណាំស្រូវដដែលលើដីស្រែតែមួយឡើយ វានាំឱ្យបាត់បង់ជីជាតិដី និងទទួលបានទិន្នផលទាប។

❖ ការធ្វើឱ្យទឹកដក់ក្នុងស្រែក៏ជាវិធីមួយជួយថែរក្សា និងបង្កើតជីជាតិដីផងដែរ ហើយម្យ៉ាងវិញទៀតទឹកភ្លៀងនាំមកនូវជាតិអាសូតយ៉ាងច្រើនដល់ដី ដូច្នេះយើងគប្បីរក្សាភ្លឺស្រែឱ្យបានខ្ពស់។

❖ ការប្រើប្រាស់ជីកំប៉ុស្តិ៍ដាក់ស្រែពី ១០ ទៅ១៥តោនក្នុងមួយហិចតា វាមានប្រសិទ្ធិភាពរយៈពេល៥ឆ្នាំ។

### ៣.៣.៣ ដំណោះស្រាយថ្លៃទីផ្សារកសិផល

រាជរដ្ឋាភិបាល ក្រសួងពាក់ព័ន្ធ និងអង្គការនានា ដែលទាក់ទងទៅនឹងវិស័យកសិកម្មគួរតែស្វែងរកដៃគូពាណិជ្ជកម្មទាំងក្នុងប្រទេស និងក្រៅប្រទេសសម្រាប់ផលិតផលកសិកម្មកម្ពុជា។ ដំបូងគឺរដ្ឋាភិបាលត្រូវទប់ស្កាត់ផលិតផលក្រៅស្រុកមួយចំនួនកុំឱ្យហូរចូលមកកម្ពុជាច្រើនពេក និងជំរុញឱ្យមានក្រុមហ៊ុនទិញ និងស្តុកទុក ដើម្បីរង់ចាំទីផ្សារកសិផលងើបឡើងវិញ។ មួយវិញទៀតត្រូវបើកយុទ្ធនាការគាំទ្រផលិតផលខ្មែរ។ យើងគាំទ្រការតាំងពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេស និងអន្តរជាតិរបស់រដ្ឋាភិបាល។ តែសកម្មភាពនេះ គួរបន្តធ្វើជាញឹកញាប់ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយទាំងក្នុងនិងក្រៅប្រទេស ជាពិសេសនៅតាមបណ្តាទូតនានារបស់កម្ពុជា ដែលមានស្នាក់ការនៅខាងក្រៅ។ រីឯកសិករខ្មែរខ្លួនឯង ត្រូវសហការជាមួយ និងអាជ្ញាធពាក់ព័ន្ធចងក្រងគ្នាជាសហគមន៍កសិករ ឬសមាគមអ្នកដាំដុះ ទៅតាមប្រភេទដំណាំនីមួយៗដែលខ្លួនដាំ។ បន្ថែមពីនេះ រដ្ឋាភិបាលគួរបញ្ជូនអ្នកជំនាញកសិកម្មជួយតម្រង់ទិសកសិករឱ្យចេះសហការគ្នារៀបចំដាំដុះតាមបែបស្តង់ដាកសិកម្មស្របតាមតម្រូវការទីផ្សារអន្តរជាតិ។ ចំពោះក្រសួងពាក់ព័ន្ធ ដូចជា ផលិតករត្រូវចេះស្រាវជ្រាវអំពីចំណុចខ្លាំង និងខ្សោយក្នុងផលិតកម្ម និងការនាំចេញ ពិសេសរចនាសម្ព័ន្ធរបស់កសិផលមួយមុខៗ ដើម្បីកាត់បន្ថយថ្លៃដើម ការនាំចេញ និងចំណាយក្រៅផ្លូវការ។ សម្រាប់ប្រជាកសិករខ្មែរវិញ ត្រូវបញ្ឈប់ទម្លាប់ដាំដុះតាមគ្នា ហើយមុនដាំដុះត្រូវ គិតពីទំហំទីផ្សារ និងសិក្សាពីបច្ចេកទេសដំណាំឱ្យច្បាស់មុនចំណាយទុនផលិតទំនិញអ្វីមួយ។ មួយវិញទៀតមន្ទីរក្រោមឱវាទត្រូវខិតខំអនុវត្តឱ្យមានប្រសិទ្ធភាពនូវសេចក្តីណែនាំរបស់ក្រសួងកសិកម្ម ដើម្បីលើកកម្ពស់ធុរកិច្ចស្រូវអង្ករ ពិសេសការជួយអន្តរាគមន៍ ទប់ស្កាត់សភាពការណ៍នៃការធ្លាក់ចុះនៃតម្លៃស្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចដាក់ចេញនូវវិធានការណែនាំចាំបាច់មួយចំនួនសម្រាប់អនុវត្តបន្ទាន់ដូចខាងក្រោម៖

១. អង្គភាពជំនាញក្រោមឱវាទក្រសួងត្រូវបន្តការស្រាវជ្រាវបញ្ចេញប្រភេទពូជស្រូវក្រអូបប្រណិត និងផលិតកម្មគ្រាប់ពូជស្រូវក្រអូបសុទ្ធតាមរយៈការផលិតនៅថ្នាក់សហគមន៍ និងក្រុម

កសិករផលិតគ្រាប់ពូជធ្វើយ៉ាងណាឱ្យមានគ្រាប់ពូជគ្រប់គ្រាន់ និងតម្លៃសមរម្យដើម្បីពង្រីកផលិតកម្មស្រូវក្រអូប។ ជាមួយគ្នានេះស្នើវិស័យឯកជនចូលរួមដាក់ទុនវិនិយោគក្នុងការផលិតគ្រាប់ពូជស្រូវក្រអូបដែលមានគុណភាពខ្ពស់ស្របតាមស្តង់ដារ និងតម្រូវការទីផ្សារ។

២.ពាក់ព័ន្ធនឹងការកាត់បន្ថយថ្លៃដើមផលិតកម្ម ត្រូវជំរុញឱ្យបានខ្លាំងក្លាបន្ថែមទៀតនូវវិធានការបច្ចេកទេសផលិតកម្មដែលទទួលបានទិន្នផលខ្ពស់ និងចំណាយតិច រួមជាមួយនឹងការអនុវត្តទំនើបភាវូបនីយកម្មកសិកម្ម។ ជាមួយគ្នានេះត្រូវបានពិនិត្យកាត់បន្ថយថ្លៃចំណាយលើការធ្វើតាមរយៈ ការបង្កើនចំនួនក្រុមហ៊ុនដែលមានសមត្ថភាពចូលរួមធ្វើការងារនេះឱ្យបានច្រើនមានការប្រកួតប្រជែង និងយកកម្រៃសេវាទាបជាងមុន។ ក្នុងន័យនេះ អគ្គនាយកដ្ឋានកសិកម្ម ត្រូវពិនិត្យសិក្សាឱ្យបានហ្មត់ចត់ និងជំរុញការងារនេះឱ្យបានឆាប់។ ម្យ៉ាងវិញទៀត ដើម្បីសម្រួលដល់ការនាំចូលជីកសិកម្ម ថ្នាំកសិកម្មឱ្យបានលឿន និងមានប្រសិទ្ធភាពជាងមុន នាយកដ្ឋាននីតិកម្មកសិកម្មត្រូវសម្រួលបែបបទការនាំចូលជីកសិកម្មថ្នាំកសិកម្ម និងសម្ភារកសិកម្មដទៃទៀតឱ្យកាន់តែប្រសើរជាងមុន។ ជាមួយគ្នានេះ ត្រូវរៀបចំក្រុមការងារបច្ចេកទេសចម្រុះ ចុះពិនិត្យគុណភាពជីគីមីកសិកម្ម និងថ្នាំកសិកម្មដើម្បីធានាពីគុណភាពស្របតាមស្តង់ដារកំណត់។

៣. អ្នកប្រមូលទិញស្រូវ ត្រូវបន្តធ្វើការទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍ជនបទដើម្បីទទួលបានឥណទានប្រមូលទិញស្រូវពីកសិករ សហគមន៍កសិកម្ម និងមិនត្រូវយកហេតុផលនៃការដាក់វិធានការការពារទីផ្សាររបស់សហគមន៍អឺរ៉ុបមកទម្លាក់ថ្លៃទិញស្រូវពីកសិករឡើយ។ ក្រុមហ៊ុននាំចេញអង្ករ ត្រូវពិនិត្យនិងធានាគុណភាពអង្ករក្រអូបឱ្យបានសុទ្ធល្អមិនត្រូវលាយបន្លំអង្ករប្រភេទផ្សេងដែលនាំឱ្យអតិថិជនបាត់បង់ជំនឿលើគុណភាពអង្ករក្រអូបកម្ពុជា។

៤. សហព័ន្ធស្រូវអង្ករកម្ពុជា គួរយកចិត្តទុកដាក់ជំរុញឱ្យសមាគមន៍ម៉ាស៊ីនកិនស្រូវ ខិតខំបង្កើនសមត្ថភាពកែច្នៃអង្ករឱ្យមានគុណភាពបន្ថែមទៀត សម្រាប់បម្រើឱ្យទីផ្សារអន្តរជាតិ ពិសេសទីផ្សារប្រទេសចិនដែលមានរហូតដល់ ៥០ម៉ឺនតោន នាពេលបច្ចុប្បន្ននេះ។ លើសពីនេះទៀតសហព័ន្ធស្រូវអង្ករកម្ពុជាគួរពិគ្រោះយោបល់ជាមួយសមាជិករបស់ខ្លួនដើម្បីពិនិត្យលើបញ្ហាប្រឈមពីផលប៉ះពាល់នៃការដាក់វិធានការការពារទីផ្សារអង្កររបស់សហគមន៍អឺរ៉ុបរួចលើកសំណើឬសំណូមពរមកក្រុមការងារផ្នែកស្រូវ-អង្ករនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ពិនិត្យ និងរកដំណោះស្រាយតាមការចាំបាច់។

ចំពោះកសិករគួរយល់ដឹងពីដំណោះស្រាយចំនួន៤ ដើម្បីជួយឱ្យទីផ្សារកសិផលមានតម្លៃៈ

**១.ការផលិតបាញ់ផ្តោះទៅកាន់ការទាមទាររបស់ទីផ្សារ** យើងឃើញថាប្រជាកសិករកម្ពុជាយើងតែងតែមានភាពរអ៊ូរទាំពីរឿង កសិផលធ្លាក់ថ្លៃ និងគ្មានទីផ្សារសម្រាប់ផលិតផលរបស់ខ្លួនទាំងនេះគឺមកពីពួកគាត់មិនគិតដល់អ្វីខ្លះជាតម្រូវការទីផ្សារ។ យើងដឹងហើយថាមនុស្សយើងម្នាក់ៗប្រាថ្នាចង់បាននូវផលិតផល ដែលមានគុណភាព សោភណភាព និងចំណែកក្នុងការផ្គត់ផ្គង់ក្នុងទីផ្សារឱ្យមានភាពទៀងទាត់ ហើយវាគឺជារឿងដែលសំខាន់ណាស់ ដែលប្រជាកសិករគួរយកចិត្តទុកដាក់សម្រាប់ការធ្វើកសិកម្មរបស់ខ្លួន។ បើកសិករអាចដឹងពីការទាមទារនៃតម្រូវការទីផ្សារវានឹងជួយឱ្យតម្លៃកសិផលមានការកើនឡើងមួយកម្រិតទៀង ពិសេសគឺការកែប្រែផលិតផលកសិកម្មឱ្យសាកសមទៅនឹងការទាមទារទាំងនោះ យើងនឹងអាចលក់កសិផលបាន។

**២.កសិករត្រូវមានភាពជាសហគ្រិន** ដើម្បីធ្វើទីផ្សារកសិផលឱ្យមានតម្លៃល្អប្រសើរ កសិករត្រូវមានភាពជាសហគ្រិននោះគឺ កសិករជាអ្នកធ្វើជំនួញលើកសិផលរបស់ខ្លួន។ ប្រជាកសិករត្រូវយល់ដឹងឱ្យបានច្បាស់លាស់ពីស្ថានភាពទីផ្សារដែលតម្លៃកសិផលមានការកើនឡើង ពេលណាត្រូវលក់ត្រសក់ ហើយពេលណាត្រូវលក់ការ៉ុត។ ជាពិសេសកសិករត្រូវយល់ថានរណាគេ គឺជាទីផ្សារធំរបស់ខ្លួន ហើយកសិករត្រូវតែកសាងសមត្ថភាព និងស្មេរភាពក្នុងការផ្គត់ផ្គង់នូវផលិតផលកសិផលដោយពុំមានភាពរាំងស្ទះដល់ការលក់នៅក្នុងទីផ្សារ។

**៣.ការផ្លាស់ប្តូរមកនិន្នាការបច្ចេកទេសថ្មី** យើងដឹងហើយថាកសិផលក្នុងស្រុកមានតម្លៃថោកណាស់ ភាគច្រើនលក់មិនចំណេញ ដោយសារតែការនាំចូលនូវកសិផលពីប្រទេសជិតខាងមានតម្លៃទាបជាង ដូច្នេះហើយដើម្បីធ្វើឱ្យប្រជាកសិករអាចប្រកួតប្រជែងជាមួយគេបាន គឺការដាំដុះត្រូវតែចំណាយថ្លៃដើមទាប។ ដើម្បីធ្វើការផលិតឱ្យមានតម្លៃទាប យើងគប្បីប្រើប្រាស់បច្ចេក-ទេសផលិតជីសរីរាង្គខ្លួនឯង ផលិតថ្នាំពុលធម្មជាតិខ្លួនឯង និងការប្រើប្រាស់កាកសំណល់លាមកគោ ក្របី ជ្រូក មាន់ទា ជាដើមដើម្បីកាត់បន្ថយការចំណាយរបស់ខ្លួន។ ជាពិសេសកសិករគួរតែកាត់បន្ថយការប្រើប្រាស់ជីគីមី និងថ្នាំពុលគីមីហួសកម្រិត ដែលនាំឱ្យខូចគុណភាពដី និងប៉ះពាល់ដល់គុណភាពផលិតផល។

**៤. កសិករត្រូវមានភាពច្នៃប្រឌិតក្នុងការលក់** កសិករត្រូវតែគិតឱ្យបានវែងឆ្ងាយ ពោលគឺកសិករត្រូវគិតគូរពីគំនិតច្នៃប្រឌិតបែបថ្មី ទាំងការវេចខ្ចប់មានស្តង់ដារ ការដឹកជញ្ជូនមានសុវត្ថិភាពដែលមិនធ្វើអោយខូចដល់គុណភាពកសិផលមានអនាម័យល្អ និងការបង្កើតទំនាក់ទំនងល្អជាមួយអតិថិជនរបស់ខ្លួន។

### ៣.៣.៤ ដំណោះស្រាយបញ្ហាសត្វចង្រៃ និងជម្ងឺសត្វ

**វិធានកការចម្រុះក្នុងការគ្រប់គ្រងដំណាំ**(IPM): វិធានការនេះ គឺជាប្រពន្ធគ្រប់គ្រង់ ដែលគ្រប់គ្រងដំណាំដែលរួមបញ្ចូលនូវវិធីសាស្ត្រទាំងអស់ដើម្បីថែរក្សា និងការពារដំណាំឱ្យបានដុះលូតលាស់ល្អ ទទួលបានទិន្នផលខ្ពស់ ធានាបាននូវនិរន្តរភាពផលិតកម្ម ប្រសិទ្ធភាពសេដ្ឋកិច្ច និងការពារនូវសុខមាលភាពរបស់ប្រជាជន និងបរិស្ថាន។ កម្មវិធី IPM នេះ គឺផ្តោតសំខាន់ទៅលើការកាត់បន្ថយការប្រើប្រាស់ថ្នាំកសិកម្មក្នុងការកម្ចាត់សមាសភាគចង្រៃ។ វិធានការ IPM នេះអាចកម្ចាត់សមាសភាពចង្រៃបានដោយប្រសិទ្ធភាព មិនចាំបាចចំណាយថវិកាច្រើន និងមិនបង្កគ្រោះថ្នាក់ដល់សុខភាព និងបរិស្ថាន។ ចំណែកវិធានការការពារតាមបែបគីមី គឺជាវិធានការចុងក្រោយដែលត្រូវប្រើក្នុងករណីចាំបាច់។ កម្មវិធី IPM អនុវត្តការងារដោយផ្អែកលើគោលការណ៍គ្រឹះសំខាន់ៗទាំង ៤ គឺ:

✓ ដាំដំណាំឱ្យដុះលូតលាស់ល្អ: កសិករត្រូវជ្រើសរើសពូជឱ្យបានល្អ គឺជាពូជដែលអាចផ្តល់ទិន្នផលបានខ្ពស់ ធន់នឹងការបំផ្លាញរបស់សត្វល្អិត និងជម្ងឺ ហើយសមស្របនឹងលក្ខខណ្ឌបរិស្ថានក្នុងតំបន់។ ក្រៅពីការជ្រើសរើសពូជកសិករត្រូវអនុវត្តការរៀបចំដីឱ្យបានល្អប្រើប្រាស់បច្ចេកទេសដាំដុះឱ្យបានត្រឹមត្រូវ ថែទាំដំណាំឱ្យបានល្អ និងប្រើប្រាស់ជីឱ្យមានតុល្យភាព។

✓ ការថែទាំសត្វមានប្រយោជន៍: កសិករត្រូវយល់ឱ្យបានច្បាស់ពីប្រភេទសត្វស៊ីដំណាំ ឬសត្វមានប្រយោជន៍នៅក្នុងស្រែចំការលក្ខណៈនៃការរស់នៅនិងការស៊ីចំណីរបស់សត្វនីមួយៗ។ កសិករគួរថៃ និងការពារសត្វមានប្រយោជន៍តាមរយៈការកាត់ប្ថយការប្រើប្រាស់ ថ្នាំកសិកម្ម ឬព្យាយាមជ្រើសរើសយកថ្នាំកសិកម្មគីមីណាដែលប៉ះពាល់តិចដល់សុខភាពមនុស្ស សត្វ សត្វមានប្រយោជន៍ និងបរិស្ថាន។

✓ ការចុះពិនិត្យស្រែជាប្រចាំ: ការចុះពិនិត្យស្រែជាប្រចាំនេះ គឺជាការដែលសំខាន់ដែលធ្វើឱ្យកសិករបានពិនិត្យ និងវាយតម្លៃពីស្ថានភាពស្រែ លក្ខណៈលូតលាស់របស់ដំណាំ ស្ថានភាពទឹក ដី ស្មៅចង្រៃ វត្តមានសត្វមានប្រយោជន៍ វត្តមានសត្វស៊ីដំណាំ និងស្ថានភាព ការបំផ្លាញរបស់វានៅតំណាក់កាលនីមួយៗនៃវគ្គលូតលាស់របស់ដំណាំ។ ការធ្វើដូច្នេះ កសិករអាចស្វែងយល់ពីបញ្ហានៅក្នុងស្រែ និងអាចដោះស្រាយទាន់ពេលវេលា។

✓ កសិករអាចនឹងក្លាយជាអ្នកជំនាញក្នុងផលិតកម្មដំណាំ: ការដែលកសិករបានទៅពិនិត្យស្រែជាប្រចាំនោះនឹងចេះវិភាគ និងធ្វើការសម្រេចដោយខ្លួនឯងប្រកបដោយភាពវៃឆ្លាតតាមរយៈការធ្វើពិសោធកន្លងមក។

ខាងក្រោមនេះជាឧទាហរណ៍ពីរបៀបគ្រប់គ្រងសមាសភាពចង្រៃលើដំណាំស្រូវ ប៉ុន្តែវិធីសាស្ត្រដែលអាចប្រើប្រាស់បាន គឺអាស្រ័យលើស្ថានភាពរបស់ដំណាំ ស្ថានភាពរបស់សមាសភាពចង្រៃ ធនធាន និងកត្តាផ្សេងៗក្នុងតំបន់។

**ក.សត្វទ្រីប** គឺជាសត្វល្អិតមួយប្រភេទ ដែលបំផ្លាញដំណាំតាមរយៈការស៊ីកោសនៅក្រោមស្រទាប់ស្លឹក វាធ្វើឱ្យស្លឹកដំណាំខូចទ្រង់ទ្រាយដើម និងមិនអាចធ្វើរស្មីសំយោគបាន ដើម្បីសម្រួលការដឹកនាំអាហារទៅឬសបាន ស្លឹករួញ និងដើមក្រិនមិនអាចលូតលាស់បានល្អ ដែលធ្វើឱ្យទិន្នផលធ្លាក់ចុះ។ វាមានលក្ខណៈសម្គាល់ និងវិធានការការពារ និងកម្ចាត់មួយចំនួនៈ

- **វដ្តជីវិត** ទ្រីបពេញវ័យញីជម្រុះពងរបស់វាទៅក្នុងជាលិកាស្លឹក ដោយប្រដាប់បញ្ចេញពង។ កូនទ្រីបនឹងញាស់មានពណ៌ស និងគ្មានស្លាប ហើយកូនញាស់នេះប្រែក្លាយទៅជាពណ៌ក្រមៅនៅពេលវាមានវ័យចំណាស់។ ទ្រីបពេញវ័យមានរាងតូចពណ៌ត្នោតខ្មៅ ហើយខ្លះមានស្លាប និងខ្លះគ្មាន។
- **ស្នាមបំផ្លាញ** បញ្ហាសត្វទ្រីបនេះមានវត្តមានគ្រប់បរិស្ថាននៃដំណាំស្រូវ ប៉ុន្តែវាកើតច្រើន នៅពេលមានអាកាសធាតុក្តៅស្ងួត។ នៅពេលកូនរបស់វាញាស់មក ហើយវាស៊ីរូងស្លឹកដែលធ្វើឱ្យស្លឹកស្ងួត និងប្រែក្លាយទៅជាពណ៌ត្នោត។
- **វិធានការការពារ** ថ្នាលសំណាប និងស្រែត្រូវមានទឹក នាំឱ្យស្រូវដុះបំពេញសងទប់ទល់ការបំផ្លាញរបស់ទ្រីប ម្យ៉ាងវិញទៀតប្រជាកសិករគប្បីការពារសត្វមានប្រយោជន៍ ដែលបំផ្លាញសត្វទ្រីប។ យើងសង្កេតឃើញថាគ្មានពូជស្រូវណា ដែលអាចធន់ទ្រាំនឹងទ្រីបបានទេ។
- **វិធានការកម្ចាត់** ដើម្បីកម្ចាត់សត្វទ្រីបនេះ គឺថ្នាលសំណាប ឬសន្ទូង គប្បីត្រូវពន្លិចទឹកឱ្យផុតចុងរយៈពេល២ថ្ងៃ ដើម្បីសម្លាប់ទ្រីប ហើយទឹកភ្លៀងក៏អាចកាត់បន្ថយទ្រីបផងដែរ។ កសិករយើងអាចយកចុងឫស្សី ដើម្បីពន្លិចចុងស្រូវឱ្យលិចទឹក ដើម្បីកម្ចាត់ទ្រីប ពិសេសយើងអាចប្រើប្រាស់ថ្នាំផ្សំពីរុក្ខជាតិដូចជា ម្ទេស១ខាំកិនឱ្យម៉ត់ លាយជាមួយទឹក១លីត្រលាយសាប៊ូ១២ក្រាម បន្ទាប់មកយកវាទៅលាយទឹកធម្មតាចំនួន ៥លីត្រ និងយកទៅបាញ់លើសំណាប ឬសន្ទូង។ ម្យ៉ាងវិញទៀត យើងអាចផ្សំថ្នាំរុក្ខជាតិផ្សេងទៀត ដូចជាៈ ម្ទេសកន្លះគីឡូ ដោយយើងស្ងោរជាមួយទឹក ៣លីត្រ រំងាស់រយៈពេល២០នាទី ហើយបន្ថែមសាប៊ូ៣០ក្រាមចូលទៅក្នុងល្បាយនោះ បន្ទាប់មកចាក់ទឹកធម្មតា ១០លីត្រចូល ទុកឱ្យត្រជាក់ ហើយយកទៅបាញ់លើសំណាប ឬសន្ទូង បើគ្មានភ្លៀងបាញ់ម្តងក្នុងមួយសប្តាហ៍ បើមានបាញ់ ២ទៅ៣ដង។

**ខ.សត្វមមាចត្នោត** ជាសត្វល្អិតចង្រៃនៃដំណាំស្រូវមានខ្លួនតូចទំហំប៉ុនគ្រាប់អង្ករ និងមានពណ៌ត្នោតនៅពេលពេញវ័យ។ ការបំផ្លាញដំណាំស្រូវរបស់មមាចត្នោតមានពីរបែបគឺ ទីមួយជញ្ជក់យកជ័រពីដើមស្រូវរហូតដល់ដើមស្រូវខ្សោះខ្លោចងាប់ និងទីពីរគឺជាភ្នាក់ងារចម្លងជំងឺវីរុស ហើយវាមានពីរប្រភេទគឺ ជម្ងឺតឿស្មៅ និងជំងឺតឿរួញស្លឹក។

❖ **វដ្តជីវិត** នៅក្នុងប្រព័ន្ធបរិស្ថាន យើងសង្កេតថាមមាចត្នោតពេញវ័យមានស្លាបវែង ហើយខ្លះមានស្លាបខ្លីទាំងញី និងឈ្មោល។ សត្វចង្រៃប្រភេទនេះ ដែលមានស្លាបខ្លីមិនអាចហើរបានទេ ប៉ុន្តែវាអាចរស់នៅបាន និងបង្កើតកូនចៅនៅក្នុងស្រែ ចំណែកឯសត្វមមាចមានស្លាបវែងអាចផ្លាស់ទីរកចំណីកន្លែងផ្សេងបាន។ សត្វមមាចត្នោតមានវដ្តជីវិត៣៥ថ្ងៃ ហើយមមាចញីស្លាបវែងអាចពងបាន ១០០ពង និងមមាចត្នោតញីស្លាបខ្លីអាចពងបាន ៣០០ពង ក្នុងពេល២សប្តាហ៍នៃជីវិតរបស់វា។ ពងរបស់សត្វនេះមានពណ៌ស ហើយរាងរបស់វាដូចស្និតចេកក្នុងស្រទបស្លឹក ឬទ្រនុងស្លឹកពី៨-១៦ពង។ កូនសត្វនេះមានសនៅពេលដំបូងហើយវានឹងមានពណ៌ត្នោតពេលវាធំឡើង។

❖ **ស្នាមបំផ្លាញ** សត្វប្រភេទនេះ ទាំងកូន និងមេជញ្ជក់រុក្ខរសពីដើមស្រូវនៅផ្នែកគល់។ យើងសង្កេតឃើញថា គល់ស្រូវនឹងមានដុះផ្សិតស ហើយប្រែទៅជាខ្មៅ។ ការបំផ្លាញនេះបានធ្វើឱ្យដើមស្រូវក្លាយជាស្រពោន ខ្លោច ហើយងាប់។

❖ **វិធានការការពារ** ដើម្បីការពារប្រជាកសិករត្រូវភ្ជួរលុបស្មៅ និងស្រូវដុះសារថ្មីបន្ទាប់ពីពួកគាត់ប្រមូលផលហើយ ដូច្នេះវាអាចបំបាត់ប្រភពជម្ងឺវីរុសបាន។ យើងមិនត្រូវដាំស្រូវលើផ្ទៃដីនេះឱ្យលើសពី២ដងក្នុងឆ្នាំ ដើម្បីកាត់បន្ថយចំណី និងជម្រករបស់វា។ ប្រើប្រាស់ជីអ៊ុយរ៉េក្នុងកម្រិតមធ្យម ដោយបាចជា៣ដំណាក់កាល គឺ១ថ្ងៃមុនពេលស្ទូង សំណាបបែកគុម្ព និងកំណារកំណើតកួរ។ ការប្រើប្រាស់ពូជធន់ IR កេសរ ទងឈូក ខា៩ អាយ៉ាភ្នំ ស្រូវក្រហម និងផ្កាស្លា ហើយយើងគប្បីធ្វើការដាំដុះឱ្យស្របពេលគ្នា និងដាំដុះឱ្យដុះលូតលាស់ល្អ។ ថែរក្សាសត្វមានប្រយោជន៍ដូចជា ស្រឹងគោ ស្រឹងទឹកជើងវែង ដង្កូវអណ្តើកមាស និងពីងពាង ព្រោះសត្វប្រភេទបំផ្លាញសត្វ មមាចត្នោត។ ថ្នាលគ្របដោយស្បៃនៅពេលល្ងាចដល់ព្រលឹម ពីព្រោះសត្វមមាចត្នោតផ្លាស់ទីនៅ ពេលល្ងាច។

❖ **វិធានការកម្ចាត់** មុនពេលសាបស្រូវ ប្រជាកសិករគប្បីតាមដានប្រជាកររបស់សត្វមមាចត្នោត ដោយប្រើអន្ទាក់ភ្លើង ចាប់ពីម៉ោង៥:៣០ ឬ៦:០០ល្ងាច រហូតដល់ម៉ោង៨:៣០ ឬ៩:០០យប់ បន្ទាប់មកប្រមូលសត្វមមាចត្នោតនេះ យកមករាប់ និងកត់ត្រាទិន្នន័យទុកជារៀង រាល់ថ្ងៃ

បើចំនួនកើនឡើង កុំទាន់សាប ប៉ុន្តែនៅពេលថយចុះ យើងចាប់ផ្តើមត្រាំគ្រាប់សាប។ យើងត្រូវបង្ហូរទឹកចេញ ទុកឱ្យស្ងួត រយៈពេល២-៣ថ្ងៃ ទើបដាក់ទឹកចូលវិញ។ ពន្លិចទឹកឱ្យលិច ចុងស្រូវ ឬបង្អាបស្រូវ ដោយធ្វើការអូសដោយស្បៃមុង ឬប្រើប្រាស់អន្ទាក់ភ្លើង ដោយដាក់ឱ្យឆ្ងាយ ពីស្រែ។ ម្យ៉ាងវិញទៀត យើងអាចប្រើប្រាស់ Butil ប្រឆាំងកាសកប្រើនៅពេលសត្វមមាចដំណាក់កាលកូន។

**គ. សត្វដង្កូវមូរស្លឹក** គឺជាសត្វស៊ីស្រូវមួយដែលអាចកើតមាននៅគ្រប់បរិស្ថានដំណាំស្រូវ។ វាកោសជាលិកាស្លឹកស្រូវផ្នែកខាងលើ ធ្វើឱ្យមាន ស្នាមសរៗ វែងៗជាច្រើននៅលើស្លឹកស្រូវ។ នៅពេលដែលមានការបំផ្លាញខ្លាំងគេឃើញមានរមូរស្លឹក និងស្នាមសរៗជាច្រើននៅលើស្លឹកស្រូវ។ វាច្រើនកើតមាននៅក្នុងស្រែ ដែលនៅក្រោមម្លប់ឈើប្រើប្រាស់ជីអាសូតច្រើន និងស្រែដែលស្ងួញឹកពេក។

- **វដ្តជីវិត** សត្វប្រភេទនេះមានវដ្តជីវិតរបស់វារយៈពេល ៣-១០ថ្ងៃ ហើយមេអំបៅញីអាចពងបានប្រហែលជា ៣០០ពង។ មេអំបៅនៃដង្កូវមូរស្លឹកនេះមានពណ៌លឿង នៅពេលវាទំសម្រាកស្លាបរបស់វាមានរាងជាត្រីកោណដែលមានជ្រុងស្មើគ្នា។ ហើយពងរបស់វាមានរាងសំប៉ែត និងពងរាយមួយៗ ផ្តុំជាម៉ុំៗ ដែលមានពងចាប់ពី ១០-១២ពង។ ដង្កូវមូរស្លឹកស្រូវជុំវិញខ្លួនរបស់វា ដោយវាបានភ្ជាប់គែមស្លឹកស្រូវដោយសសៃសូត្រ នៅពេលដែលវាសកម្តងៗ ដង្កូវនេះនឹងធ្វើការផ្លាស់ប្តូរទៅស្លឹកថ្មីមួយទៀតហើយវាមានដឹកខឿនៅក្នុងបំពង់ស្លឹករមូរ។ ដង្កូវវ័យចំណាស់មានពណ៌បៃតងលឿង និងក្បាលពណ៌ត្នោតក្រមៅ។
- **ស្នាមបំផ្លាញ** យើងសង្កេតឃើញថាស្លឹក ដែលមូរដោយដង្កូវនេះ(មូរពាក់កណ្តាលស្លឹក) ហើយវានឹងបណ្តាលឱ្យថយចុះសកម្មភាពរស្មីសំយោគ បន្ទាប់វាស៊ីបកជាលិកាផ្ទៃស្លឹកដែលនាំឱ្យលេចនូវឆ្នូតពណ៌សថ្លាវែងៗ ហើយស្លឹកស្រូវដែលបានបំផ្លាញខ្លាំងធ្ងន់ធ្ងរនឹងស្ងួតខ្លោច និងងាប់។
- **វិធានការការពារ** ប្រជាកសិករយើងត្រូវប្រើប្រាស់ជីអាសូតឱ្យបានសមស្រប និងមិនត្រូវធ្វើការដាំដុះនៅក្រោមម្លប់ឈើ ព្រមទាំងសម្អាតស្មៅ ឬស្រងែ ដែលនៅជុំវិញបរិវេណស្រែ និងក្នុងស្រែមុនពេលដាំដុះ និងបន្ទាប់ពីប្រមូលផលស្រូវ។ យើងត្រូវថែរក្សាសត្វមានប្រយោជន៍ដូចជា៖ ខ្មុតដី ចង្រិត កណ្តុរ ពីងពាង ឪម៉ាល់ប៉ារ៉ាស៊ីត និងអណ្តើកមាសជាដើម ពិសេសយើងគួរតែស្វែងបែបប្រពលវប្បកម្មដំណាំស្រូវ។

➢ **វិធានការកម្ចាត់** យើងត្រូវយកមែកឈើ ដែលមានបន្លាអូសឱ្យរហែកស្លឹករមូរចោល និងកាត់ចុងស្រុងចោលនៅពេលលូតលាស់។

**ឃ.ជម្ងឺសារទឹក:** ជាប្រភេទជម្ងឺរាតត្បាតយ៉ាងសាហាវមួយក្នុងចំណោមជម្ងឺឆ្លងនានាដែលវាបង្កឡើងដោយបាក់តេរី ប៉ាស្ទ័រ៉េលឡា ម៉ុលតូសីដា(Pasteurella Multocida)។ ជម្ងឺនេះភាគច្រើនកើតឡើងនៅតំបន់ទំនាបសើមជោគជាំទឹក ពិសេសនៅដើមរដូវភ្លៀង វាកើតលើសត្វគ្រប់ ប្រភេទដូចជា គោ ក្របី ចៀម ពពែ ជាដើម។

➢ **រោគសញ្ញា**



○ <u>កម្រិតស្រាល</u>

- ស្វិតរលាកស្រាល
- ហើមសន្លាក់ជើង ស្បែកក្រហមរបកទាំងផ្ទាំង
- ជម្ងឺអូសបន្លាយបាន ៤-៥អាទិត្យទើបងាប់

○ <u>កម្រិតមធ្យម</u>

- ស៊ីតិច ឬមិនស៊ី ក្តៅខ្លាំង
- ហើមបំពង់ក ក្អកស្ងួត ទឹកមាត់ សំបោខាប់
- លាមករាគលាយឈាម
- កន្លែងស្បែកស្តើង(ក ទ្រូង ពោះ កៀនភ្លៅ) មានពណ៌ក្រហម ឬផ្ទាំងខៀវ។

○ <u>កម្រិតធ្ងន់</u>

- សត្វមានអាការៈគ្រុនក្តៅ សីតុណ្ហភាព ៤១-៤២អង្សាសេ
- ក មុខ និងច្រមុះហើមឡើងលឹប
- ក្បាលសំយ៉ុង ពិបាកដកដង្ហើម
- ស៊ីចំណីតិច ឬមិនស៊ីសោះ
- អាចងាប់ក្នុងរយៈពេល ១-២ថ្ងៃ។



➢ **វិធីការពារ**

- ធ្វើអនាម័យក្រោល ឬទ្រុងឱ្យបានស្អាតជានិច្ច
- ត្រូវចាក់វ៉ាក់សាំងការពារជម្ងឺឱ្យបានទៀងទាត់តាមប្រតិទិនចាក់ថ្នាំការពារ
- ត្រូវពិនិត្យគុណភាពចំណី និងតាមដានសុខភាពសត្វ
- ត្រូវរាយការណ៍ទៅភ្នាក់ងារសុខភា ពសត្វភូមិ ករណីដែលមានសត្វឈឺ

- ត្រូវបំបែកសត្វដែលឈឺចេញពីហ្វូង
- ត្រូវសម្លាប់មេរោគក្នុងទ្រុង ដោយប្រើកំបោស ឬបាញ់ថ្នាំរម្ងាប់មេរោគ។

**ង.ជម្ងឺអុតក្ដាម:** ជាជម្ងឺឆ្លងសត្វគ្រប់ប្រភេទកើតតាមចង្អែបជើងទាំងសត្វស្រុក និងសត្វព្រៃ។

- **រោគសញ្ញា**

- សត្វមិនសូវស៊ីចំណី ដើរខ្ញើចៗ ព្រោះឈឺជើង
- មានពងដោរលើក្រអូមមាត់ អណ្ដាត់ បបូរមាត់ បំពង់ក ចុងច្រមុះ ចង្អែបជើងជាដើម
- ពងដោរនេះអាចបាត់ទៅវិញ ហើយក្លាយជាដំបៅស៊ីជ្រៅ នាំឱ្យរលួយក្រចក។

- **ការការពារ**

- ចាក់វ៉ាក់សាំងការពារជម្ងឺ
- ត្រូវបំប៉ន់ចំណី ទឹក ទាំងអបរិមាណ និងគុណភាពឱ្យបានគ្រប់គ្រាន់
- ត្រូវធ្វើអនាម័យសត្វឱ្យបានជាប្រចាំ
- ត្រូវដុសលាងដំបៅ ពងដោរ ដោយទឹកម្ជូរ
- រាយការណ៍ជូនភ្នាក់ងារសត្វភូមិដើម្បីព្យាបាល។

# សេចក្ដីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

តាមរយៈការចុះកម្មសិក្សា ធ្វើការស្រាវជ្រាវលើប្រធានបទ "ការអភិវឌ្ឍវិស័យកសិកម្មខេត្តស្វាយរៀង" ក្រុមយើងខ្ញុំអាចវាយតម្លៃឃើញថាកសិកម្មនៅក្នុងខេត្តនេះ មានការរីកចម្រើនគួរឱ្យកត់សម្គាល់។ វាបានរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឱ្យសម្រេចនូវគោលដៅអភិវឌ្ឍន៍នានា ដូចជាវិស័យសេដ្ឋកិច្ច សន្តិសុខស្បៀង និងបរិស្ថានជាដើម។ ស្រូវ គឺជាដំណាំចម្បងជាងគេសម្រាប់ប្រជាកសិករនៅក្នុងខេត្តនេះ។ ចំពោះផលិតកម្មស្រូវនៅក្នុងខេត្តរយៈពេល៥ឆ្នាំចុងក្រោយនេះមានការរីកចម្រើនណាស់ដែរ ពោលគឺកើនឡើងបានជាង ៦ពាន់តោន(ធៀបឆ្នាំ២០១៨)។ ក្រៅពីនេះ ក៏មានការចិញ្ចឹមសត្វ ការដាំដំណាំចម្ការអំពៅ ដំឡូង កៅស៊ូ និងឪឡឹកផងដែរ។ ឯការចិញ្ចឹមសត្វមានការរីកលូតលាស់តែសត្វដែលមានតម្រូវការលើទីផ្សារប៉ុណ្ណោះ ដូចជាសត្វបក្សី គោ និងសត្វជ្រូកជាដើម។ មួយទៀត ការនេសាទវិញ ភាគច្រើនជាលក្ខណៈគ្រួសារប៉ុណ្ណោះ ហើយក៏មានការធ្វើវារីវប្បកម្ម គឺការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ និងសហគមន៍។

ទោះបីជាកសិកម្មនៅក្នុងខេត្តនេះមានការរីកចម្រើនលូតលាស់ក្តីក៏បញ្ហាប្រឈមនៅតែមានមិនចេះឈប់នោះទេ។ បញ្ហាទាំងនោះមានដូចជា៖ ការខ្វះខាតទឹកសម្រាប់ធ្វើស្រែ ចម្ការ ជាពិសេសនៅរដូវប្រាំង ដីហិរ ខ្វះជីជាតិ ការផ្ទុះឡើងនៃជម្ងឺឆ្លងនៃសត្វ ហើយបញ្ហា ដែលសំខាន់នោះគឺបញ្ហាទីផ្សារ និងតម្លៃរបស់កសិផល។ ជាការឆ្លើយតបបញ្ហាទាំងអស់នេះ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបានសហការជាមួយមន្ទីរពាក់ព័ន្ធ ព្រមទាំងដៃគូអភិវឌ្ឍន៍នានាដោយយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការដោះស្រាយបញ្ហាប្រឈមក្នុងវិស័យនេះ។ សកម្មភាពទាំងនោះមានដូចជា៖ ការស្តារឡើងវិញនូវប្រឡាយចាស់ៗ ការចុះវ៉ាក់សាំងសត្វ ការចុះពង្រឹងសហគមន៍នេសាទ ព្រមទាំងធ្វើការហាមឃាត់នូវការនាំចូលជ្រូកខុសច្បាប់ពីប្រទេសជិតខាងដើម្បីជួយសម្រួលដល់ផលិតផលសត្វរបស់ខេត្ត។ ក្រៅពីនេះក៏បានខិតខំបង្កើតសហគមន៍នេសាទបន្ថែមទៀត ព្រមទាំងការទប់ស្កាត់នូវបទល្មើសនេសាទគ្រប់ទម្រង់ ដើម្បីជានានូវកំណើនក្នុងវិស័យជលផល។

## ២. អនុសាសន៍

តាមរយៈការសិក្សាស្រាវជ្រាវ និងបានចុះកម្មសិក្សានៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀងផ្ទាល់មក ក្រុមយើងខ្ញុំសូមចូលរួមជាយោបល់មួយចំនួនដើម្បីរួមចំណែកក្នុងការអភិវឌ្ឍកសិកម្មក្នុងខេត្តនេះដូចខាងក្រោម៖

- ជម្រុញការស្តារប្រព័ន្ធទឹកដែលមានស្រាប់ និងសិក្សាពីការជីកប្រព័ន្ធធារាសាស្ត្របន្ថែម។
- សិក្សាពីការទាញយកទឹកពីទន្លេវ៉ៃគោដោយការជីកប្រឡាយមេពីទន្លេបន្ថែម។
- ពង្រីកភាពជាដៃគូឱ្យបានច្រើនបន្ថែមទៀត ជាមួយនឹងអង្គការផ្សេងៗដើម្បីជួយដល់កសិករទាំងបច្ចេកទេស និងសម្ភារៈ ឬទុនផ្សេងៗ ដូចជាទុនដើម្បីជីកអណ្តូងទឹកក្នុងស្រែជាដើម។
- ជម្រុញការផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីៗ ដល់សហគមន៍កសិករ។
- ពង្រឹងការអនុវត្តច្បាប់ឱ្យបានល្អបន្ថែមទៀតលើការនាំចូលនូវរាល់ផលិតផលកសិកម្មពីបរទេស។
- អាជ្ញាធរពាក់ព័ន្ធគួរសិក្សាអំពីការកសាងឃ្លាំងស្តុកផលិតផលកសិកម្មក្នុងខេត្តបន្ថែមសម្រាប់ប្រមូលទិញផលិតផលកសិកម្ម នៅពេលជន់ជោរលើទីផ្សារដើម្បីទប់ស្កាត់ការធ្លាក់ចុះនៃតម្លៃកសិផល។
- មន្ទីរគួរជំរុញការផ្សព្វផ្សាយបន្ថែមទៀតពីវិធានការការពារ និងការដោះស្រាយបញ្ហាសមាសភាគចង្រៃដែលបំផ្លាញដំណាំតាមសហគមន៍កសិកម្មនៅមូលដ្ឋាន។
- មន្ត្រីជំនាញគួរយកការទុកដាក់ឱ្យបានល្អជាងនេះលើបញ្ហាសុខភាពសត្វ ជាពិសេសនៅមូលដ្ឋានដើម្បីបញ្ចៀសការកើតជម្ងឺឆ្លងនានា។
- មន្ទីរគួររៀបចំ និងរក្សាទុកនូវរបាយការណ៍ប្រចាំឆ្នាំឱ្យបានល្អ និងមានទម្រង់ច្បាស់លាស់។
- មន្ត្រីពាក់ព័ន្ធគួរអនុវត្តឱ្យបានល្អតាមតួនាទី និងគោលនយោបាយ យុទ្ធសាស្ត្រល្អៗដែលរាជរដ្ឋាភិបាល និងក្រសួងបានដាក់ចេញក្នុងគោលបំណងធ្វើឱ្យមានវឌ្ឍនភាពលើវិស័យមួយនេះ។

# ឯកសារយោង

# ឯកសារយោង


- សៀវភៅ សេដ្ឋកិច្ចកម្ពុជា (បណ្ឌិត ហង់ ជួន ណារ៉ុន,២០១៥)
- សៀវភៅ មូលដ្ឋានគ្រឹះនៃវិស្វកម្មកសិកម្ម(ខូយ រ៉ាដា, ២០១១)
- សៀវភៅ ប្រវត្តិខេត្តស្វាយរៀង( ឯកឧត្តម ម៉ែន វិបុល,២០១៩)

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១២ និងលើកទិសដៅ២០១៣
- របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៥ និងលើកទិសដៅ២០១៧
- របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៨ និងលើកទិសដៅ២០១៩
- របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១២ និងលើកទិសដៅ២០១៣

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វារៀង

- របាយការណ៍ស្តីពី លទ្ធផលនៃការងារកសិកម្មប្រចាំឆ្នាំ២០០៨ ទូទាំងខេត្តស្វាយរៀង និងលើកទិសដៅឆ្នាំ២០០៩
- របាយការណ៍ស្តីពី លទ្ធផលនៃការងារកសិកម្មប្រចាំឆ្នាំ២០០៩ ទូទាំងខេត្តស្វាយរៀង និងលើកទិសដៅឆ្នាំ២០១០
- របាយការណ៍ស្តីពី លទ្ធផលនៃការងារកសិកម្មប្រចាំឆ្នាំ២០១០ ទូទាំងខេត្តស្វាយរៀង និងលើកទិសដៅឆ្នាំ២០១១
- របាយការណ៍ស្តីពី លទ្ធផលនៃការងារកសិកម្មប្រចាំឆ្នាំ២០១១ ទូទាំងខេត្តស្វាយរៀង និងលើកទិសដៅឆ្នាំ២០១២
- របាយការណ៍ស្តីពី លទ្ធផលនៃការងារកសិកម្មប្រចាំឆ្នាំ២០១២ ទូទាំងខេត្តស្វាយរៀង និងលើកទិសដៅឆ្នាំ២០១៣
- របាយការណ៍ បូកសរុបលទ្ធផល ផលិតកម្មកសិកម្មប្រចាំឆ្នាំ២០១៣ និងលើកទិសដៅឆ្នាំ២០១៤

- របាយការណ៍ បូកសរុបលទ្ធផល ផលិតកម្មកសិកម្មប្រចាំឆ្នាំ២០១៤ និងលើកទិសដៅឆ្នាំ២០១៥
- របាយការណ៍ បូកសរុបលទ្ធផល ផលិតកម្មកសិកម្មប្រចាំឆ្នាំ២០១៥ និងលើកទិសដៅឆ្នាំ២០១៦
- របាយការណ៍ បូកសរុបលទ្ធផល ផលិតកម្មកសិកម្មប្រចាំឆ្នាំ២០១៦ និងលើកទិសដៅឆ្នាំ២០១៧
- របាយការណណ៍ស្តីពី លទ្ធផលការងារផលិតកម្មកសិកម្មប្រចាំឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨
- របាយការណ៍ស្តីពី លទ្ធផលការងារផលិតកម្មកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៨ ទូទាំងខេត្តស្វាយរៀង និងទិសដៅឆ្នាំ២០១៩
- ឯកសារព័ត៌មានស្តីពី ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៩ ខេត្តស្វាយរៀង(មន្ទីរផែនការខេត្តស្វាយរៀង ២០១៩)
- កម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៩-២០២១ ខេត្តស្វាយរៀង (អនុម័ក្នុងកិច្ចប្រជុំសាមញ្ញលើកទី៥៥ របស់ក្រុមប្រឹក្សាខេត្ត ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៩)
- សារណាបញ្ចប់ការសិក្សា ការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជា(ឡៃ បូរ៉ាពីន,២០១៧)
- https://www.mef.gov.kh
- https://vayofm.com/news/detail/79104-956158587.html
- http://m.freshnewsasia.com/index.php/en/localnews/111666-2019-01-28-07-34-47.html
- https://cambonomist.com/news/cassava-prices-plummet/

# ឧបសម្ព័ន្ធ

# ព្រះរាជក្រឹត្យស្ដីពីការបង្កើតខេត្តស្វាយរៀង និងបែងចែក

# ស្រុក ខណ្ឌ ក្នុងខេត្តស្វាយរៀង (ឧបសម្ព័ន្ធទី១)

ORDONNANCE ROYALE

J.49.

NOUS

Préa bat Samdach Préa SISOWATH Chamchakrapong Harirêach Barminthor Phouvanay

Kraykeofa Soulalay Préa Chau Crung Campuchéa Thippedey

ROI DU CAMBODGE

Vu l'Ordonnance royale du II Juillet 1897, sur l'Administration générale du Royaume;

Vu l'ordonnance royale du 3 juillet 1905, fixant les attributions du Conseil des Ministres;

Vu l'ordonnance royale N° 102 du II décembre 1921, portant organisation des formations administrayives indigènes des circonscriptions résidentielles du Cambodge;

Vu la délibération du Conseil des Ministres présidé par M. le Résident Supérieur de la République Française au Cambodge dans sa 433ème séance plénière en date du 30 Mars 1922;

Vu l'entente intervenue entre M. le Résident Supérieur et Nous;

Sur la proposition du Conseil des Ministres,

ORDONNONS:

Article [illegible] - [illegible] circonscription résidentielle de Soai-Rieng telle qu'elle [illegible]ellement, est constituée en un seul Khet qui porte [illegible] [illegible]i-Rieng et qui a pour chef-lieu le siège de [illegible]

Artic[illegible] [illegible] Soai-Rieng ne comporte qu'un seul Srok :

Le Srok [illegible], chef-lieu Prey-Chhlac, qui est constitué par les provinces actuelles de Romduol, Soai-Téap et Roméas-Hêk.

Article 3.- Le Srok de Romduol est dévisé en trois Khands dont le ressort respectif est déterminé par l'ensemble des [illegible] qui les composent .

I°- KHAND DE ROMDUOL, Chef-lieu Prey-Chhlac.

Ressort : les Khums de :

ព្រះរាជក្រឹត្យស្ដីពីការបង្កើតខេត្តស្វាយរៀងនិងបែងចែក
ស្រុក ខណ្ឌ ក្នុងខេត្តស្វាយរៀង

# ផែនទីខេត្តស្វាយរៀង (ឧបសម្ព័ន្ធទី២)

## ផែនទី ខេត្តស្វាយរៀង




ប្រភព៖ *មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត*

# ផលិតកម្មដំណាំស្រូវរយៈពេល១០ឆ្នាំ( ឧបសម្ព័ន្ធទី៣ )

## ផលិតកម្មដំណាំស្រូវរយៈពេល ១០ ឆ្នាំ ២០០៨-២០១៧

ឧបសម្ព័ន្ធទី ១៣

| ឆ្នាំ-កំរិតកំណត់ | ឯកតា | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | មធ្យមភាគ ១០ឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| **ផ្ទៃដីដាំដុះប្រចាំឆ្នាំ** | ហត | **2,719,080** | **2,795,892** | **2,968,529** | **3,007,545** | **3,052,420** | **3,055,507** | **3,051,412** | **3,118,160** | **3,206,523** | **3,335,929** | **3,031,100** |
| - វស្សា | ហត | *2,334,228* | *2,391,016* | *2,496,569* | *2,512,038* | *2,567,723* | *2,564,572* | *2,561,957* | *2,599,586* | *2,657,768* | *2,739,446* | *2,542,490* |
| - ប្រាំង | ហត | *384,852* | *404,876* | *471,960* | *495,507* | *484,697* | *490,935* | *489,455* | *518,574* | *548,755* | *596,483* | *488,609* |
| **ផ្ទៃដីប្រមូលផលប្រចាំឆ្នាំ** | ហត | **2,674,603** | **2,777,323** | **2,766,617** | **2,980,297** | **2,968,967** | **3,028,836** | **3,025,630** | **3,099,769** | **3,189,485** | **3,248,061** | **2,975,959** |
| - វស្សា | ហត | *2,290,552* | *2,372,519* | *2,294,784* | *2,484,832* | *2,485,521* | *2,537,976* | *2,536,175* | *2,581,255* | *2,641,637* | *2,654,314* | *2,487,956* |
| - ប្រាំង | ហត | *384,051* | *404,804* | *471,833* | *495,465* | *483,446* | *490,860* | *489,455* | *518,514* | *547,848* | *593,747* | *488,002* |
| **ទិន្នផលប្រចាំឆ្នាំ** | ត/ហត | **2.836** | **2.970** | **3.173** | **3.117** | **3.163** | **3.079** | **3.085** | **3.211** | **3.298** | **3.353** | **3.13** |
| - វស្សា | ត/ហត | *2.620* | *2.760* | *2.920* | *2.872* | *2.925* | *2.815* | *2.827* | *2.959* | *3.047* | *3.094* | *2.88* |
| - ប្រាំង | ត/ហត | *4.126* | *4.201* | *4.406* | *4.349* | *4.383* | *4.443* | *4.422* | *4.465* | *4.508* | *4.512* | *4.38* |
| **បរិមាណផលប្រចាំឆ្នាំ** | តោន | **7,585,870** | **8,249,452** | **8,779,365** | **9,290,940** | **9,389,961** | **9,324,416** | **9,335,284** | **9,952,270** | **10,518,339** | **10,891,735** | **9,331,763** |
| - វស្សា | តោន | *6,001,385* | *6,548,709* | *6,700,439* | *7,136,139* | *7,271,251* | *7,143,521* | *7,170,684* | *7,636,906* | *8,048,797* | *8,212,893* | *7,187,072* |
| - ប្រាំង | តោន | *1,584,485* | *1,700,743* | *2,078,926* | *2,154,801* | *2,118,710* | *2,180,896* | *2,164,600* | *2,315,364* | *2,469,542* | *2,678,842* | *2,144,691* |
| **ត្រូវការស្បៀងក្នុង១ឆ្នាំ** | តោន | **1,979,214** | **2,076,542** | **2,108,022** | **2,142,178** | **2,137,878** | **2,178,050** | **2,222,078** | **2,266,335** | **2,298,001** | **2,329,364** | **2,173,766** |
| ស្បៀងសល់ ឬខ្វះ (អង្ករ) | តោន | **2,244,598** | **2,516,752** | **2,780,328** | **3,031,017** | **3,090,452** | **3,013,783** | **2,975,809** | **3,275,089** | **3,558,612** | **3,735,153** | **3,022,159** |
| ស្បៀងសល់ ឬខ្វះ (ស្រូវ) | តោន | *3,507,185* | *3,932,425* | *4,344,263* | *4,735,964* | *4,828,832* | *4,709,036* | *4,649,702* | *5,117,327* | *5,560,331* | *5,836,177* | **4,722,124** |

# ស្ថិតិ ផ្ទៃដី ផលិតផល ទិន្នផល និងការនាំចេញកៅស៊ូប្រចាំឆ្នាំ២០០១- ២០១៨( ឧបសម្ព័ន្ធទី៤)

## ស្ថិតិ ផ្ទៃដី ផលិតផល ទិន្នផល និងការនាំចេញកៅស៊ូ ឆ្នាំ២០០១-២០១៨

ឧបសម្ព័ន្ធទី ២៨

| ឆ្នាំ | សរុបផ្ទៃដី (ហិកតា) | ផ្ទៃដីចៀរ (ហិកតា) | ផលិតផល (តោន) | ទិន្នផល (គ.ក្រ/ហ.ត/ឆ្នាំ) | នាំចេញ (តោន) |
|---|---|---|---|---|---|
| 2001 | 51,458 | 37,680 | 38,562 | 1,023 | 35,672 |
| 2002 | 55,582 | 36,773 | 32,384 | 881 | 36,774 |
| 2003 | 53,527 | 33,696 | 32,382 | 961 | 32,764 |
| 2004 | 54,209 | 31,590 | 33,770 | 1,069 | 33,558 |
| 2005 | 60,406 | 30,402 | 29,464 | 969 | 29,950 |
| 2006 | 69,994 | 32,390 | 32,077 | 990 | 31,184 |
| 2007 | 82,059 | 30,491 | 32,975 | 1,081 | 33,121 |
| 2008 | 107,901 | 34,313 | 37,050 | 1,080 | 36,000 |
| 2009 | 127,723 | 34,135 | 37,380 | 1,095 | 36,500 |
| 2010 | 181,433 | 38,406 | 42,250 | 1,100 | 42,000 |
| 2011 | 213,104 | 45,163 | 51,339 | 1,137 | 44,969 |
| 2012 | 280,355 | 55,361 | 64,525 | 1,166 | 59,917 |
| 2013 | 328,771 | 78,493 | 85,244 | 1,086 | 86,052 |
| 2014 | 357,809 | 90,545 | 97,054 | 1,072 | 100,151 |
| 2015 | 388,955 | 111,232 | 126,861 | 1,141 | 128,047 |
| 2016 | 432,734 | 126,995 | 145,200 | 1,143 | 145,100 |
| 2017 | 436,340 | 170,233 | 193,285 | 1,135 | 188,832 |
| 2018 | 436,684 | 201,950 | 220,101 | 1,090 | 217,500 |

# ស្ថានភាពប្រជាសាស្ត្រនៅក្នុងខេត្តស្វាយរៀង២០១៩ (ឧបសម្ព័ន្ធទី៥)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងផែនការ
មន្ទីរផែនការខេត្តស្វាយរៀង

## តារាងស្ថិតិប្រជារាស្ត្រ តាមក្រុង-ស្រុក នៃខេត្តស្វាយរៀង ដើមឆ្នាំ២០១៩

(ប្រភព៖ *ទិន្នន័យមូលដ្ឋានឃុំ-សង្កាត់ ឆ្នាំ២០១៨*)

| លេខកូដ | ក្រុង-ស្រុក | គ្រួសារសរុប | ប្រជារាស្ត្រសរុប | | ក្រុមអាយុពី០-១៤ឆ្នាំ | | ក្រុមអាយុពី១៥-១៧ឆ្នាំ | | ក្រុមអាយុពី១៨-៦០ឆ្នាំ | | ក្រុមអាយុ ៦១ឆ្នាំឡើង | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 20 | ខេត្តស្វាយរៀង | 149,891 | 634,636 | 326,329 | 179,414 | 89,315 | 39,595 | 19,747 | 353,060 | 182,833 | 62,567 | 34,434 |
| 2001 | ចន្ទ្រា | 7,720 | 31,425 | 15,730 | 9,348 | 4,519 | 2,002 | 943 | 17,367 | 8,772 | 2,708 | 1,496 |
| 2002 | កំពង់រោទិ៍ | 18,878 | 74,737 | 38,523 | 21,708 | 10,705 | 4,969 | 2,461 | 41,281 | 21,648 | 6,779 | 3,709 |
| 2003 | រំដួល | 14,111 | 61,735 | 31,529 | 16,897 | 8,509 | 3,941 | 1,998 | 34,281 | 17,358 | 6,616 | 3,664 |
| 2004 | រមាសហែក | 33,008 | 143,513 | 73,810 | 39,051 | 19,447 | 7,806 | 3,840 | 81,510 | 42,325 | 15,146 | 8,198 |
| 2005 | ស្វាយជ្រំ | 39,770 | 168,499 | 87,376 | 48,906 | 24,349 | 10,601 | 5,267 | 93,268 | 48,889 | 15,724 | 8,871 |
| 2006 | ស្វាយរៀង | 10,915 | 47,829 | 24,788 | 12,733 | 6,402 | 3,290 | 1,674 | 27,536 | 14,308 | 4,270 | 2,404 |
| 2007 | ស្វាយទាប | 15,171 | 64,352 | 32,550 | 18,537 | 9,042 | 4,047 | 2,031 | 34,547 | 17,714 | 7,221 | 3,763 |
| 2008 | បាវិត | 10,318 | 42,546 | 22,023 | 12,234 | 6,342 | 2,939 | 1,533 | 23,270 | 11,819 | 4,103 | 2,329 |

ថ្ងៃ ខែ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ស្វាយរៀង,ថ្ងៃទី ខែ ឆ្នាំ២០១៩
**ប្រធានមន្ទីរផែនការខេត្ត**

**ថោង សាមាន**

ស្វាយរៀង, ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩
**អ្នកធ្វើតារាង**

**ខឹម សុផារ៉ាច័ន**

# រចនាសម្ព័ន្ធដឹកនាំរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង( ឧបសម្ព័ន្ធទី ៦)



# ស្ថិតិ ផ្ទៃដីដំណាំដុះ ទិន្នផល និង អតិរេកស្រូវក្នុងខេត្តស្វាយរៀងឆ្នាំ ២០០៨-២០១៨( ឧបសម្ព័ន្ធទី  ៧)

(ផ្ទៃដីគិតជា ហិចតា, បរិមាណផលគិតជា តោន)

| ឆ្នាំ | ផ្ទៃដីដាំដុះស្រូវ សរុប | ផ្ទៃដីដាំដុះស្រូវ រដូវវស្សា | ផ្ទៃដីដាំដុះស្រូវ រដូវប្រាំង | ផ្ទៃដីប្រមូលផល ស្រូវរដូវវស្សា | ផ្ទៃដីប្រមូលផល ស្រូវរដូវប្រាំង | ផ្ទៃដីប្រមូល ផល សរុប | ទិន្នផលស្រូវ ប្រចាំឆ្នាំ (ត/ហ.ត) | បរិមាណ ផលស្រូវ (តោន) | អតិរេកស្រូវ (តោន) |
|---|---|---|---|---|---|---|---|---|---|
| 2008 | 175,241 | 160,413 | 14,828 | 160,250 | 14,828 | 175,078 | 2.388 | 418,141 | 163,719 |
| 2009 | 180,532 | 165,015 | 15,517 | 164,497 | 15,469 | 179,966 | 2.465 | 443,679 | 177,877 |
| 2010 | 183,638 | 167,178 | 16,460 | 167,178 | 16,240 | 183,418 | 2.559 | 469,320 | 189,778 |
| 2011 | 188,790 | 165,722 | 23,068 | 160,693 | 23,068 | 183,761 | 2.751 | 505,490 | 209,469 |
| 2012 | 187,549 | 166,720 | 20,829 | 166,551 | 21,811 | 188,362 | 2.820 | 528,915 | 222,897 |
| 2013 | 186,971 | 166,549 | 20,422 | 166,313 | 20,400 | 186,713 | 2.880 | 539,202 | 214,534 |
| 2014 | 186,723 | 166,756 | 19,967 | 166,519 | 19,945 | 186,464 | 2.905 | 541,620 | 212,786 |
| 2015 | 187,893 | 167,946 | 19,947 | 167,658 | 19,947 | 187,605 | 2.810 | 527,036 | 293,454 |
| 2016 | 188,858 | 168,528 | 20,330 | 168,356 | 20,330 | 188,686 | 2.983 | 562,955 | 218,035 |
| 2017 | 188,168 | 167,529 | 20,639 | 167,105 | 20,639 | 187,744 | 2.994 | 562,144 | 214,662 |
| 2018 | 189,927 | 168,871 | 21,056 | 167,383 | 20,940 | 188,323 | 2.910 | 547,989 | 205,438 |

## តារាង ការចិញ្ចឹមសត្វ(ក្បាល)ក្នុងខេត្តស្វាយរៀងឆ្នាំ ២០០៨-២០១៨ (ឧបសម្ព័ន្ធទី៨)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|---|---|---|---|---|---|---|
| គោ | 124,793 | 158,168 | 159,281 | 159,342 | 159,985 | 164,775 | 166,428 | 124,922 | 122,251 | 124,216 | 137,863 |
| ក្របី | 130,430 | 123,895 | 119,621 | 119,805 | 120,360 | 120,210 | 122,554 | 109,282 | 105,892 | 107,449 | 96,275 |
| ជ្រូក | 351,851 | 326,456 | 155,595 | 156,955 | 156,783 | 156,959 | 186,657 | 131,216 | 140,341 | 147,472 | 153,553 |
| មាន់ទា | 1,501,975 | 1,415,755 | 1,194,372 | 1,502,003 | 1,209,781 | 1,502,003 | 1,584,502 | 1,116,702 | 1,123,062 | 2,901,335 | 2,356,231 |

## តារាង ស្ថិតិការប្រែប្រួលកសិកម្មក្នុងខេត្តស្វាយរៀង( ឧបសម្ព័ន្ធទី៩ )

| ឆ្នាំ | ផ្ទៃដីដាំដុះ | បរិមាណផលស្រូវ |
|---|---|---|
| 2008 | 175241 | 418141 |
| 2009 | 180532 | 443679 |
| 2010 | 183638 | 469320 |
| 2011 | 188790 | 505490 |
| 2012 | 187549 | 528915 |
| 2013 | 186971 | 539202 |
| 2014 | 186723 | 541620 |
| 2015 | 187695 | 527036 |
| 2016 | 188858 | 562955 |
| 2017 | 188168 | 562144 |
| 2018 | 189927 | 547989 |

១. វិធីសាស្ត្រព្យាករណ៍កំណើនផ្ទៃដីដាំដុះ ដោយយកផ្ទៃដីដាំដុះរាល់ឆ្នាំ ជាអថេរត្រូវពន្យល់តាងដោយ y និងលំដាប់ឆ្នាំជាអថេរពន្យល់តាងដោយ x នោះយើងបានសមីការ y=-1948282.855+1060.163636x ដោយប្រើវិធីសាស្ត្រ Linear Regression

SUMMARY OUTPUT

| *Regression Statistics* | |
|---|---|
| Multiple R | 0.798891148 |
| R Square | 0.638227066 |
| Adjusted R Square | 0.598030073 |
| Standard Error | 2790.476817 |

| | |
|---|---|
| Observations | 11 |

ANOVA

| | *df* | *SS* | *MS* | *F* | *Significance F* |
|---|---|---|---|---|---|
| Regression | 1 | 123634163 | 123634162.9 | 15.87748296 | 0.0031833 |
| Residual | 9 | 70080848 | 7786760.865 | | |
| Total | 10 | 193715011 | | | |

| | *Coefficients* | *Standard Error* | *t Stat* | *P-value* | *Lower 95%* | *Upper 95%* | *Lower 95.0%* | *Upper 95.0%* |
|---|---|---|---|---|---|---|---|---|
| Intercept | -1948282.855 | 535582.51 | -3.63768946 | 0.005420342 | -3159854.7 | -736711.04 | -3159855 | -736711 |
| X Variable 1 | 1060.163636 | 266.06153 | 3.98465594 | 0.003183323 | 458.29065 | 1662.03662 | 458.2907 | 1662.037 |

២. វិធីសាស្ត្រព្យាករណ៍បរិមាណផលស្រូវ ដោយយកទិន្នផលស្រូវរាល់ឆ្នាំជាអថេរត្រូវពន្យល់តាងដោយ y និងលំដាប់ឆ្នាំជាអថេរពន្យល់តាងដោយ x នោះយើងបានសមីការ y=-26201059.24+ 13270.92727x ដោយប្រើប្រាស់វិធីសាស្ត្រ Linear Regression

SUMMARY OUTPUT

| *Regression Statistics* | |
|---|---|
| Multiple R | 0.901121896 |
| R Square | 0.812020671 |
| Adjusted R Square | 0.791134079 |
| Standard Error | 22322.75854 |
| Observations | 11 |

ANOVA

| | *df* | *SS* | *MS* | *F* | *Significance F* |
|---|---|---|---|---|---|
| Regression | 1 | 1.94E+10 | 1.94E+10 | 38.8776 | 0.000152 |

| | | | |
|---|---|---|---|
| Residual | 9 | 4.48E+09 | 4.98E+08 |
| Total | 10 | 2.39E+10 | |

| | *Coefficients* | *Standard Error* | *t Stat* | *P-value* | *Lower 95%* | *Upper 95%* | *Lower 95.0%* | *Upper 95.0%* |
|---|---|---|---|---|---|---|---|---|
| Intercept | -26201059.24 | 4284457 | -6.11537 | 0.000176 | -3.6E+07 | -1.7E+07 | -3.6E+07 | -1.7E+07 |
| X Variable 1 | 13270.92727 | 2128.392 | 6.235191 | 0.000152 | 8456.171 | 18085.68 | 8456.171 | 18085.68 |

## តារាស្ថិតិប្រែប្រួលចំនួនគោ ក្របី និងជ្រូកក្នុងខេត្តស្វាយរៀង( ឧបសម្ព័ន្ធទី១០ )

| ឆ្នាំ | គោ | ក្របី | ជ្រូក |
|---|---|---|---|
| 2008 | 124,793 | 130430 | 1,501,975 |
| 2009 | 158,168 | 123895 | 1,415,755 |
| 2010 | 159,281 | 119621 | 1,194,372 |
| 2011 | 159,342 | 119805 | 1,502,003 |
| 2012 | 159,985 | 120360 | 1,209,781 |
| 2013 | 164,775 | 120210 | 1,502,003 |
| 2014 | 166,428 | 122554 | 1,584,502 |
| 2015 | 124,922 | 109282 | 1,116,702 |
| 2016 | 122,251 | 105892 | 1,123,062 |
| 2017 | 124,216 | 107449 | 2,901,335 |
| 2018 | 137,863 | 96275 | 2,356,231 |

១. វិធីសាស្ត្រព្យាករណ៍កំណើនសត្វគោ ដោយយកចំនួនគោរាល់ឆ្នាំ ជាអថេរត្រូវពន្យល់តាងដោយ y និងលំដាប់ឆ្នាំជាអថេរពន្យល់តាងដោយ x នោះយើងបានសមីការ y=4609832.045-2217.681818x ដោយប្រើវិធីសាស្ត្រ Linear Regression

SUMMARY OUTPUT

| *Regression Statistics* | |
|---|---|
| Multiple R | 0.395122856 |
| R Square | 0.156122072 |
| Adjusted R Square | 0.062357857 |
| Standard Error | 18025.27857 |
| Observations | 11 |

ANOVA

| | *df* | *SS* | *MS* | *F* | *Significance F* |
|---|---|---|---|---|---|
| Regression | 1 | 5.41E+08 | 5.41E+08 | 1.66505 | 0.229087 |
| Residual | 9 | 2.92E+09 | 3.25E+08 | | |
| Total | 10 | 3.47E+09 | | | |

| | *Coefficients* | *Standard Error* | *t Stat* | *P-value* | *Lower 95%* | *Upper 95%* | *Lower 95.0%* | *Upper 95.0%* |
|---|---|---|---|---|---|---|---|---|
| Intercept | 4609832.045 | 3459632 | 1.332463 | 0.215459 | -3216400 | 12436064 | -3216400 | 12436064 |
| X Variable 1 | -2217.681818 | 1718.643 | -1.29037 | 0.229087 | -6105.52 | 1670.158 | -6105.52 | 1670.158 |

២. វិធីសាស្ត្រព្យាករណ៍កំណើនសត្វក្របី ដោយយកចំនួនក្របីរាល់ឆ្នាំ ជាអថេរត្រូវពន្យល់តាងដោយ y និងលំដាប់ឆ្នាំជាអថេរពន្យល់តាងដោយ x នោះយើងបានសមីការ y=5543722.764-2696.345455x ដោយប្រើវិធីសាស្ត្រ Linear Regression

SUMMARY OUTPUT

| *Regression Statistics* | |
|---|---|
| Multiple R | 0.899997209 |

| | |
|---|---|
| R Square | 0.809994977 |
| Adjusted R Square | 0.788883308 |
| Standard Error | 4565.538394 |
| Observations | 11 |

ANOVA

| | *df* | *SS* | *MS* | *F* | *Significance F* |
|---|---|---|---|---|---|
| Regression | 1 | 8E+08 | 8E+08 | 38.36717 | 0.00016 |
| Residual | 9 | 1.88E+08 | 20844141 | | |
| Total | 10 | 9.87E+08 | | | |

| | *Coefficients* | *Standard Error* | *t Stat* | *P-value* | *Lower 95%* | *Upper 95%* | *Lower 95.0%* | *Upper 95.0%* |
|---|---|---|---|---|---|---|---|---|
| Intercept | 5543722.764 | 876274.1 | 6.326471 | 0.000137 | 3561453 | 7525992 | 3561453 | 7525992 |
| X Variable 1 | -2696.345455 | 435.307 | -6.19412 | 0.00016 | -3681.08 | -1711.61 | -3681.08 | -1711.61 |

៣. វិធីសាស្ត្រព្យាករណ៍កំណើនសត្វជ្រូក ដោយយកចំនួនជ្រូករាល់ឆ្នាំ ជាអថេរត្រូវពន្យល់តាងដោយ y និងលំដាប់ឆ្នាំជាអថេរពន្យល់តាងដោយ x នោះយើងបានសមីការ y=32666315.24-16134.47273x ដោយប្រើវិធីសាស្ត្រ Linear Regression

SUMMARY OUTPUT

| *Regression Statistics* | |
|---|---|
| Multiple R | 0.700871085 |
| R Square | 0.491220278 |
| Adjusted R Square | 0.434689198 |
| Standard Error | 57405.91168 |
| Observations | 11 |

ANOVA

| | *df* | *SS* | *MS* | *F* | *Significance F* |
|---|---|---|---|---|---|
| Regression | 1 | 2.86E+10 | 2.86E+10 | 8.689384 | 0.01628 |
| Residual | 9 | 2.97E+10 | 3.3E+09 | | |
| Total | 10 | 5.83E+10 | | | |

| | *Coefficients* | *Standard Error* | *t Stat* | *P-value* | *Lower 95%* | *Upper 95%* | *Lower 95.0%* | *Upper 95.0%* |
|---|---|---|---|---|---|---|---|---|
| Intercept | 32666315.24 | 11018046 | 2.964801 | 0.015836 | 7741763 | 57590867 | 7741763 | 57590867 |
| X Variable 1 | -16134.47273 | 5473.439 | -2.94778 | 0.01628 | -28516.3 | -3752.69 | -28516.3 | -3752.69 |

**តារាស្ថិតិចំនួនសត្វមាន់ទាក្នុងខេត្តស្វាយរៀង( ឧបសម្ព័ន្ធទី១១ )**

| ឆ្នាំ | ចំនួនមាន់ទា |
|---|---|
| 2008 | 1,501,975 |
| 2009 | 1,415,755 |
| 2010 | 1,194,372 |
| 2011 | 1,502,003 |
| 2012 | 1,209,781 |
| 2013 | 1,502,003 |
| 2014 | 1,584,502 |
| 2015 | 1,116,702 |
| 2016 | 1,123,062 |
| 2017 | 2,901,335 |

| | |
|---|---|
| 2018 | 2,356,231 |

១. វិធីសាស្ត្រព្យាករណ៍កំណើនសត្វមាន់ទា ដោយយកចំនួនសត្វមាន់ទារាល់ឆ្នាំជាអថេរត្រូវពន្យល់តាងដោយ y និងលំដាប់ឆ្នាំជាអថេរពន្យល់តាងដោយ x នោះយើងបានសមីការ y= -174166818.6+87307.17273x ដោយប្រើវិធីសាស្ត្រ Linear Regression

SUMMARY OUTPUT

| *Regression Statistics* | |
|---|---|
| Multiple R | 0.519835349 |
| R Square | 0.27022879 |
| Adjusted R Square | 0.1891431 |
| Standard Error | 501594.2706 |
| Observations | 11 |

ANOVA

| | *df* | *SS* | *MS* | *F* | *Significance F* |
|---|---|---|---|---|---|
| Regression | 1 | 8.38E+11 | 8.38E+11 | 3.332632 | 0.101208 |
| Residual | 9 | 2.26E+12 | 2.52E+11 | | |
| Total | 10 | 3.1E+12 | | | |

| | *Coefficients* | *Standard Error* | *t Stat* | *P-value* | *Lower 95%* | *Upper 95%* | *Lower 95.0%* | *Upper 95.0%* |
|---|---|---|---|---|---|---|---|---|
| Intercept | -174166818.6 | 96272120 | -1.80911 | 0.103881 | -3.9E+08 | 43615847 | -3.9E+08 | 43615847 |
| X Variable 1 | 87307.17273 | 47825.14 | 1.82555 | 0.101208 | -20880.8 | 195495.1 | -20880.8 | 195495.1 |

## តារាងស្ថិតិផ្ទៃដីដាំ និងទិន្នផលដំណាំផ្សេងៗក្នុងខេត្តស្វាយរៀង(ឧបសម្ព័ន្ធទី១២)

| ឆ្នាំ | ផ្ទៃដី | ទិន្នផល |
|---|---|---|
| 2012 | 21545 | 545763 |
| 2013 | 28617 | 791573 |
| 2014 | 19453 | 571266 |
| 2015 | 19569 | 580425 |
| 2016 | 21205 | 571213 |
| 2017 | 16520 | 421991 |
| 2018 | 17002 | 460526 |

១. វិធីសាស្រ្តព្យាករណ៍កំណើនផ្ទៃដីដាំដុះ ដោយយកទុបាំផ្ទៃដីរាល់ឆ្នាំ ជាអថេរត្រូវពន្យល់តាងដោយ y និងលំដាប់ឆ្នាំជាអថេរពន្យល់តាងដោយ x នោះយើងបានសមីការ y=2616382.464-1288.25x ដោយប្រើវិធីសាស្រ្ត Linear Regression

SUMMARY OUTPUT

| *Regression Statistics* | |
|---|---|
| Multiple R | 0.690397441 |
| R Square | 0.476648627 |
| Adjusted R Square | 0.371978352 |
| Standard Error | 3194.417496 |
| Observations | 7 |

ANOVA

| | *df* | *SS* | *MS* | *F* | *Significance F* |
|---|---|---|---|---|---|
| Regression | 1 | 46468466 | 46468466 | 4.553811 | 0.085971 |

| | | | |
|---|---|---|---|
| Residual | 5 | 51021516 | 10204303 |
| Total | 6 | 97489981 | |

| | *Coefficients* | *Standard Error* | *t Stat* | *P-value* | *Lower 95%* | *Upper 95%* | *Lower 95.0%* | *Upper 95.0%* |
|---|---|---|---|---|---|---|---|---|
| Intercept | 2616382.464 | 1216432 | 2.150866 | 0.084153 | -510556 | 5743321 | -510556 | 5743321 |
| X Variable 1 | -1288.25 | 603.6882 | -2.13397 | 0.085971 | -2840.08 | 263.5798 | -2840.08 | 263.5798 |

២. វិធីសាស្ត្រព្យាករណ៍កំណើនទិន្នផល ដោយយកទិន្នផលដំណាំរាល់ឆ្នាំ ជាអថេរត្រូវពន្យល់តាងដោយ y និងលំដាប់ឆ្នាំជាអថេរពន្យល់តាងដោយ x នោះយើងបានសមីការ y=72162533.86+( -35533.14286)x ដោយប្រើវិធីសាស្ត្រ Linear Regression

SUMMARY OUTPUT

| *Regression Statistics* | |
|---|---|
| Multiple R | 0.651205022 |
| R Square | 0.424067981 |
| Adjusted R Square | 0.308881578 |
| Standard Error | 97993.10204 |
| Observations | 7 |

ANOVA

| | *df* | *SS* | *MS* | *F* | *Significance F* |
|---|---|---|---|---|---|
| Regression | 1 | 3.54E+10 | 3.54E+10 | 3.68158 | 0.113111 |
| Residual | 5 | 4.8E+10 | 9.6E+09 | | |
| Total | 6 | 8.34E+10 | | | |

| | *Coefficients* | *Standard Error* | *t Stat* | *P-value* | *Lower 95%* | *Upper 95%* | *Lower 95.0%* | *Upper 95.0%* |
|---|---|---|---|---|---|---|---|---|
| Intercept | 72162533.86 | 37315714 | 1.933838 | 0.110943 | -2.4E+07 | 1.68E+08 | -2.4E+07 | 1.68E+08 |
| X Variable 1 | -35533.14286 | 18518.96 | -1.91874 | 0.113111 | -83137.6 | 12071.35 | -83137.6 | 12071.35 |